00709842

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 06 / 2011
ម៉ោង (Time/Heure) : 16:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

D411/3/6

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (**អបជ76, អបជ 112, អបជ 113, អបជ 114, អបជ 115, អបជ 142, អបជ 157, អបជ 164, អបជ 165 និង អបជ 172)**[១]

ចំពោះមុខ: **ចៅក្រម ប្រាក់ គឹមសាន ប្រធាន**
**ចៅក្រម Katinka LAHUIS**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Catherine MARCHI-UHEL**
**ចៅក្រម ហួត វុទ្ធី**

ក្រឡាបញ្ជី **សរ ចំន្ទរ៉ាត**
**Entela JOSIFI,**
**គង់ សារាឆាត**
**Anne-Marie BURNS,**

កាលបរិច្ឆេទ: ២៤ ខែ មិថុនា ឆ្នាំ ២០១១

## សាធារណៈ:

## សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

**<u>សហព្រះរាជអាជ្ញា</u>**
ជា លាង
Andrew T. CAYLEY

**<u>ជនត្រូវចោទ</u>**
អៀង សារី
អៀង ធីរិទ្ធ
នួន ជា
ខៀវ សំផន

[១] នីមួយៗ "បណ្តឹងឧទ្ធរណ៍មួយ" និង ជាសមូហភាព "បណ្តឹងឧទ្ធរណ៍ច្រើន"

**មេធាវីនៃភាគីដើមបណ្តឹងរដ្ឋប្បវេណី**

សំ សុខគង់
Lyma Thuy NGUYEN
ហុង គឹមសួន
**Pascal AUBOIN**
ពេជ អង្គ
ជេត វណ្ណលី
វ៉ែន ពៅ
ឡោ ជុនធី
Olivier BAHOUGNE
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Christinne MARTINEAU
Elisabeth RABESANDRATANA
Philippe CANNONE
Martine JACQUIN
Annie DELAHIE
Fabienne TRUSSES-NAPROUS
គង់ ពិសី
យុង ផានិត
ស៊ិន សុវ៉ន
Silke STUNDZINSKY
Mahdev MOHAN
Patrick BAUDOIN
Marie GUIRAUD
ទី ស្រីនណា
Ferdinand DJAMMEN-NZEPA
Isabelle DURAND
Emmanuel ALTIT
Emmanuel JACOMY
Barnabe NEKUIE
Daniel LOSQ
Julien RIVET
Francoise GAUTRY
Laure DESFORGES

**សហមេធាវីការពារក្តី**

អាង ឧត្តម
Michael G. KARNAVAS
ផាត់ ពៅស៊ាង
Diana ELLIS
សុន អរុណ
Michiel PESTMAN
Victor KOPPE
ស សូវាន
Jacques VERGÈS

00709844

**មាតិកា**


I. **ប្រវត្តិ** ..........04

II. **សេចក្តីសង្ខេបនៃបណ្តឹងឧទ្ធរណ៍** ..........16

III. **ដីកាសម្រេចនានា** ..........18

IV. **ច្បាប់ដែលអាចយកមកអនុវត្តបាន** ..........23

V. **ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍** ..........25

VI. **បទដ្ឋាននៃការពិនិត្យឡើងវិញ** ..........25

VII. **ការពិនិត្យទៅលើកំហុសដែលបានរកឃើញនៅក្នុងដីកាសម្រេចនានា** ..........27

VIII. **ការពិចារណាទៅលើតម្រូវការផ្នែកច្បាប់ ដែលអាចអនុវត្តបានចំពោះ ពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណី** ..........41

ក. ទំនាក់ទំនងហេតុផល ..........48

ខ. ព្យសនកម្ម ..........60

គ. កម្រិតនៃភស្តុតាង ..........68

ឃ. ភស្តុតាងនៃអត្តសញ្ញាណ ..........68

ង. តើពាក្យសុំដែលមានលក្ខណៈវិនិច្ឆ័យទូលំទូលាយជាងមុន សម្រាប់ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ះពាល់ដល់តុល្យភាពនៃសិទ្ធិរបស់ភាគីដទៃទៀតដែលពាក់ព័ន្ធក្នុងដំណើរការនីតិវិធីឬទេ? ..........68

IX. **ការវាយតម្លៃជាលក្ខណៈបុគ្គលទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** ....70

X. **<u>បទបញ្ញត្តិ</u>** ..........71

XI. **មតិជំទាស់របស់ចៅក្រម Catherine MARCHI-UHEL** ..........77


E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

**អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ("អ.វ.ត.ក") បានទទួលបណ្តឹងឧទ្ធរណ៍ ដែលបានដាក់ដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវី") ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត (ពាក្យថា "ដីកាសម្រេចដែលរងការជំទាស់" គឺសំដៅលើដីកាសម្រេចនីមួយៗ ហើយពាក្យថា "ដីកាសម្រេចដែលរងការជំទាស់ទាំងអស់" គឺសំដៅលើដីកាសម្រេចទាំងអស់) ស្តីពីភាពអាចទទួលយកបាននៃពាក្យសុំ ដែលបានដាក់ដោយជនរងគ្រោះ ដើម្បីឱ្យបានក្លាយខ្លួនទៅជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ។

## I. ប្រវត្តិ

១. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ខ្លួនទៅឱ្យសហចៅក្រមស៊ើបអង្កេត ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")[២]។ សហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណជនសង្ស័យចំនួនប្រាំនាក់[៣] រួមមាន នួន ជា អៀង ធីរិទ្ធ អៀង សារី ខៀវ សំផន និង កាំង ហ្កេចអាវ ហៅ ឌុច ដែលសហព្រះរាជអាជ្ញាអះអាងថាបានចូលរួមនៅក្នុងផែនការឧក្រិដ្ឋរួមមួយ[៤] ដែលការចូលរួមអនុវត្តផែនការនោះបង្កើតបានជាការដកហូតដោយខុសច្បាប់ និងមានលក្ខណៈជាប្រព័ន្ធនូវសិទ្ធិជាសារវ័ន្តរបស់ប្រជាជនកម្ពុជា[៥]។ សហព្រះរាជអាជ្ញាបានកំណត់ស្ថានភាពអង្គហេតុដោយឡែកពីគ្នាចំនួនម្ភៃប្រាំ រួមមាន អំពើមនុស្សឃាត[៦] ទារុណកម្ម[៧] ការផ្លាស់ទីកន្លែងដោយបង្ខំ[៨] ការឃុំខ្លួនមិនស្របច្បាប់[៩] ពលកម្មដោយបង្ខំ[១០] និងការធ្វើទុក្ខបុកម្នេញដោយសារ មូលហេតុសាសនា នយោបាយ និងជាតិពន្ធុ[១១]។ អំពើទាំងនេះគឺជាភស្តុតាងនៃឧក្រិដ្ឋកម្ម

---

[២] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ឯកសារ D3 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ")។

[៣] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៧៣ ដល់ ១១៣។

[៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៥ ដល់ ១៦។

[៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ២ ដល់ ៣។

[៦] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៩ ដល់ ៧២។

[៧] *ដូចគ្នានឹងជើងទំព័រខាងលើ*។

[៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៣៧ ដល់ ៤២។

[៩] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៤៣ ដល់ ៤៨។

[១០] *ដូចគ្នានឹងជើងទំព័រខាងលើ*។

[១១] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៦៩ កថាខណ្ឌ ៧០ និង ៧២។

ដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងការអនុវត្តផែនការឧក្រិដ្ឋកម្មរួមនេះ ដែលបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវនានា ឃាតកម្ម ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា[១២]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាំងអស់ដែលបានដាក់ក្រោយមកទៀត ត្រូវបានដាក់ជាឯកសារសម្ងាត់បំផុត។ ហេតុដូច្នេះ សាធារណជន ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចចូលមើលឯកសារ ទាំងនេះបានទេ ប៉ុន្តែមេធាវីរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលមើលបាន បន្ទាប់ពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះបានទទួលស្គាល់ពួកគេរួចមក។

២. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានសម្រេច៖

ក. បំបែកសំណុំរឿងរបស់ ឌុច សម្រាប់ "អង្គហេតុទាំងឡាយដែលបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមន្ទីរសន្តិសុខ ស-២១" ដែល "ផ្នែកនៃសំណុំរឿងនេះ នឹងត្រូវបានស៊ើបអង្កេតនៅក្រោមសំណុំរឿងលេខ ០០១/១៨-០៧-២០០៧"។

ខ. ប្រកាសថា "អង្គហេតុដទៃទៀតដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងឲ្យទៅស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧" និង "អង្គហេតុទាំងឡាយទាក់ទងទៅនឹង ឌុច ឬជនត្រូវចោទដទៃទៀតដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឲ្យទៅស៊ើបសួរខាងលើនេះ នឹងត្រូវបានស៊ើបអង្កេតនៅក្រោមសំណុំរឿងលេខ ០០២/១៩-០៩-២០០៧"[១៣]។

៣. នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយ[១៤] ដោយស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត បើកកិច្ចស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្តឡើង ដោយសារតែប្រតិបត្តិការរបស់មន្ទីរសន្តិសុខភូមិភាគឧត្តរ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលឧក្រិដ្ឋកម្មទាំងនេះត្រូវបានគេជឿជាក់ថា ស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបាន

[១២] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ១២២។

[១៣] ដីកាបំបែកសំណុំរឿង ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ ឯកសារ D18។

[១៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៨ ឯកសារ D83។

បញ្ជូនអង្គហេតុថ្មីៗទាំងនេះមកឱ្យខ្លួន ដោយបានស្នើសុំជាយោបល់ថាតើសហចៅក្រមស៊ើបអង្កេត គួរបើកកិច្ចស៊ើបសួរទៅលើខ្លឹមសារនានា នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលសហចៅក្រមស៊ើបអង្កេតបានទទួលដែរឬយ៉ាងណា [១៥]។ បន្ទាប់មក សហព្រះរាជអាជ្ញាបានបំភ្លឺថា[១៦] កថាខណ្ឌ ៣៧ ដល់ កថាខណ្ឌ ៣៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាសំណើសុំឱ្យបើកកិច្ចស៊ើបសួរ តែទៅលើការជម្លៀសមនុស្សដោយបង្ខំចេញពីទីក្រុងភ្នំពេញតែប៉ុណ្ណោះ ហើយកថាខណ្ឌ ៣៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ "រៀបរាប់អំពីដើមកំណើតនៃគោលនយោបាយដែលនាំឱ្យមានការជម្លៀសប្រជាជន ហើយបានធ្វើការកត់សម្គាល់យ៉ាងសាមញ្ញថា គោលនយោបាយនេះត្រូវបានគេអនុវត្តទៅលើទីក្រុងទាំងអស់នៅក្នុងប្រទេសកម្ពុជា មិនមែនតែទីក្រុងភ្នំពេញមួយប៉ុណ្ណោះទេ"។ សហព្រះរាជអាជ្ញាបានចាត់ចំណាត់ថ្នាក់អង្គហេតុថ្មីៗនេះថា ជាអំពើឃាតកម្ម ទារុណកម្ម និងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈអំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយមកលើអតីតមន្ត្រីរបស់របបសាធារណរដ្ឋខ្មែរ និងតាមរយៈអំពើអមនុស្សធម៌ដទៃទៀត។ ចំពោះជនសង្ស័យទាំងប្រាំនាក់នោះ សហព្រះរាជអាជ្ញាបានលើកឡើងថា "អំពើទាំងនេះ គឺជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួម ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥ ដល់កថាខណ្ឌ ១៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ"។

៤. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់សេចក្តីបំភ្លឺមួយ[១៧] ដែលបញ្ជាក់ថាកិច្ចស៊ើបសួរមិនត្រូវកំហិតត្រឹមតែអង្គហេតុដែលបានកំណត់ជាក់លាក់នៅក្នុងកថាខណ្ឌ ៣៧ ដល់ ៤២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង កថាខណ្ឌ ៥ ដល់ ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ ប៉ុន្តែ កិច្ចស៊ើបសួរនេះគ្របដណ្តប់ទៅលើអង្គហេតុទាំងអស់ដែលត្រូវបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានទាំងពីរនេះ ឱ្យតែអង្គហេតុទាំងនេះជួយដល់ការស៊ើបអង្កេត ថា

---

[១៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៨ ឯកសារ D83 កថាខណ្ឌ ២ និង ៣។

[១៦] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភូមិភាគឧត្តរ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៨ ឯកសារ D83 កថាខណ្ឌ ៤ ។

[១៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើសុំឱ្យបញ្ជាក់អំពីវិសាលភាពនៃកិច្ចស៊ើបសួរ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D98/1។

តើស្ថានភាពអង្គហេតុជាក់លាក់ទាំងនោះ បង្កើតឱ្យបានជាឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ឬក៏បង្កើតឱ្យទៅជាទម្រង់នៃការទទួលខុសត្រូវនានា ដែលត្រូវបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែរឬយ៉ាងណានោះ ។

៥. នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយ[១៨] ដែលនៅក្នុងនោះសហព្រះរាជអាជ្ញាបានស្នើសុំ និងអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបអង្កេតទៅលើព្រឹត្តិការណ៍នានានៃការរៀបការដោយបង្ខំ និងសម្ព័ន្ធភាពផ្លូវភេទដោយបង្ខំ ដូចបានរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួន ដែលនាពេលនោះ ពាក្យសុំទាំងនោះមិនត្រូវបានសម្រេចទទួលដោយសហចៅក្រមស៊ើបអង្កេតនៅឡើយ។ បន្ថែមលើនេះទៀត នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយទៀត[១៩] ដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត "តាមដែលខ្លួនកំណត់ថាសមស្រប "ដើម្បីពិចារណា និងធ្វើការស៊ើបសួរបន្ថែមទៀតទៅលើឧប្បត្តិហេតុនានាដូចដែលបានចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ និងសម្ព័ន្ធភាពផ្លូវភេទដោយបង្ខំ ក្រៅអំពីឧប្បត្តិហេតុនានា [ដូចដែលបានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨]"។

៦. នៅថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមមួយ[២០] ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាបានលើកឡើងថា អំពើប្រល័យពូជសាសន៍មកលើជនជាតិចាម អំពើឃាតកម្ម ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនាមកលើជនជាតិចាម និងអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរ

---

[១៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបញ្ជូនរឿងឱ្យទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ ឯកសារ D146/3។

[១៩] សេចក្តីអនុញ្ញាតបន្ថែម ដោយអនុលោមតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៨ ទៅនឹងដីកាបញ្ជូនរឿងឱ្យទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ឯកសារ D146/4។

[២០] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងអំពើប្រល័យពូជសាសន៍មកលើជនជាតិចាម ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារ D196។

ឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ សាសនា និងពូជសាសន៍ មកលើជនជាតិចាម និងអំពើអមនុស្សធម៌ដទៃទៀត បានក្លាយទៅជាផ្នែកមួយនៃកិច្ចស៊ើបអង្កេត។[២១] ចំពោះជនសង្ស័យទាំងប្រាំនាក់ សហព្រះរាជអាជ្ញាបានលើកឡើងថា "អំពើទាំងនេះគឺជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ឬ សហឧក្រិដ្ឋកម្មរួម ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥ ដល់ ១៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ"។ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាំងមូល សហព្រះរាជអាជ្ញាបានសំដៅទៅលើប្រជាជនចាមទាំងមូលថាជាក្រុមមួយ។

៧. នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមួយ[២២] ដោយបញ្ជាក់បំភ្លឺថា វិសាលភាពនៃការចោទប្រកាន់ទៅលើអង្គហេតុ ដែលត្រូវបានស៊ើបអង្កេតទៅលើជនសង្ស័យនានា មានការប្រែប្រួលពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដើមដំបូងពាក់ព័ន្ធទៅនឹងទីតាំងចំនួនប្រាំកន្លែង ហើយបានស្នើថា បញ្ហាអង្គហេតុ និងឧក្រិដ្ឋកម្មដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមនេះ ក្លាយទៅជាផ្នែកមួយនៃសំណុំរឿង ០០២ ដែលកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតនៅឡើយ។ សហ-ព្រះរាជអាជ្ញាកំណត់ប្រភេទអង្គហេតុទាំងនេះថា ជាឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដោយរួមមាន ប៉ុន្តែ មិនកំណត់ត្រឹមតែអំពើឃាតកម្ម និងការធ្វើទារុណកម្ម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុណ្ណោះទេ គឺរួមបញ្ចូលផងដែរ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង អំពើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូល-ហេតុនយោបាយទៅលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ និងអំពើអមនុស្សធម៌ដទៃទៀត។ សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួនមានហេតុផលគួរឲ្យជឿជាក់ថា ជនសង្ស័យទាំងប្រាំនាក់នេះបានប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនេះ ដែលជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួម ឬសហឧក្រិដ្ឋកម្មរួម ដូចបានពណ៌នានៅក្នុងកថាខណ្ឌ ៥ ដល់កថាខណ្ឌ ១៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

---

[២១] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងអំពើប្រល័យពូជសាសន៍មកលើជនជាតិចាម ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារ D ១៩៦ កថាខណ្ឌ ២៤។

[២២] សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំកន្លែង ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារ D202។

៨. នៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីថ្លែងការណ៍មួយ ដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា ខ្លួនមានបំណងបញ្ចប់ការស៊ើបអង្កេត ក្នុងសំណុំរឿង ០០២ នៅចុងឆ្នាំ ២០០៩ ហើយថា "អនុលោមតាមវិធានផ្ទៃក្នុងដែលត្រូវបានធ្វើវិសោធនកម្ម ជនណាដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរយ៉ាងយូរ ១៥ ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងថា សហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួនហើយ"[២៣]។ "ដើម្បីជួយដល់សាធារណជនទាំងឡាយ ដែលមានបំណងចង់ដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" នៅក្នុងសេចក្តីថ្លែងការណ៍នេះ សហចៅក្រមស៊ើបអង្កេតបានផ្តល់ "ព័ត៌មានអំពីអង្គហេតុដែលស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបសួររបស់ខ្លួនដែលកំពុងតែបន្តនេះ"។ សហចៅក្រមស៊ើបអង្កេតបានពន្យល់ថា "អនុលោមតាមវិធានផ្ទៃក្នុង[២៤] ជនរងគ្រោះ គឺជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលរងការខូចខាតលើករាងកាយ សម្ភារៈ ឬផ្លូវចិត្ត ដោយផ្ទាល់ពីអំពើនៃការប្រព្រឹត្តបទល្មើសណាមួយដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក"។ "ប្រសិនបើជនរងគ្រោះណាម្នាក់ចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *នោះ*ការទទួលរងព្យសនកម្មរបស់ពួកគាត់ ត្រូវតែផ្ទាល់ខ្លួន និងជាប់ទាក់ទងដោយផ្ទាល់ទៅនឹងស្ថានភាពអង្គហេតុមួយ ឬច្រើន ដែលបង្កើតបានជាមូលដ្ឋាននៃការស៊ើបសួរដែលកំពុងដំណើរការ"។ បន្ទាប់មក សហចៅក្រមស៊ើបអង្កេត បានរៀបរាប់ពីបញ្ជី "អង្គហេតុសំខាន់ៗដែលជាផ្នែកមួយនៃកិច្ចស៊ើបសួរ [របស់តុលាការ]" ដែលមានដូចជា "សហករណ៍ និងការដ្ឋាននានា" ព្រមទាំង "មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សនានា" ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ និង "អំពើប្រព្រឹត្តឡើងប្រឆាំងនឹងប្រជាជន និង/ឬ ក្រុមមនុស្សមួយចំនួន"។

៩. ដោយអនុលោមតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង នៅថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងមួយ ទាក់ទងទៅនឹងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងសំណុំរឿង[២៥]។ សេចក្តីជូនដំណឹងបានបញ្ជាក់ឡើងវិញថា ជនរងគ្រោះមានរយៈ

---

[២៣] សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ អាសយដ្ឋានគេហទំព័រ http://www.eccc.gov.kh/english/cabinet/press/138/ECCC_Press_Release_5_Nov_2009_Eng.pdf

[២៤] ត្រូវកត់សម្គាល់ថា វិធានផ្ទៃក្នុងដែលចូលជាធរមានត្រឹមថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០៩ គឺវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ដែលត្រូវបានអនុម័តនៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩។

[២៥] សេចក្តីជូនដំណឹង អនុលោមតាមវិធាន ២៣ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការដាក់បញ្ចូលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទៅក្នុងសំណុំរឿង ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ឯកសារ D316។

ពេលចំនួន ១៥ ថ្ងៃ បន្ទាប់ពីការជូនដំណឹងរបស់ចៅក្រមស៊ើបអង្កេតស្តីពីការបញ្ចប់កិច្ចស៊ើបសួររបស់តុលាការ ដើម្បីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សេចក្តីជូនដំណឹងនេះបានពន្យល់ថា គ្រប់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារគាំទ្រទាំងអស់ ត្រូវដាក់ទៅកាន់អង្គភាពគាំពារជនរងគ្រោះរបស់ អ.វ.ត.ក ហើយបន្ទាប់មកត្រូវបញ្ជូនទៅក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ដោយភ្ជាប់ជាមួយនឹង "ទម្រង់បែបបទព័ត៌មានជនរងគ្រោះ" ដែលក្នុងទម្រង់នេះមានការរៀបរាប់សង្ខេបអំពីអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។ សហចៅក្រមស៊ើបអង្កេត ក៏បានទាញចំណាប់អារម្មណ៍ទៅលើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ពួកខ្លួន ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ដែលបានបញ្ជាក់សារជាថ្មីអំពីលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

"ប្រសិនបើជនរងគ្រោះណាម្នាក់ មានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖

i. ព្យសនកម្មដែលគាត់អះអាងថាបានទទួលរងនោះ ត្រូវតែជាព្យសនកម្មផ្ទាល់ខ្លួន និងដោយផ្ទាល់ ហើយ

ii. ជាប់ទាក់ទងដោយផ្ទាល់ទៅនឹងស្ថានភាពអង្គហេតុមួយ ឬ ច្រើនដែលបង្កើតបានជាមូលដ្ឋាននៃការស៊ើបសួរដែលកំពុងបន្ត [...] ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា"។

១០. នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញសេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន[២៦] ដែលបានបញ្ជាក់អំពីការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងបទចោទស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ អំពើប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា។

E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

១១. នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញអនុស្សរណៈអន្តរការិយាល័យមួយស្តីអំពីការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការដាក់បណ្តឹង[២៧]។ អនុស្សរណៈនោះត្រូវបានធ្វើឡើងក្នុងគោលបំណងផ្តល់ជូនដល់ "អង្គភាពជនរងគ្រោះនូវព័ត៌មានលម្អិតចាំបាច់

---

[២៦] សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ ឯកសារ D317។

[២៧] ការដាក់ពាក្យបណ្តឹងធម្មតា និង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១០ ឯកសារ D337។

នានា ដើម្បីផ្តល់ពត៌មានដល់អ្នកដាក់ពាក្យបណ្តឹង និងដើមបណ្តឹងរដ្ឋប្បវេណី"។ អនុស្សរណៈនោះ បានបញ្ជាក់ថា បន្ទាប់ពីការបញ្ចប់កិច្ចស៊ើបសួរ ជនរងគ្រោះមានរយៈពេល ១៥ ថ្ងៃ ដើម្បីដាក់ពាក្យសុំរបស់ខ្លួន ដែលកាលបរិច្ឆេទកំណត់នោះគឺនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០។ បន្ទាប់មក **អង្គភាពគាំពារជនរងគ្រោះ** ត្រូវដាក់ពាក្យសុំទាំងនោះទៅក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១០។ អង្គភាពគាំពារជនរងគ្រោះក៏អាចដាក់ព័ត៌មានបន្ថែមណាមួយ ដែលខ្លួនបានទទួលដើម្បីបំពេញបន្ថែមទៅលើពាក្យសុំបឋម នៅក្នុងរយៈពេលបីខែ ចាប់ពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០ ។

១២. នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០ វិសោធនកម្មលើកទីប្រាំនៃវិធានផ្ទៃក្នុងបានចូលជាធរមាន។ វិសោធនកម្មលើកទីប្រាំនៃវិធានផ្ទៃក្នុងនេះ បានបញ្ចូលវិធាន ២៣ *ក្វូទ* (១)(ខ) ដែលចែងថា៖

> "ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ៖
>
> ក. បង្ហាញពីអត្តសញ្ញាណឲ្យបានច្បាស់លាស់ និង
>
> ខ. បង្ហាញថា ជាផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយក្នុងចំណោមបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់មកលើជនត្រូវចោទ និងថាខ្លួនពិតជាបានទទួលរងព្យសនកម្មលើរាងកាយ សម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាព"។

១៣. វិធាន ២៣(២) នៃវិធានផ្ទៃក្នុង ដែលបានធ្វើវិសោធនកម្មលើកទីប្រាំ បានចែងថា៖

> "សិទ្ធិធ្វើបណ្តឹងរដ្ឋប្បវេណី អាចធ្វើឡើងដោយជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដោយគ្មានការរើសអើងចំពោះលក្ខណៈវិនិច្ឆ័យ ដូចជាលំនៅដ្ឋានបច្ចុប្បន្ន ឬ សញ្ជាតិនោះឡើយ។ ដើម្បីឲ្យបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន ព្យសនកម្មត្រូវតែ៖
>
> ក. ជាព្យសនកម្មលើរាងកាយ សម្ភារៈ ឬ ផ្លូវចិត្ត និង
>
> ខ. ជាផលវិបាកដោយផ្ទាល់ពីបទល្មើស និងពិតជាកើតមានប្រាកដមែន" ។

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

១៤. នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានពន្យារឱសានវាទសម្រាប់អង្គភាព

គាំពារជនរងគ្រោះ ដើម្បីដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាប់ពីថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១០ រហូតរដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០[២៨]។

១៥. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញអនុស្សរណៈអន្តរការិយាល័យមួយជាភាសាអង់គ្លេស ជូនទៅប្រធានអង្គភាពគាំពារជនរងគ្រោះ[២៩] ដោយអនុញ្ញាតផ្តល់ឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នូវពេលវេលាបន្ថែមដើម្បីដាក់ព័ត៌មានបន្ថែមដែលពាក់ព័ន្ធទៅនឹងពាក្យសុំរបស់ខ្លួន ទៅកាន់អង្គភាពគាំពារជនរងគ្រោះ ដោយសហចៅក្រមស៊ើបអង្កេតបានពន្យារកាលបរិច្ឆេទផុតឱសានវាទរហូតដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០ សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណា ដែលបានដាក់ពាក្យសុំរបស់ខ្លួនរួចហើយ ទៅកាន់អង្គភាពគាំពារជនរងគ្រោះត្រឹមថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០។

១៦. នៅថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយជាភាសាខ្មែរ និងអង់គ្លេស ដោយអនុលោមតាមវិធាន ២៣ *ស្ទួនពីរ* ស្តីពីការរៀបចំអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានអ្នកតំណាងចំនួន ៧៩៩ នាក់[៣០]។ ដីកាសម្រេចនោះត្រូវបានជូនដំណឹងជាភាសាបារាំងនៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១០។ នៅថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញចម្លើយតបមួយចំពោះសំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំឲ្យពន្យារថិរវេលាដើម្បីប្រមូល និងដាក់ព័ត៌មានបន្ថែមសម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥៦៩ នាក់ដែលទើបតែមានមេធាវីតំណាង[៣១] ដោយបានបដិសេធសំណើសុំនេះ ដោយសារថាវាជិតដល់ពេលចេញដីកា

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

[២៨] កាលបរិច្ឆេទកំណត់ក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលនៅសល់ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D337/1។

[២៩] រយៈពេលសម្រាប់ដាក់ព័ត៌មានបន្ថែម ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០ ឯកសារ D337/6។

[៣០] ដីកាសម្រេចស្តីពីការរៀបចំតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុវត្តតាមវិធាន ២៣ ស្ទួនពីរ នៃវិធានផ្ទៃក្នុង(D337/10) ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០ ។

[៣១] ចម្លើយតបទៅសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំពន្យារថិរវេលាសម្រាប់ប្រមូល និងដាក់ព័ត៌មានបន្ថែម សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥៦៩ នាក់ ដែលទើបនឹងមានតំណាង ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D337/11/1។

ដំណោះស្រាយហើយ ប៉ុន្តែ បានរំឭកដល់មេធាវីទាំងនោះថា ពួកគេនៅតែមានសិទ្ធិដាក់ព័ត៌មានបន្ថែមទាំងឡាយណាដែលខ្លួនមាន ក្នុងអំឡុងពេលប្តឹងឧទ្ធរណ៍។

១៧. នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ដោយអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង[៣២] ដែលនៅក្នុងនោះ សហព្រះរាជអាជ្ញាបានស្នើថា ត្រូវចោទប្រកាន់ជនត្រូវចោទទាំងនោះ ហើយបញ្ជូនពួកគេទៅកាត់សេចក្តីអំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភបំពានក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ របស់ប្រទេសកម្ពុជា[៣៣] ក្នុងនាមជាថ្នាក់លើ[៣៤]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ចុងចោទម្នាក់ៗត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលដោយសារតែការប្រព្រឹត្ត ការធ្វើផែនការ ការញុះញង់ ការបញ្ជា និង/ឬការជួយ និងជំរុញឱ្យប្រព្រឹត្តបទល្មើសទាំងនេះ[៣៥]។ សហព្រះរាជអាជ្ញាបានលើកឡើងថា ចុងចោទម្នាក់ៗមានការទទួលខុសត្រូវចំពោះការប្រព្រឹត្តបទល្មើសទាំងនេះតាមរយៈសហឧក្រិដ្ឋកម្មរួម[៣៦]។ ដីកាសន្និដ្ឋានស្ថាពរនេះត្រូវបានជូនដំណឹងដល់ភាគីទាំងអស់នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១០។

១៨. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ[៣៧] ដោយសន្និដ្ឋានថា "តាមលទ្ធផលនៃកិច្ចស៊ើបសួរបានបង្ហាញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹង នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ នៅទីក្រុងភ្នំពេញ នៅលើទឹកដីប្រទេសកម្ពុជា និងនៅក្នុងអំឡុងពេលនៃការវាយលុកលុយចូលក្នុងទឹកដីវៀតណាម ក្នុងចន្លោះរវាងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ តាមរយៈអំពើសកម្ម និងអំពើអកម្ម ដែលបានប្រព្រឹត្ត (តាមរយៈសហឧក្រិដ្ឋកម្មរួម)

[៣២] ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D390 (ដីកាសន្និដ្ឋានស្ថាពរ)។

[៣៣] ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១៦៤៥ ។

[៣៤] ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១៥៦៥ កថាខណ្ឌ ១៥៩០ កថាខណ្ឌ ១៦១៥ កថាខណ្ឌ ១៦៤០ និងកថាខណ្ឌ ១៦៤៦។

[៣៥] ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១៥៣៥ កថាខណ្ឌ ១៥៣៦ កថាខណ្ឌ ១៥៧១ កថាខណ្ឌ ១៥៩៦ និង កថាខណ្ឌ ១៦២២។

[៣៦] ដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១៥៣៧ចច កថាខណ្ឌ ១៥៧២ចច កថាខណ្ឌ ១៥៩៧ចច និង កថាខណ្ឌ ១៦២៣ចច។

[៣៧] ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D427 ("ដីកាដំណោះស្រាយ")។

បានរៀបចំផែនការ បានញុះញង់ បានបញ្ជា បានជួយ និងជំរុញចារី ឬត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ" ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[៣៨]។ ដីកាដំណោះស្រាយត្រូវបានជូនដំណឹងដល់ភាគីនានានៅថ្ងៃដដែលនោះដែរ។

១៩. នៅចន្លោះពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១០ និងថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចចំនួន ២៥ សម្រេចលើភាពអាចទទួលយកបាននៃជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុង។

២០. អនុលោមតាមវិធាន ៧៧ *ស្ទួន* នៃវិធានផ្ទៃក្នុង សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់បណ្តឹងឧទ្ធរណ៍សម្រាប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានសម្រេចថា មិនអាចទទួលយកបានទេ។ បណ្តឹងឧទ្ធរណ៍ទាំងនោះត្រូវបានដាក់នៅក្នុងពេលវេលាកំណត់ដូចបានចែងនៅក្នុងវិធានផ្ទៃក្នុង ឬដោយយោងតាមសេចក្តីណែនាំជាក់លាក់នានារបស់អង្គបុរេជំនុំជម្រះ[៣៩]។ នៅក្នុងបណ្តឹងឧទ្ធរណ៍ទាំងនោះ សហមេធាវីស្នើសុំឱ្យអង្គបុរេជំនុំជម្រះច្រានចោលដីកាសម្រេចដែលរងការជំទាស់ទាំងអស់ ដែលពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំ ហើយសម្រេចទទួលយកពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណី។

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

២១. នៅថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ សហមេធាវីការពារជនជាប់ចោទ អៀង សារី បានដាក់ចម្លើយតបមួយទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងអស់[៤០] ដែលអាចអនុវត្តបានចំពោះបណ្តឹងឧទ្ធរណ៍ទាំង

---

[៣៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១៣។

[៣៩] សហមេធាវីមួយចំនួនត្រូវបានបង្គាប់ឱ្យធ្វើការកែប្រែ ឬ ដាក់បណ្តឹងឧទ្ធរណ៍ជាថ្មីម្តងទៀត ដែលបានដាក់ពាក់ព័ន្ធទៅនឹងដីកាសម្រេចដែលត្រូវបានជំទាស់ដែលមានចំនួនច្រើនជាងមួយ។ នៅក្នុងករណីនីមួយៗ សហមេធាវីបានធ្វើតាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ។

[៤០] ចម្លើយតបរបស់ អៀងសារី ចំពោះបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតបានបដិសេធចោល, ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D399/2/2។

អស់ដោយផ្អែកលើ "ឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះក្នុងការសម្រេច ថាតើសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់លក្ខណៈវិនិច្ឆ័យត្រឹមត្រូវដែរ ឬយ៉ាងណា នៅពេលធ្វើការវាយតម្លៃឲ្យបានត្រឹមត្រូវទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ២៣ *ស្ទួន* ហើយស្របពេលជាមួយគ្នានេះដែរ ក៏ជំរុញឲ្យអង្គបុរេជំនុំជម្រះជ្រើសយកវិធីសាស្ត្រដែលមានលក្ខណៈបត់បែន និងពេញលេញ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើភាពអាចទទួលយកបាន នៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី"។

២២. នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះបានចេញសេចក្តីណែនាំដល់សហមេធាវីការពារក្តីរបស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ឲ្យដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនោះ "មិនមានជាភាសាអង់គ្លេសទេ" ដោយមិនចាំបាច់រង់ចាំការបកប្រែបណ្តឹងឧទ្ធរណ៍ទាំងនោះទៅជាភាសាអង់គ្លេសទេ និងកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១[៤១]។ នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះក៏បានចេញសេចក្តីណែនាំដល់សហមេធាវីការពារក្តីរបស់ ខៀវ សំផន ឲ្យដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនោះ "មិនមានជាភាសាបារាំងទេ" ដោយមិនចាំបាច់រង់ចាំការបកប្រែបណ្តឹងឧទ្ធរណ៍ទាំងនោះទៅជាភាសាបារាំងទេ និងកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១[៤២]។ សហមេធាវីការពារក្តីរបស់ជនជាប់ចោទត្រូវបានតម្រូវឲ្យ "ប្រើប្រាស់ធនធានផ្នែកភាសារបស់ខ្លួនផ្ទាល់ ... ដោយការប្រើប្រាស់ភាសាខ្មែរ" ឬភាសាអង់គ្លេស ឬភាសាបារាំងនៃបណ្តឹងឧទ្ធរណ៍ទាំងនោះ តាមដែលអាចធ្វើទៅបាន។

---

[៤១] សេចក្តីណែនាំចំពោះសហមេធាវីការពារក្តីរបស់ អៀង សារី, អៀង ធីរិទ្ធ និង នួន ជា ឲ្យដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ដែលបានប្តឹងដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D392/2/2។ សូមមើលផងដែរ ឯកសារ D393/4/2; D394/2/2; D394/4/2; D397/5/2; D401/4/3; D401/5/2; D401/6/2; D399/3/2; D424/4/2; D426/4/2; D419/2/2; D419/7/2; D419/8/2; D404/5/2; D423/6/2; D423/7/2; D406/3/2; D417/4/2។

[៤២] សេចក្តីណែនាំចំពោះសហមេធាវីការពារក្តីរបស់ ខៀវ សំផន ឲ្យដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ដែលបានប្តឹងដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D417/2/4។ សូមមើលផងដែរ ឯកសារ D404/3/2; D393/3/3; D394/3/2; D395/3/2; D396/3/2; D397/2/2;D397/6/2; D398/2/2; D398/3/3; D401/3/2; D399/2/3; D399/4/2; D424/3/5; D424/2/2; D426/2/2; D426/3/2; D404/6/2; D423/4/2; D423/5/3; D416/5/2; D416/6/2; D403/2/2; D409/2/2; D403/2/2; D409/2/2; D409/2/2D406/2/2; D415/2/2; D415/5/2; D414/3/2; D417/7/2; D416/7/2; D415/7/2; D423/8/2; D410/6/2; D410/5/2; D417/8/2; D418/5/2; D426/6/3; D403/6/2; D406/4/2; D409/5/2; D423/9/2; D410/7/2; D403/7/2; D418/6/2; D415/8/2; D416/8/2; D414/5/2; D411/5/2។

២៣. នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១ សហមេធាវីការពារក្ដីរបស់ អៀង សារី បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្ដឹងឧទ្ធរណ៍ទាំងនោះ[៤៣] ដោយមានការបញ្ជាក់ជាថ្មីម្ដងទៀតថា ពួកគេអាចសំអាងទៅលើ "ឆន្ទានុសិទ្ធិរបស់អង្គបុរេជំនុំជម្រះក្នុងការសម្រេច ថាតើសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់លក្ខណៈវិនិច្ឆ័យត្រឹមត្រូវដែរ ឬយ៉ាងណា នៅពេលធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ២៣ *ស្ទួន* ហើយស្របពេលដំណាលគ្នានេះ ក៏បានជំរុញឱ្យអង្គបុរេជំនុំជម្រះជ្រើសរើសយកវិធីសាស្ត្រដែលមានលក្ខណៈបត់បែន និងពេញលេញ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី"។

២៤. មិនមានចម្លើយតបផ្សេងទៀតទៅនឹងបណ្ដឹងឧទ្ធរណ៍ទាំងនេះ ត្រូវបានដាក់ជូននោះទេ។ អនុលោមតាមវិធាន ៧៧ *ស្ទួន*(២) នៃវិធានផ្ទៃក្នុង ការឆ្លើយតបមិនត្រូវបានអនុញ្ញាតនោះទេ។

## II. សេចក្ដីសង្ខេបនៃបណ្ដឹងឧទ្ធរណ៍

### ១. សំណូមពរដែលបានស្នើសុំដោយសហមេធាវីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

២៥. នៅក្នុងបណ្ដឹងឧទ្ធរណ៍ទាំងអស់ មេធាវីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះ៖

ក. ប្រកាសទទួលយកបណ្ដឹងឧទ្ធរណ៍។

ខ. ច្រានចោលដីកាសម្រេចនីមួយៗរបស់សហចៅក្រមស៊ើបអង្កេត នូវរាល់ដីកាសម្រេចទាំងអស់ដែលបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានប្ដឹងឧទ្ធរណ៍។

គ. ផ្ដល់ឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ ដូចមានឈ្មោះនៅក្នុងបណ្ដឹងឧទ្ធរណ៍ នូវឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២។

---

[៤៣] ចម្លើយតបរបស់ អៀង សារី ទៅនឹងបណ្ដឹងឧទ្ធរណ៍នានាស្ដីពីការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលសហចៅក្រមស៊ើបអង្កេត បានបដិសេធចោល កាលពីថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១១ ឯកសារ D392/2/3; សូមមើលផងដែរ ឯកសារ D393/4/3; D394/2/3; D394/4/3; D397/5/3; D401/4/4; D401/5/3; D401/6/3; D399/3/3;, D424/4/3; D426/4/3; D419/2/3; D404/5/3; D423/6/3; D423/7/3; D417/4/3។

## ២. សំណើសុំដោយសហមេធាវីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍

២៦. ជាទូទៅ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងនូវទឡ្ហីករណ៍ដូចខាងក្រោម សម្រាប់ភាពអាចទទួលយកបាននៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួន៖

> "ផ្អែកតាម វិធាន ៧៧ ស្ទួន(១) និង(២) នៃវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មលើកទី ៥ ដីកាសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អាចត្រូវបានប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដប់ (១០) ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកាសម្រេចនេះ គឺថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១០។ កាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់បណ្ដឹងឧទ្ធរណ៍ គឺនៅថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១០។ ហេតុដូច្នេះ បណ្ដឹងឧទ្ធរណ៍នេះត្រូវបានដាក់ជូនតាមពេលកំណត់។ ដីកាដែលត្រូវបានប្ដឹងបដិសេធ គឺជាសេចក្ដីសម្រេចស្ដីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហេតុដូច្នេះ បណ្ដឹងឧទ្ធរណ៍នេះគឺជាអាចទទួលយកបានទាំងផ្នែកអង្គហេតុ និងពេលវេលា។

## ៣. មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍

២៧. បណ្ដឹងឧទ្ធរណ៍ដែលបានដាក់ជូនអង្គបុរេជំនុំជម្រះ ដោយមេធាវីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺមានមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍មួយចំនួន។ មុននឹងពិភាក្សាលម្អិតនៅក្នុងផ្នែកនេះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ក្នុងពេលដែលមតិភាគច្រើនលើសលប់របស់ចៅក្រមនៃអង្គបុរេជំនុំជម្រះ បានពិនិត្យទៅលើបណ្ដឹងឧទ្ធរណ៍ និងដីកាដែលរងការជំទាស់ ដែលនឹងត្រូវរៀបរាប់នៅផ្នែកខាងក្រោមនោះ ចៅក្រម Catherine Marchi Uhel មានការជំទាស់ទៅនឹងវិធីសាស្ត្រដែលអនុម័តិយកដោយមតិភាគច្រើនលើសលប់ ហើយដោយអនុលោមទៅតាមមាត្រា ១៤(២) នៃច្បាប់អ.វ.ត.ក និងវិធានផ្ទៃក្នុង ៧៧(១៤) បានដាក់ភ្ជាប់យោបល់ជំទាស់នេះដាច់ដោយឡែក និងដោយផ្អែក ដែលមតិជំទាស់នេះមានចាប់ពីទំព័រទី៦៣ រហូតដល់ចុងបញ្ចប់។ សំអាងហេតុសម្រាប់មតិភាគច្រើនលើសលប់របស់ចៅក្រមគឺមាននៅត្រង់កថាខណ្ឌ ២៨ ដល់ ១១៨ ខាងក្រោម[44]។ ពាក្យ "អង្គបុរេជំនុំជម្រះ" ដែលប្រើប្រាស់នៅក្នុងកថាខណ្ឌ ២៨ ដល់ ១១៨ គឺត្រូវបកស្រាយថា "មតិភាគច្រើនលើសលប់របស់អង្គបុរេជំនុំជម្រះ"។

---

[44] អនុលោមតាមវិធាន៧៧(១៣) នៃវិធានផ្ទៃក្នុង "សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឲ្យមានសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូប" យ៉ាងតិច ដូច្នេះសម្រេចដែលបានឯកភាព និងលើកឡើងនៅពេលនេះគឺជា "សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ"។

២៨. អង្គបុរេជំនុំជម្រះយល់ឃើញថា មូលដ្ឋានទូទៅ និងសំខាន់បំផុតមួយចំនួនរួមមាន ពាក្យបណ្តឹងដែលលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំលើអង្គច្បាប់ ដោយមិនបានផ្តល់សំអាងហេតុឲ្យបានច្បាស់លាស់ ចំពោះការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារថា ការភ័ន្តច្រឡំអង្គច្បាប់ដោយសហចៅក្រមស៊ើបអង្កេតនៅមុន និងក្រោយពេលចេញដីកាសម្រេចនានារបស់ខ្លួន ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានបណ្តាលឲ្យមានភាពមិនត្រឹមត្រូវផ្នែកនីតិវិធី ហើយដោយការបង្កើតពាក្យថា "ព្យសនកម្ម" សហចៅក្រមស៊ើបអង្កេតបានបង្កឲ្យមានការភ័ន្តច្រឡំអង្គច្បាប់ និងបានបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងមិនត្រឹមត្រូវទាល់តែសោះ។

## III. ដីកាសម្រេចនានា

២៩. នៅក្នុងដីកាសម្រេចដែលរងការជំទាស់លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់គោលការណ៍ណែនាំដូចខាងក្រោម ដើម្បីឈានទៅដល់ការធ្វើសេចក្តីសម្រេច មិនទទួលយកពាក្យសុំទាំងនេះ៖

"**ក. គោលការណ៍ណែនាំ**

៨. បណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺបើកចំហរចំពោះជនរងគ្រោះទាំងអស់ ដែលអាចបង្ហាញ **នៅក្នុងលក្ខណៈមួយដែលអាចឲ្យជឿជាក់បានថា** ពួកគាត់បានទទួលរងព្យសនកម្មលើរាងកាយ សម្ភារៈ ឬផ្លូវចិត្ត *តាមព្រឹត្តិហេតុ* ដែលជាផលវិបាកដោយផ្ទាល់ យ៉ាងហោចណាស់ពីបទល្មើសមួយក្នុងចំណោម<u>បទល្មើសជាច្រើន ដែលត្រូវបានចោទប្រកាន់ចំពោះជនត្រូវចោទ</u> មានន័យថា អង្គហេតុផ្នែកសម្ភារៈនៃអំពើព្រហ្មទណ្ឌ <u>ដែលស្ថិតនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ ក.ស.ព</u>។

**i) កម្រិតនៃការបង្ហាញភស្តុតាង និងភាពគ្រប់គ្រាន់នៃព័ត៌មាន**

[...] សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា នៅដំណាក់កាលមុនការជំនុំជម្រះ ពួកគាត់មិនមានតួនាទីធ្វើការសម្រេចជាចុងក្រោយ ទាក់ទងទៅនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលនោះទេ។ ការសម្រេចជាចុងក្រោយបែបនេះនឹងត្រូវធ្វើឡើងឲ្យបានត្រឹមត្រូវដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសាលក្រមរបស់ខ្លួន ដោយសំអាងទៅលើភស្តុតាងទាំងអស់ដែលបានលើកឡើង នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធី។ ជា

លទ្ធផល ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយអាចទទួលយកបាន ដោយសំអាងទៅលើធាតុផ្សំទាំងអស់នៅក្នុងសំណុំរឿង នោះសហចៅក្រមស៊ើបអង្កេតត្រូវវាយតម្លៃ ថាតើមានមូលដ្ឋានដែលគួរឱ្យជឿជាក់បាន*ជាបឋម* ដើម្បីសម្រេចថា អ្នកដាក់ពាក្យសុំពិតជាបានទទួលរងព្យសនកម្ម ដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងអង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរនោះមែន។

[...]

ម្យ៉ាងវិញទៀត អ្នកដាក់ពាក្យសុំទាំងអស់ត្រូវតែបង្ហាញអត្តសញ្ញាណរបស់ខ្លួនឱ្យបានច្បាស់លាស់។ ទោះជាយ៉ាងណាក៏ដោយ សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថាបញ្ហានីតិវិធីសម្រាប់ការចុះបញ្ជីកំណើត និងការចុះបញ្ជីមរណភាព នៅក្នុងប្រទេសកម្ពុជាមានការលំបាក និងជួនកាលមិនអាចឱ្យអ្នកដាក់ពាក្យសុំខ្លះផ្តល់ការបង្ហាញអត្តសញ្ញាណរបស់ខ្លួនឱ្យបានពេញលេញនោះទេ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា គួរតែមានវិធីសាស្ត្រមួយដែលមានលក្ខណៈអាចបត់បែនបាន។

លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា អ្នកដាក់ពាក្យសុំភាគច្រើនដែលលើកឡើងពីព្យសនកម្មផ្លូវចិត្ត នឹងមិនអាចចង្អុលបង្ហាញទំនាក់ទំនងរបស់ខ្លួនជាមួយនឹងជនរងគ្រោះដោយផ្ទាល់នោះទេ។ ហេតុដូច្នេះ ក្នុងករណីសមស្រប ពួកគេនឹងអនុវត្តការសន្មតជាមុនអំពីទំនាក់ទំនងសាច់ញាតិ ដោយសំអាងទៅលើទម្រង់ព័ត៌មានជនរងគ្រោះរបស់អ្នកដាក់ពាក្យសុំ និងឯកសារគាំទ្រដទៃទៀតដែលអាចមាន។

**ii) អត្ថិភាពនៃព្យសនកម្ម**

ដើម្បីមានសិទ្ធិចូលរួម ជនរងគ្រោះដែលមានបំណងចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែអះអាងដែលគួរឱ្យជឿជាក់បាន ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតអាចទទួលយកអត្ថិភាពនៃព្យសនកម្មផ្ទាល់ខ្លួនលើរាងកាយ សម្ភារៈ ឬផ្លូវចិត្ត ដែលពិតជាកើតមាន តាមដែលអាចធ្វើទៅបាន។ ទាក់ទងទៅនឹងព្យសនកម្មផ្លូវចិត្ត សហចៅក្រមស៊ើបអង្កេត កត់សម្គាល់ឃើញថា មាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះចែងថា៖ [*"ព្យសនកម្មផ្លូវចិត្តអាចរួមមាន មរណភាពនៃសាច់ញាតិ ដែលជាជនរងគ្រោះពីឧក្រិដ្ឋកម្មទាំងនោះ"*]។ ហេតុដូច្នេះ ដើម្បីអាចឱ្យទទួលយកបាន ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរង មិនចាំបាច់ត្រូវតែដោយផ្ទាល់នោះទេ ប៉ុន្តែ វាត្រូវតែជាព្យសនកម្មផ្ទាល់ខ្លួន។ ដើម្បីបង្ហាញអំពីអត្ថិភាពនៃព្យសនកម្មផ្លូវចិត្តផ្ទាល់ខ្លួន សហចៅក្រមស៊ើបអង្កេតពិចារណាថា៖

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ក. មានការសន្មតទុកជាមុនអំពីព្យសនកម្មផ្លូវចិត្ត ចំពោះសមាជិកគ្រួសារផ្ទាល់របស់ជនរងគ្រោះដោយផ្ទាល់នេះ។ នៅក្នុងការអនុវត្តលក្ខណៈវិនិច្ឆ័យដែលបានកំណត់ក្នុងដីកាសម្រេចនាពេលបច្ចុប្បន្ននេះ សញ្ញាណនៃសាច់ញាតិជិតស្និទ្ធមិនមែនគ្របដណ្តប់តែទៅលើឪពុកម្តាយ និងកូនប៉ុណ្ណោះទេ ប៉ុន្តែ ក៏រាប់បញ្ចូលនូវសហព័ទ្ធ និងបងប្អូនបង្កើតរបស់ជនរងគ្រោះដោយផ្ទាល់នេះផងដែរ។ ការសន្មតទុកជាមុននេះនឹងត្រូវបានពិចារណាថាជាការកំណត់ស្ថានភាពដូចខាងក្រោមនេះ៖

i) នៅពេលដែលជនរងគ្រោះដោយផ្ទាល់នេះបានស្លាប់ ឬបានបាត់ខ្លួនដោយសារតែផលវិបាកផ្ទាល់ពីអង្គហេតុ ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។

ii) នៅពេលដែលជនរងគ្រោះដោយផ្ទាល់ ត្រូវបានផ្លាស់ប្តូរទីលំនៅ និងបំបែកចេញពីគ្រួសារដោយបង្ខំ ដែលជាផលវិបាកផ្ទាល់ពីអង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។ ការបំបែកចេញពីគ្រួសារនេះបណ្តាលឲ្យមានការឈឺចាប់ចំពោះសមាជិកគ្រួសារផ្ទាល់ ដែលបំពេញលក្ខណៈវិនិច្ឆ័យស្តីពីព្យសនកម្មផ្លូវចិត្តផ្ទាល់ខ្លួននេះ។

ខ. នៅពេលជនរងគ្រោះដោយផ្ទាល់នេះត្រូវបានរៀបការដោយបង្ខំ នោះកាលៈទេសៈបែបនេះពិតជាបណ្តាលឲ្យមានការឈឺចាប់ ដែលបំពេញលក្ខណៈវិនិច្ឆ័យស្តីពីព្យសនកម្មផ្លូវចិត្តផ្ទាល់ខ្លួន ចំពោះឪពុកម្តាយ សហព័ទ្ធ និងកូនៗរបស់ខ្លួនហើយ។

គ. សហចៅក្រមស៊ើបអង្កេត យល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងដែលយល់ឃើញថា *"ទាក់ទងទៅនឹងចំណងគ្រួសារសាច់ញាតិឆ្ងាយ នោះព្យសនកម្មដោយផ្ទាល់អាចកាន់តែមានការលំបាកក្នុងការចង្អុលបង្ហាញ"* និងពិចារណាថាមានតែការសន្មតជាមុនអំពីសាច់ញាតិ ដែលមានចំពោះសមាជិកគ្រួសារសាច់ញាតិឆ្ងាយ (ជីដូន ជីតា មីង ពូ ក្មួយប្រុស ក្មួយស្រី បងប្អូនជីដូនមួយ សាច់ថ្លៃ និងសាច់ញាតិឆ្ងាយដទៃទៀត)។ ក្នុងករណីបែបនេះ សហចៅក្រមស៊ើបអង្កេតនឹងវាយតម្លៃទៅតាមករណីនីមួយៗ ថាតើមានធាតុផ្សំគ្រប់គ្រាន់ដើម្បីសន្មតអំពីចំណងនៃសេចក្តីស្រឡាញ់ ឬការរស់នៅក្នុងបន្ទុករវាងអ្នកពាក្យសុំ និងជនរងគ្រោះដោយផ្ទាល់នេះដែរឬអត់។ ការសន្មតទុកជាមុន នឹងត្រូវបានចាត់ទុកថាជាកត្តាកំណត់ នៅពេលដែលជនរងគ្រោះដោយផ្ទាល់នេះបានស្លាប់ ឬបានបាត់ខ្លួន

ដោយសារតែផលវិបាកដោយផ្ទាល់ពីអង្គហេតុ ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ។

ឃ. ហេតុដូច្នេះ ព្យសនកម្មផ្លូវចិត្តផ្ទាល់ខ្លួនដែលបានលើកឡើងថា ជាផលវិបាកដោយផ្ទាល់ពីអំពើមនុស្សឃាត ឬការបាត់ខ្លួនសាច់ញាតិ នឹងមានលក្ខណៈងាយស្រួលទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ជាងករណីរៀបការដោយបង្ខំ ឬការធ្វើទុក្ខបុកម្នេញផ្នែកសាសនា។ សំអាងហេតុដូចគ្នាត្រូវតែអនុវត្ត*ការសន្មតទុកជាមុនអំពីភស្តុតាងដែលមានលក្ខណៈរឹងមាំ (a fortiori)* ចំពោះសាក្សីធម្មតាពីអង្គហេតុទាំងឡាយដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរដែលថា៖ ព្យសនកម្មផ្លូវចិត្តមានទំហំ និងលក្ខណៈខុសពីការឈឺចាប់ផ្លូវអារម្មណ៍ដែលអាចចាត់ទុកថា ពិតជាបានកើតឡើងចំពោះសាក្សីដែលបានឃើញឧក្រិដ្ឋកម្មប្រភេទនេះមែន ហើយពាក្យសុំរបស់ពួកគេនឹងត្រូវបានបដិសេធចោល លើកលែងតែសាក្សីទាំងនោះបានឃើញព្រឹត្តិការណ៍ដែលសាហាវហួសហេតុ និងគួរឱ្យតក់ស្លុតបំផុតនោះ។

**iii) ទំនាក់ទំនងហេតុនិងផល រវាងព្យសនកម្ម និងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ចំពោះជនត្រូវចោទ**

ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំត្រូវបង្ហាញថា ព្យសនកម្មគឺជាផលវិបាកដោយផ្ទាល់ពីអង្គហេតុ ដែលស្ថិតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

លក្ខខណ្ឌវិនិច្ឆ័យនេះ គឺមានលក្ខណៈច្បាស់លាស់ចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការធ្វើអន្តរាគមន៍។ ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅក្រោមនីតិវិធី អ.វ.ត.ក អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចធ្វើការស៊ើបអង្កេតដោយគ្រាន់តែបានចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីបានទេ។ ដោយការកំហិតចំពោះ*សកម្មភាពតាមរយៈអន្តរាគមន៍* នោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគ្រាន់តែអាចចូលរួមនៅក្នុងដំណើរការនីតិវិធីដែលកំពុងតែបន្ត តាមរយៈការដាក់ពាក្យសុំនេះតែប៉ុណ្ណោះ និងមិនអាចពង្រីកការស៊ើបអង្កេតឱ្យហួសពីបណ្តឹង*ទៅលើអង្គហេតុ (in rem seisin) ដែលសហព្រះរាជអាជ្ញាបានប្តឹងមកសហចៅក្រមស៊ើបអង្កេតនោះបានទេ'*)។

ហេតុដូច្នេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកម្រិត មានន័យថា ពាក្យសុំនេះមិនអាចលើកឡើងនូវអង្គហេតុថ្មីក្នុងអំឡុងពេលស៊ើបអង្កេត ដោយមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញាបានឡើយ។

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

អាស្រ័យហេតុនេះ ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចទទួលយកបាន នោះតម្រូវឱ្យអ្នកដាក់ពាក្យសុំត្រូវបង្ហាញថា ព្យសនកម្មដែលខ្លួនបានលើកឡើង គឺបណ្ដាលមកពីអង្គហេតុដែលត្រូវបានបើកកិច្ចស៊ើបសួររួចរាល់ហើយតែប៉ុណ្ណោះ”។

៣០. នៅក្នុងកថាខណ្ឌទាំងឡាយដែលបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ផ្ដល់សំអាងហេតុដែលកំណត់ត្រឹមតែអ្វីដែលត្រូវបានដកស្រង់ដូចខាងក្រោម (*ដើម្បីងាយស្រួលដល់ការយោង នោះលេខយោងជើងទំព័រមិនត្រូវបានលុបចោលទេ*)៖

> “សហចៅក្រមស៊ើបអង្កេតយល់ឃើញថា **ទំនាក់ទំនងហេតុទៅនិងផលជាចាំបាច់រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញដោយ** [...] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ[៤៥] ដោយហេតុថាអង្គហេតុដែលបានបញ្ជាក់ មានលក្ខណៈខុសគ្នាទាំងស្រុងពីអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានទទួលនាពេលបច្ចុប្បន្ននេះ ហើយមិនមានកាលៈទេសៈណាមួយដែលអនុញ្ញាតសហចៅក្រមស៊ើបអង្កេត ពិចារណាទៅលើលទ្ធភាពនៃទំនាក់ទំនងដោយផ្ទាល់ រវាងព្យសនកម្មដែលបានលើកឡើង និងឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរនោះទេ។
>
> លើសពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា [...] **នៅក្នុងពាក្យសុំរបស់ខ្លួន** អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[៤៦] **មិនបានផ្ដល់ព័ត៌មានឱ្យបានគ្រប់គ្រាន់ដើម្បីបង្ហាញភាពស្របគ្នានឹង**វិធាន ២៣ *ស្ទួន*(១) និង (៤) នៃវិធានផ្ទៃក្នុងនោះទេ។
>
> [...] អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[៤៧] មិនបានបង្ហាញអត្តសញ្ញាណរបស់ខ្លួនឱ្យបានគ្រប់គ្រាន់ទេ”។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

---

[៤៥] សូមមើលឧបសម្ព័ន្ធ [...] ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលយក៖ ព្យសនកម្មមិនជាប់ទាក់ទងទៅនឹងអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេតនោះទេ។

[៤៦] សូមមើលឧបសម្ព័ន្ធ [...] ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលយក៖ មិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីបញ្ជាក់ថាស្របជាមួយវិធាន ២៣ *ស្ទួន*(១) និង (៤) នៃវិធានផ្ទៃក្នុងនោះទេ។

[៤៧] សូមមើលឧបសម្ព័ន្ធ [...] ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនត្រូវបានទទួលយក៖ មិនបានផ្ដល់ការបង្ហាញអត្តសញ្ញាណទេ។

សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ២២ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

## IV. ច្បាប់ដែលអាចយកមកអនុវត្តបាន

៣១. ឯកសារយោង គឺសំដៅទៅលើ៖

ក. កិច្ចព្រមព្រៀង[៤៨] និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ("ច្បាប់បង្កើត អ.វ.ត.ក)[៤៩]។

ខ. វិធាន ២១ វិធាន ២៣ វិធាន ២៣ ស្ទួន (វិសោធនកម្មលើកទី ៣ ទី ៤ ទី ៥ និងលើកទី ៧)[៥០] វិធាន ២៣ ស្ទួនពីរ វិធាន ២៣ ស្ទួនបី វិធាន ២៣ ស្ទួនបួន វិធាន ៨០ វិធាន ៨១ និង វិធាន ១១៤ នៃវិធានផ្ទៃក្នុង។

គ. មាត្រា ៣.២ មាត្រា ៣.៧ និងមាត្រា ៣.៨ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ហើយ

៣២. ការណែនាំអាចរកឃើញនៅក្នុងគោលការណ៍ទូទៅ[៥១] ស្តីពីជនរងគ្រោះ ដូចដែលមាននៅក្នុងច្បាប់អន្តរជាតិ ដែលក្នុងនោះរួមមាន៖

**មាត្រា ១ មាត្រា ២ មាត្រា ៤ និងមាត្រា ១៨ នៃសេចក្តីប្រកាសពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌ សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្ម និងការរំលោភអំណាច ដែលបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្តីសម្រេចលេខ ៤០.៣៤ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ចែងថា៖**

១. "ជនរងគ្រោះ" មានន័យថា ជនទាំងឡាយណា ទោះជាឯកត្តបុគ្គលក្តី ឬជាសមូហភាពក្តី ដែលបានទទួលរងអន្តរាយ រួមទាំងរបួសស្នាមផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់សតិអារម្មណ៍ ការបាត់បង់ផ្នែកសេដ្ឋកិច្ច ការខូចខាតយ៉ាងធំនៃសិទ្ធិជាមូលដ្ឋានរបស់ពួកគេ តាមរយៈអំពើសកម្ម ឬអកម្ម ដែលជាការរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌដែលកំពុងអនុវត្តនៅក្នុងរដ្ឋ

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

---

[៤៨] កិច្ចព្រមព្រៀងរវៀងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង")។

[៤៩] ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញបូកជាមួយច្បាប់វិសោធនកម្មដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦), ("ច្បាប់ អ.វ.ត.ក")។

[៥០] សូមកត់សម្គាល់ថា វិធាន ២៣ *ស្ទួន* នៃវិសោធនកម្មវិធានផ្ទៃក្នុងលើកទី ៥ និងលើកទី ៧ គឺដូចគ្នាតែម្តង។

[៥១] *Lubanga* ICC ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ ICC-01/04-01/06 OA9 AO10 កថាខណ្ឌ ៣៣៖ "អង្គជំនុំជម្រះសាលាឧទ្ធរណ៍មិនបានរកឃើញកំហុសនៅក្នុងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើគោលការណ៍ជាមូលដ្ឋានសម្រាប់គោលបំណងនៃការណែនាំនោះទេ" ។

ជាសមាជិក រួមទាំងច្បាប់ទាំងឡាយដែលហាមប្រាមពីការរំលោភអំណាចដែលមានចរិតព្រហ្មទណ្ឌ។

២. យោងតាមសេចក្ដីប្រកាសនេះ បុគ្គលម្នាក់អាចត្រូវបានចាត់ទុកថាជាជនរងគ្រោះបាន ដោយមិនគិតថា ជនល្មើសត្រូវបានបង្ហាញអត្តសញ្ញាណ ចាប់ខ្លួន ចោទប្រកាន់ ឬ ផ្ដន្ទាទោសនោះទេ និងដោយមិនគិតពីទំនាក់ទំនងគ្រួសាររវាងជនរងគ្រោះ និងជនល្មើសនោះឡើយ។ ពាក្យថា "ជនរងគ្រោះ" ក៏មានរួមបញ្ចូលផងដែរ នូវគ្រួសារ ឬសមាជិកគ្រួសារផ្ទាល់របស់ជនរងគ្រោះផ្ទាល់ និងជនទាំងឡាយណាដែលបានរងព្យសនកម្មដោយសារតែបានអន្តរាគមន៍ជួយដល់ជនរងគ្រោះ ឬទប់ស្កាត់មិនឲ្យកើតមានជនរងគ្រោះ។

៤. ជនរងគ្រោះគួរត្រូវបានគេប្រព្រឹត្តដោយក្ដីមេត្តាករុណា និងដោយក្ដីគោរពចំពោះសេចក្ដីថ្លៃថ្នូររបស់ពួកគេ។ ពួកគេមានសិទ្ធិទទួលបានយន្តការនៃយុត្តិធម៌ និងដំណោះស្រាយឆាប់រហ័ស ដូចដែលមានចែងក្នុងច្បាប់ជាតិ ចំពោះព្យសនកម្ម ដែលពួកគេបានទទួលរង។

១៨. "ជនរងគ្រោះ" មានន័យថា ជនទាំងឡាយណា ទោះជាឯកត្តបុគ្គលក្ដី ឬជាសមូហភាពក្ដី ដែលបានទទួលរងព្យសនកម្ម រួមទាំងព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់សតិអារម្មណ៍ ការបាត់បង់ផ្នែកសេដ្ឋកិច្ច ឬការខូចខាតយ៉ាងធំនៃសិទ្ធិជាមូលដ្ឋានរបស់ពួកគេ តាមរយៈអំពើសកម្ម ឬអកម្ម ដែលមិនទាន់បានបង្កើតទៅជាការរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌជាតិនៅឡើយ តែពិតជាបានរំលោភបំពានលើវិធានទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ។

**គោលការណ៍ទី ៨ និងទី ៩ នៃមហាសន្និបាតអង្គការសហប្រជាជាតិ គោលកាណ៍ជាមូលដ្ឋាន និងការណែនាំស្ដីពីសិទ្ធិទទួលបានដំណោះស្រាយ និងការជួសជុលសំណងព្យសនកម្មដល់ជនរងគ្រោះដោយការរំលោភបំពានដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ តាមសេចក្ដីសម្រេចលេខ A/RES/៦០/១៤៧ ដែលចែងថា៖**

៨. សម្រាប់គោលបំណងនៃឯកសារនេះ ជនរងគ្រោះគឺជាបុគ្គលទាំងឡាយដែលជាឯកត្តបុគ្គល ឬជាសមូហភាព ដែលបានទទួលរងការខូចខាត ដោយរួមទាំងព្យសនកម្មខាងផ្លូវកាយ ឬផ្លូវចិត្ត ការឈឺចាប់ខាងផ្លូវអារម្មណ៍ ការខាតបង់ខាងសេដ្ឋកិច្ច ឬដោយការអន្តរាយជាដុំកំភួនដល់សិទ្ធិជាមូលដ្ឋានរបស់ខ្លួន តាមរយៈអំពើសកម្ម ឬអកម្ម ដែលបង្កើតបានជាការរំលោភដ៏កំរោលលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានដ៏ធ្ងន់ធ្ងរលើ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ច្បាប់មនុស្សធម៌អន្តរជាតិ។ ក្នុងករណីសមស្រប និងអនុលោមតាមច្បាប់ជាតិ ពាក្យថា "ជនរងគ្រោះ" ក៏រាប់បញ្ចូលផងដែរនូវក្រុមគ្រួសារផ្ទាល់ ឬអ្នកទាំងឡាយណាដែលរស់នៅក្នុងបន្ទុកផ្ទាល់ និងបុគ្គលទាំងឡាយណាដែលបានទទួលរងការខូចខាតដោយសារតែការធ្វើអន្តរាគមន៍ជួយជនរងគ្រោះដែលកំពុងស្ថិតនៅក្នុងភាពអាសន្ន ឬដើម្បីទប់ស្កាត់កុំឲ្យក្លាយជាជនរងគ្រោះ។

៩. បុគ្គលម្នាក់ត្រូវបានចាត់ទុកថាជាជនរងគ្រោះ ដោយមិនចាំបាច់គិតថាទាល់តែជនល្មើសត្រូវបានកំណត់អត្តសញ្ញាណ ចាប់ខ្លួន ចោទប្រកាន់ ឬផ្តន្ទាទោសនោះទេ ហើយក៏មិនចាំបាច់គិតពីទំនាក់ទំនងក្រុមគ្រួសាររវាងជនល្មើស និងជនរងគ្រោះនោះដែរ។

## V. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៣៣. វិធាន ៧៤(៤)(ខ) នៃវិធានផ្ទៃក្នុងចែងថា៖ "ដើមបណ្តឹងឧទ្ធរណ៍អាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត [...] ដែលប្រកាសពីការមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ។ វិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុងចែងថា៖ "ក្នុងរយៈពេល ១០ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីសម្រេចទៅលើភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម្ចាស់បណ្តឹងឧទ្ធរណ៍ ត្រូវដាក់បណ្តឹងឧទ្ធរណ៍នេះ"។ បណ្តឹងឧទ្ធរណ៍ទាំងនេះត្រូវបានដាក់ដោយអនុលោមតាមវិធាន ៧៤(៤)(ខ) និងវិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះ បណ្តឹងឧទ្ធរណ៍ទាំងនេះអាចទទួលយកបាន។

## VI. បទដ្ឋាននៃការពិនិត្យឡើងវិញ

៣៤. វិធាន ៧៧*ស្ទួន* នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យអង្គជំនុំជម្រះបដិសេធដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំអង្គហេតុ និង/ឬអង្គច្បាប់។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា "ចំពោះបណ្តឹងឧទ្ធរណ៍ គេបានបង្ហាញយ៉ាងច្បាស់នៅក្នុងយុត្តិសាស្ត្រអន្តរជាតិថា កំហុសលើអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យ *ជាថ្មីឡើងវិញ* ដើម្បីពិចារណាថាតើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬអត់ ហើយកំហុសលើអង្គហេតុត្រូវបានពិនិត្យឡើងវិញ ស្របតាមបទដ្ឋានស្តីពីភាពសមស្របដើម្បីសម្រេចថាតើ អ្នកវិនិច្ឆ័យសេចក្តី ទៅលើអង្គហេតុមិនប្រកបដោយហេតុផល ដែលអាចនាំឲ្យឈានដល់ការ

សម្រេចទៅលើអង្គហេតុ ដែលបានលើកឡើងនេះដែរឬអត់”[៥២]។

៣៥. អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចធានាថា ដំណើរការនីតិវិធី នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌។ ផ្នែកនេះគឺពាក់ព័ន្ធទៅនឹងបុគ្គលទាំងឡាយ ដែលស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា ដែលត្រូវបានប្រព្រឹត្តដោយភាពស្មើគ្នានៅចំពោះមុខ សាលាក្តីនេះ[៥៣]។ គោលការណ៍ជាសារវ័ន្តនៃនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ដែលបានចែងនៅក្នុង វិធាន ២១ នៃវិធានផ្ទៃក្នុងតម្រូវថា ត្រូវតែបកស្រាយច្បាប់ក្នុងន័យ “*ការពារជានិច្ចដល់ ផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់*” ថា ត្រូវប្រុងប្រយ័ត្នដើម្បី “រក្សាឲ្យបាននូវ*តុល្យភាព* រវាងសិទ្ធិរបស់ភាគីទាំងឡាយ និងថា “ដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ត្រូវតែឈានដល់ ការធ្វើសេចក្តីសន្និដ្ឋាននៅក្នុង*រយៈពេលមួយសមស្រប*”។[៥៤] ដោយការពិចារណាទៅលើចំណុចនេះ និងដោយការពិចារណាទៅលើចំនួនបណ្តឹងឧទ្ធរណ៍ដ៏ច្រើននៅចំពោះមុខខ្លួន បន្ទាប់ពីបានទទួល បណ្តឹងឧទ្ធរណ៍លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៥ និងក្រោយពីបានពិនិត្យ ទៅលើដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតដែលពាក់ព័ន្ធរួចមក អង្គបុរេជំនុំជម្រះបាន រកឃើញកំហុសចម្បងៗមួយចំនួនដែលពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានបដិសេធ។ អង្គបុរេជំនុំជម្រះបានកំណត់ក្រុមប្រឹក្សាជំនុំជម្រះពីរ ផ្សេងគ្នា[៥៥] ដើម្បីបញ្ចូលផងដែរនូវបណ្តឹងដែលបានដាក់ប្រឆាំងនឹងដីកាដែលរងការជំទាស់ក្នុង គោលបំណងអនុញ្ញាតធ្វើការត្រួតពិនិត្យកំហុសជាមូលដ្ឋានដែលមានលក្ខណៈរួម នៅក្នុងសេចក្តី

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

---

[៥២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៣។

[៥៣] កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បានអនុម័ត និងបើកឲ្យចុះហត្ថលេខា ឲ្យសច្ចាប័ន និងឲ្យចូល ជាសមាជិកតាមសេចក្តីសម្រេចចិត្តលេខ២២០០ A(XXI) ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ របស់មហាសន្និបាតអង្គការសហប្រជា ជាតិ ចូលជាធរមាននៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦ ស្របតាមមាត្រា១៤ (១) ឃ្លាទី ១ ។

[៥៤] *សូមមើលផងដែរ* ICCPR, មាត្រា ១៤ (១) និង (៣)(គ)។

[៥៥] សូមមើលផងដែរ នូវសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ PTC73, PTC74, PTC77, PTC78, PTC79, PTC80, PTC81, PTC82, PTC83, PTC84, PTC85, PTC86, PTC87, PTC88, PTC89, PTC90, PTC91, PTC92, PTC93, PTC94, PTC95, PTC96, PTC97, PTC98, PTC99, PTC100, PTC101, PTC102, PTC103, PTC105, PTC106, PTC107, PTC108, PTC109, PTC110, PTC111, PTC116, PTC117, PTC118, PTC119, PTC120, PTC121, PTC122, PTC123, PTC124, PTC125, PTC126, PTC127, PTC128, PTC129, PTC130, PTC131, PTC132, PTC133, PTC134, PTC135, PTC136, PTC137, PTC138, PTC139, PTC140, PTC141, PTC143, PTC144, PTC148, PTC149, PTC150, PTC151, PTC153, PTC154, PTC155, PTC156, PTC158, PTC159, PTC160, PTC161, PTC162, PTC163, PTC166, PTC167, PTC168, PTC169, PTC170, PTC171.

សម្រេចរបស់ខ្លួន[៥៦] ។ ហេតុដូច្នេះ ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ បន្ទាប់ពីការពិនិត្យមើលកំហុសបែបនោះ និងការទាញសេចក្តីសន្និដ្ឋានរួចមក អង្គបុរេជំនុំជម្រះបានសម្រេចពិនិត្យមើលជាថ្មីឡើងវិញទៅលើមូលដ្ឋាននៃសំអាងហេតុទាក់ទងទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត ហើយដែលបានប្តឹងឧទ្ធរណ៍រួចមក។

៣៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍ទាំងនេះមិនត្រូវបានជំទាស់[៥៧] ហើយក៏ត្រូវបានយកមកពិចារណាទៅលើអានុភាពនៃសិទ្ធិរបស់ភាគីដទៃទៀតនៅក្នុងសំណុំរឿង ០០២។

## VII. ការពិនិត្យទៅលើកំហុសដែលបានរកឃើញនៅក្នុងដីកាសម្រេចនានា

### ១. កំហុសលើអង្គច្បាប់ - កង្វះសំអាងហេតុជាក់លាក់ចំពោះការច្រានចោលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៣៧. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធីសាស្ត្រដែលបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតជាពិសេសទាក់ទងទៅនឹងបណ្តាកថាខណ្ឌទាំងឡាយ នៅក្នុងដីកាសម្រេចទាំងអស់របស់ខ្លួន និងទាក់ទងទៅនឹងឧបសម្ព័ន្ធ ដែលសហចៅក្រមស៊ើបអង្កេតបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានបង្ហាញគ្រប់គ្រាន់ ឬឲ្យបានត្រឹមត្រូវទៅលើការពិចារណាចំពោះពាក្យសុំទាំងនោះក្នុងលក្ខណៈជាបុគ្គលនោះទេ។ ក្នុងន័យនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងពេលខ្លួនបដិសេធមិនទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតបានលើកឡើងតែមូលដ្ឋានដែលថា "ទំនាក់ទំនងហេតុនិងផលចាំបាច់ រវាងព្យសនកម្មដែលបានលើកឡើង និងអង្គហេតុទាំងឡាយដែលស្ថិតនៅក្រោមការស៊ើបអង្កេត មិនត្រូវបានបង្ហាញ" ឬ "អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់នៅក្នុង

PRE-TRIAL CHAMBER CHAMBRE PRÉLIM. E.C.C.C • C.E.T.C

---

[៥៦] កត់សម្គាល់ថា ទោះបី ជាសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ ដែលចេញ ដោយក្រុមប្រឹក្សាជំនុំជម្រះពីរផ្សេងក៏ដោយ ក៏សំអាងហេតុ នៃមតិភាគច្រើន នៅក្នុងសេចក្តីសម្រេចដែលជាគោលការណ៍ដូចគ្នា ។ សូមកត់សម្គាល់ថា យោងតាមសំអាងហេតុរបស់ខ្លួន អង្គបុរេជំនុំជម្រះ បានសម្រេចផ្តល់ សំណើសុំពិចារណាម្តងទៀត លើសេចក្តីសម្រេចមួយក្នុងចំណោម សេចក្តីសម្រេចជាច្រើនពីមុនរបស់ខ្លួន (សំណើត្រូវបានដាក់ នៅក្នុងបណ្តឹងឧទ្ធរណ៍ អបជ ៧៤ ដោយក្រុមមេធាវី តំណាងឲ្យអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាជនជាតិវៀតណាម )។

[៥៧] ក្នុងចំណោមជនជាប់ចោទទាំងអស់ មានតែសហមេធាវីការពារក្តីរបស់ អៀង សារី បានដាក់ការឆ្លើយតបរួមចំពោះបណ្តឹងឧទ្ធរណ៍ ហើយពួកគេក៏មិនបានជំទាស់ទៅនឹងបណ្តឹងឧទ្ធរណ៍ទាំងនោះដែរ។

សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ២៧ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ពាក្យសុំរបស់ខ្លួន ដើម្បីបញ្ជាក់អំពីភាពស្របគ្នាទៅនឹងវិធាន ២៣ ស្ទួន(១) និង(៤) នោះទេ"។ នៅក្នុងឧបសម្ព័ន្ធនីមួយៗដែលភ្ជាប់ទៅនឹងប្រយោគទាំងឡាយនៅក្នុងដីកាសម្រេចទាំងនោះ សហចៅក្រមស៊ើបអង្កេត បានផ្តល់ជូននូវតារាងមួយដែលមានព័ត៌មានអំពីអ្នកដាក់ពាក្យសុំទាំងអស់ ដែលត្រូវបានបដិសេធ។ តារាងនីមួយៗនេះមានបីជួរ ដែលនៅក្នុងជួរទីមួយ និងជួរទីពីរ បញ្ជាក់ពីចំនួនពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយជួរទីបីបញ្ជាក់ពី "សំអាងហេតុ" សម្រាប់ការបដិសេធនេះ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងតារាងទាំងនេះ ចំនួនប្រយោគដែលបានប្រើប្រាស់ ដើម្បីរៀបរាប់ពីសំអាងហេតុសម្រាប់ធ្វើការបដិសេធអ្នកដាក់ពាក្យសុំម្នាក់ ដែលយ៉ាងច្រើនបំផុតមានតែពីរឃ្លា ដែលឃ្លានីមួយៗមានចំនួនពី ៥ ទៅ ១៥ ពាក្យ ហើយខ្លឹមសារសម្រាប់ការច្រានចោលអ្នកដាក់ពាក្យសុំម្នាក់ៗនៅក្នុងសំអាងហេតុទាំងនេះ គឺដូចគ្នាទាំងអស់ និងមិនមានភាពជាក់លាក់ចំពោះពាក្យសុំនីមួយៗនោះទេ។ ឧទាហរណ៍ ឃ្លានីមួយៗគ្រាន់តែសរសេរថា៖ "ព្យសនកម្មនេះ មិនជាប់ទាក់ទងទៅនឹងអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេតនោះទេ" ឬ "មិនមានព័ត៌មានគ្រប់គ្រាន់ដើម្បីបញ្ជាក់ភាពស្របទៅនឹងវិធាន ២៣ *ស្ទួន*(១) និង(៤) នៃវិធានផ្ទៃក្នុង ទាក់ទងទៅនឹងអំពើព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់នេះទេ"។ មិនមានការពន្យល់បន្ថែមនៅក្នុងដីកាសម្រេចនានា ឬឧបសម្ព័ន្ធទាំងឡាយដែលពាក់ព័ន្ធនោះទេ។

៣៨. បន្ទាប់ពីបានធ្វើការសង្កេតដូចខាងលើរួចមក អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនបានទទួលស្គាល់លក្ខខណ្ឌតម្រូវដែលថា សេចក្តីសម្រេចទាំងអស់របស់តុលាការតម្រូវឱ្យផ្តល់សំអាងហេតុ ដោយសារថា វាជាបទដ្ឋានអន្តរជាតិ[៥៨]។ នៅក្នុងសេចក្តីសម្រេចមុនៗរបស់ខ្លួន អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមិនមានកាតព្វកិច្ច "ផ្តល់ការយល់ឃើញទៅលើកត្តាទាំងអស់" ដែលបានពិចារណានៅក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ខ្លួននោះឡើយ[៥៩]។ សំខាន់បំផុតគឺ ភាគីពាក់ព័ន្ធទាំងអស់ដឹងអំពីមូលហេតុនៃសេចក្តីសម្រេចនីមួយៗ។ អង្គជំនុំជម្រះបានពិចារណាថា ចំណុចនេះគឺជាការចាំបាច់ដើម្បីឱ្យ "ភាគីរងគ្រោះដែលស្ថិតក្នុងស្ថានភាពមួយអាចកំណត់ថាតើនឹងប្តឹងឧទ្ធរណ៍ឬអត់ និងប្តឹងទៅលើមូលដ្ឋានអ្វីដែរនោះ។ ដូចគ្នាដែរនេះ ភាគីដែល

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

---

[៥៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំឱ្យធ្វើមោឃភាព ចុះថ្ងៃទី ២៦ ខែសីហា ២០០៨ ឯកសារ D55/I/8 កថាខណ្ឌ ២១។

[៥៩] សាលដីកាលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ អៀង សារី ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០០៨ ឯកសារ C22/I/73 កថាខណ្ឌ ៦៦។

សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ២៨ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ មានសិទ្ធិទទួលបានការជូនដំណឹងអំពីសំអាងហេតុ ដើម្បីឲ្យខ្លួនអាចត្រៀមរៀបចំការឆ្លើយតបឲ្យបានត្រឹមត្រូវ និងមានការពាក់ព័ន្ធ”[៦០]។ “ភាគីរងគ្រោះ” គឺជាបុគ្គលទាំងឡាយដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ និងអាចរាប់បញ្ចូលទាំងជនជាប់ចោទ ព្រមទាំងអ្នកដាក់ពាក្យសុំដែលត្រូវបានបដិសេធផងដែរ។ សំអាងហេតុក៏ជាការចាំបាច់សម្រាប់ឲ្យអង្គបុរេជំនុំជម្រះអាច “ពិនិត្យលើបណ្តឹងឧទ្ធរណ៍ឡើងវិញប្រកបដោយប្រសិទ្ធភាព ដោយអនុលោមតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង”[៦១]។ តាមរយៈបណ្តឹងឧទ្ធរណ៍ដែលដាក់ដោយក្រុមមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ ប្រឆាំងនឹងការបដិសេធទៅលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ អង្គបុរេជំនុំជម្រះបានពិចារណា ថាតើសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតត្រូវតែលម្អិតប៉ុនណា ដោយអនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង”។ អង្គជំនុំជម្រះបានពិនិត្យមើលទៅលើវិធានផ្ទៃក្នុងរបស់តុលាការនេះ[៦២] និងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប[៦៣] និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY)[៦៤] មុននឹងផ្តល់ការណែនាំដូចខាងក្រោមនេះ៖

> “សហចៅក្រមស៊ើបអង្កេត មានឆន្ទានុសិទ្ធិក្នុងការសម្រេចពីកម្រិតនៃភាពលម្អិតឲ្យបានជាក់លាក់ដែលតម្រូវដោយក្រមខ័ណ្ឌច្បាប់របស់ អ.វ.ត.ក ដែលអង្គបុរេជំនុំជម្រះអាចពិនិត្យឡើងវិញ ដោយផ្អែកលើបណ្តឹងឧទ្ធរណ៍ដែលអាចទទួលយកបានរួចមក។ សហចៅក្រមស៊ើបអង្កេតត្រូវអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយគោរពតាមគោលបំណងនៃលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ក្នុងការបដិសេធដោយមានសំអាងហេតុ ចំពោះសំណើសុំណាមួយដូចបានរៀបរាប់ខាងលើ។ អង្គបុរេជំនុំជម្រះមិន

---

[៦០] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ស្តីពីសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ដែលនឹងជួយដល់ការបញ្ជាក់អំពីការដឹងឮរបស់ជនត្រូវចោទ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង ចុះទី ១៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D365/2/10 កថាខណ្ឌ ២៤។

[៦១] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ចំពោះសំណើសុំ D153 D172 D173 D174 D178 និង D284 (សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទី ១២ របស់ នួន ជា) ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D300/1/5 កថាខណ្ឌ ៤១ ។

[៦២] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹង “ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហមេធាវីការពារក្តី អៀង ធីរិទ្ធ” ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ២៣

[៦៣] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៤ ដល់ ២៦

[៦៤] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៧។

មានន័យថា សហចៅក្រមស៊ើបអង្កេតគួរបានផ្ដល់ឲ្យបានលម្អិតនូវ "ព័ត៌មានទាំងអស់ដែលមាននៅក្នុងសំណុំរឿង" នោះទេ។ ផ្ទុយទៅវិញ អង្គបុរេជំនុំជម្រះសម្រេចថា យ៉ាងហោចណាស់ក៏សហចៅក្រមស៊ើបអង្កេត គួរបានផ្ដល់ព័ត៌មានជាគំរូបែបនេះ រួមទាំងលេខឯកសារពាក់ព័ន្ធ តាមការសមស្រប។ ប្រសិនបើលេខឯកសារយោងមិនអាចរកបាន សហចៅក្រមស៊ើបអង្កេតត្រូវផ្ដល់ព័ត៌មានលម្អិតឲ្យបានគ្រប់គ្រាន់ ស្ដីពីប្រភព ទីកន្លែង និងខ្លឹមសារនៃព័ត៌មានជាគំរូ ដែលមានរួចហើយ នៅក្នុងសំណុំរឿង"[៦៥]។

៣៩. អង្គបុរេជំនុំជម្រះយល់ឃើញថា ជាទូទៅ សេចក្ដីសម្រេចរបស់តុលាការត្រូវបង្ហាញទាំងស្រុងនូវឯកសារសម្ភារៈ ដែលចៅក្រមបានយកមកពិចារណានៅពេលចេញសេចក្ដីសម្រេច។ ចំណុចត្រង់នេះនឹងធានាថា ភាគីនានាដែលមិនទទួលបានជោគជ័យនៅក្នុងពាក្យសុំរបស់ខ្លួន អាចត្រូវបានធានាថា អង្គហេតុដែលបានដាក់ជូន និងការលើកឡើងរបស់ខ្លួនទាក់ទងទៅនឹងអង្គច្បាប់ ត្រូវបានយកមកពិចារណាយ៉ាងត្រឹមត្រូវ និងពេញលេញ។ អ្នកដាក់ពាក្យសុំចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ មានសិទ្ធិទទួលបាននូវការពិចារណាទៅលើពាក្យសុំជាឯកត្តបុគ្គលរបស់ខ្លួន និងទទួលបាននូវការបង្ហាញថា ចំណុចនេះពិតជាកើតឡើងមែន បើទោះបីជាសេចក្ដីសម្រេចនោះត្រូវបានចេញនៅក្នុងទម្រង់មួយខ្លី និងជាតារាងក៏ដោយ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមទៀតថា ដោយសារនីតិវិធីស្ដីពីការប្ដឹងឧទ្ធរណ៍ដែលមានចែងនៅក្នុងវិធាន ២៣ *ស្ទួន*(២) នៃវិធានផ្ទៃក្នុង គឺជាបណ្ដឹងឧទ្ធរណ៍ដែល "ឆាប់រហ័ស" ឬជាសង្ខេប នោះការពិចារណារបស់សហចៅក្រមស៊ើបអង្កេតទៅលើពាក្យសុំចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី មិនគួរត្រូវបានពិចារណាក្នុងលក្ខណៈបែបនេះនោះទេ។ ដោយសារតែទំហំការងារដ៏ធំធេងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត និងលក្ខខណ្ឌតម្រូវសម្រាប់ការពិចារណាទៅលើបញ្ហាទាំងអស់នេះ "នៅក្នុងពេលវេលាមួយដែលសមស្រប" នោះករណីរបស់អ្នកដាក់ពាក្យសុំដែលត្រូវបានបដិសេធ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សំអាងហេតុកាន់តែលម្អិតដែលបានលើកឡើងនៅក្នុងដីកាសម្រេចនានា ត្រូវបានធានារួចហើយ។

៤០. អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា នេះគឺជាកំហុសលើអង្គច្បាប់ដែលលេចធ្លោរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាសម្រេចទាំងអស់របស់ខ្លួន ទាក់ទងទៅនឹងផ្នែកទាំង

---

[៦៥] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៣០។

សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៣០ នៃទំព័រ ៧៧
អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី

ឡាយនៃដីកាសម្រេច ដែលសហចៅក្រមស៊ើបអង្កេតបានបដិសេធពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

## ខ. ការភ័ន្តច្រឡំផ្នែកអង្គច្បាប់ - ការអនុវត្តខុសនូវលក្ខណៈវិនិច្ឆ័យ ក្នុងការសម្រេចពីទំនាក់ទំនងរវាង ហេតុ និងផល

៤១. អង្គបុរេជំនុំជម្រះ បានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានដោះស្រាយបញ្ហាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋាននៃអង្គហេតុដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[៦៦]។ សហចៅក្រមស៊ើបអង្កេតបានអនុវត្តដូច្នេះនៅពេលដែលខ្លួនជិតចេញដីកាដំណោះស្រាយ[៦៧] ហេតុដូច្នេះគេអាចធ្វើការសន្និដ្ឋានបានថា សហចៅក្រមស៊ើបអង្កេតពិតជាដឹង ពីការចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះយ៉ាងពិតប្រាកដ។ សហចៅក្រមស៊ើបអង្កេតបានជម្រាបជូនជនរងគ្រោះនៅដំណាក់កាលចុងក្រោយ ក្នុងកិច្ចស៊ើបអង្កេត ដោយគ្រាន់តែជាការសង្ខេបនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ព្រមទាំងពន្យល់ថា "ករណីដែលជនរងគ្រោះចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្យសនកម្មដែលជនរងគ្រោះប្តឹង ត្រូវតែជាព្យសនកម្មបុគ្គល និងមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងស្ថានភាពអង្គហេតុ មួយឬច្រើន ដែលបង្កើតបានជាមូលដ្ឋានសម្រាប់កិច្ចស៊ើបអង្កេតដែលកំពុងតែបន្ត"[៦៨]។ សហចៅក្រមស៊ើបអង្កេតក៏បានអនុវត្តផងដែរនូវបទដ្ឋានដែលខុសគ្នា នៅក្នុងដីកាដែលរងការជំទាស់ នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានដាក់កំហិតការទទួលយកជនរងគ្រោះ ជាដើមបណ្តឹងរដ្ឋប្បវេណី តែចំពោះជនរងគ្រោះណាដែលបានទទួលរងព្យសនកម្មដែលជាលទ្ធផល "ដោយផ្ទាល់ពីអង្គហេតុដែលបានធ្វើការស៊ើបអង្កេតរួចហើយ" ហើយសហចៅក្រមស៊ើបអង្កេតបានកំណត់អង្គហេតុទាំងនោះថា កំណត់តែត្រឹម "ស្ថានភាពអង្គហេតុណាដែលសហចៅក្រមស៊ើបអង្កេតបានទទួលពីសហព្រះរាជអាជ្ញាតែប៉ុណ្ណោះ

[៦៦] សូមកត់សម្គាល់ថា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមបានស្នើឲ្យសហចៅក្រមស៊ើបអង្កេត "បើកកិច្ចស៊ើបសួរតាមផ្លូវតុលាការ" ប្រឆាំងជនជាប់ចោទហើយ ដីកានេះថែមទាំង "ដាក់ស្នើនូវបទចោទ" ប្រឆាំងនឹងជនជាប់ចោទទាំងអស់នេះទៀតផង។

[៦៧] ដីកាដែលរងការជំទាស់ទាំងអស់ត្រូវបានប្រកាស នៅក្នុងរយៈពេល ពីរទៅបីសប្តាហ៍ មុនថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១០ ដែលដីកាដំណោះស្រាយសំណុំរឿង ០០២ ត្រូវបានប្រកាស។

[៦៨] សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

(in rem seisin)"។ សហចៅក្រមស៊ើបអង្កេតបានធ្វើយុត្តិកម្មបញ្ហានេះដោយបានយោងទៅលើយុត្តិសាស្ត្រ ដែលដកស្រង់ចេញពី តុលាការកំពូលបារាំង (*French Cour de Cassation*) ហើយសហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានថា "ដូចនេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានកំហិតនៅក្នុងលក្ខខណ្ឌ ដែលពាក្យសុំមិនបានប្តឹងទៅលើអង្គហេតុថ្មីនៅក្នុងដំណាក់កាលស៊ើបសួរឡើយ ប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញាទេនោះ" ។

៤២. ទោះជាមានការយល់ស្របគ្នាដែលថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងចោទទៅលើអង្គហេតុថ្មីសម្រាប់គោលបំណងនៃកិច្ចស៊ើបសួរ ដោយខ្លួនឯងបាន អង្គបុរេជំនុំជម្រះបានពិចារណាថា សហចៅក្រមស៊ើបអង្កេត គួរតែអាចរកឃើញនូវភាពខុសគ្នា រវាងស្ថានភាពទាំងពីរដែលខុសគ្នាដូចជា ១) ដើមបណ្តឹងរដ្ឋប្បវេណី *បានលើកឡើងពីអង្គហេតុថ្មី ក្នុងគោលបំណងនៃការស៊ើបអង្កេត* និង ២) ជនរងគ្រោះបានបង្ហាញពី*អង្គហេតុ* នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី *ដែលអាចជួយបង្ហាញថា ពួកគាត់បានទទួលរងនូវព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់នៃ "ឧក្រិដ្ឋកម្មយ៉ាងតិចបំផុតក៏មួយ ដែលឧក្រិដ្ឋកម្មនេះត្រូវបានចោទប្រកាន់ប្រឆាំងជនត្រូវចោទ"* ។ វិធាន ២៣ស្ទួន (១)(ខ) មិនបានទាមទារឲ្យមានទំនាក់ទំនងហេតុនិងផល រវាងព្យសនកម្ម និងអង្គហេតុដែលត្រូវបានស៊ើបអង្កេតនោះឡើយ គឺវាតម្រូវឲ្យមានទំនាក់ទំនងហេតុនិងផល រវាងព្យសនកម្ម និងឧក្រិដ្ឋកម្មណាមួយដែលត្រូវបានចោទប្រកាន់ប៉ុណ្ណោះ។ ឧក្រិដ្ឋកម្មគឺជា ការកំណត់ប្រភេទបទល្មើសដែលត្រូវបានស៊ើបអង្កេត ពាក្យថា "ឧក្រិដ្ឋកម្ម" មិនអាចកំណត់ថាជា ឬជំនួសដោយពាក្យ "អង្គហេតុ" នោះឡើយ។ សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ផ្នែកអង្គច្បាប់ ដោយបានបង្កើតលក្ខណៈវិនិច្ឆ័យខុសឆ្គង សម្រាប់ពិនិត្យទៅលើអត្ថិភាពនៃទំនាក់ទំនងរវាងហេតុនិងផល។ ជាលទ្ធផល អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ជនរងគ្រោះជាច្រើនរូបត្រូវបានបដិសេធមិនទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី បើទោះបីជាព្យសនកម្មរបស់ពួកគាត់ជាប់ទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ក៏ដោយ។ បើទោះបីជាអង្គហេតុដែលត្រូវស៊ើបអង្កេតកំណត់ត្រឹមតែទៅលើតំបន់ ឬទីតាំងឧក្រិដ្ឋកម្មមួយចំនួនក៏ដោយ ក៏ការកំណត់បទចោទនៃអង្គហេតុ ដូចដែលមានសរសេរយ៉ាងច្បាស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[៦៩] ដីកា

PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

---

[៦៩] សហព្រះរាជអាជ្ញា បានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នូវស្ថានភាពអង្គហេតុ ខុសៗគ្នា ចំនួន ២៥ ដែលមាន មនុស្សឃាត ការធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការឃុំឃាំងដោយខុសច្បាប់ ពលកម្មដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៣២ នៃចំនួន ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាដំណោះស្រាយ[៧០] បានរួមបញ្ចូលនូវឧក្រិដ្ឋកម្មដែលតំណាងឱ្យអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ដែលត្រូវបានចោទប្រកាន់ថា ជនត្រូវចោទបានធ្វើឡើងរួមគ្នា ក្នុងពេលអនុវត្តសហឧក្រិដ្ឋកម្មរួម ព្រមទាំងរួមបញ្ចូលឧក្រិដ្ឋកម្មដទៃទៀតដែលបានធ្វើឡើងប្រឆាំងប្រជាជន និង "*នៅទូទាំង*ប្រទេស"[៧១]។ វាគឺជាការកំណត់បទចោទទៅលើស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេត មិនមែនជាស្ថានភាពអង្គហេតុដែលត្រូវធ្វើការស៊ើបអង្កេតនោះទេ ដែលសហចៅក្រមស៊ើបអង្កេតគួរធ្វើការពិចារណា នៅពេលដែលខ្លួនធ្វើការពិនិត្យទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមទៅតាមវិធាន ២៣ស្ទួន (១)(ខ)។

៤៣. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ យល់ឃើញថា នេះគឺជាការភ័ន្តច្រឡំផ្នែកអង្គច្បាប់ដ៏សំខាន់មួយដែលសហចៅក្រមស៊ើបអង្កេតបានធ្វើឡើង ក្នុងដីកាសម្រេចទាំងអស់របស់ខ្លួន ទាក់ទិននឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ។

## ៣. ការភ័ន្តច្រឡំផ្នែកអង្គច្បាប់ - ការអនុវត្តដោយតឹងរឹង ទៅលើពាក្យ "ព្យសនកម្ម" ដែលនាំដល់ការបដិសេធដោយខុសឆ្គង ទៅលើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖

---

ដោយមូលហេតុសាសនា នយោបាយ និងពូជសាសន៍។ ទាំងអស់នេះ គឺជាភស្តុតាងនៃឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តក្នុងការអនុវត្តនូវផែនការឧក្រិដ្ឋកម្មរួម ដែលផែនការនេះ បង្កើតបានជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ អំពើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញទៅលើសាសនា។

[៧០] ដីកាដំណោះស្រាយ ត្រង់កថាខណ្ឌ ១៦១៣ បានសន្និដ្ឋានថា "**អាស្រ័យហេតុនេះ** កិច្ចស៊ើបសួរបានបង្ហាញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា, អៀង សារី, ខៀវ សំផន** និង **អៀង ធីរិទ្ធ** តាមរយៈអំពើសកម្ម និងអំពើអកម្ម នៅទីក្រុងភ្នំពេញ នៅលើទឹកដីប្រទេសកម្ពុជា និងនៅក្នុងអំឡុងពេលនៃការចូលលុកលុយចូលទឹកដីវៀតណាម ក្នុងរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ បានប្រព្រឹត្ត (ដោយបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម), រៀបចំផែនការ, ញុះញង់ឱ្យប្រព្រឹត្ត, បញ្ជាឱ្យមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដូចខាងក្រោម, បានជួយនិងជំរុញដល់អ្នកចារី ឬត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ" ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភបំពានលើក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦។

[៧១] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣៥, ១៣៤១, ១៣៤៩, ១៣៥០, ១៣៦២, ១៣៦៣, ១៣៧២, ១៣៨០, ១៣៩០, ១៣៩៦, ១៤០១, ១៤០៧, ១៤១៤, ១៤១៥, ១៤៣១, ១៤៣៤, ១៤៣៥, ១៤៤០, ១៤៤២, ១៤៦៦, ១៤៦៧, ១៤៧៦, ១៤៧៨ និង ១៦១៣។

៤៤. ក្រោយពីបានពិនិត្យមើលលើដីកាសម្រេច អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានធ្វើតាមវិធីសាស្ត្របែបតឹងរ៉ឹងផងដែរ នៅពេលដែលខ្លួនបានប្រើប្រាស់ពាក្យ"ព្យសនកម្ម" ជាពិសេសនៅក្នុងពេលប្រើប្រាស់ដើម្បីសំដៅទៅលើព្យសនកម្មផ្លូវចិត្ត ។ សហចៅក្រមស៊ើបអង្កេតមិនបានពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយទៅលើលក្ខណៈការទទួលរងគ្រោះ ពីឧក្រិដ្ឋកម្មនានា ដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលរួមមានការសម្លាប់រង្គាលទ្រង់ទ្រាយធំ និងការបំពារបំពានធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ ព្រមទាំងលក្ខណៈ និងទំហំនៃព្យសនកម្ម ហើយនិងការពិតដែលថា វិធាន ២៣ស្ទួន (១)(ខ) បានរួមបញ្ចូលការពិចារណាលើ "ទទួលរងនូវព្យសនកម្ម [...] ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្តនិងសមូហភាព"។ អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា នៅក្នុងដីកាសម្រេច គឺគ្មានការពិចារណាទៅលើព្យសនកម្មជាបុគ្គល ដែលបានទទួលរងក្នុងបរិបទ នៃការចោទប្រកាន់ពីភាពសាហាវឃោរឃៅជាទ្រង់ទ្រាយធំនោះទេ។ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខណៈនៃការទទួលរងគ្រោះ ពីភាពសាហាវឃោរឃៅជាទ្រង់ទ្រាយធំនោះ មិនត្រូវបានពិចារណាឱ្យបានត្រឹមត្រូវ និងគ្រប់គ្រាន់ឡើយ ចំពោះការបដិសេធមិនទទួលស្គាល់អ្នកដាក់ពាក្យសុំទាំងឡាយ ដែលការសន្មត់ទុកជាមុនមិនត្រូវបានប្រើប្រាស់ចំពោះពួកគេ ដោយសារតែព្យសនកម្មផ្លូវចិត្ត ត្រូវបានដកចេញជាពិសេស ហើយការសន្មតទុកជាមុនមួយចំនួន ដែលត្រូវអនុវត្តសម្រាប់ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការអនុវត្តបែបនេះធ្វើឱ្យជនរងគ្រោះជាច្រើនត្រូវបានបដិសេធមិនទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយភ័ន្តច្រឡំ។

៤៥. ជាបឋម អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា ការដែលសហចៅក្រមស៊ើបអង្កេត ប្រើប្រាស់ "ឋានានុក្រមនៃឧក្រិដ្ឋកម្ម"[៧២] ជាពិសេសទាក់ទងទៅនឹងព្យសនកម្មផ្លូវចិត្ត គឺមិនអាចអនុវត្តបាននៅពេលដែលធ្វើការវាស់វែងទៅលើព្យសនកម្មផ្លូវចិត្តដែលបង្កឡើងដោយឧក្រិដ្ឋកម្មនានា ដូចមានចោទប្រកាន់ក្នុងសំណុំរឿង ០០២។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក៏បានកត់សម្គាល់ទៅលើចំណុចនេះដែរ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន។ ហេតុការណ៍តែមួយដាច់តែឯង ប្រហែលជាមិនអាចបង្កជាព្យសនកម្មបាននោះទេ ប៉ុន្តែនៅពេលដែលហេតុការណ៍មួយនោះ ត្រូវបានបញ្ចូលទៅក្នុងបរិបទនៃអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ វាអាចនាំទៅរកចំណុចផ្សេងៗទៀត៖

[៧២] សូមមើល កថាខណ្ឌ ១៤/គ និង ឃ ក្នុងដីកាសម្រេចដែលរងការជំទាស់ (*កត់សម្គាល់ថាលេខកថាខណ្ឌ អាចខុសគ្នាបន្តិចនៅក្នុងដីកាដែលត្រូវបានជំទាស់មួយចំនួន*)។

កម្រិតនៃភាពភ័យខ្លាច ដែលអាចកើតមានឡើងដោយសារការមើលឃើញហេតុការណ៍ និង/ឬការដឹងឮពីអត្ថិភាព និងការអនុវត្តនូវគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា [៧៣]ដែលការនេះងាយនឹងយល់បាន។ ការពិតដែលថា រយៈពេល៣០ឆ្នាំ ក្រោយហេតុការណ៍បានកើតឡើង មនុស្សម្នាក់គត់នៅចងចាំថា បានឃើញហេតុការណ៍ជាក់លាក់ខ្លះ ព្រមទាំងការចងចាំពីការភ័យខ្លាចក្នុងអារម្មណ៍ បានបង្ហាញថាហេតុការណ៍នេះ មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើបុគ្គលនោះ។

៤៦. ទីពីរ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា ទាក់ទងទៅនឹងព្យសនកម្មផ្លូវចិត្ត សហចៅក្រមស៊ើបអង្កេតបានអនុវត្ត ការសន្មតនៃសម្ព័ន្ធភាពគ្រួសារ មាត្រា ៣.២ នៃសេចក្តីណែនាំអនុវត្តដែលថា "ការខូចខាតផ្លូវចិត្ត អាចរួមបញ្ចូលទាំងមរណភាពរបស់សាច់ញាតិ ដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មនេះ"។ អង្គបុរេជំនុំជម្រះ បានពិចារណាថា និយមន័យនេះជានិយមន័យដែលមានលក្ខណៈទូទៅ (inclusive definition) តែត្រូវបានប្រើប្រាស់ដោយភ័ន្តច្រឡំជានិយមន័យដែលមានលក្ខណៈពិសេស (exclusive definition) ដោយសហចៅក្រមស៊ើបអង្កេត។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះកត់សម្គាល់ថា គ្មានការដាក់កំហិតបែបនេះ ចំពោះនិយមន័យនៃ "ការខូចខាតផ្លូវចិត្ត" ទាំងនៅក្នុងវិធានផ្ទៃក្នុង ឬច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលនៅជាធរមាននោះឡើយ។ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ទោះបីជាសេចក្តីណែនាំអនុវត្តបានដាក់កំហិតបែបនេះទៅលើនិយមន័យនេះក៏ដោយ (ដែលតាមពិតសេចក្តីណែនាំអនុវត្តមិនបានដាក់កំហិតបែបនេះទេ) ក៏មិនត្រូវយល់ឃើញថា ជាការដាក់កំហិតទៅលើនិយមន័យទៅតាមអ្វីដែលមាននៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងច្បាប់ អ.វ.ត.ក នោះឡើយ។

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

៤៧. ទីបី អង្គបុរេជំនុំជម្រះក៏បានកត់សម្គាល់ថា មិនមានបទប្បញ្ញត្តិជាក់លាក់ណាមួយនៅក្នុងវិធានផ្ទៃក្នុង ឬច្បាប់ អ.វ.ត.ក ដែលថាការខូចខាតត្រូវតែជាលក្ខណៈបុគ្គលនោះដែរ។ សហចៅក្រមស៊ើបអង្កេតដោយយោងទៅលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ICC[៧៤] បានបង្ហាញការយល់ឃើញនៅក្នុងដីកាសម្រេចរបស់ខ្លួនថា "ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរង មិនចាំបាច់ថាជាព្យសនកម្មផ្ទាល់នោះទេ តែព្យសនកម្មនេះត្រូវតែជាព្យសនកម្មបុគ្គល"។ បើទោះបីជាអង្គ

---

[៧៣] ពាក្យ CPK សំដៅលើបក្សកុម្មុយនីស្តកម្ពុជា (សូមមើលដីកាដំណោះស្រាយ ផ្នែកទីមួយ, II.ក)

[៧៤] Lubanga ICC ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៩ អង្គជំនុំជម្រះសាលាដំបូង ១ (ICC-01/04-01/06) កថាខណ្ឌ ៤៩ និង *Lubanga* ICC ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ (ICC-01/04-01/06 OA9 AO10) កថាខណ្ឌ ៣២។

សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៣៥ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

បុរេជំនុំជម្រះយល់ស្របជាមួយនឹងការប្រើប្រាស់ពាក្យ ជាបុគ្គល ដើម្បីចាត់ទុកថាជាការខូចខាតក៏ដោយ ក៏អង្គបុរេជំនុំជម្រះពិចារណាថា ការប្រើប្រាស់ពាក្យ "បុគ្គល" សម្រាប់ការវាយតម្លៃពី "ព្យសនកម្មផ្លូវចិត្ត" សហចៅក្រមស៊ើបអង្កេត គួរប្រើប្រាស់ក្នុងបរិបទនៃអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ នៅក្នុងសំណុំរឿង ០០២ ។ អង្គបុរេជំនុំជម្រះសូមសង្កត់ធ្ងន់ថា បើទោះបីជាបទប្បញ្ញត្តិក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក បង្គាប់ឱ្យស្វែងរកសេចក្តីណែនាំពីគោលការណ៍ក្នុងការអនុវត្តច្បាប់ដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិក៏ដោយ ក៏គួរតែមានការប្រុងប្រយ័ត្នក្នុងការស្វែងរកសេចក្តីណែនាំ ទាក់ទិននឹងការអនុវត្តជាពិសេសនូវច្បាប់ទាំងនោះ ដែលច្បាប់ទាំងនោះមិនមែនអាចអនុវត្តបានគ្រប់ករណីចំពោះវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នោះឡើយ។ ច្បាប់ទាំងនោះមិនបានផ្តល់ដល់ភាគីនានា នូវសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីដូចគ្នា និងការផ្តល់ឱ្យនៅ អ.វ.ត.ក នោះឡើយ ហើយច្បាប់ទាំងនោះក៏មិនអនុវត្តនៅក្នុងស្ថានភាពដូចគ្នាបេះបិទ នឹងស្ថានភាពនៅ អ.វ.ត.ក នោះដែរ។

៤៨. ជាបន្ថែម អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា សហចៅក្រមស៊ើបអង្កេតបានកំណត់និយមន័យ "ព្យសនកម្មផ្លូវចិត្តជាបុគ្គល" នៅក្នុងដីកាសម្រេចរបស់ខ្លួន ក្នុងលក្ខណៈចង្អៀត។ អង្គបុរេជំនុំជម្រះពិចារណាថា ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទំនាក់ទំនងគ្រួសារគឺជាកត្តាតម្រូវជាចាំបាច់នោះ គឺសហចៅក្រមស៊ើបអង្កេត បានអនុវត្តនូវការដាក់កំហិតដោយគ្មានមូលដ្ឋាន ឬការពិចារណាឱ្យបានត្រឹមត្រូវនោះឡើយ[៧៥]។ ការសន្មតទុកជាមុនទាក់ទិននឹងព្យសនកម្មផ្លូវចិត្តត្រូវបានប្រើប្រាស់ ដោយគ្មានការពិចារណាទៅលើចំណុចផ្សេងៗឡើយ ហើយត្រូវបានសន្និដ្ឋាននៅក្នុងកថាខណ្ឌ ១៤ ឃ នៃដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានឯកសារគាំទ្រ។ កថាខណ្ឌ ១៤ ឃ នៃដីកាសម្រេចបានចែងថា "ដូច្នេះ ព្យសនកម្មផ្លូវចិត្តជាបុគ្គល ដែលបានលើកឡើងដោយអ្នកដាក់ពាក្យសុំ ដែលពាក់ព័ន្ធនឹងអំពើមនុស្សឃាត ឬការបាត់ខ្លួនសាច់ញាតិ គឺមានលក្ខណៈងាយស្រួលក្នុងការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ជាងក្នុងករណីនៃការរៀបការដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា។ ទទ្បឹករណ៍ដូចគ្នាត្រូវតែយកមកអនុវត្តផងដែរ ក្នុងករណីដែលអ្នកស្នើសុំគឺជាសាក្សីធម្មតា ចំពោះអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត គឺថា៖ ព្យសនកម្មផ្លូវចិត្តបង្កប់នូវកម្រិត និងលក្ខណៈដោយឡែកផ្ទុយពីការឈឺចាប់ផ្នែកអារម្មណ៍ ដែលសាក្សីធម្មតាត្រូវបង្ហាញ ហើយពាក្យស្នើសុំរបស់គេនឹងត្រូវបដិសេធចោល

[៧៥] សូមមើល កថាខណ្ឌ ១៤/គ និង ឃ ក្នុងដីកាសម្រេចដែលរងការជំទាស់ ។

លើកលែងតែថាសាក្សីនោះ បានឃើញអង្គហេតុនៃអំពើហិង្សាហួសហេតុ និងអំពើដែលមានលក្ខណៈតក់ស្លុតខ្លាំង”។

៤៩. ការខូចខាតផ្លូវចិត្តគួរត្រូវបានពិចារណានៅក្នុងបរិបទជាក់លាក់ ក្នុងសង្គមកម្ពុជាជាទូទៅ ហើយគួរពិចារណាជាពិសេសអំពីលក្ខណៈ ព្រមទាំងរចនាសម្ព័ន្ធរបស់សង្គម នៅក្នុងអំឡុងរបបបក្សកុម្មុយនីស្តកម្ពុជា បែបផែននៃការរស់នៅរបស់សង្គមកម្ពុជា គឺមានភាពខុសគ្នាពីសង្គមដទៃ។ យើងអាចនិយាយបានទៀតថា សូម្បីតែបែបផែននៃការរស់នៅរបស់សហគមន៍ ឬក៏ក្រុមខុសៗគ្នា នៅក្នុងប្រទេសតែមួយ ក៏មានលក្ខណៈខុសគ្នាដែរ។ គេមិនអាចមើលរំលងលក្ខណៈខុសគ្នានេះឡើយ។ ក្នុងករណីដែលទំនាក់ទំនង “សាច់ញាតិ” គឺជាទំនាក់ទំនងជិតស្និទ្ធិតែមួយគត់ដែលសហចៅក្រមស៊ើបអង្កេតបានកំណត់ គឺមានប្រជាជនជាច្រើនទៀត ដែលគួរត្រូវបានកំណត់ថា អាចសន្មតទុកជាមុនថាបានទទួលរងនូវការខូចខាតដែលបណ្តាលមកពីឧក្រិដ្ឋកម្មដែលបានធ្វើឡើងប្រឆាំងបុគ្គលម្នាក់ ឬក៏ត្រូវបានពិចារណាថាជាបញ្ហាដែលត្រូវបង្ហាញនូវភស្តុតាងជាឯករាជ្យ។ នេះបើគិតទៅដល់លក្ខណៈនៃឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់។ ចំណុចនេះពិតជាត្រឹមត្រូវ ពិសេសក្នុងករណីដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថា បានចូលរួមក្នុងការបង្កើត និងអនុវត្តគោលនយោបាយ ដែលនាំទៅដល់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានបង្ហាញពីការយល់ឃើញជាវិជ្ជមាន ទាក់ទិននឹងការវាយប្រហារជាប្រព័ន្ធ និងទ្រង់ទ្រាយធំ ទៅលើប្រជាជនស៊ីវិលកម្ពុជាទាំងអស់ ឬក៏ក្នុងក្រុមគោលដៅណាមួយ ហើយការចូលរួមជាគំនិតរបស់ជនជាប់ចោទ នៅក្នុងការវាយប្រហារនេះ គឺក្លាយជាមូលដ្ឋានសម្រាប់ធាតុផ្សំចេតនា នៅក្នុងឧក្រិដ្ឋកម្មមួយចំនួនដែលត្រូវបានចោទប្រកាន់ ប្រឆាំងជនជាប់ចោទ។ អង្គហេតុនានាដូចជា ការកើតឡើងនូវព្រឹត្តិការណ៍នៃអំពើហិង្សាតែមួយ ឬក៏ការបាត់ខ្លួនមិត្តភ័ក្តិ ឬអ្នកជិតខាង ក៏ដូចជាការបាត់ខ្លួនសាច់ញាតិ គឺគ្រប់គ្រាន់ដែលថាបុគ្គលម្នាក់នេះបានទទួលរងនូវការខូចខាតផ្លូវចិត្ត ក្នុងករណីដែលព្រឹត្តិការណ៍មួយនេះត្រូវបានពិនិត្យមើលក្នុងបរិបទនៃអំពើសាហាវឃោឃៅ ជាទ្រង់ទ្រាយធំ ដែលអំពើនេះត្រូវបានធ្វើឡើងក្នុងលក្ខណៈជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ក្នុងផ្ទៃប្រទេសទាំងមូល ដែលការប្រព្រឹត្តិនេះគឺជាលទ្ធផលនៃការអនុវត្តគោលនយោបាយនៃបក្សកុម្មុយនីស្តកម្ពុជា ។ ដោយពិចារណាទៅលើស្ថានភាពបែបនេះ បុគ្គលទាំងនោះប្រហែលជាទទួលរងផងដែរនូវព្យសនកម្មជាសមូហភាព។ ព្យសនកម្មបែបនេះពិតជាបានកើតឡើងដោយសារ ហើយមានទាំងភស្តុតាងនៅក្នុងលក្ខណៈនៃ ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលជាការ

រំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ[៧៦]។ នៅតាមតុលាការអន្តរជាតិដទៃទៀត ដែលធ្វើការជំនុំជម្រះទៅលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ តុលាការទាំងនេះត្រូវអនុវត្តគោលការណ៍ទី៨ ដូចគ្នាបេះបិទនឹងសំណុំរឿង ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិនោះ ប៉ុន្តែតុលាការទាំងនោះហាក់ដូចជា "ត្រៀមខ្លួនរួចរាល់សម្រាប់ការបោះបង់ចោលគោលការណ៍ ដែលផ្តោតទៅលើបុគ្គល ហើយជាជំនួសបានជ្រើសរើសយកវិធីសាស្ត្រដែលមានលក្ខណៈទូលំទូលាយជាង ដោយសារតែជាញឹកញាប់ សំណុំរឿងទាំងនោះបានបង្ហាញនូវការរំលោភបំពានជារួម មិនមែនជាការរំលោភបំពានទៅលើបុគ្គលណាម្នាក់នោះឡើយ"[៧៧]។

៥០. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា នេះគឺជាការភ័ន្តច្រឡំផ្នែកអង្គច្បាប់ដ៏សំខាន់មួយ ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើឡើង ក្នុងដីកាសម្រេចទាំងអស់របស់សហចៅក្រមស៊ើបអង្កេតទាក់ទិននឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបដិសេធ។

## ៤. កង្វះខាតការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវ របស់សហចៅក្រមស៊ើបអង្កេត៖

៥១. អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ទៅលើបញ្ហា ដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍ថា ការផ្លាស់ប្តូរនៅក្នុងវិធានផ្ទៃក្នុងដែលនៅជាធរមាន បានធ្វើឡើងនៅក្នុងពេលដែលសហមេធាវី ត្រូវដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឱ្យកូនក្តីរបស់ខ្លួន ហើយការផ្លាស់ប្តូរនេះបានបង្កឱ្យមានការយល់ច្រឡំ អំពីសម្ភារៈឯកសារដែលត្រូវដាក់

---

[៧៦] មហាសន្និបាតអង្គការសហប្រជាជាតិ, គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានរួមលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ៖ សេចក្តីសម្រេចត្រូវបានអនុម័តដោយមហាសន្និបាត ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ឯកសារលេខ A/RES/60/147, គោលការណ៍៨។

[៧៧] Judith Schonsteiner "វិធានការរួញរា និង "សង្គមទាំងមូល"៖ ទ្រឹស្តីសម្រាប់រៀបចំការងារនៅតុលាការសិទ្ធិមនុស្សអន្តរអាមេរិក" ("Dissuasive Measures and the "Society as a Whole": A working Theory of Reparations in the Inter-American Court of Human Rights") ត្រង់ទំព័រ 138 ដោយយោងទៅដល់រឿងក្តី *Goiburu តទល់នឹង ប្រទេសប៉ារាហ្គាយ* តុលាការសិទ្ធិមនុស្សអន្តរអាមេរិក (IACtHR) ឆ្នាំ ២០០៦ (ser. C) No. 153, 82 ដែលថ្លែងថា៖ "ការទទួលខុសត្រូវត្រូវបានកើនឡើង នៅពេលដែលមានការរំលោភបំពានជាផ្នែកនៃគំរូជាប្រព័ន្ធ" និងយោងទៅដល់ Dinah Shelton, ដំណោះស្រាយនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ (Remedies In International Human Rights Law), Oxford University Press, ស.រ.អា (ឆ្នាំ ២០០៥) ត្រង់ទំព័រ 99 ដោយធ្វើការកត់សម្គាល់ថា "កង្វល់របស់ជនរងគ្រោះមិនមែនជាផ្នែកនៃរឿងក្តីវិវាទទេ រួមទាំងជនរងគ្រោះសំខាន់ៗផងដែរ ត្រូវតែស្ថិតនៅក្នុងចំណោមកត្តាដទៃទៀតដែលបានត្រូវបានយកទៅពិចារណាចំពោះការផ្តល់ជាសំណង"។ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៣៨ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីផ្តល់ប្រយោជន៍ដ៏ល្អបំផុតដល់កូនក្តីរបស់ខ្លួន។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេត មិនបានជូនដំណឹងដល់ជនរងគ្រោះឲ្យបានទាន់ពេលវេលាឡើយ[៧៨]។ អង្គបុរេជំនុំជម្រះពិចារណាថា ការបង្ហាញពីការមិនយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវ[៧៩] ក្នុងការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេត គឺជាកត្តាពាក់ព័ន្ធមួយ នៅពេលដែលធ្វើការពិចារណាទៅលើសិទ្ធិរបស់ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធី។ ហេតុដូច្នេះ ការពិនិត្យមើលទៅលើដំណាក់កាលនានាដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្ត ព្រមទាំងការពិនិត្យមើលថាតើការអនុវត្តនេះប៉ះពាល់ កម្រិតណាដែរចំពោះស្ថានភាពរបស់ជនរងគ្រោះ គឺជាការចាំបាច់។ វិធានផ្ទៃក្នុងបានចែងទាក់ទងដល់បញ្ហានេះដូចតទៅ៖

៥២. ទោះបីជាអង្គបុរេជំនុំជម្រះធ្លាប់យល់ឃើញតាំងពីពេលមុនថា "មានកត្តាជាច្រើនដែលជះឥទ្ធិពលដល់ការកំណត់ពេលវេលាក្នុងការចេញសេចក្តីសម្រេច"[៨០] ហើយអង្គបុរេជំនុំជម្រះក៏ទទួលស្គាល់ផងដែរថា សហចៅក្រមស៊ើបអង្កេតត្រូវបានចងកាតព្វកិច្ច ដោយបទប្បញ្ញត្តិជាក់លាក់មួយចំនួនក្នុងវិធានផ្ទៃក្នុង ទាក់ទងនឹងការរក្សាការសម្ងាត់ នៃការស៊ើបអង្កេត ទើបធ្វើឲ្យមានការរឹតបន្តឹងទៅ

[៧៨] សហចៅក្រមស៊ើបអង្កេតបានចេញគោលការណ៍ណែនាំលើកដំបូងរបស់ខ្លួន ដើម្បីដោះស្រាយចំពោះការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[៧៩] អង្គបុរេជំនុំជម្រះពិចារណាថា ការវិភាគពីការយកចិត្តទុកដាក់ឲ្យបានត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេត គឺពិតជាមានការពាក់ព័ន្ធ ពិសេសនៅពេលដែលពិចារណាលើបញ្ហា ការបន្តការឃុំខ្លួន ឬដោះលែងជនជាប់ចោទ ដែលបញ្ហានេះត្រូវបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ។ សូមមើល សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាសម្រេចពន្យាពេលការឃុំខ្លួន លេខ C22/9/14, ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ពីកថាខណ្ឌ ៥៧ ដល់ កថាខណ្ឌ ៦១ សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចពន្យាពេលការឃុំខ្លួន លេខ C20/9/15, ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ពីកថាខណ្ឌ ៤៤ ដល់ កថាខណ្ឌ ៥០ សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចពន្យាពេលការឃុំខ្លួន លេខ C26/9/12, ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១០ ពីកថាខណ្ឌ ៤០ ដល់ កថាខណ្ឌ ៤៧ សាលដីកាស្តីពីបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចពន្យាពេលការឃុំខ្លួន លេខ C9/4/6, ចុះថ្ងៃទី 4 ខែ ឧសភា ២០០៩ ពីកថាខណ្ឌ ៤៤ ដល់ កថាខណ្ឌ ៤៩។

[៨០] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំប្តឹងដកចិត្តសហចៅក្រមស៊ើបអង្កេត លោក Marcel Lemonde ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ Doc. No. 7, ERN 00414098-00414110 សំណើសុំ អ.ប.ជ ០២ កថខណ្ឌ ៣៣ បានដកស្រង់ រដ្ឋអាជ្ញា តទល់នឹង *Bagosora* និងអ្នកដទៃទៀត ICTR-98-41-T "សេចក្តីសម្រេចលើបណ្តឹងដកចិត្តចៅក្រម" (ការិយាល័យ) ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៧ កថាខណ្ឌ ១៥, *Karemera* និងអ្នកដទៃទៀត ICTR-98-44-T សេចក្តីសម្រេចលើបណ្តឹងរបស់ Nzirorera ប្តឹងដកចិត្តចៅក្រមអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៤ កថាខណ្ឌ ២៧។

សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៣៩ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

លើព័ត៌មានដែលសហចៅក្រមស៊ើបអង្កេត អាចជម្រាបជូនដល់សាធារណជន តែអង្គបុរេជំនុំជម្រះកត់សម្គាល់ថា បទប្បញ្ញត្តិជាក់លាក់ទាំងនោះ គួរត្រូវបកស្រាយគ្រប់ពេលវេលា ដោយភ្ជាប់ជាមួយបទប្បញ្ញត្តិស្តីពីគោលការណ៍ជាសារវន្តនៃដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក ដែលតម្រូវឱ្យ "ជូនដំណឹងដល់ជនរងគ្រោះ ព្រមទាំងគោរពដល់សិទ្ធិរបស់ជនរងគ្រោះ នៅក្នុងដំណើរការនីតិវិធី"[៨១]។ អង្គបុរេជំនុំជម្រះ សូមសង្កត់ធ្ងន់ថា វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង មិនបានទុកចន្លោះប្រហោងសម្រាប់ការបកស្រាយនោះឡើយ ដោយវិធាននេះមិនបាននិយាយ "ឆាប់បំផុតតាមដែលអាចធ្វើទៅបាន" ឬក៏ "ក្នុងពេលណាក៏ដោយមុនពេលបញ្ចប់កិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ"[៨២]។ បទប្បញ្ញត្តិជាក់លាក់នៅក្នុងវិធានផ្ទៃក្នុង ទាក់ទងនឹងភាពចាំបាច់ក្នុងការជូនដំណឹងដល់ជនរងគ្រោះក្នុងពេលដំណើរការនីតិវិធី គឺមានសារៈសំខាន់ព្រោះ ដោយអនុលោមទៅតាមវិធានផ្ទៃក្នុង អ្នកតំណាងតាមផ្លូវច្បាប់ឱ្យជនរងគ្រោះ ដែលខុសពីមេធាវីរបស់ភាគីនានានៃដំណើរការនីតិវិធីនោះ មិនមានសិទ្ធិជាស្វ័យប្រវត្តិក្នុងការចូលទៅក្នុងសំណុំរឿងនោះឡើយ។ ដូច្នេះអ្នកតំណាងតាមផ្លូវច្បាប់ឱ្យជនរងគ្រោះទាំងនោះ ត្រូវពឹងផ្អែកទាំងស្រុងទៅលើព័ត៌មានដែលពួកគាត់បានទទួលពីសហចៅក្រមស៊ើបអង្កេត។

៩៣. អង្គបុរេជំនុំជម្រះសូមធ្វើការកត់សម្គាល់បន្ថែមថា ដោយអនុលោមទៅតាមការតម្រូវក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីធានាដល់ផលប្រយោជន៍របស់គ្រប់ភាគីទាំងអស់ សហចៅក្រមស៊ើបអង្កេតគួរធ្វើការពិចារណាទៅលើអង្គហេតុដែលថា វិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មគ្រង់លទ្ធភាពនៃការទទួលយកជនរងគ្រោះ ជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណាក់ការជំនុំជម្រះ[៨៣]។ នៅក្នុងពេលកន្លងមក បើទោះបីជាក្នុងដំណាក់កាល "សវនាការបឋម" អង្គជំនុំជម្រះធ្វើការពិចារណា

---

[៨១] វិធាន ២១(១)(គ) នៃវិធានផ្ទៃក្នុង។

[៨២] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[៨៣] ជាជំនួសឱ្យការស្វែងរកការណែនាំពីយុត្តិសាស្ត្ររបស់តុលាការនានា ដែលបានអនុវត្តនៅក្នុងប្រព័ន្ធរបស់ខ្លួន នៅក្នុងសំណុំរឿង និងនៅក្នុងស្ថានភាពខុសគ្នានោះ ជាឧទាហរណ៍ដូចជាតុលាការ French Cour de Cassation តុលាការ ICC ឬសូម្បីតែសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក នៅក្នុងសំណុំរឿង ០០១ នោះ សហចៅក្រមស៊ើបអង្កេតបានយល់ឃើញនៅក្នុងដីកាសម្រេចទាំងអស់របស់ខ្លួនថា "នៅដំណាក់កាលមុនការជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតមិនមានតួនាទីធ្វើការសម្រេចជាស្ថាពរ ទាក់ទិនដល់ព្យសនកម្មដែលជនរងគ្រោះបានទទួលរងនោះឡើយ។ ការសម្រេចជាស្ថាពរបែបនេះ គឺត្រូវធ្វើឡើងដោយអង្គជំនុំជម្រះសាលាដំបូងតែមួយគត់ នៅក្នុងសាលក្រមរបស់ខ្លួន ដោយផ្អែកលើភស្តុតាងទាំងអស់ដែលបានដាក់ជូនអង្គជំនុំជម្រះ ក្នុងពេលដំណើរការនីតិវិធី" ។
សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៤០ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

“ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណា ដែលជនរងគ្រោះបានដាក់ ដើម្បីចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី”[៨៤] ដែលការពិចារណានេះធ្វើឡើងដោយពឹងផ្អែកលើដីកាដំណោះស្រាយក៏ដោយ ក៏ប្រព័ន្ធមួយនេះត្រូវបានធ្វើការកែប្រែថ្មី ដែលធ្វើឲ្យសេចក្តីសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្ថិតនៅក្នុងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតតែមួយ ហើយបណ្តឹងឧទ្ធរណ៍ចំពោះបញ្ហានេះត្រូវស្ថិតក្នុងអង្គបុរេជំនុំជម្រះ[៨៥]។ បញ្ហានេះតម្រូវឲ្យមានការជូនដំណឹងគ្រប់គ្រាន់ និងទាន់ពេលវេលាទៅដល់ជនរងគ្រោះ នៅក្នុងដំណាក់កាលមុនជំនុំជម្រះ ហើយការជូនដំណឹងនេះជាកាតព្វកិច្ចដែលចាំបាច់ជាងពេលមុនទៅទៀត។

៥៤. សម្រាប់សំអាងហេតុទាំងអស់នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា ការប្រព្រឹត្តរបស់សហចៅក្រមស៊ើបអង្កេត មិនបានបំពេញតាមតម្រូវការនៃការយកចិត្តទុកដាក់ដ៏ត្រឹមត្រូវ ហើយជាលទ្ធផលធ្វើឲ្យសិទ្ធិជាសារវន្តរបស់ជនរងគ្រោះ មិនត្រូវបានការពារឲ្យបានត្រឹមត្រូវនោះទេ។

## សេចក្តីសន្និដ្ឋាន

៥៥. ដោយបានពិចារណាទៅលើការភ័ន្តច្រឡំទាំងអស់ និងភាពធ្ងន់ធ្ងរនៃការភ័ន្តច្រឡំដែលបានរៀបរាប់ពីខាងលើរួចមក អង្គបុរេជំនុំជម្រះនឹងធ្វើការសម្រេចជាថ្មីទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធ ដោយពិចារណាទៅលើអង្គហេតុជាក់ស្តែងនៅក្នុងដីកាដំណោះស្រាយព្រមទាំងឯកសារព័ត៌មានបន្ថែមនានា ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់ជូន។

## VIII. ការពិចារណានៅលើតម្រូវការផ្នែកច្បាប់ ដែលអាចអនុវត្តបានចំពោះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

[៨៤] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៤ ដែលបានត្រួតពិនិត្យកាលពីថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩), វិធាន៨៣ នៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពី ការចូលរួមរបស់ជនរងគ្រោះ ០២/២០០៧/វិសោធនកម្មលើកទី ១ ធ្វើវិសោធនកម្មកាលពីថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៨ មាត្រា ៣.៧ និង ៣.៨។

[៨៥] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥ ដែលបានសម្រេចកាលពីថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៩) វិធាន ៨៣ ត្រូវបានលុបចោល ហើយវិធាន ២៣ស្ទួន (៣) បានបង្កើតវិធានថ្មី គឺវិធាន ៧៧ស្ទួន ដែលទាក់ទងតែនឹងបណ្តឹងឧទ្ធរណ៍នៅចំពោះមុខ អង្គបុរេជំនុំជម្រះ គឺមិនទាក់ទងនឹងបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលទេ ហើយវិធាននេះចែងថា៖ “សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ត្រូវបិទផ្លូវតវ៉ា”។ វិធាន ១១០(៥) ដែលមាននៅក្នុងវិធានផ្ទៃក្នុងវិសោធនកម្មលើកទី៤ ត្រូវបានរក្សាទុកនៅក្នុងវិសោធនកម្មលើកទី៥ ដោយវិធាននេះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះតុលាការកំពូល “តែក្នុងករណីដែលទាក់ទងដល់ផលប្រយោជន៍រដ្ឋប្បវេណីរបស់ខ្លួនតែប៉ុណ្ណោះ”។

៥៦. លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺមានចែងក្នុងវិធាន ២៣ស្ទួន(១)[៨៦] ដែលចែងថា៖

១. “ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវ:

ក - បង្ហាញពីអត្តសញ្ញាណឲ្យបានច្បាស់លាស់

ខ-បង្ហាញ ជាលទ្ធផលដោយផ្ទាល់ពីបទឧក្រិដ្ឋ យ៉ាងហោចណាស់មួយនៃបទឧក្រិដ្ឋជាច្រើន ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ ថាខ្លួនពិតជាបានទទួលរងនូវព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬ ផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់ការទាមទារសំណងផ្លូវចិត្តនិងសមូហភាព ។

នៅពេលពិចារណាអំពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតត្រូវតែមានជំនឿថា អង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះមានភាពពិតប្រាកដ។

៥៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ធាតុផ្សំ នៅក្នុងវិធាន ២៣ស្ទួន(១) នៃវិធានផ្ទៃក្នុងរួមមាន៖

- អត្ថិភាពនៃទំនាក់ទំនងរវាងឧក្រិដ្ឋកម្ម និងព្យសនកម្ម,
- ការខូចខាត,
- ភស្តុតាងនៃអត្តសញ្ញាណ
- កម្រិតនៃភស្តុតាង

៥៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា វិធានផ្ទៃក្នុងមិនបានផ្តល់នូវការបកស្រាយ ឬលក្ខណៈវិនិច្ឆ័យណាមួយ ទាក់ទងវិធីសាស្ត្រក្នុងការអនុវត្តធាតុផ្សំទាំងនេះ ទៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ស្ថិតក្នុងស្ថានភាពបែបនេះ ដោយពិចារណាទៅលើលក្ខណៈពិសេសនៃ អ.វ.ត.ក ក្នុងការអនុវត្តធាតុផ្សំដែលមានក្នុងវិធានផ្ទៃក្នុង ទៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះនោះ អង្គជំនុំជម្រះត្រូវអនុវត្តតាមគោលការណ៍ដែលបានបង្កើតឡើងក្នុងកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក។

---

[៨៦] ក្នុងពេលនេះ គឺពេលដែលអង្គបុរេជំនុំជម្រះកំពុងធ្វើការពិនិត្យទៅលើ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វិធានផ្ទៃក្នុងវិសោធនកម្មលើកទី ៧ ដែលបានសម្រេចកាលពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ គឺនៅជាធរមាន។ ដោយអនុលោមទៅតាមវិធាន ១១៤ “វិសោធនកម្មទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានអនុម័តក្នុងកិច្ចប្រជុំពេញអង្គលើកទី៧ , ទី៨ និងទី៩ នឹងត្រូវអនុវត្តចំពោះរាល់សំណុំរឿងទាំងអស់ លើកលែងតែសំណុំរឿងលេខ០០១/១៨-០៧-២០០៧/ អ.វ.ត.ក”។ សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៤២ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៥៩. គោលការណ៍ជាទូទៅនៃកិច្ចព្រមព្រៀង គឺមាននៅក្នុងមាត្រា២ ដែលចែងថា "កិច្ចព្រមព្រៀងនេះត្រូវអនុវត្តតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា ជាពិសេសមាត្រា២៦ និង ២៧"។ មាត្រា ២៦ នៃអនុសញ្ញាទីក្រុងវីយែនចែងថា រដ្ឋជាសមាជិកទាំងអស់ត្រូវតែអនុវត្តតាមសន្ធិសញ្ញាដោយត្រឹមត្រូវ ហើយមាត្រា ២៧ តម្រូវឱ្យរដ្ឋជាសមាជិក មិនត្រូវយកច្បាប់ក្នុងស្រុកមកប្រើធ្វើជាយុត្តិកម្មសម្រាប់ការដែលខ្លួនមិនបានអនុវត្តទៅតាមសន្ធិសញ្ញានោះទេ។

៦០. គោលការណ៍ជាក់លាក់ផ្សេងទៀតគឺមានចែងនៅក្នុងមាត្រា ១២(២) នៃកិច្ចព្រមព្រៀង និងមាត្រា ៣៣ថ្មី នៃច្បាប់ អ.វ.ត.ក ដែលចែងថា "ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។ អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ក្នុងពេលអនុវត្តវិធានរបស់ខ្លួន តុលាការព្រហ្មទណ្ឌអន្តរជាតិ បានស្វែងរកគោលការណ៍ណែនាំពីបណ្តាគោលការណ៍ដែលមានចែងក្នុងអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា[៨៧]។ តុលាការព្រហ្មទណ្ឌអន្តរជាតិយល់ឃើញថា "បទប្បញ្ញត្តិនេះគួរត្រូវបានបកស្រាយ ក្នុងបរិបទ ព្រមទាំងស្របទៅតាមគោលដៅ និងគោលបំណងរបស់ខ្លួន" ហើយថាគោលការណ៍នេះ "អនុវត្តចំពោះវិធាន"។ តុលាការនេះបានពន្យល់ទៀតថា "បរិបទនៃបទប្បញ្ញត្តិច្បាប់ដែលបានលើកឡើង គឺត្រូវបានកំណត់ដោយផ្នែកជាក់លាក់មួយនៅក្នុងច្បាប់ ដែលត្រូវបកស្រាយទាំងស្រុង ដោយបកស្រាយរួមជាមួយនឹងផ្នែកនៃបញ្ញត្តិច្បាប់ទាំងមូលតែម្តង" ហើយថា "គោលដៅរបស់វា អាចប្រមូលយកពីជំពូកមួយនៃច្បាប់ ដែលក្នុងជំពូកនេះមានរួមបញ្ចូលនូវផ្នែកជាក់លាក់មួយនេះ ហើយគោលបំណងរបស់វា អាចប្រមូលយកពីគោលដៅដ៏ទូលំទូលាយនៃច្បាប់ ដែលចំណុចទាំងនេះ អាចប្រមូលយកពីបុព្វកថា និងច្បាប់ទូទៅ"[៨៨]។ អង្គបុរេជំនុំជម្រះនឹងពិចារណាលើគោលការណ៍ណែនាំ ទាក់ទិនដល់ការអនុវត្តវិធានឱ្យបានសមស្រប។

---

[៨៧] អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញា ចុះហត្ថលេខា ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៦៩ ហើយចូលជាធរមានថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៨០ អង្គការសហប្រជាជាតិ, *Treaty Series*, vol. 1155, 18232 ("អនុសញ្ញាទីក្រុងវីយែន")

[៨៨] *Lubanga* ICC ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ អង្គជំនុំជម្រះសាលាដំបូង ១ (ICC-01/04-01/06-1432 OA9 AO10) កថាខណ្ឌ ៥៤ ដល់ ៥៨។

៦១. ពាក់ព័ន្ធនឹងការអនុវត្តដោយផ្អែកលើបរិបទ នៃវិធាន ២៣ស្ទួន(១) អង្គបុរេជំនុំជម្រះសូមកត់សម្គាល់ថា វិធាននេះមានចំណងជើងថា "ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ហើយវិធាននេះនៅក្នុងជំពូក III "នីតិវិធី" នៃវិធានផ្ទៃក្នុង ហើយនៅក្នុងអនុជំពូក ក "បទប្បញ្ញត្តិទូទៅ"។ ផ្នែកនៃវិធាន ២៣ស្ទួន(១) នេះបង្ហាញពីបទប្បញ្ញត្តិទូទៅ ដែលទាក់ទងនឹងនីតិវិធីសម្រាប់ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុដូច្នេះ វិធាននេះត្រូវបកស្រាយជាមួយនឹង៖

- វិធាន ២១ នៃវិធានផ្ទៃក្នុង ដែលលើកឡើងពីគោលការណ៍ជាសារវន្តនៃនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ហើយចែងថា "វិធានផ្ទៃក្នុង ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ ... ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង"
- វិធាន ២៣ នៃវិធានផ្ទៃក្នុងលើកឡើងពីគោលការណ៍ទូទៅនៃការចូលរួមរបស់ជនរងគ្រោះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកទាំងឡាយណាដែលទទួលខុសត្រូវ ... ដោយគាំទ្រតែការចោទប្រកាន់ (ប៉ុណ្ណោះ) ហើយស្វែងរកសំណងផ្លូវចិត្ត និងសំណងសមូហភាព ដូចមានចែងក្នុងវិធាន ២៣ស្ទួនបួន
- វិធាន ២៣ស្ទួនពីរ និង ២៣ស្ទួនបី ដែលបានចែងពីការតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវរៀបចំជាលក្ខណៈសមូហភាព ព្រមទាំងចែងពីលទ្ធភាពសម្រាប់ "ក្រុមជនរងគ្រោះ" ដើម្បីរៀបចំបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនទាំងអស់ ដោយការចូលជាសមាជិក "សមាគមជនរងគ្រោះ" វិធាន ២៣ស្ទួនបួន (៣)(ក) បានចែងថា ក្នុងករណីដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនចាប់ចោទ "សោហ៊ុយនៃសំណង" ត្រូវតែជាបន្ទុករបស់ពិរុទ្ធជន
- វិធាន ៨០(២) ចែងថា ក្នុងពេលជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចងក្រងគ្នាជាក្រុមមានសិទ្ធិកោះហៅសាក្សី ដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែលផ្តល់ឲ្យដោយសហព្រះរាជអាជ្ញា។

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C *

៦២. អង្គបុរេជំនុំជម្រះពិចារណាថា វត្ថុបំណង និងគោលបំណងនៃវិធាន ២៣ស្ទួន (១) នៃវិធានផ្ទៃក្នុងមិនមែនបង្កើតឡើងសម្រាប់រឹតបន្តឹង ឬកំណត់ទៅលើសកម្មភាពរបស់ជនរងគ្រោះ ឬសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅ អ.វ.ត.ក នោះទេ។ ប៉ុន្តែវិធាននេះ បង្កើតឡើងសម្រាប់កំណត់

លក្ខណៈ វិនិច្ឆ័យក្នុងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

៦៣. គោលដៅ និងបញ្ញត្តិទូទៅដែលទូលំទូលាយ នៅក្នុងវិធានផ្ទៃក្នុង ដូចមានចែងក្នុងវិធាន ២១ គឺមាននៅក្នុងចំណុច "លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។"

៦៤. នៅក្នុងបុព្វកថា នៃកិច្ចព្រមព្រៀងបានចែងថា៖
"ដោយហេតុថា នៅក្នុងសេចក្តីសម្រេចចិត្តដដែលនេះ មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ"[៨៩]។

៦៥. ក្នុងបរិបទនេះ មានការកត់សម្គាល់ថា កិច្ចព្រមព្រៀងបានចែងថា គោលការណ៍ជាសារវន្តមួយ ក្នុងការបង្កើត អ.វ.ត.ក គឺ "ការបង្រួបបង្រួមជាតិ"។ ចំណុចនេះជាការបង្ហាញដល់ចៅក្រម ក៏ដូចជាអង្គជំនុំជម្រះ នៅ អ.វ.ត.ក ឲ្យស្វែងរកទាំងការពិតស្តីពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការយកចិត្តទុកដាក់ជាពិសេស និងការធានាថា មានការចូលរួមប្រកបដោយអត្ថន័យរបស់ជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ដែលនេះគឺជាផ្នែកមួយនៃការបង្រួបបង្រួមជាតិ។

៦៦. ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងក្នុងមាត្រា ១ ថា "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"។ លក្ខណៈពិសេសរបស់ អ.វ.ត.ក គឺការដែល អ.វ.ត.ក ត្រូវដោះស្រាយទាំង

[៨៩] យើងសូមរំឭកថា អង្គបុរេជំនុំជម្រះបានសម្រេចរួចហើយថា "ការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី ទៅក្នុងដំណើរការនីតិវិធីគឺជាការទទួលស្គាល់នូវការស្វែងរកការបង្រួបបង្រួមជាតិដូចមានចែងរួចហើយ" សូមមើល សេចក្តីសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន, ឯកសារលេខ C11/53 ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០៨ កថាខណ្ឌ ៣៧។

ចំពោះការរំលោភទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ក៏ដូចជាការដោះស្រាយចំពោះឧក្រិដ្ឋកម្ម និង ទម្រង់នៃការទទួលខុសត្រូវអន្តរជាតិ។ ឧក្រិដ្ឋកម្ម និងការទទួលខុសត្រូវទាំងនេះរួមមាន៖ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[៥០] ដែលផ្តោតទៅលើក្រុមទាំងមូល មិនមែនទៅលើបុគ្គលណាម្នាក់ទេ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[៥១] គឺជាអំពើដែលប្រព្រឹត្តឡើងជាផ្នែកនៃការវាយប្រហារ "ជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ" ប្រឆាំងនឹងប្រជាជន ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ ដូចជាសហឧក្រិដ្ឋកម្មរួម[៥២] ការទទួលខុសត្រូវរបស់ថ្នាក់លើ ការរៀបចំផែនការ ការញុះញង់ឲ្យប្រព្រឹត្ត ការបញ្ជាឲ្យប្រព្រឹត្ត ការសមគំនិតដោយការជួយ ឬជំរុញ[៥៣] ដែលប្រសិនបើរកឃើញថាពិតជាមានមែននោះ វានឹងបង្កើននូវស្ថានទម្ងន់ ព្រមទាំងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនេះបន្ថែមទៀត ដែលការរកឃើញនេះនឹងជួយបញ្ជាក់ថា អំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ត្រូវបានប្រព្រឹត្តឡើងបែបរចនាសម្ព័ន្ធ ហើយមិនមែនផ្តោតគោលដៅតែទៅលើក្រុមជាក់លាក់ ឬទីតាំងឧក្រិដ្ឋកម្មជាក់លាក់ណាមួយទេ ប៉ុន្តែគឺផ្តោតគោលដៅទៅលើប្រជាជនទាំងអស់ នៅទូទាំងប្រទេស។ បន្ថែមពីលើនេះទៀត អ.វ.ត.ក មានយុត្តាធិការតែទៅលើប្រភេទពីរជាក់លាក់ប៉ុណ្ណោះ គឺមេដឹកនាំជាន់ខ្ពស់បំផុត និងអ្នកទទួលខុសត្រូវខ្ពស់បំផុតសម្រាប់ឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។

៦៧. ដោយសារតែលក្ខណៈពិសេសរបស់ អ.វ.ត.ក នេះហើយ ទើបអង្គបុរេជំនុំជម្រះបកស្រាយវិធានផ្ទៃក្នុងដោយគិតពិចារណាទៅលើលក្ខណៈ ទំហំ និងទម្រង់នៃការចូលរួម ព្រមទាំងធាតុផ្សំបង្កើតបទល្មើសដែលរងការចោទប្រកាន់ ព្រមទាំងពីតម្រូវការរបស់សហគមន៍ដែលទទួលរងផលប៉ះពាល់ ដូចមានចែងក្នុងលិខិតុបករណ៍ជាសារវន្តរបស់ អ.វ.ត.ក។

---

[៥០] ច្បាប់ អ.វ.ត.ក មាត្រា ៤។

[៥១] ច្បាប់ អ.វ.ត.ក មាត្រា ៥។

[៥២] ទោះបីជាសហឧក្រិដ្ឋកម្មរួម មិនត្រូវបានកំណត់ជាបទចោទឲ្យជាក់ស្តែង នៅក្នុងច្បាប់ អ.វ.ត.ក ក៏ដោយ ក៏បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការប្រើប្រាស់ទម្រង់នៃសហឧក្រិដ្ឋកម្មរួម នៅចំពោះមុខ អ.វ.ត.ក ត្រូវបានច្រានចោល (ដោយផ្នែក) ដោយអង្គបុរេ-ជំនុំជម្រះ៖ សូមមើលសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតស្តីពីសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ឯកសារ D97/14/15; D97/17/6; D97/16/10។ សូមមើលផងដែរដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥ ដល់១០ និង ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦១៣។

[៥៣] ច្បាប់ អ.វ.ត.ក មាត្រា ២៩។

៦៨. លក្ខណៈពិសេសរបស់ អ.វ.ត.ក គឺថាបើទោះបីជាវិធានផ្ទៃក្នុងត្រូវបានបង្កើតឡើងដោយយកគំរូតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលក្រមនេះយកគំរូតាមច្បាប់ប្រទេសបារាំងក៏ដោយ ក៏វិធានផ្ទៃក្នុងនេះមានលក្ខណៈខុសពីក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា និង ច្បាប់ប្រទេសបារាំង ដែលដោះស្រាយឧក្រិដ្ឋកម្មមានលក្ខណៈធម្មតា ព្រមទាំងបណ្តឹងទាមទារសំណងជាលក្ខណៈបុគ្គល ដែលសំណងនេះមានលក្ខណៈអាចប៉ាន់ប្រមាណបាន។ ជាពិសេសសម្រាប់សំណុំរឿង០០២ អ.វ.ត.ក មិនគ្រាន់តែត្រូវដោះស្រាយចំពោះបទចោទប្រកាន់ពីឧក្រិដ្ឋកម្មជាលក្ខណៈអន្តរជាតិដ៏ធ្ងន់ធ្ងរបំផុតសម្រាប់មនុស្សជាតិនោះទេ ប៉ុន្តែ អ.វ.ត.ក ត្រូវដោះស្រាយចំពោះបទចោទប្រកាន់ពីទម្រង់នៃការទទួលខុសត្រូវជាក់លាក់ ដែលក្នុងពេលបញ្ចូលគ្នា វានឹងបង្កើតជាអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធ។ ព្រឹត្តិការណ៍ផ្ទាល់ទាក់ទិនដល់អំពើសាហាវឃោរ-ឃៅនេះ ត្រូវបានលើកឡើងថា បានបង្កឱ្យមានការខូចខាតជាសមូហភាព ដែលការខូចខាតនេះមិនអាចប៉ាន់ប្រមាណបាននោះទេ សម្រាប់បុគ្គលម្នាក់ៗ ប៉ុន្តែការខូចខាតនេះអាចត្រូវបានមើលឃើញក្នុងបរិបទនៃការខូចខាតជាសមូហភាព ចំពោះសង្គមទាំងមូល ឬក៏ផ្នែកមួយនៃសង្គមនោះ។

៦៩. បន្ថែមពីលើនេះទៀត ជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក ជាពិសេសក្នុងសំណុំរឿង ០០២ គឺស្ថិតក្នុងស្ថានភាពខុសគ្នា ពីជនរងគ្រោះនៅចំពោះមុខតុលាការក្នុងស្រុក និងសូម្បីតែជនរងគ្រោះនៅ អ.វ.ត.ក ក្នុងសំណុំរឿង ០០១ ក៏មានស្ថានភាពខុសគ្នាដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការក្នុងស្រុក ជាទូទៅបានដឹងពីបទចោទ ព្រមទាំងអង្គហេតុជាក់លាក់ដែលខ្លួនអាចប្តឹងដោយផ្អែកលើអង្គហេតនេះ។ នៅក្នុងតុលាការក្នុងស្រុក ការទទួលបានព័ត៌មានពីបញ្ហាដែលត្រូវបានចោទប្រកាន់គឺឆាប់រហ័ស និងងាយស្រួល ព្រោះវាមិនមានការពន្យារពេលវេលា ឬក៏មិនមានការបញ្ចូលការពិចារណាទៅលើឧក្រិដ្ឋកម្មអន្តរជាតិ ព្រមទាំងភាពស្មុគស្មាញដែលទាក់ទិនដល់ឧក្រិដ្ឋកម្មទាំងនេះ ព្រមទាំងទម្រង់ពិសេសផ្សេងទៀតនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងសំណុំរឿង ០០១ របស់ អ.វ.ត.ក ជនរងគ្រោះដឹងថា ពួកគាត់អាចដាក់ពាក្យបណ្តឹងទាក់ទងតែទៅនឹងទីតាំងតែមួយប៉ុណ្ណោះ គឺមន្ទីរ ស-២១ ហើយមានជនជាប់ចោទតែម្នាក់ប៉ុណ្ណោះដែលត្រូវចោទប្រកាន់។ ឌុច មិនត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅទូទាំងប្រទេសនោះឡើយ ហើយក៏មិនត្រូវបានចោទប្រកាន់ថា មានទម្រង់នៃការទទួលខុសត្រូវផ្សេងៗគ្នានោះដែរ ដែលចំណុចទាំងអស់នេះហើយធ្វើឱ្យសំណុំរឿង ០០២ ខុសពីសំណុំរឿង ០០១។ ក្នុងសំណុំរឿង ០០២

* អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER E.C.C.C • C.E.T.C CHAMBRE PRÉLIMINAIRE

ជនជាប់ចោទត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តឧក្រិដ្ឋកម្មនៅទូទាំងប្រទេស។

៧០. នៅចំពោះមុខ អ.វ.ត.ក ម្ចាស់បណ្តឹងរដ្ឋប្បវេណីម្នាក់មិនមានសិទ្ធិទទួលបានសំណងលើការខូចខាតទេ គឺពួកគាត់អាចត្រឹមប្តឹងទាមទារសំណងសមូហភាព និងសំណងផ្លូវចិត្ត។ សំណងផ្លូវចិត្តមានន័យថាកាតព្វកិច្ចខាងផ្លូវចិត្តអាចត្រូវកើតឡើង ទាក់ទិនដល់ការខូចខាតដែលបានកើតឡើង ក្រោយពីមានការអះអាងបញ្ជាក់ទៅលើការចោទប្រកាន់ពីការប្រព្រឹត្តបទល្មើស តាមរយៈការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដោយជនជាប់ចោទ[៩៤]។ សំណងសមូហភាពក៏កើតចេញពីការខូចខាតជាសមូហភាព ដែលមានផលប៉ះពាល់ជាបុគ្គលផងដែរ។ វាជាការមិនត្រឹមត្រូវ ប្រសិនបើយើងពិនិត្យមើលការខូចខាតដែលបង្កដោយអំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ តែទៅលើមូលដ្ឋានជាបុគ្គល ព្រោះការខូចខាតនេះគ្របដណ្តប់ទៅលើផ្នែកជាបុគ្គលនានា។ អំពើសាហាវឃោរឃៅជាទ្រង់ទ្រាយធំ ដែលជាផលវិបាកនៃការអនុវត្តគោលនយោបាយជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ហើយដែលការអនុវត្តនេះផ្តោតទៅលើសហគមន៍ទាំងមូល ក៏ដូចជាទៅលើក្រុមជាក់លាក់នានា ព្រមទាំងបុគ្គលនៅក្នុងសហគមន៍នោះផងដែរ។ បើទោះបីជាមានការខូចខាតជាបុគ្គលក៏ដោយ ក៏ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាបុគ្គល ត្រូវតែបានពិនិត្យមើលក្នុងស្ថានភាពពិសេស នៃជម្លោះ។ លក្ខណៈវប្បធម៌ និងលក្ខណៈសង្គមកម្ពុជា គួរត្រូវបានពិចារណាផងដែរ។ បន្ថែមពីលើនេះទៀត ក្នុងអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ រចនាសម្ព័ន្ធសង្គមទាំងមូលត្រូវបានផ្លាស់ប្តូរយ៉ាងខ្លាំង ដែលការផ្លាស់ប្តូរនេះគឺបណ្តាលមកពីសកម្មភាពរបស់ជនជាប់ចោទ ដែលបានបំពេញជាមួយគ្នា ព្រមទាំងជាមួយជនដទៃទៀត ដូចមានរៀបរាប់ក្នុងដីកាដំណោះស្រាយ។

## ក. ទំនាក់ទំនងហេតុនិងផល

៧១. វិធាន២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងចែងថា ព្យសនកម្មត្រូវតែជាផលវិបាកផ្ទាល់ពី "បទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទ"។ អ.ប.ជ កត់សម្គាល់ឃើញថា នៅក្នុងសំណុំរឿង ០០២ មានដីកាដំណោះស្រាយតែមួយប៉ុណ្ណោះប្រឆាំងនឹងជនជាប់ចោទបួននាក់រួមគ្នា[៩៥]។ ជនជាប់ចោទទាំងនេះត្រូវបានចោទប្រកាន់ពីបទល្មើស ដែលត្រូវបានប្រព្រឹត្តតាមវិធីដែលពួកគេបានចូលរួមជាមួយគ្នានៅក្នុងសហឧក្រិដ្ឋកម្មរួម (និងទម្រង់នៃការទទួលខុសត្រូវដទៃទៀត) នៅទូទាំងប្រទេស

[៩៤] សូមកត់សម្គាល់ថា ការផ្តល់សំណងផ្លូវចិត្តអាចទាក់ទងដល់ចំណាយហិរញ្ញវត្ថុ។

[៩៥] ដីកាដំណោះស្រាយ កថាខណ្ឌ១៦១៣។

កម្ពុជា រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និងការរំលោភបំពានដល់ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៦៥។

៧២. អង្គបុរេជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ខុសពីសំណុំរឿង០០១ ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែបង្ហាញពីទំនាក់ទំនងទៅនឹងបទល្មើសដែលត្រូវបានប្រព្រឹត្តតែនៅក្នុងមន្ទីរសន្តិសុខ ស-២១ ប៉ុណ្ណោះ[៥៦] តែនៅក្នុងសំណុំរឿង០០២ វិញ ដែលមានការចោទប្រកាន់ពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាត្រូវបានគេយកទៅអនុវត្តនៅទូទាំងប្រទេសកម្ពុជា តាមវិធីដែលជនជាប់ចោទបានចូលរួមជាសហឧក្រិដ្ឋកម្មរួម (ឬ ធ្វើសកម្មភាពជាមួយគ្នា ជាទម្រង់នៃការទទួលខុសត្រូវដទៃទៀត) អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនចាំបាច់ត្រូវបង្ហាញពីទំនាក់ទំនងរវាងព្យសនកម្មរបស់ខ្លួនទៅនឹងទីតាំងឧក្រិដ្ឋកម្មតែមួយ ឬទីតាំងឧក្រិដ្ឋកម្មនានាដែលមានរៀបរាប់នៅក្នុងផ្នែកសន្និដ្ឋានទៅលើអង្គហេតុ នៃដីកាដំណោះស្រាយនោះទេ។ ដោយសារបទឧក្រិដ្ឋទាំងនោះ និងគោលនយោបាយជាមូលដ្ឋានរបស់ខ្មែរក្រហមបានបង្កើតជាមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា។ ដីកាដំណោះស្រាយបានចោទប្រកាន់ថា ការប្រព្រឹត្តបទឧក្រិដ្ឋនានាដែលបានរៀបរាប់នោះ ដោយការចូលរួមទៅក្នុងសហឧក្រិដ្ឋកម្មរួម (និងទម្រង់នៃការទទួលខុសត្រូវដទៃទៀត) ចេតនារបស់ជនជាប់ចោទគឺមិនត្រឹមតែប្រព្រឹត្តបទឧក្រិដ្ឋដែលបានកើតឡើងនៅឯទីតាំងឧក្រិដ្ឋកម្មជាក់លាក់នេះទេ តែដើម្បីអនុវត្តគោលនយោបាយ បក្សកុម្មុយនិស្តកម្ពុជានៅទូទាំងប្រទេសកម្ពុជាទាំងមូល។ សហចៅក្រមស៊ើបអង្កេតបានធ្វើសេចក្តីសន្និដ្ឋានជាវិជ្ជមានពីលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនៃការវាយប្រហារទៅលើប្រជាជនស៊ីវិល។ ការចូលរួមផ្នែកគំនិតរបស់របស់ជនជាប់ចោទ គឺជាមូលដ្ឋាននៃធាតុផ្សំអត្តនោម័ត ចំពោះបទឧក្រិដ្ឋមួយចំនួនដែលជនជាប់ចោទត្រូវបានចោទប្រកាន់។ អាស្រ័យហេតុនេះ ព្យសនកម្មដែលសហគមន៍ ឬក្រុមមនុស្សជាក់លាក់បានទទួលរងក៏ត្រូវតែអាចមើលឃើញផងដែរថា មានទំនាក់ទំនងទៅនឹងជនជាប់ចោទ ដោយបានធ្វើឡើងដើម្បីអនុវត្តគោលនយោបាយរបស់ពួកខ្មែរក្រហម នៅទូទាំងប្រទេសកម្ពុជា។ ព្យសនកម្មដែលបណ្តាលមកពីសកម្មភាពរបស់ជនជាប់ចោទរួមជាមួយនឹងជនរងគ្រោះម្នាក់ៗ គឺជាផ្នែកមួយនៃព្យសនកម្មរួម និងដែលមិនអាចគណនាបាន ដែលក្រុមមនុស្សជាគោលដៅ និងសហគមន៍ដែល



---

[៥៦] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង លើសំណុំរឿង០០១ , ឯកសារ E188 ("សាលក្រមសំណុំរឿង០០១") កថាខណ្ឌ៦៤៤ ជាបន្តបន្ទាប់ ។

សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៤៩ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

បុគ្គលម្នាក់ជាសមាជិកបានទទួលរង។ នៅក្នុងបរិបទនេះ លក្ខណៈនៃការទទួលខុសត្រូវរបស់ជនជាប់ចោទត្រូវមានបទដ្ឋានរួមទាក់ទិននឹងការបង្ហាញព្យសនកម្ម។ បើផ្អែកលើលក្ខណៈដែលដីកាដំណោះស្រាយត្រូវបានបង្កើតឡើងនោះ វាមិនមែនជាការសមរម្យទេដែលត្រូវបង្កើតឱ្យមានព្យសនកម្មជាលក្ខណៈបុគ្គល ប្រឆាំងនឹងជនជាប់ចោទម្នាក់ៗនោះ។

៧៣. អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ត្រូវបានទទួលយកនៅក្នុងសំណុំរឿង០០២ ចំពោះការប្តឹងទាមទារប្រឆាំងនឹងជនជាប់ចោទ ជាលក្ខណៈបុគ្គលផង ជាលក្ខណៈរួមជាក្រុមផង។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ចំណុចនេះមិនស្របទៅនឹងអត្ថន័យនៃវិធាន ២៣*ស្ទួន*(១)(ខ) ទេ ដែលចែងថា ទំនាក់ទំនងហេតុនិងផលត្រូវតែបង្កើតឡើងជាមួយបទឧក្រិដ្ឋដែលបានចោទប្រកាន់លើ "ជនត្រូវចោទ" នោះគឺ "ជនត្រូវចោទ" ម្នាក់ៗ។ ដីកាដំណោះស្រាយលើកឡើងពីការទទួលខុសត្រូវរបស់ជនជាប់ចោទ ដែលបានប្រព្រឹត្តរួមគ្នានៅក្នុងសហឧក្រិដ្ឋកម្មរួមមួយ។ ដោយបានដឹងពីករណីនេះហើយ ទើប ស.ច.ស អាចគ្មានជម្រើសអ្វីក្រៅពីការអនុវត្តតាមវិធាន២៣ស្ទួន(១) នៃវិធានផ្ទៃក្នុងតាមវិធីមួយដូចដែលពួកគាត់បានធ្វើ តែដោយមិនបានពន្យល់ពីសំអាងហេតុនៅក្រោយបញ្ហានេះ នៅក្នុងដីការបស់ខ្លួនដែលរងការជំទាស់ទេ។ នៅក្នុងន័យនេះអង្គបុរេជំនុំជម្រះសន្និដ្ឋានថា វាជាកាតព្វកិច្ចដែលត្រូវអនុវត្តតាមវិធីសាស្ត្រដែល ដោយសារសហ-ចៅក្រមស៊ើបអង្កេតចង់បញ្ចៀសមិនឱ្យមានភាពមិនស៊ីសង្វាក់គ្នាសំខាន់ៗ នៅក្នុងជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេត និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកដោយអង្គបុរេជំនុំជម្រះរួចហើយ។

៧៤. ដីកាដំណោះស្រាយបានធ្វើការសន្និដ្ឋានទៅលើអង្គហេតុស្តីពីសហឧក្រិដ្ឋកម្មរួម ដូចខាងក្រោម។ កថាខណ្ឌ ១៥៦, ១៥៧, ១៥៨ និង ១៥៩ នៃដីកាដំណោះស្រាយរៀបរាប់ថា៖

I. **ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហឧក្រិដ្ឋកម្មរួម**

១៥៦. មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាមានផែនការរួមដើម្បីបង្កើតនៅក្នុងប្រទេសកម្ពុជានូវបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈគ្រប់មធ្យោបាយចាំបាច់តាម "សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ។

១៥៧. ដើម្បីធ្វើឱ្យសម្រេចនូវផែនការរួម មេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជាបានរៀបចំបង្កើត និងបានអនុវត្តនូវគោលនយោបាយទាំងប្រាំដូចជា ៖



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C.

- ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត ។
- ការបង្កើត និងដាក់ឱ្យដំណើរការសហករណ៍ និងការដ្ឋាន។
- ការអប់រំ "សមាសភាពមិនល្អ" និង ការកម្ទេច "ខ្មាំង" ដែលត្រូវបានរកឃើញទាំងនៅក្នុង និងនៅក្រៅបក្ស។
- ការចេញនូវវិធានការជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនានានៃសាធារណរដ្ឋខ្មែរ (រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ)។
- ការដាក់បទបញ្ញាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍។

១៥៨. ផែនការរួមកើតមានតាំងតែពីមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានបន្តយ៉ាងហោចណាស់រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ គោលនយោបាយទាំងប្រាំដែលត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យសម្រេចផែនការរួមនេះ ត្រូវបានអនុវត្តក្នុងរវាង ឬមុនកាលបរិច្ឆេទទាំងនេះ។ គោលនយោបាយទាំងនេះបានប្រែប្រួលនៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យដែលមានលក្ខណៈកាន់តែធំ និងតឹងរ៉ឹង។ ផលវិបាកមួយក្នុងចំណោមផលវិបាកនានានៃគោលនយោបាយទាំងនេះ គឺការធ្វើសមូហភាវូបនីយកម្មសង្គមលើគ្រប់វិស័យទាំងអស់។ សមូហភាវូបនីយកម្មសង្គមនេះ រួមមាន ការលុបបំបាត់ផ្សារ រូបិយវត្ថុ និងកម្មសិទ្ធិឯកជន ការហាមឃាត់ការធ្វើដំណើរទៅមកដោយសេរីរបស់មនុស្ស និងជាចុងក្រោយគឺការប្រមូលផ្តុំមនុស្សជាអង្គភាពដោយឡែកៗពីគ្នាដោយធ្វើការបែងចែកជាប្រភេទ ដែលក្នុងនោះមនុស្សត្រូវរស់នៅរួមគ្នាជាលក្ខណៈទូទៅ។ ការណ៍នេះបានបង្កើតនូវប្រព័ន្ធមួយ ដែលក្រោយមកប្រជាជនកម្ពុជាបានកំណត់ជាទូទៅថា៖ **ប្រទេសទាំងមូលបានក្លាយទៅជា "គុកឥតជញ្ជាំង"**។

១៥៩. បុគ្គលដែលបានចូលរួមក្នុងផែនការរួមនេះ យ៉ាងហោចណាស់មានសមាជិកនៃគណៈកម្មាការអចិន្ត្រៃយ៍ ដូចជា **នួន ជា** និង **អៀង សារី** អ្នកដែលស្ថិតនៅក្នុងគណៈកម្មាធិការមជ្ឈិម ដូចជា **ខៀវ សំផន** រដ្ឋមន្ត្រីនានាដូចជា **អៀង ធីរិទ្ធ** លេខាភូមិភាគ និងតំបន់ស្វយ័ត និងមេដឹកនាំកងពលយោធាមជ្ឈិម"។

៧៥. នៅក្នុងដីកាដំណោះស្រាយ មានការរៀបរាប់ និងការរាយការណ៍ពីទីតាំងឧក្រិដ្ឋកម្មផ្សេងៗដែលត្រូវបានស៊ើបអង្កេត ទាក់ទិននឹងរបៀបអនុវត្តគោលនយោបាយទាំងនេះ។ ព័ត៌មានពិស្តាររួមមានការចោទប្រកាន់ពីរបៀបអនុវត្តគោលនយោបាយទាំងនេះ ដែលក្លាយទៅជាអំពើឃោរឃៅជាក់ស្តែងជាទ្រង់ទ្រាយធំនៅទូទាំងប្រទេសកម្ពុជា។ សហចៅក្រមស៊ើបអង្កេតបានថ្លែងនៅក្នុងដីកាដំណោះស្រាយថា ពី "មន្ទីរសន្តិសុខប្រហែល ២០០ កន្លែង និងកន្លែងសម្លាប់មនុស្សយ៉ាងច្រើនរាប់

មិនអស់ [...] នៅគ្រប់ភូមិភាគទូទាំងប្រទេសកម្ពុជា និងនៅគ្រប់ថ្នាក់ទាំងអស់នៃរចនាសម្ព័ន្ធរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជា រួមទាំងនៅកម្រិតមជ្ឈិមបក្សផងដែរ" សហចៅក្រមស៊ើបអង្កេតបានទទួលការប្ដឹងត្រឹមតែអំពីមន្ទីរសន្តិសុខចំនួន ១១ កន្លែង និងកន្លែងសម្លាប់មនុស្សចំនួន ៣ កន្លែងតែប៉ុណ្ណោះ[៩៧]។ ទោះបីបានពិពណ៌នាពីរបៀបអនុវត្ត "គោលដៅសំខាន់ពីររបស់មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្ស" ក៏ដោយ តែវាបានបង្ហាញច្បាស់ថា មន្ទីរសន្តិសុខចំនួន ១១ កន្លែង និងកន្លែងសម្លាប់មនុស្សចំនួន ៣ កន្លែងនោះគ្រាន់តែជាឧទាហរណ៍ ដើម្បីបង្ហាញពីរបៀបដំណើរការ មន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សនៅទូទាំងប្រទេសកម្ពុជាតែប៉ុណ្ណោះ[៩៨]។

៧៦. អង្គហេតុដែលបានចោទប្រកាន់ទាំងនេះ ជាពិសេសទាក់ទិននឹងតួនាទីពីដំបូងរបស់ជនជាប់ចោទនោះ (កថាខណ្ឌ១៥២៤ នៃដីកាដំណោះស្រាយ) ដែលត្រូវបានចាត់ទុកថាបានប្រព្រឹត្តរបៀបជាការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនាពេលនោះ នោះគោលបំណងរួមបានសម្រេចតាមរយៈការបង្កើត និងអនុវត្តគោលនយោបាយប្រាំយ៉ាងដូចដែលបានរៀបរាប់ខាងលើ ក្លាយជាបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។ ទម្រង់នៃការទទួលខុសត្រូវបន្ថែមទៀតដែលមានរៀបរាប់រួមមាន ការធ្វើផែនការ ការញុះញង់ ការទទួលខុសត្រូវរបស់ថ្នាក់លើ ការបញ្ជា ការជួយនិងជំរុញ។ ដីកាដំណោះស្រាយបានរៀបរាប់ទៀតថា៖

> **ការទទួលខុសត្រូវព្រហ្មទណ្ឌក្រោមទម្រង់នៃការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម**
>
> ១៥២៤. ផែនការរួមរបស់មេដឹកនាំបក្សកម្ពុជាប្រជាធិបតេយ្យ គឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជា តាម "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមែនមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួមនេះរួមមានជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក. ឬក៏ជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។
>
> ១៥២៥. ដើម្បីសម្រេចបានផែនការរួមនេះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានកំណត់យកគោលនយោបាយ ៥ យ៉ាងដូចមានរៀបរាប់ខាងក្រោម ដែលការដាក់ឱ្យអនុវត្តនូវគោលនយោបាយទាំង៥ នេះដែលការអនុវត្តរួមមាន ជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ឬក៏ជាការជាប់

[៩៧] ដីកាដំណោះស្រាយ កថាខណ្ឌ១៧៨។

[៩៨] ដីកាដំណោះស្រាយ កថាខណ្ឌ១៧៨ ជាបន្តបន្ទាប់។

ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួម ព្រមទាំងបុគ្គលនានាដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនេះ៖

**(១) ការផ្លាស់ទីលំនៅប្រជាជនជាច្រើនដង ពីទីប្រជុំជនទៅជនបទ និងពីជនបទមួយទៅជនបទមួយទៀត**

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា ២៩ (ថ្មី) និង មាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

(គ) អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការជម្លៀសដោយបង្ខំ )

**(២) ការបង្កើត និងការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋាននានា ៖**

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការធ្វើឲ្យទៅជាទាសករ

(ឃ) ការដាក់នៅក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ច) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

(ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

(ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

(ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត (ក្រោមទម្រង់នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)

**(៣) ការអប់រំកែប្រែ "សមាសភាពមិនល្អ" និង ការកម្ទេច "*ខ្មាំង*" ទាំងនៅក្នុង និងនៅក្រៅបក្ស៖**

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការធ្វើឲ្យទៅជាទាសករ

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE
E.C.C.C * C.E.T.C

(ឃ) ការដាក់នៅក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ច) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

(ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

(ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

(ឈ) អំពើអមនុស្សធម៌ផ្សេងៗទៀត(ក្រោមទម្រង់នៃការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ)

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩**
បទល្មើសដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា៦ មាត្រា២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាតដោយចេតនា

(ខ) ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

(គ) ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព

(ឃ) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

(ង) ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

(ច) ការនិរទេសជនស៊ីវិលដោយខុសច្បាប់

**(៤) ការចេញនូវវិធានការចំពោះក្រុមមនុស្សជាក់លាក់ ជាពិសេសជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ (ដែលមានជាអាទិ៍ មន្ត្រីទាហាន និងគ្រួសាររបស់ពួកគេ) ៖**

**ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៤ មាត្រា២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមានប្រល័យពូជសាសន៍លើ៖

(ក) ជនជាតិចាម

(ខ) ជនជាតិវៀតណាម

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាត

(ខ) ការសម្លាប់រង្គាល

(គ) ការនិរទេស

(ឃ) ការដាក់នៅក្នុងមន្ទីរឃុំឃាំង

(ង) ការធ្វើទារុណកម្ម

(ឆ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍

(ជ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា

(ញ) អំពើអមនុស្សធម៌ផ្សេងៗទៀត ដោយការបាត់ខ្លួនដោយបង្ខំ

**ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៦ មាត្រា២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក) ការធ្វើមនុស្សឃាតដោយចេតនា

**(៥) ការដាក់បទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍៖**

**ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** បទល្មើសដែលមានចែង និងផ្តន្ទាទោសដោយមាត្រា៥ មាត្រា ២៩ (ថ្មី) និង មាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក រួមមាន៖

(ក) ការរំលោភលើផ្លូវភេទ

(ខ) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

១៥២៦. បន្ទាប់ពីបានចូលកាន់អំណាចលើទឹកដីទូទាំងប្រទេសរួចហើយ ឧក្រិដ្ឋកម្មទាំងនេះកាន់តែមានទំហំធំ និងមានភាពធ្ងន់ធ្ងរឡើង នៅពេលដែលមេដឹកនាំ ប.ក.ក បានខិតខំប្រឹងប្រែងធ្វើយ៉ាងណាដើម្បីឱ្យបានសម្រេចបាននូវផែនការបដិវត្តន៍របស់ខ្លួន ដោយធ្វើការកែតម្រូវទៅលើអ្វីដែលខ្លួនសន្មតថា ជាការខ្វះខាត។

១៥២៧. ទាក់ទងដល់គោលនយោបាយប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម ផែនការក្នុងការកម្ទេចក្រុមមនុស្សអស់ទាំងនេះបានកើតមានឡើងចាប់តាំងពីខែមេសា ឆ្នាំ ១៩៧៧ ចំពោះជនជាតិវៀតណាម និងចាប់តាំងពីដើមឆ្នាំ ១៩៧៧ ចំពោះជនជាតិចាម។ បន្ទាប់ពីនោះមក សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមបានដឹងអំពីការណ៍ដែលថា ការធ្វើឱ្យបានសម្រេចនូវផែនការរួម ត្រូវបានពន្លាតផងដែរដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើក្រុមមនុស្សដែលទទួលបានការការពារទាំងនេះ។ ការដែលថា សមាជិកទាំងឡាយនៃសហឧក្រិដ្ឋកម្មរួមទទួលយកការបង្កើនមធ្យោបាយប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមធ្យោបាយនេះត្រូវបានប្រើប្រាស់ដើម្បីធ្វើឱ្យបានសម្រេចនូវផែនការរួម មានន័យថា សមាជិកទាំងនោះមានចេតនាក្នុងការ ធ្វើឱ្យបានសម្រេចនូវផែនការនោះតាមរយៈអំពើប្រល័យពូជសាសន៍។

១៥២៨. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ផែនការរួមនេះបានលេចចេញជារូបរាងមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ម្ល៉េះ ហើយបានបន្តអត្ថិភាពរបស់ខ្លួនក្នុងរបបកម្ពុជា

ប្រជាធិបតេយ្យទាំងមូលយ៉ាងហោចណាស់ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ គោលនយោបាយទាំង៥ ត្រូវបានដាក់ឱ្យអនុវត្តនាមុនសម័យកាលដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែលនេះបង្ហាញថា **ជនត្រូវចោទ**មានចេតនារួចទៅហើយតាំងតែពីមុនឆ្នាំ ១៩៧៥ ក្នុងការធ្វើឱ្យសម្រេចនូវផែនការរួម និង បង្កើតនូវមាគ៌ាដឹកនាំមួយ ដែលចេតនានេះបានបន្តនៅក្នុងសម័យកាល ដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។

១៥២៩. សមាជិកនៃផែនការរួម រួមមានយ៉ាងហោចណាស់ សមាជិកនៃគណៈអចិន្ត្រៃយ៍ ដូចជា **នួន ជា** និង **អៀង សារី**, សមាជិកគណៈមជ្ឈិម ដូចជា **ខៀវ សំផន**, រដ្ឋមន្ត្រីនានា ដូចជា **អៀង ធីរិទ្ធ**, លេខាភូមិភាគ **និង** លេខាតំបន់ស្វយ័ត និង ថ្នាក់ដឹកនាំកងពលយោធារបស់មជ្ឈិម ដូចដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា នៃដីកាដំណោះស្រាយនេះ។

១៥៣០. ការរួមចំណែករបស់**ជនត្រូវចោទ**នៅក្នុងសហឧក្រិដ្ឋកម្មរួមមិនកម្រិតត្រឹមការបង្កើតបក្សកុម្មុយនីស្តកម្ពុជា រដ្ឋបាលគ្រប់គ្រងរបស់បក្ស និង រចនាសម្ព័ន្ធទំនាក់ទំនងរបស់បក្សប៉ុណ្ណោះទេ ប៉ុន្តែ ដូចដែលបានរៀបរាប់ខាងក្រោម ជនត្រូវចោទបានរួមចំណែកយ៉ាងសកម្មដល់ការពង្រីកផែនការរួម តាមមធ្យោបាយផ្សេងៗជាច្រើន ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។

១៥៣១. ទាក់ទិនទៅនឹងការចូលរួម និង ការរួមចំណែក របស់**ជនត្រូវចោទ**នៅក្នុងសហឧក្រិដ្ឋកម្មរួម និង ចេតនារបស់ជនត្រូវចោទនៅក្នុងការបន្តសម្រេចឱ្យបាននូវផែនការរួម សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ទាក់ទិនទៅនឹង ៖ ...”។

៧៧. ក្នុងដីកាដំណោះស្រាយ នៅគ្រប់កាលៈទេសៈទាំងអស់ដែល ស.ច.ស ចាត់ទុកអង្គហេតុទាំងនោះថាជាបទឧក្រិដ្ឋនោះ ស.ច.ស បានថ្លែងថា ជនជាប់ចោទបានបង្កើត និងអនុវត្តនូវគោលនយោបាយសម្រាប់*ប្រទេសកម្ពុជាទាំងមូល*។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា នៅពេលដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ពួកគេបានទទួលរងព្យសនកម្មពីការអនុវត្តគោលនយោបាយទាំងនោះ ទោះបីនៅតាមតំបន់ដែលមិនត្រូវបានជ្រើសរើសដើម្បីធ្វើការស៊ើបអង្កេតក៏ដោយ ក៏ពួកគេទាំងនោះគួរតែត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីដែរ។

៧៨. អង្គបុរេជំនុំជម្រះសូមធ្វើការកត់សម្គាល់បន្ថែមថា ក្នុងសេចក្តីសន្និដ្ឋាន[៩៩] របស់ដីកាដំណោះ-ស្រាយ សហចៅក្រមស៊ើបអង្កេត បានកំណត់លក្ខណៈនៃអង្គហេតុ ថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

PRE-TRIAL CHAMBER ECCC C.E.T.C. CHAMBRE PRELIMINAIRE

[៩៩] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១៣

និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវចោទប្រកាន់ថាជនជាប់ចោទជាអ្នកប្រព្រឹត្ត តាមរយៈអំពើសកម្ម ឬអកម្ម ដែលបានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម ព្រមទាំងតាមរយៈសកម្មភាពបញ្ជារបស់ពួកគេ តាមរយៈឧក្រិដ្ឋកម្ម ដែលតាមនិយមន័យ គឺជាការដឹកនាំដែលធ្វើឡើងប្រឆាំងនឹងក្រុមមនុស្សមួយចំនួន ឬប្រឆាំងនឹងប្រជាជនទាំងមូល[១០០]។ ការនេះគឺដោយហេតុថា សកម្មភាពដាច់ដោយឡែកនីមួយៗ ដែលធ្វើឡើងប្រឆាំងនឹងសមាជិកម្នាក់ៗនៃក្រុមនោះ ដែលតាមនិយមន័យគឺត្រូវបានប្រព្រឹត្តឡើង "ដោយមានចេតនាពិសេស ក្នុងការបំផ្លាញទាំងស្រុង ឬដោយផ្នែក នូវក្រុម [...] មួយ ហើយវាជា "ផ្នែកមួយនៃការវាយប្រហាជាប្រព័ន្ធ និងជាទ្រង់ទ្រាយធំ ប្រឆាំងនឹងជនស៊ីវិល[១០១]"។ ទោះបីជាយ៉ាងណាក៏ដោយ បទល្មើសដែលត្រូវបានចោទប្រកាន់ និងគោលនយោបាយជាមូលដ្ឋាននឹងត្រូវបានបង្កើតឡើងដើម្បីជះឥទ្ធិពលទៅលើក្រុមមនុស្សទាំងមូល ឬប្រជាជនទាំងមូល ហើយគួរយកមកពិចារណាផងដែរនូវភាពក្លាយជាជនរងគ្រោះនៃកាលៈទេសៈបែបនេះ[១០២] នៅពេលមានសំអាងហេតុដែលបង្ហាញថា វាបានកើតឡើងនៅទូទាំងប្រទេសនោះ។ ហេតុនេះ ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងទិដ្ឋភាពនៃអំពើឃោរឃៅជាទ្រង់ទ្រាយធំគួរតែសំដៅដល់ឧបវិបទ ដែលឆ្លើយតបទៅនឹងសកម្មភាពដែលបានប្រព្រឹត្តយ៉ាងទូលំទូលាយ និងជាប្រព័ន្ធ ដែលកើតចេញពីការអនុវត្តនូវគោលនយោបាយទាំងនេះនៅទូទាំងប្រទេស ដែលក្នុងនោះការទទួលខុសត្រូវជា

---

[១០០] មាត្រា៤ និង៥ នៃច្បាប់ អ.វ.ត.ក។ ដូចដែលបានលើកឡើងផងដែរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី, សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Milosevic,* សំណុំរឿងលេខ IT-02-54-T នៅតុលាការ ICTY, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅលើពាក្យសុំឱ្យមានសាលក្រមស្តីពីការលើកលែងការចោទប្រកាន់, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៤, កថាខណ្ឌ២៤៦ បានលើកឡើងថា៖ "ចេតនានៅក្នុងអំពើប្រល័យពូជសាសន៍របស់ពួកមេដឹកនាំស៊ែបប៊ូស្នី អាចរកបាននៅក្នុងភស្តុតាងទាំងអស់ ... ទំហំ និងគំរូនៃការវាយប្រហារ ប្រពលភាពនៃការវាយប្រហារទាំងនោះ ចំនួនដ៏ច្រើននៃពួកមូស្លីមដែលត្រូវបានសម្លាប់ ... ការដាក់ពួកមូស្លីមនៅក្នុងមន្ទីរឃុំឃាំង ការប្រព្រឹត្តយ៉ាងឃោរឃៅទៅលើអ្នកទាំងនោះនៅក្នុងមន្ទីរឃុំឃាំង និងនៅកន្លែងដទៃទៀត និងការកំណត់ជាគោលដៅនូវបណ្តាជនដែលបានជួយឱ្យពួកមូស្លីមនៅរស់រានមានជីវិតថាជាក្រុមមួយ ដែលកត្តាទាំងអស់នេះត្រូវបានកំណត់ថាជាអំពើប្រល័យពូជសាសន៍"។

[១០១] *សូមមើល* Antonio Cassese, *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (International Criminal Law),* Oxford University Press, ឆ្នាំ ២០០៣ ("Cassese 2003"), ទំព័រ 106៖ "[អំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] មិនបានបង្កើតជាព្រឹត្តិការណ៍ដាច់ពីគ្នាឡើយ ដោយសារបទឧក្រិដ្ឋទាំងពីរនេះមានទ្រង់ទ្រាយធំ និងជាការរំលោភយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សផង និងដោយសារបទឧក្រិដ្ឋទាំងពីរនេះមានទំនាក់ទំនងទៅនឹងការប្រព្រឹត្តមិនគប្បីជាទ្រង់ទ្រាយធំផង"។ ។

[១០២] មហាសន្និបាតអង្គការសហប្រជាជាតិ, គោលការណ៍មូលដ្ឋាន និងការណែនាំស្តីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះនៃការរំលោភបំពានរួមលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ៖ សេចក្តីសម្រេចត្រូវបានអនុម័តដោយមហាសន្និបាត ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ឯកសារលេខ A/RES/60/147, គោលការណ៍៨។

លក្ខណៈបុគ្គលដែលបានចោទប្រកាន់លើជនជាប់ចោទម្នាក់ៗគួរធ្វើជាលក្ខណៈរួមវិញ ដោយសារមានការចោទប្រកាន់ពីការធ្វើសកម្មភាពរួមគ្នាជាផ្នែកមួយនៃសហឧក្រិដ្ឋកម្មរួម។

៧៩. អង្គបុរេជំនុំជម្រះក៏សូមធ្វើការកត់សម្គាល់បន្ថែមថា ទោះបីជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលជាឧក្រិដ្ឋកម្មមួយត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ ប្រឆាំងនឹងជនជាប់ចោទ ដែលតាមនិយមន័យ គឺជាឧក្រិដ្ឋកម្មមួយធ្វើឡើងប្រឆាំងនឹងមនុស្សក៏ដោយ[១០៣] ប៉ុន្តែវិធីសាស្ត្រដែលអង្គហេតុ ត្រូវបានកំណត់ក្នុងដីកាដំណោះស្រាយនោះ[១០៤] អាចនាំដល់សេចក្តីសន្និដ្ឋានថា វាអាចទៅរួចដែលឧក្រិដ្ឋកម្មបែបនេះ ក្នុងករណីសមស្របណាមួយ ត្រូវមើលឃើញថាមានលក្ខណៈជាប្រព័ន្ធ ហើយត្រូវបានរៀបចំឡើងប្រឆាំងនឹង "ជនជាប់ឃុំទាំងអស់" ឬយ៉ាងហោចណាស់ក៏មានផលប៉ះពាល់ផ្នែកផ្លូវចិត្ត ទាំងចំពោះបុគ្គល ក៏ដូចជាចំពោះសមូហភាពផងដែរ។ ចំណុចនេះត្រូវបានបង្ហាញដោយការយល់ឃើញនៅក្នុងដីកាដំណោះស្រាយដូចខាងក្រោម៖ "ស្ថានភាព [ត្រូវបានរៀបចំឡើង] ដើម្បីធ្វើឲ្យជនជាប់ឃុំ[១០៥] ត្រូវស្ថិតក្នុងបរិយាកាសនៃភាពភ័យខ្លាចជារៀងរហូត"[១០៦]។ អង្គបុរេជំនុំជម្រះបានពិចារណាទៅលើចំណុចនេះ នៅពេលដែលខ្លួនធ្វើការត្រួតពិនិត្យឡើងវិញ លើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

៨០. អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតក៏បានបញ្ជូនជនជាប់ចោទទៅធ្វើការជំនុំជម្រះ សម្រាប់ការបំពារបំពានទៅលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[១០៧] (ឧក្រិដ្ឋកម្មជាតិ) ដែលតាមនិយមន័យ គឺជាឧក្រិដ្ឋកម្មដែលធ្វើឡើងប្រឆាំងនឹងមនុស្ស។ បើទោះបីជាមានសំអាងហេតុ នៅក្នុងដីកាដំណោះស្រាយ[១០៨] បង្ហាញពីមូលហេតុដែលសហ

---

[១០៣] ច្បាប់ អ.វ.ត.ក មាត្រា ៦ ។

[១០៤] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៩១-១៥២០។

[១០៥] មានការបញ្ជាក់អត្ថន័យបន្ថែមចំពោះការប្រើប្រាស់ពាក្យជនជាប់ឃុំជាទម្រង់ពហុវចនៈ។

[១០៦] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥០២។

[១០៧] ដីកាដំណោះស្រាយ កថាខណ្ឌ ១៦១៣។

[១០៨] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦៤-១៥៧៦។

ចៅក្រមស៊ើបអង្កេត "យល់ឃើញថាខ្លួនស្ថិតនៅក្នុងភាពជាប់គាំងផ្នែកនីតិវិធី" ទាក់ទិនដល់ឧក្រិដ្ឋកម្មជាតិ ក៏ដោយក៏អង្គបុរេជំនុំជម្រះបានកត់សម្គាល់ជាឯកច្ឆន្ទដូចតទៅ៖

> "សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលចោទប្រកាន់ជនជាប់ចោទពីបទល្មើសជាតិបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានពិចារណាថា អំពើនានាដែលមានរៀបរាប់នៅក្នុង "ជំពូក៣៖ ការកំណត់ប្រភេទបទល្មើស" ផ្នែក "III. បទល្មើសប្រល័យពូជសាសន៍" "IV. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" និង "V. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ" អាចត្រូវបានកំណត់តាមផ្លូវច្បាប់ថាជាបទល្មើសមនុស្សឃាត អំពីទារុណកម្ម និងការវាយប្រហារលើសាសនា តាមមាត្រា២០៩, ២១០, ៥០០, ៥០១, ៥០៣ និង៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយថាមានភស្តុតាងគ្រប់គ្រាន់ដែលថា ជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ។
>
> បើតាមខ្លឹមសារនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជនជាប់ចោទបានទទួលដំណឹងពីអំពើនានាដែលគេត្រូវបានចោទប្រកាន់ តែមិនមានភាពច្បាស់លាស់ថាតើអង្គហេតុជាក់លាក់ណាមួយអាចត្រូវបានចាត់ទុកបទល្មើសជាតិនោះ។ ទម្រង់នៃការទទួលខុសត្រូវក៏មានស្ថានភាពនេះដូចគ្នាដែរ។ សហចៅក្រមស៊ើបអង្កេតបានអះអាងពីអង្គហេតុ ដែលគាំទ្រដល់សំអាងហេតុរបស់ខ្លួនថា មានភស្តុតាងគ្រប់គ្រាន់ដែលថា ជានជាប់ចោទបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់ហើយក៏បានអះអាងថាផងដែរ ពីទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តចំពោះបទល្មើសអន្តរជាតិនីមួយៗ។ ទោះជាយ៉ាងណាក្តី ពួកគាត់មិនបានអះអាងពីទម្រង់នៃការទទួលខុសត្រូវជាក់លាក់ដែលត្រូវអនុវត្តចំពោះបទល្មើសជាតិទេ។
>
> បន្ទាប់ពីបានអានដីកាដំណោះស្រាយទាំងមូលរួចមក អង្គបុរេជំនុំជម្រះយល់ថា ការចោទប្រកាន់ពីបទឧក្រិដ្ឋថ្នាក់ជាតិគឺផ្អែកទៅលើអង្គហេតុនានា ដែលមានរៀបរាប់នៅក្នុងកថាខណ្ឌទាក់ទិននឹងបទឧក្រិដ្ឋនានាដូចជាអំពីប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬការរំលោភបំពានធ្ងន់ធ្ងរដល់អនុសញ្ញាទីក្រុងហ្សឺណែវ។ ចំណុចនេះក៏ដូចគ្នាផងដែរចំពោះទម្រង់នៃការទទួលខុសត្រូវដោយពុំនិយាយដល់ទម្រង់នៃការទទួលខុសត្រូវតាមបទដ្ឋានអន្តរជាតិ ដែលហៅថា ជាការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈសហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលមិនត្រូវយកមកអនុវត្តចំពោះឧក្រិដ្ឋកម្មថ្នាក់ជាតិទេ។ ចំពោះអង្គហេតុនានាដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលអាចកំណត់ជាបទឧក្រិដ្ឋនានាដូចជាមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ជាបញ្ហានៃការកំណត់បទឧក្រិដ្ឋតាមផ្លូវច្បាប់ដែលត្រូវសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង ហើយនៅក្នុងដំណាក់កាលនេះ វាមិនមានផលប៉ះពាល់ទៅដល់យុត្តាធិការរបស់ អ.វ.ត.ក ក្នុងការបញ្ជូនជនជាប់ចោទទៅជំនុំជម្រះទាក់ទិននឹងឧក្រិដ្ឋកម្មទាំងនេះទេ។

៨១. អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលដូចគ្នាចំពោះឧក្រិដ្ឋកម្ម នៅក្នុងបរិបទនៃដីកាដំណោះស្រាយ ។

៨២. អង្គបុរេជំនុំជម្រះត្រូវពិនិត្យថា តើព្យសនកម្មដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

បានចោទប្រកាន់នោះ ពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ ដូចដែលមានរៀបរាប់នៅក្នុងដីកាដំណោះស្រាយឬទេ។

**ខ. ព្យសនកម្ម:**

៨៣. វិធាន២៣*ស្ទួន*(១)(ខ) នៃវិធានផ្ទៃក្នុងចែងថា ព្យសនកម្មត្រូវតែជាព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត។ អង្គបុរេជំនុំជម្រះ ដូចដែលសហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់នៅក្នុងដីការបស់ខ្លួន បានអនុម័តយកសេចក្តីសម្រេចរបស់តុលាការកំពូលនៃតុលាការ ICC ព្យសនកម្មត្រូវតែជាលក្ខណៈជារូបវន្ត និងថា មិនចាំបាច់ត្រូវតែដោយផ្ទាល់ទេ[១០៩]។ អង្គបុរេជំនុំជម្រះបានអនុម័តយកសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC ដែលថា ព្យសនកម្មផ្លូវចិត្តរួមមានជំងឺផ្លូវចិត្ត ឬវិកលចរិត តួយ៉ាងជំងឺបាក់ស្បាតជាដើម[១១០]។ ទាក់ទិននឹងព្យសនកម្មផ្លូវចិត្ត អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ជាការសំខាន់គេត្រូវពិចារណាលើភាពក្លាយជាជនរងគ្រោះផងដែរ នៅក្នុងបរិបទសង្គម និងវប្បធម៌ដែលពាក់ព័ន្ធនឹងពេលវេលាដែលបទឧក្រិដ្ឋនេះបានកើតឡើងនៅក្នុងប្រទេសកម្ពុជា។ ការថែទាំជាពិសេសក៏ត្រូវចាំបាច់ឲ្យមានដែរ ដើម្បីធានាថា ជំហររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានយកទៅពិចារណានៅក្នុងបរិបទដែលសមរម្យ។ បរិបទបែបនេះត្រូវមានលក្ខណៈពិសេសទៅតាមប្រទេស និងវប្បធម៌នីមួយៗផងដែរ។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មិនអាចមានបទដ្ឋានណាមួយដែលត្រូវបានអនុម័ត ឬត្រូវបានយកមកពិចារណាទាក់ទិននឹងបរិបទបែបនេះទេ [១១១]។

ECCC * CETC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

---

[១០៩] សូមមើល សាលដីកាលើ Lubanga របស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICC ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៨ ICC-01/04-01/06 OA9 OA10, ផ្នែកសម្រេចសេចក្តី កថាខណ្ឌ1(i)។

[១១០] សាលក្រមរបស់ អ.ជ.ស.ដ ក្នុងសំណុំរឿង០០១ កថាខណ្ឌ៦៤១។

[១១១] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា តុលាការអន្តរជាតិដទៃទៀតបានអនុវត្ត*វិធីសាស្ត្រដែលមានលក្ខណៈរសើបផ្នែកវប្បធម៌*ស្រដៀងគ្នានេះដែរ។ ឧទាហរណ៍ សូមមើល៖ *រឿងក្តី Aloeboetoe និងអ្នកដទៃទៀត*, សាលក្រមជួសជុលសំណង ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៣ តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, កថាខណ្ឌ 54 – 63 (ការសង្កត់ន័យត្រូវបានបន្ថែមនៅកថាខណ្ឌ55); *រឿងក្តីប្រជាជន Saramaka តទល់នឹងប្រទេសស៊ូរីណាម* តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, អញ្ញត្តកម្ម អង្គសេចក្តី ការជួសជុលសំណង និងការចំណាយ, សាលក្រមថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ទំព័រ188-189; សូមមើលផងដែរ Nowak, Manfred, *សេចក្តីអធិប្បាយចំពោះកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (U.N. Covenant on Civil and Political Rights CCPR Commentary)*, N.P.Engel, ("សេចក្តីអធិប្បាយចំពោះ ICCPR"), ទំព័រ405៖ ដែលយោងទៅដល់សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រម ស៊ើបអង្កេតលើភាព ៦០ នៃទំព័រ ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

៨៤. ដូចបានកត់សម្គាល់ពីខាងលើរួចមកហើយគឺថា អង្គបុរេជំនុំជម្រះសង្កេតឃើញថា ទស្សនៈរបស់អ្នកជំនាញទាក់ទិននឹងលក្ខណៈគ្រួសារសាច់ឆ្ងាយ នៅប្រទេសកម្ពុជា ត្រូវបានផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ក្នុងសំណុំរឿង០០១ ដោយលោក ឈឹម សុធារ៉ា អ្នកជំនាញផ្នែកចិត្តសាស្ត្រ និងជាសាស្ត្រាចារ្យសាកលវិទ្យាល័យដែលបានរស់នៅ និងបម្រើការងារនៅទីក្រុងភ្នំពេញ ហើយដែលអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃថា គាត់មានគុណសម្បត្តិជាអ្នកជំនាញមួយរូប។ នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ នៅពេលដែលគាត់បានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងឆ្លើយសំណួរដោយផ្ទាល់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក សុធារ៉ា បានឆ្លើយតបដូចតទៅ[១១២]៖

> "សំណួរ៖ បាទសូមអរគុណ។ ទាក់ទងនឹងមន្ទីរសន្តិសុខ ស២១ ឬក៏សព្វថ្ងៃយើងហៅថា សារមន្ទីរបទប្រល័យពូជសាសន៍ទួលស្លែងដដែលនេះ ភាគច្រើនជនរងគ្រោះជាសាច់ឈាមរបស់អ្នកដែលត្រូវបានគេសម្លាប់នៅក្នុងមន្ទីរ ស២១ ឬក្រៅមន្ទីរ ស២១។ តើហេតុផលភាគច្រើនយ៉ាងម៉េច ដែលមនុស្ស ឬក៏ជនរងគ្រោះគាត់នៅតែចង់ដឹងថា កន្លែងដែលបងប្អូន ឬសាច់ឈាមគាត់ស្លាប់នៅកន្លែងណា? កន្លែងនេះសូមលោកវេជ្ជបណ្ឌិតបញ្ជាក់ថា ការចង់ដឹងចង់ឮកន្លែងហ្នឹងវាមានហេតុផលទាក់ទងនឹងផ្លូវចិត្តយ៉ាងម៉េច?
>
> ចម្លើយ៖ បាទ, សូមអរគុណសំណួរនេះ។ គឺថា ខ្ញុំបាទសូមបញ្ជាក់ថា ទីមួយខ្ញុំចង់សំដៅទៅលើសង្គមគ្រួសារកម្ពុជាម្តងទៀត។ សង្គមគ្រួសារកម្ពុជា គឺជាសង្គមគ្រួសារដែលបងប្អូនរស់នៅជាមួយគ្នា[១១៣] អ៊ីចឹងវាមានដូចជា ទំនាក់ទំនងខាងផ្នែកអារម្មណ៍ ផ្លូវចិត្តហ្នឹងវាមានខ្លាំង វាមានច្រើន។ ហើយទំនាក់ទំនងនេះហើយ ដែលធ្វើឱ្យដោយមានការជិតស្និទ្ធរវាងអាចជាជនរងគ្រោះជាមួយនឹងអ្នកដែលបានស្លាប់ទៅ។ ហើយជួនកាល ខ្ញុំអាចគិតបានថា អ្នកស្លាប់ទៅហ្នឹងគឺជាអ្នកដែលអាចមានគុណសម្បត្តិ ឬគុណស្រ័យអ្វីមួយសម្រាប់គាត់ ជាអ្នកសាច់ឈាមដែលសំខាន់នៅក្នុងគ្រួសារគាត់។ អ៊ីចឹង ការប៉ះពាល់ការស្លាប់ដល់ - ការស្លាប់របស់បងប្អូនគាត់ហ្នឹង ទុក្ខព្រួយរបស់បងប្អូនគាត់គឺជាទុក្ខព្រួយរបស់គាត់ដែរ។ នៅក្នុងទ្រឹស្តី ខ្ញុំបាទសូមបញ្ជាក់មួយទៀតថា គឺថា *សិចិនដារី*

---

ការអនុវត្តរបស់ ECtHR ហើយគណៈកម្មាធិការសិទ្ធិមនុស្សបានកត់សម្គាល់ថា "ពាក្យថាគ្រួសារត្រូវបានបកស្រាយយ៉ាងទូលំទូលាយក្នុងន័យឱ្យបានយល់ពីវប្បធម៌របស់រដ្ឋជាភាគី"។

[១១២] ប្រតិចារឹកសវនាការ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ឯកសារ D288/4.68.1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ (ផ្នែកភាសាអង់គ្លេស) ត្រង់ទំព័រ ៤៧ ពីបន្ទាត់ទី២៥ (សំនួររបស់មេធាវីអន្តរជាតិ Alain Werner)។

[១១៣] នៅទីនេះ ប្រតិចារឹកជាភាសាអង់គ្លេសប្រើពាក្យថា "separately"។ អង្គបុរេជំនុំជម្រះបានពន្យល់នៅលើសំណៅជាភាសាខ្មែរនៃប្រតិចារឹកនេះដែលជាសម្តីដើមរបស់អ្នកជំនាញ និងបានកត់សម្គាល់ឃើញថាពាក្យ "separately" គួរតែមានន័យថាជា "closely together" វិញ ប្រសិនបើបកប្រែដោយត្រឹមត្រូវពីភាសាខ្មែរ។

*ត្រូម៉ាថាយសេសិន* (Secondary Traumatization) គឺជាការប៉ះពាល់ទង្គិចផ្លូវចិត្ត។ ទោះបីជាការប៉ះទង្គិចផ្លូវចិត្តហ្នឹង អ្នកហ្នឹងមិនបានរងនូវបញ្ហាផ្លូវចិត្ត មិនរងនូវទារុណកម្មដោយផ្ទាល់មែន ប៉ុន្តែដោយសារភាពជិតស្និទ្ធទំនាក់ទំនងជិតស្និទ្ធរវាងគាត់និងអ្នក ដែលបានស្លាប់ទៅហ្នឹងហើយ ដែលជាកត្តាមួយដែលនាំឱ្យមាន *សិមិនដារី ត្រូម៉ាថាយសេសិន* ជាការឮនូវទារុណកម្ម ជាការស្តាប់ឮ ជាការមើលឃើញ ជាបញ្ហាអ្វីផ្សេងទៀតដែលទាក់ទងទៅនឹងអ្នកដែលគាត់ស្លាប់ទៅហ្នឹងហើយ ដែលធ្វើឱ្យគាត់ហ្នឹងរងនូវបញ្ហាឈឺចាប់ស្រដៀង ឬក៏របៀបដែលៗបងប្អូន ឬក៏ជនរងគ្រោះនុំងដែលបានទទួលដែរ អាហ្នឹងគឺជាបញ្ហា"[១១៤]។

៨៥. ការសាកសួរសំណួរដល់អ្នកជំនាញរូបនេះបានបន្តដូចខាងក្រោម៖

"សំណួរ៖ សំណួរចុងក្រោយរបស់ខ្ញុំ៖ កូនក្តីខ្លះរបស់ខ្ញុំមិនត្រឹមតែបាត់បង់ម្តាយ ឬក៏បងប្អូន ឬក៏ឪពុកទេ ប៉ុន្តែត្រូវបាត់បង់បងប្អូនជីដូនមួយ ឬក៏ជីដូនជីតា ឬក៏បងប្អូនថ្លៃផង។ អ្នកដែលគេចាត់ទុកថានៅក្នុងវប្បធម៌ផ្សេងគឺថានៅសាច់ឆ្ងាយ ប៉ុន្តែនៅក្នុងអង្គជំនុំជម្រះក្នុងនីតិវិធីនេះ កូនក្តីរបស់យើងមានការឈឺចាប់គឺវាលក្ខណៈធ្ងន់ធ្ងរ។ តើលោកអាចពន្យល់បានទេ អ្នកដែលបាត់បង់ជីដូនជីតា ឬក៏បងប្អូនថ្លៃ ថាតើមានការឈឺចាប់ក្នុងទំហំណាដែរ សាច់ញាតិដែលមិនជាប់ផ្ទាល់នោះ?

ចម្លើយ៖ ក្នុងករណីនេះវាអាស្រ័យទៅលើ *អាថាច់មិន* (Attachment) ទៅលើចំណងរវាងគាត់ហើយនឹងអ្នកដែលស្លាប់ទៅ។ ចំពោះសង្គមគ្រួសារកម្ពុជា យើងឃើញថា ជាសង្គមគ្រួសារមួយពីដើមដែលមានការគោរពចាស់ទុំ មានការដឹងគុណ មានការសងគុណ ហើយចំពោះអ្នកដែលជាកូនជាចៅជាបងប្អូនជីដូនមួយជាដើមហ្នឹង គាត់អាចមាននូវទំនាក់ទំនងអ្វីមួយនៅក្នុងជាមួយអ្នកដែលស្លាប់។ ឧទាហរណ៍អ្នកដែលស្លាប់អាចជាអ្នកចិញ្ចឹមបីបាច់ថែរក្សាគាត់ អ្នកដែលស្លាប់អាចជាអ្នកដែលផ្តល់ដំបូន្មានល្អសម្រាប់គាត់។ ឧទាហរណ៍ អ្នកដែលស្លាប់អាចជាអ្នកដែលមានគំរូល្អសម្រាប់គាត់ ដែលជាអ្នកត្រួសត្រាយផ្លូវសម្រាប់ជីវិតគាត់។ អ៊ីចឹងករណីទាំងអស់នេះ វាជាចំណងមួយដ៏ជិតស្និទ្ធដែលធ្វើឱ្យគាត់មិនអាចបំភ្លេចបាន។ អ៊ីចឹងហើយគាត់ត្រូវធ្វើយ៉ាងណាដើម្បីសងគុណចំពោះអ្នកដែលស្លាប់ ប៉ុន្តែដោយសារការសងគុណហ្នឹងមិនអាចធ្វើបានដោយសារគាត់ស្លាប់។ អ៊ីចឹងគាត់ត្រូវធ្វើយ៉ាងណាដើម្បីសងគុណគាត់ តាមវិធីសាស្ត្ររកយុត្តិធម៌ អ៊ីចឹងហើយបានជាខ្ញុំជឿថាការសងគុណនេះ ការដឹងគុណនេះ ការចែករំលែកការឈឺចាប់នេះហើយដែលធ្វើឱ្យពួកគាត់ដាក់មកប្តឹងនៅតុលាការដើម្បីរកយុត្តិធម៌"[១១៥]។

---

[១១៤] ប្រតិចារឹកសវនាការ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ឯកសារ D288/4.68.1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ (ផ្នែកភាសាអង់គ្លេស), ត្រង់ទព័រ ៣៦-៣៧ ពីបន្ទាត់ទី ១៤ (សំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហុង គឹមសួន)..។

[១១៥] ប្រតិចារឹកសវនាការ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ឯកសារ D288/4.68.1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០០៩ (ផ្នែកភាសាអង់គ្លេស) ត្រង់ទំព័រ ៤៧ ពីបន្ទាត់ទី២៥ (សំនួររបស់មេធាវីអន្តរជាតិ Alain Werner)។

៨៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា បរិបទសង្គម និងវប្បធម៌នាពេលដែលបទឧក្រិដ្ឋទាំងនោះបានកើតឡើង តម្រូវឱ្យមានការពិចារណាមួយទៀតដែលមានលក្ខណៈទូលំទូលាយជាងមុនគឺ ភាពក្លាយជាជនរងគ្រោះ។ នេះជាលក្ខណៈដោយឡែក ទាក់ទិននឹងការចូលរួមរបស់ជនជាប់ចោទក្នុងការអនុវត្តគោលនយោបាយដែលប៉ះពាល់ដល់ក្រុម និងសហគមន៍ទាំងមូល រហូតដល់សង្គមកម្ពុជាទាំងមូលផង។ ស្ថិតក្នុងកាលៈទេសៈបែបនេះ ទំនាក់ទំនងនៃអ្នកនៅក្នុងបន្ទុកមានការពាក់ព័ន្ធ ដូចជាទំនាក់ទំនងរបស់មនុស្សនៅក្នុងសហគមន៍ភូមិតែមួយ ដែលប្រជាជនស្គាល់គ្នាច្បាស់ និងតែងពឹងពាក់គ្នាទៅវិញទៅមកតាមវិធីនានាជាច្រើន ដើម្បីរស់នៅ និងចិញ្ចឹមជីវិត។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការត្រឹមតែដឹងពីជោគវាសនារបស់មនុស្សណាម្នាក់ដែលជាជនរងគ្រោះផ្ទាល់ពីបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើង ដោយសារការអនុវត្តគោលនយោបាយរហូតមានការប៉ះពាល់យ៉ាងដូច្នេះ វាលើសពីការរំខានផ្លូវចិត្តទៅទៀតចំពោះមនុស្ស ដែលមានសភាពផ្លូវចិត្តធម្មតា។ ការរំខានបែបនេះមិនត្រឹមតែកើតចេញពីការបានឃើញផ្ទាល់ភ្នែក នូវការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះប៉ុណ្ណោះទេ តែក៏កើតចេញពីការគំរាមកំហែងដែលកើតមានជាបន្តបន្ទាប់ ដោយសារព្រឹត្តិការណ៍ទាំងនេះអាចនឹងបង្កជាការភ័យខ្លាចដល់អ្នកដទៃទៀតដែលថា ពួកគេនឹងជួបនូវជោគវាសនាបែបនេះដែរ ដោយសារពួកគេស្ថិតនៅក្នុងក្រុម ឬសហគមន៍តែមួយ ជាមួយជនរងគ្រោះផ្ទាល់នៃបទឧក្រិដ្ឋណាមួយដែលបានប្រព្រឹត្តឡើង ជាផ្នែកមួយនៃការអនុវត្តនូវគោលនយោបាយទាំងនោះ។

៨៧. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ការអនុវត្តគោលនយោបាយរបស់ពួកខ្មែរក្រហម ដោយការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម (និងទម្រង់នៃការទទួលខុសត្រូវដទៃទៀត) រួមជាមួយអ្នកដទៃទៀត បាននាំមកនូវផលវិបាកនូវការរៀបចំជាថ្មី នូវរចនាសម្ព័ន្ធសង្គមទាំងមូលនៅប្រទេសកម្ពុជានាសម័យនោះ[១១៦] ការបង្កើត "ប្រជាជនថ្មី" ដែលសម្រេចបានដោយសារ៖ ការផ្លាស់ប្តូរទីកន្លែងប្រជាជនពីតាមទីក្រុង និងទីប្រជុំជន ទៅតំបន់ជនបទ ដោយការ "អប់រំ "ពួកសមាសភាពមិនល្អ" និង "ពួកខ្មាំង" ទាំងក្នុងជួរ និងក្រៅជួរបក្ស" ឬ ដោយការបង្កើតសហករណ៍ និងការដ្ឋានថ្មីៗ។ ការរៀបចំរចនាសម្ព័ន្ធថ្មីនេះបានធ្វើឱ្យប្រជាជនដែលបានព្រាត់ប្រាសក្រុមគ្រួសាររបស់ខ្លួនហើយនោះ ត្រូវទៅរស់នៅក្នុងបរិយាកាសថ្មីមួយ និងក្នុងចំណោមប្រជាជនដទៃទៀតដែលពួកគេមិនដែលបានឃើញ ឬ មិនដែលបានជួបពីមុនមកក្នុងជីវិតរបស់ខ្លួន តែប្រការដែលសំខាន់ជាងគេបំផុតនោះគឺថា ពួកគេត្រូវចែករំលែកនូវជោគវាសនាដូចគ្នា ក្នុងកាលៈទេសៈនៃការ

CHAMBRE PRÉLIMINAIRE C.E.T.C.

[១១៦] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៨, ១៦១, ១៦៩, ២០៧។

លំបាកលំបិន និងការធ្វើបាបយ៉ាងខ្លាំងក្លា។ វាជាការត្រឹមត្រូវដែលគេត្រូវពិចារណាថា ចំណង ពិសេសផងទៃដែលកើតចេញពីសមាជិកក្នុងគ្រួសារតែមួយក៏បានវិវឌ្ឍន៍កើតមាន ដែលករណី ស្រដៀងគ្នានេះក៏បានកើតឡើងនូវចំណងពិសេសដែរ រវាងអ្នកទោសពីរនាក់ដែលបានជាប់ក្នុង បន្ទប់ឃុំឃាំងតែមួយ[១១៧]។ ដោយសារពួកគាត់គឺជាផ្នែកមួយនៃក្រុម ឬសហគមន៍គោលដៅ អ្នក ទាំងនេះទំនងជាត្រូវចែករំលែកអ្វីៗទាំងអស់រួមទាំងការភ័យខ្លាច និងទុក្ខព្រួយផងដែរ ជាមួយប្រជា ជនដែលគេមិនដែលបានជួបពីមុនមកសោះ តាមវិធីដូចគ្នា ឬ អាចមានភាពជ្រាលជ្រៅជាង អ្វី ដែលពួកគេបានជាមួយសមាជិកគ្រួសារសាច់ជិតរបស់គេ ក្នុងកាលៈទេសៈធម្មតាតទៅទៀត។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា គេក៏ត្រូវយកចិត្តទុកដាក់ដែរចំពោះចំណងបែបនេះ ហើយ មិនអាចអនុវត្តត្រឹមតែការសន្មតជាសមាជិកគ្រួសារសាច់ជិតឡើយ ដែលក្នុងកាលៈទេសៈនេះ វាជា ការរឹតត្បិតជ្រុលពេកហើយ។ ចំពោះទិដ្ឋភាពទូលំទូលាយមួយ ជាការសមហេតុផលដែលត្រូវ សន្មតថា ដោយសារការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅទូទៅប្រទេស កម្ពុជាបែបនេះ ប្រជាជនដែលមិនមានទំនាក់ទំនងអ្វីជាមួយគ្នាបន្តិចសោះពីមុនមក ក៏ប៉ុន្តែ ក៏ជា ផ្នែកមួយនៃក្រុម ឬសហគមន៍គោលដៅក៏ត្រូវតែពឹងផ្អែកទៅលើគ្នាទៅវិញទៅមកដើម្បីជីវិតរស់។

៨៨. អង្គបុរេជំនុំជម្រះពិចារណាឃើញថា សម្រាប់សំអាងហេតុដូចបានរៀបរាប់ខាងលើ នៅក្នុងសំណុំ រឿង០០២ កម្រិតនៃទំនាក់ទំនងរវាងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនឹង ជនរងគ្រោះផ្ទាល់មិនត្រឹមតែពឹងផ្អែកលើការសន្មតជាសមាជិកគ្រួសារប៉ុណ្ណោះទេ តែក៏ត្រូវលាត សន្ធឹងចំពោះអង្គហេតុដែលអ្នកដាក់ពាក្យសុំស្ថិតនៅក្នុងក្រុម ឬសហគមន៍នោះជាមួយជនរងគ្រោះ ដោយផ្ទាល់ដែរ។ នៅពេលជនរងគ្រោះដោយប្រយោលជាសមាជិកនៃក្រុមមនុស្ស ឬសហគមន៍ ណាមួយដែលក្លាយជាគោលដៅនៃការអនុវត្តគោលនយោបាយបក្សកុម្មុនិស្តកម្ពុជានោះ មិនមាន ភាពខុសគ្នារវាងអ្វីដែលមានកើតឡើងចំពោះបុគ្គលម្នាក់ៗ និងអ្វីដែលបានកើតឡើងជារួមឡើយ។

៨៩. នៅក្នុងបរិបទនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ដីកាដំណោះស្រាយ[១១៨] និងពាក្យសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីចោទប្រកាន់ថា ក្នុងការអនុវត្តនូវគោលនយោបាយរបស់ខ្លួន មេដឹកនាំបក្ស កុម្មុនិស្តកម្ពុជា និងអ្នកក្រោមបង្គាប់របស់ខ្លួន បានបង្ហាញឲ្យឃើញច្បាស់ថា ភាពភ័យខ្លាចនៃអំពើ ហិង្សា ឬសេចក្តីស្លាប់ត្រូវបានធ្វើឲ្យលេចចេញជារូបរាង ចំពោះសមាជិក ដែលនៅក្នុងក្រុមមនុស្ស

---

[១១៧] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៨៖ "ប្រទេសទាំងមូលក្លាយជា "គុកឥតជញ្ជាំង""។

[១១៨] ដីកាដំណោះស្រាយ កថាខណ្ឌ២១០-២១២, ២១៩, ២២០, ២៣១-២៣២។

ឬសហគមន៍ជាគោលដៅនោះ ហេតុនេះវាជាការបញ្ជូនសារទៅកាន់មនុស្សគ្រប់គ្នា ដែលកាលៈទេសៈនោះបង្ហាញថា មិនត្រឹមតែជនរងគ្រោះដោយផ្ទាល់នៃបទឧក្រិដ្ឋនោះប៉ុណ្ណោះទេតែអ្នកដែលមានឃើញបទឧក្រិដ្ឋនោះក៏ត្រូវទទួលរងផងដែរ ដោយសារពួកគេទទួលរងនូវក្តីរន្ធត់ និងភាពភ័យខ្លាចដោយផ្ទាល់ថា ខ្លួននឹងក្លាយជាកម្មវត្ថុនៃការធ្វើបាប ដូចគ្នាដែរ ដោយសារតែខ្លួននៅក្នុងក្រុមមនុស្ស ឬសហគមន៍នោះ។ ស្ថិតក្រោមកាលៈទេសៈដែលបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តជាលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនោះ អ្នកបានឃើញនូវការប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងនឹងសមាជិកម្នាក់ទៀតនៃក្រុម ឬសហគមន៍ជាមួយគ្នានោះទំនងជាទទួលរងនូវការឈឺចាប់ និងព្យសនកម្មផ្លូវចិត្តផងដែរ។

៩០. ដីកាដំណោះស្រាយបានចោទប្រកាន់ពីការធ្វើបាប*ក្រុមមនុស្ស*ដែលជាគោលដៅ ហើយថា "សកម្មភាពនេះបានប៉ះពាល់ដោយផ្ទាល់ ឬ ដោយប្រយោល ដល់*ក្រុមមនុស្ស*ជាច្រើន [...]"[១១៩]។ ដីកាដំណោះស្រាយក៏បានអះអាងដែរថា "សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីអង្គហេតុបែបនេះ [ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ]"[១២០] និង [ការបង្កើត និងដាក់ឲ្យដំណើរការសហករណ៍ និងការដ្ឋាន][១២១] ដែលបានកើតឡើង*នៅទូទាំង*ប្រទេសកម្ពុជា" ហើយថា "គោលដៅមួយក្នុងចំណោមគោលដៅទាំងអស់នៃការផ្លាស់ទីលំនៅប្រជាជន គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកម្លាំងពលកម្មសម្រាប់សហករណ៍ និងការដ្ឋានទាំងឡាយ"[១២២] ដែលត្រូវបានបង្កើតឡើង*នៅទូទាំង*ប្រទេសកម្ពុជា[១២៣]។ ការអនុវត្តនូវគោលនយោបាយទាំងនេះមិនត្រឹមតែផ្តល់ផលប៉ះពាល់ត្រឹមតែទៅលើបុគ្គលម្នាក់ៗប៉ុណ្ណោះទេ តែវាក៏ប៉ះពាល់ដល់ក្រុមប្រជាជន ឬសហគមន៍ទាំងមូលនៅទូទាំងប្រទេសកម្ពុជាដែរ។

៩១. ដីកាដំណោះស្រាយបានចោទប្រកាន់បន្ថែមថា គោលនយោបាយត្រូវបានអនុវត្តដោយធ្វើ *"អ្វីៗទាំងអស់"* ដើម្បីសម្រេចបានតាមគោលដៅ ហើយដែលចំណុចនេះរួមទាំងការណែនាំឲ្យ*សម្លាប់*

[១១៩] ដីកាដំណោះស្រាយ កថាខណ្ឌ២០៥។
[១២០] ដីកាដំណោះស្រាយ កថាខណ្ឌ២១៦។
[១២១] ដីកាដំណោះស្រាយ កថាខណ្ឌ១៦៨។
[១២២] ដីកាដំណោះស្រាយ កថាខណ្ឌ១៦១។
[១២៣] ដីកាដំណោះស្រាយ កថាខណ្ឌ១៦៨។

*សមាជិកទាំងអស់*ដែលស្ថិតក្នុងក្រុមណាមួយផងដែរ[១២៤] ការសម្លាប់ និងការគំរាមកំហែងថានឹងសម្លាប់អ្នកដែលមិនធ្វើតាមការណែនាំ[១២៥]។ ដីកាដំណោះស្រាយក៏ចោទប្រកាន់ផងដែរថា ប្រជាជននៅទូទាំងប្រទេសកម្ពុជាទំនងជាមិនអាចបង្ហាញការជំទាស់បានទេ ដោយសារពួកគេ*ខ្លាចទទួលរងអំពើហិង្សា និងសេចក្តីស្លាប់*។ សេចក្តីភ័យខ្លាចបែបនេះ រួមជាមួយបរិយាកាសជុំវិញនាពេលនោះដូចមានរៀបរាប់ក្នុងដីកាដំណោះស្រាយ ទំនងជាថា សូម្បីតែអ្នកដែលបានឃើញផ្ទាល់ភ្នែកនូវព្រឹត្តិការណ៍នានា[១២៦] ឬបានដឹងពីឧក្រិដ្ឋកម្មអាចទទួលរងការឈឺចាប់ផ្លូវចិត្ត និងព្យសនកម្មផ្លូវចិត្តដោយមិនត្រឹមតែបណ្តាលមកពីព្យសនកម្មដែលអ្នកដទៃបានទទួលរងប៉ុណ្ណោះទេ តែដោយសារ*ការទទួលការគំរាមកំហែងដោយផ្ទាល់ និងជាក់ស្តែង* ថាពួកគេនឹងជួបនូវផលវិបាកដូចគ្នាមិនខាន ប្រសិនបើពួកគេស្ថិតនៅក្នុងក្រុមមនុស្ស ដែលជាគោលដៅដូចគ្នា ឬក្នុងសហគមន៍ណាមួយ។

៩២. វាទំនងជាស្របទៅនឹងសតិរបស់មនុស្សដែលថា អ្នកដែលបានឃើញអ្វីមួយបានកើតឡើងចំពោះអ្នកដែលជំទាស់ (អ្នកនោះមិនចាំបាច់តែជាសមាជិកគ្រួសារទេ) មានការភ័យខ្លាចថា ខ្លួននឹងទទួលរងនូវផលវិបាកដូចគ្នាមិនខាន ដោយរួមជាមួយនឹងហេតុការណ៍ដែលថាពួកគេត្រូវបានបំបែកចេញពីផ្ទះសម្បែង និងមនុស្សជាទីស្រឡាញ់ផ្ទុយពីបំណងរបស់ខ្លួនផងនោះ (ជួនកាលហេតុការណ៍រួមជាមួយសមាជិកគ្រួសាររបស់ខ្លួនដែលកំពុងសម្រាកក្នុងមន្ទីរពេទ្យ ឬភរិយា/ម្តាយ/កូនស្រី ដែលទើបសម្រាលកូនរួចផង)[១២៧] ហេតុនេះហើយគេមានអារម្មណ៍ថារស់នៅឯកោ បាត់បង់អស់ក្តីសង្ឃឹមនៅពេលគេត្រូវមានភាពរឹងប៉ឹង បានជួបប្រទះនឹងព្យសនកម្មផ្លូវចិត្ត។

៩៣. អាស្រ័យហេតុនេះ ចំពោះអ្នកដាក់ពាក្យសុំទាំងឡាយណាដែលអះអាងថា បានទទួលរងព្យសនកម្មផ្លូវចិត្ត ដែលមិនមានភាពជិតស្និទ្ធជាមួយជនរងគ្រោះផ្ទាល់នោះ អង្គបុរេជំនុំជម្រះត្រូវអនុវត្តតាម

[១២៤] សូមមើលជាឧទាហរណ៍ ដីកាដំណោះស្រាយ កថាខណ្ឌ២១៤។

[១២៥] ដីកាដំណោះស្រាយ កថាខណ្ឌ២១០, ២១១, ២១៩។

[១២៦] អ.ប.ជ នៅក្នុងសាលដីកាសម្រេចទៅលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការទទួលយក អ.ប.ជ ៤៧ និង៤៨ បានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីរួចមកហើយ នូវជនរងគ្រោះដែលអះអាងថា បានទទួលរងព្យសនកម្មពីការបានឃើញនូវបទឧក្រិដ្ឋមួយ៖ សាលដីកាលើបណ្តឹងឧទ្ធរណ៍លើដីកាសម្រេចរួមរបស់សហចៅក្រមស៊ើបអង្កេតលេខ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកាសម្រេចលេខ D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ លើការទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារលេខ D250/3/2/1/5 កថាខណ្ឌ៣៨។

[១២៧] ដីកាដំណោះស្រាយ កថាខណ្ឌ២២៥។

ការសន្មតថាជាព្យសនកម្មរួមនៅក្នុងការវាយតម្លៃចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២។ ការសន្មតទុកជាមុនពីការខូចខាតជាសមូហភាព គឺកើតចេញពីលក្ខណៈដូចគ្នានៃប្រភពដែលបង្កឲ្យមានការខូចខាតនេះ ហើយប្រភពទាំងនោះ មានដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលតាមនិយមន័យ ដូចដែលបានរៀបរាប់ពីខាងលើ គឺជាឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមមនុស្ស ឬប្រឆាំងនឹងប្រជាជន[១២៨]។ អង្គបុរេជំនុំជម្រះយល់ថា វិធីតែមួយក្នុងការធ្វើឲ្យការខូចខាតជាសមូហភាព មានលក្ខណៈរូបី គឺតាមរយៈការបង្ហាញនូវឧទាហរណ៍របស់បុគ្គលនីមួយៗ ដែលអាចបុគ្គលទាំងនេះអាចបង្ហាញពីលក្ខណៈ ព្រមទាំងទំហំនៃការខូចខាតដែលបង្កឡើងចំពោះក្រុមជាសមូហភាពនេះ[១២៩]។ ដោយប្រើប្រាស់ការសន្មតទុកជាមុនពីការខូចខាតជាសមូហភាព អង្គបុរេជំនុំជម្រះចង់មានន័យថា ករណីដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងថា គាត់គឺជា *សមាជិកនៃក្រុម ឬសហគមន៍គោលដៅតែមួយ* ជាមួយនិងជនរងគ្រោះផ្ទាល់ គឺព្យសនកម្មអាចជា ព្យសនកម្មផ្លូវចិត្ត ដែលជនរងគ្រោះដោយប្រយោលបានទទួលរង ដែលព្យសនកម្មនេះកើតចេញពីព្យសនកម្មដែលជនរងគ្រោះផ្ទាល់បានទទួល ហើយព្យសនកម្មនេះបង្កឡើងដោយការប្រព្រឹត្តឧក្រិដ្ឋកម្មដែលតំណាងឲ្យការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដូចមានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ។

---

[១២៨] សូមមើលផងដែរ Cassese ឆ្នាំ ២០០៣, ទំព័រ 89-90 ដោយយោងទៅដល់ *Chambre d'accusation* នៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍ទីក្រុងប៉ារីស៍, សាលដីកាចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩២ ក្នុងរឿងក្តី *Touvier* (ត្រង់ទំព័រ 352)៖ "ជនជាតិជ្វីហ្វ និងសមាជិកចលនាតស៊ូដែលត្រូវបានធ្វើទុក្ខបុកម្នេញជាលក្ខណៈប្រព័ន្ធ ក្នុងនាមរដ្ឋមួយដែលអនុវត្តគោលនយោបាយឧត្តមានុភាពផ្នែកមនោគមវិជ្ជា ចំពោះពួកជ្វីហ្វ ***ដោយសំអាងហេតុថាពួកគេជាសមាជិកសហគមន៍ជាតិសាសន៍ ឬសាសនាមួយ*** ចំណែកសមាជិកចលនាតស៊ូ ***ដោយសារពួកគេប្រឆាំងនឹងគោលនយោបាយនោះ*** អាចក្លាយជាជនរងគ្រោះដូចគ្នាចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។

[១២៩] អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា តុលាការសិទ្ធិមនុស្សអន្តរអាមេរិក (IACtHR) ក៏មានអនុវត្តតាមវិធីសាស្ត្រស្រដៀងគ្នានេះដែរ៖ *រឿងក្តីផែនការសម្លាប់រង្គាលនៅ de Sánchez តទល់នឹងប្រទេសហ្គាតេម៉ាឡា*, សាលក្រមថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤, ការជួសជុលសំណង, តុលាការសិទ្ធិមនុស្សអន្តរអាមេរិក, កថាខណ្ឌ93៖ "ការជួសជុលសំណងមិនមែនត្រឹមតែជាការសងដល់ការខូចខាតដែលអាចទូរទាត់ជាប្រាក់កាសបាន និងដែលមិនអាចទូរទាត់ជាប្រាក់កាសឡើយ (កថាខណ្ឌ៧២ ដល់៧៨ និង ពី កថាខណ្ឌ៨០ ដល់៨៩ ខាងលើ); ទម្រង់នៃការជួសជុលសំណងដទៃទៀតត្រូវតែបន្ថែម។ វិធានការទាំងនេះមានការពាក់ព័ន្ធជាពិសេសក្នុងរឿងក្តីនេះ ដោយមិនគិតដល់ស្ថានទម្ងន់នៃអង្គហេតុ និង*លក្ខណៈរួមនៃការខូចខាតដែលបានកើតឡើងឡើយ*"។

**គ. កម្រិតនៃភស្តុតាងៈ**

៩៤. អនុលោមតាមវិធានផ្ទៃក្នុង នៅពេលពិចារណាទៅលើការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.ប.ជ ត្រូវពិនិត្យទៅលើអង្គហេតុដែលបានអះអាង ដើម្បីគាំទ្រដល់ពាក្យសុំនោះថា *អាចជាការពិត*ជាមុនសិន។

**ឃ. ភស្តុតាងនៃអត្តសញ្ញាណៈ**

៩៥. អង្គបុរេជំនុំជម្រះត្រូវអនុវត្តនូវវិធីសាស្ត្រមួយដែលមានការបត់បែន ទាក់ទិនទៅនឹងលក្ខខណ្ឌតម្រូវអនុលោមតាមវិធាន២៣ស្ទួន(១)(ខ) សម្រាប់អ្នកដាក់ពាក្យសុំទាំងអស់ ដើម្បីធ្វើការបញ្ជាក់ឱ្យបានច្បាស់ពីអត្តសញ្ញាណរបស់ខ្លួន។ នៅក្នុងន័យនេះ អង្គបុរេជំនុំជម្រះក៏ត្រូវអនុវត្តផងដែរទៅតាមការអនុវត្តក្នុងតុលាការកម្ពុជា និងត្រូវទទួលយកជាភស្តុតាងនៃអត្តសញ្ញាណផងដែរនូវសេចក្តីថ្លែង-ការណ៍នានាតាមទម្រង់ណាមួយ ឬទម្រង់ផ្សេងទៀតដែលបានចេញដោយអ្នកភូមិចាស់ទុំ ឬមេភូមិជាដើម។

**ង. តើពាក្យសុំដែលមានលក្ខណៈវិនិច្ឆ័យទូលំទូលាយជាងមុន សម្រាប់ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ះពាល់ដល់តុល្យភាពនៃសិទ្ធិរបស់ភាគីដទៃទៀតដែលពាក់ព័ន្ធក្នុងដំណើរការនីតិវិធីឬទេ?**

៩៦. អ.ប.ជ កត់សម្គាល់ឃើញថា គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺ៖ ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយគាំទ្រដល់ការចោទប្រកាន់ទោស និង ខ) ស្វែងរកសំណងរួម និងសំណងផ្លូវចិត្ត ដូចមានចែងក្នុងវិធាន២៣*ស្ទួនបី*[១៣០]។

**ការចូលរួមក្នុងដំណើរការនីតិវិធី៖**

៩៧. អ.ប.ជ កត់សម្គាល់ឃើញថា អ.វ.ត.ក តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការត្រូវបានកំហិតដូចតទៅ៖ ក្នុងនាមជាសមាជិកនៃក្រុមរួមមួយ ពួកគេអាចកោះអញ្ជើញសាក្សីដែលមិនមានឈ្មោះនៅក្នុងបញ្ជីដែលសហព្រះរាជអាជ្ញាបានផ្តល់ជូនបាន[១៣១] ពួកគេអាចអញ្ជើញឱ្យផ្តល់

---

[១៣០] វិធាន២៣ នៃវិធានផ្ទៃក្នុង។

[១៣១] វិធាន៨០(២) នៃវិធានផ្ទៃក្នុង។

សក្ខីកម្មដោយអង្គជំនុំជម្រះសាលាដំបូង[១៣២] តាមរយៈមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអាចទទួលការអនុញ្ញាតឱ្យសួរសំណួរ ឬជំទាស់ទៅនឹងការស្តាប់សក្ខីកម្មរបស់សាក្សីណាម្នាក់ ប្រសិនបើគេយល់ថា សក្ខីកម្មបែបនេះមិនបាននាំពន្លឺដល់ការស្វែងរកការពិតទេនោះ។ បើតាមសិទ្ធិដែលដើមបណ្តឹងរដ្ឋប្បវេណីមានក្នុងដំណើរការនីតិវិធីនៅ អ.វ.ត.ក នោះ ពួកគេពុំមានឥទ្ធិពលដោយផ្ទាល់លើការសម្រេចដែលជះឥទ្ធិពលផ្ទាល់ និងផ្ទុយចំពោះជំហររបស់ជនជាប់ចោទ ដូចជាថាត្រូវយកទៅជំនុំជម្រះទោសទៅឬក៏អត់នោះ ពួកគេមិនមានសំឡេងនៅក្នុងការកែប្រែបទចោទ ឬទាក់ទិននឹងសេចក្តីសម្រេចក្នុងការធ្វើសវនាការរួមគ្នា ឬដាច់ដោយឡែកពីគ្នា ឬ ទៅលើពិរុទ្ធភាពនោះឡើយ។ អង្គបុរេជំនុំជម្រះពិចារណាថា លក្ខណៈរួមនៃការតំណាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងគោលបំណងធម្មតានៃបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលសវនាការនៅចំពោះមុខ អ.វ.ត.ក នោះ មិនបានគាំទ្រដល់បញ្ហាដែលថា ការទទួលយកប្រជាជនក្នុងចំនួនដ៏ច្រើនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចប៉ះពាល់ជាអវិជ្ជមានទៅលើសិទ្ធិរបស់ជនជាប់ចោទឡើយ។

### សំណងក្នុងករណីមានការផ្តន្ទាទោស៖

៩៨. វិធាន២៣*ស្ទួនបួន*ចែងថា៖

"**បណ្តឹងទាមទារសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

១. នៅពេលដែលអង្គជំនុំជម្រះរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្តល់ឱ្យតែ*សំណងផ្លូវចិត្ត* និង*ជាសមូហភាព*ទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណី*តែប៉ុណ្ណោះ*។ តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និងសមូហភាព គឺជាវិធានការទាំងឡាយដែល៖

ក) ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស និង

ខ) ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងការខូចខាតនេះ។ ផលប្រយោជន៍ទាំងនេះ មិនត្រូវមានទម្រង់នៃសំណងជាប្រាក់ដល់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

២. សំណងត្រូវតែស្នើឡើងជាសេចក្តីសន្និដ្ឋានរួមតែមួយ ដែលសេចក្តីសន្និដ្ឋាននេះ អាចធ្វើការទាមទារសំណងមួយចំនួនមានកំណត់។ សេចក្តីសន្និដ្ឋាននេះត្រូវផ្តល់នូវ៖

ក) ការពិពណ៌នាអំពីសំណងដែលត្រូវទាមទារ។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

---

[១៣២] វិធាន៩១ នៃវិធានផ្ទៃក្នុង។

ខ) ទម្រង់ករណ៍សមហេតុផលដូចជា ការលើកពីការខូចខាតដែលពួកគេទទួលរង និងក្នុងករណី ដែលអាចអនុវត្តបាន បញ្ជាក់អំពីក្រុមដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុមរួមដែលពួកគេជាប់ពាក់-ព័ន្ធ។

គ) ទម្រង់នៃការអនុវត្តជាក់លាក់តែមួយលើសំណងនីមួយៗ ដែលមានចែងក្នុងវិធាន ២៣*ក្វួនបួន*(៣)(ក), (ខ) ដែលទាមទារ។

៣. នៅពេលសម្រេចអំពីបែបបទនៃការអនុវត្តសំណងពាក់ព័ន្ធនឹងសំណងនីមួយៗ អង្គជំនុំជម្រះអាច៖

ក) បង្គាប់ថា សោហ៊ុយនៃសំណងត្រូវតែជាបន្ទុករបស់ពិរុទ្ធជន ឬ

ខ) ទទួលស្គាល់នូវគម្រោងជាក់លាក់ដែលមានលក្ខណៈសមស្របឆ្លើយតបទៅនឹងសំណង ដែលទាមទារដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយអាចអនុវត្តបាន។ គម្រោងបែបនេះនឹងត្រូវបានគេបង្កើតឡើង ឬ បង្ហាញច្បាស់លាស់ដោយសហការជាមួយអង្គភាពគាំពារជនរងគ្រោះ ហើយបានធានានូវការផ្តល់មូលនិធិគ្រប់គ្រាន់ពីខាងក្រៅ"។

៩៩. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សិទ្ធិដែលដើមបណ្តឹងរដ្ឋប្បវេណីមានក្នុងករណីមានការផ្តន្ទាទោស ដែលអាចប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិរបស់ជនជាប់ចោទគឺថា ដើម្បីស្វែងរកនៅក្នុង "សារណាតែមួយ" "ទាក់ទិននឹងការទាមទារនីមួយៗ វិធីជាក់លាក់តែម្តងនៃការអនុវត្ត" ការទាមទារនោះ ដែលអាចរួមមាន "ដីកាសម្រេចដែលថា សោហ៊ុយនៃសំណងជាបន្ទុករបស់ទណ្ឌិត"។ បញ្ហានេះមិនទាក់ទិននឹងសោហ៊ុយនៃសំណងទេ តែទាក់ទិននឹងអង្គហេតុដែលថា ក្នុងនាមជាសមាជិក "ឋានៈ" រួម ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិស្នើសុំសំណងផ្លូវចិត្តបាន។ នេះជាសិទ្ធិដែលកើតចេញពីហេតុការណ៍របស់អ្នកដែលបានចូលរួមក្នុងដំណើរការនីតិវិធី ហើយវាមិនមែនជាបញ្ហាតុល្យភាពប្រឆាំងនឹងជំហររបស់ជនជាប់ចោទទេ។

## IX. <u>**ការវាយតម្លៃជាលក្ខណៈបុគ្គលនៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖**</u>

១០០. អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យឡើងវិញសាជាថ្មី នូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ដែលបានដាក់ជូនអង្គបុរេជំនុំជម្រះ តាមរយៈបណ្តឹងឧទ្ធរណ៍។ សំអាងហេតុពេញលេញសម្រាប់ការបដិសេធ ឬការទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ នឹងត្រូវដាក់ជូនដាច់ដោយឡែក ក្នុងលក្ខណៈជាឯកសារភ្ជាប់ជាមួយនឹងសាលដីកានេះ។

១០១. ដោយសារតែពួកគាត់មានព័ត៌មានសំខាន់ៗ ទាក់ទងទៅនឹងអង្គហេតុដែលបានកើតឡើង ក្នុងចន្លោះ

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ហើយកើតមានឡើងនៅក្នុងដែនដីនៃកម្ពុជាប្រជាធិបតេយ្យ ពាក្យសុំរបស់អ្នកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយណា ដែលត្រូវបានបដិសេធ ត្រូវបានរក្សាទុកនៅក្នុងសំណុំរឿង ០០២ ក្នុងនាមជាអ្នកប្ដឹង ដូចដែលសហចៅក្រមស៊ើបអង្កេតបានបង្ហាញនៅក្នុងដីកាសម្រេចរបស់ខ្លួនផងដែរ។

## X. បទបញ្ញត្តិ

### ហេតុដូច្នេះអង្គបុរេជំនុំជម្រះសម្រេចដូចតទៅនេះ៖

ក. ប្រកាសជាឯកច្ឆន្ទថា បណ្ដឹងឧទ្ធរណ៍ទាំងនេះ អាចទទួលយកបាន

ខ. ច្រានចោលជាឯកច្ឆន្ទ នូវដីកាដែលរងការជំទាស់របស់សហចៅក្រមស៊ើបអង្កេត ត្រង់ចំណុចដែលពាក់ព័ន្ធនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដូចមានក្នុងតារាងបញ្ជីខាងក្រោម ហើយទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នោះ ព្រមទាំងផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណីដល់ពួកគាត់ សម្រាប់សំណុំរឿង ០០២។

| | | |
|---|---|---|
| **Appeals against Impugned Order D411 (Kampong Speu Province)**[១៣៣] | | |
| **PTC 76**[១៣៤] | | |
| 08-VU-01222 (D22/1401) | 08-VU-01227 (D22/1411) | 08-VU-01306 (D22/1013) |
| 09-VU-02516 (D22/2288) | 09-VU-02517 (D22/2289) | 09-VU-02521 (D22/2293) |
| 09-VU-03309 (D22/2318) | 09-VU-3310 (D22/2319) | 09-VU-03311 (D22/2320) |
| 09-VU-03314 (D22/2323) | 09-VU-03318 (D22/2327) | 09-VU-3323 (D22/2331) |
| 09-VU-03331 (D22/2337) | 09-VU-03349 (D22/2353) | 09-VU-03350 (D22/2354) |
| 09-VU-03358 (D22/2362) | 09-VU-03393 (D22/2395) | 09-VU-03395 (D22/2397) |
| 09-VU-03429 (D22/2424) | 09-VU-03455 (D22/3164) | 09-VU-03461 (D22/3170) |
| 09-VU-04172 (D22/2463) | 09-VU-04178 (D22/2469) | 09-VU-04187 (D22/2473) |
| 09-VU-04189 (D22/3583) | 10-VU-00026 (D22/2505) | 10-VU-00404 (D22/3822) |
| 08-VU-01483 (D22/1752) | 09-VU-01052 (D22/1545) | 09-VU-01502 (D22/0785) |
| 09-VU-04191 (D22/3585) | 09-VU-03312 (D22/2321) | |
| **PTC 172**[១៣៥] | | |
| 08-VU-01347 (D22/383) | 09-VU-01417 (D22/0843) | 08-VU-01460 (D22/1723) |

---

[១៣៣] ដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពង់ស្ពឺ លេខ D411,ចុះថ្ងៃទី 9 ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដែលរងការចោទប្រកាន់ D411").

[១៣៤] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការមិនទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពង់ស្ពឺ លេខ D411,ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ("PTC 76") ។

[១៣៥] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពង់ស្ពឺ លេខ D411/5/1,ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ("PTC172") ។

| | | |
|---|---|---|
| 09-VU-01422 (D22/1860) | 08-VU-01303 (D22/364) | |
| **Appeals against Impugned Order D419 (Kampot Province)**[១៣៦] | | |
| **PTC 112**[១៣៧] | | |
| 09-VU-03389 (D22/2392) | 09-VU-01186 (D22/1490) | 08-VU-01858 (D22/1946) |
| 09-VU-04181 (D22/3577) | | |
| **PTC 113**[១៣៨] | | |
| 09-VU-01336 (D22/0647) | 09-VU-01317 (D22/0636) | |
| **PTC 114**[១៣៩] | | |
| 08-VU-00820 (D22/448) | 08-VU-01553 (D22/385) | 08-VU-01775 (D22/1500) |
| 08-VU-01776 (D22/388) | 08-VU-01783 (D22/919) | 08-VU-01787 (D22/1501) |
| 08-VU-01789 (D22/923) | 08-VU-01833 (D22/225) | 09-VU-00576 (D22/1982) |
| 09-VU-03790 (D22/3441) | 09-VU-03870 (D22/3521) | 09-VU-03874 (D22/3525) |
| 09-VU-03876 (D22/3527) | 09-VU-03880 (D22/3530) | 09-VU-03882 (D22/3532) |
| 09-VU-03896 (D22/3546) | 09-VU-04254 (D22/3640) | 09-VU-04257 (D22/3643) |
| 09-VU-03793 (D22/3444) | 08-VU-01785 (D22/921) | 08-VU -01844 (D22/224) |
| 08-VU-02184 (D22/478) | 08-VU-02370 (D22/1147) | 09-VU-00059 (D22/1720) |
| 09-VU-00060 (D22/1719) | 09-VU-00572 (D22/2080) | 09-VU-00573 (D22/1979) |
| 09-VU-00575 (D22/221) | 09-VU-00619 (D22/l978) | 09-VU-00621 (D22/900) |
| 09-VU-00723 (D22/830) | 09-VU-03773 (D22/3424) | 09-VU-03783 (D22/3434) |
| 09-VU-03796 (D22/3447) | 09-VU-03794 (D22/3445) | 09-VU-03864 (D22/3515) |
| 09-VU-03871 (D22/3522) | 09-VU-03875 (D22/3526) | 09-VU-03878 (D22/3528) |
| 09-VU-03883 (D22/3533) | 09-VU-03885 (D22/3535) | 09-VU-03890 (D22/3540) |
| 09-VU-03892 (D22/3542) | 09-VU-04240 (D22/3626) | 09-VU-04244 (D22/3630) |
| 09-VU-04253 (D22/3639) | 09-VU-04262 (D22/3648) | 08-VU-01778 (D22/945) |
| 09-VU-00055 (D22/531) | 09-VU-00622 (D22/1502) | |
| **PTC 115**[១៤០] | | |
| 09-VU-03797 (D22/3448) | 09-VU-00261 (D22/1970) | 09-VU-00262 (D22/1459) |

---

[១៣៦] ដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពត លេខ D419,ចុះថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១០ (“ដីកាដែលរងការជំទាស់ D419”).

[១៣៧] បណ្ដឹងឧទ្ធរណ៍របស់ក្រុមមេធាវីបារាំងប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពត លេខ D419, ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០, D419/2/1 (“PTC112”) ។

[១៣៨] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពត ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១០, D419/5/1 (“PTC113”) ។

[១៣៩] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពត *(52 requérants) Table des sources* (ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០, D419/7/1 (“PTC113”) ។ ទោះបី លេខយោង តារាងនៃចំណងជើងឯកសារក៏ដោយ វាមានខ្លួវបណ្ដឹងឧទ្ធរណ៍ដែលតារាងនោះមានក្នុងឯកសារដែលមានឈ្មោះ បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពត *(52 requérants) Table des sources* (ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០, D419/7/1.1 («Appeal PTC 114 »).

[១៤០] បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្ដីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មកពីខេត្តកំពត (23 Applicants)*Table des sources* (ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០១០, D419/8/1 (“Appeal PTC 115”).

| | | |
|---|---|---|
| 09-VU-03761 (D22/3412) | 08-VU-01832 (D22/1943) | 09-VU-03863 (D22/3514) |
| 09-VU-00062 (D22/1673) | 09-VU-01426 (D22/1915) | 09-VU-02063 (D22/3024) |
| 08-VU-01828 (D22/1200) | 09-VU-01427 (D22/1916) | 09-VU-00703 (D22/1605) |
| **PTC157**[១៦១] | | |
| 08-VU-02160 (D22/0098) | 08-VU-02163 (D22/0215) | 09-VU-00329 (D22/1815) |
| **PTC 164**[១៦២] | | |
| 09-VU-01756 (D22/2169) | | |
| **PTC 165**[១៦៣] | | |
| 09-VU-00926 (D22/1253) | 09-VU-03359 (D22/2363) | 09-VU-2104 (D22/2200) |

គ. ច្រានចោលដោយសំឡេងគាំទ្រភាគច្រើនពីចៅក្រមចំនួនបួនរូប ដោយមានមតិជំទាស់ ពីចៅក្រម Marchi-Uhel នូវដីកាដែលរងការជំទាស់របស់សហចៅក្រមស៊ើបអង្កេត ត្រង់ចំណុចដែលពាក់ព័ន្ធនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងតារាងដូចខាងក្រោម ហើយទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ ព្រមទាំងផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីដល់ពួកគាត់ សម្រាប់សំណុំរឿង ០០២។

| **Appeals against Impugned Order D411 (Kampong Speu Province)** | | |
|---|---|---|
| **PTC 76** | | |
| 09-VU-03394 (D22/2396) | 09-VU-02519 (D22/2291) | 09-VU-02520 (D22/2292) |
| 09-VU-03397 (D22/3146) | 08-VU-01533 (D22/0408) | 09-VU-03462 (D22/3171) |
| 09-VU-03430 (D22/2425) | 08-VU-02024 (D22/0372) | 09-VU-04176 (D22/2467) |
| 09-VU-03431 (D22/2426) | 08-VU-02026 (D22/1025) | 09-VU-04184 (D22/3579) |
| 09-VU-03433 (D22/2427) | 08-VU-02037 (D22/0361) | 08-VU-00227 (D22/1298) |
| 09-VU-03453 (D22/3162) | 08-VU-02335 (D22/0474) | 08-VU-00248 (D22/1375) |
| 09-VU-03454 (D22/3163) | 08-VU-02340 (D22/386) | 08-VU-00666 (D22/363) |
| 09-VU-03457 (D22/3166) | 08-VU-02341 (D22/0407) | 08-VU-01178 (D22/387) |
| 09-VU-03458 (D22/3167) | 08-VU-02345 (D22/1141) | 08-VU-01295 (D22/373) |
| 09-VU-03826 (D22/3477) | 08-VU-02347 (D22/0413) | 08-VU-01298 (D22/1012) |
| 09-VU-04153 (D22/3560) | 08-VU-02348 (D22/1142) | 08-VU-01303 (D22/0428) |
| 09-VU-04174 (D22/2465) | 09-VU-00014 (D22/0473) | 08-VU-01342 (D22/0914) |
| 09-VU-04183 (D22/3578) | 09-VU-00016 (D22/1176) | 08-VU-01457 (D22/1768) |
| 09-VU-04186 (D22/3581) | 09-VU-00017 (D22/0499) | 08-VU-01485 (D22/1731) |
| 09-VU-00348 (D22/3773) | 09-VU-00162 (D22/0617) | 08-VU-01486 (D22/1730) |

---

[១៦១] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មកពីខេត្តកំពត (D419),ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១០, D419/10/1 ("Appeal PTC 157").

[១៦២] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មកពីខេត្តកំពត (D419), ចុះថ្ងៃទី ២ វិច្ឆិកា ឆ្នាំ ២០១០, D419/11/1 ("Appeal PTC 164").

[១៦៣] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មកពីខេត្តកំពត (D419), ចុះថ្ងៃទី ២ វិច្ឆិកា ឆ្នាំ ២០១០, D419/12/1 ("Appeal PTC 165").

| | | |
|---|---|---|
| 09-VU-00469 (D22/3827) | 09-VU-01048 (D22/1688) | 08-VU-01514 (D22/0768) |
| 09-VU-01059 (D22/2087) | 09-VU-01051 (D22/1547) | 09-VU-03326 (D22/2334) |
| 09-VU-01060 (D22/1430) | 09-VU-01054 (D22/1548) | 09-VU-03328 (D22/2335) |
| 09-VU-01411 (D22/1849) | 09-VU-01055 (D22/1550) | 09-VU-03330 (D22/3140) |
| 09-VU-01413 (D22/1848) | 09-VU-01057 (D22/1551) | 09-VU-03339 (D22/2343) |
| 09-VU-01910 (D22/2897) | 09-VU-02431 (D22/2210) | 09-VU-03341 (D22/D2345) |
| 09-VU-01911 (D22/2898) | 09-VU-02432 (D22/2211) | 09-VU-03344 (D22/2348) |
| 09-VU-01912 (D22/2899) | 09-VU-02433 (D22/2212) | 09-VU-03345 (D22/2349) |
| 09-VU-01915 (D22/2902) | 09-VU-02434 (D22/2213) | 09-VU-03347 (D22/2351) |
| 09-VU-01916 (D22/2903) | 09-VU-02435 (D22/2214) | 09-VU-03348 (D22/2352) |
| 09-VU-01917 (D22/2904) | 09-VU-02514 (D22/2286) | 09-VU-03351 (D22/2355) |
| 09-VU-01918 (D22/2905) | 09-VU-02518 (D22/2290) | 09-VU-03352 (D22/2356) |
| 09-VU-01919 (D22/2906) | 09-VU-02428 (D22/2208) | 09-VU-03353 (D22/2357) |
| 09-VU-02427 (D22/2207) | 09-VU-03316 (D22/2325) | 09-VU-03354 (D22/2358) |
| 09-VU-02430 (D22/2209) | 09-VU-03319 (D22/2328) | 09-VU-03356 (D22/2360) |
| 09-VU-03321 (D22/2329) | 09-VU-03324 (D22/2332) | |
| **PTC 142**[១៦៦] | | |
| 08-VU-01230 (D22/2046) | 08-VU-01443 (D22/1798) | 08-VU-01228 (D22/1400) |
| 08-VU-01293 (D22/0437) | 08-VU-01550 (D22/1045) | 08-VU-01229 (D22/1409) |
| 08-VU-01300 (D22/1658) | 08-VU-02052 (D22/0946) | 08-VU-01231 (D22/1404) |
| **Appeals against Impugned Order D419 (Kampot)** | | |
| **PTC 112** | | |
| 09-VU-00777 (D22/0552) | 09-VU-03380 (D22/2383) | 08-VU-02364 (D22/0466) |
| 09-VU-03391 (D22/2394) | 09-VU-00774 (D22/1114) | 09-VU-00505 (D22/0960) |
| 09-VU-03771 (D22/3422) | 09-VU-00775 (D22/1101) | 09-VU-01460 (D22/2713) |
| 09-VU-03788 (D22/3439) | 09-VU-00776 (D22/0553) | 09-VU-01750 (D22/2164) |
| 09-VU-03865 (D22/3516) | 09-VU-00780 (D22/0807) | 09-VU-00772 (D22/0555) |
| 09-VU-03879 (D22/3529) | 09-VU-00781 (D22/0806) | |
| 09-VU-04127 (D22/3551) | 09-VU-00782 (D22/0805) | 09-VU-03305 (D22/2314) |
| 09-VU-04129 (D22/2445) | 09-VU-00787 (D22/1627) | 09-VU-03308 (D22/2317) |
| 09-VU-04130 (D22/3552) | 09-VU-00790 (D22/1592) | 09-VU-03298 (D22/2307) |
| 09-VU-04131 (D22/2446) | 09-VU-00801 (D22/1449) | 09-VU-03300 (D22/2309) |
| 09-VU-04133 (D22/2447) | 09-VU-00803 (D22/1447) | 09-VU-03301 (D22/2310) |
| 09-VU-04135 (D22/3555) | 09-VU-00806 (D22/1523) | 09-VU-03304 (D22/2313) |
| 09-VU-04136 (D22/2448) | 09-VU-00808 (D22/1516) | 09-VU-03306 (D22/2315) |
| 09-VU-04137 (D22/3556) | 09-VU-00905 (D22/1117) | 09-VU-03360 (D22/2364) |
| 09-VU-04139 (D22/3557) | 09-VU-00907 (D22/1096) | 09-VU-03361 (D22/2365) |
| 09-VU-04140 (D22/2450) | 09-VU-01175 (D22/1493) | 09-VU-03363 (D22/2367) |
| 09-VU-04143 (D22/2453) | 09-VU-01176 (D22/1492) | 09-VU-03364 (D22/2368) |
| 09-VU-04144 (D22/2454) | 09-VU-01177 (D22/2698) | 09-VU-03365 (D22/2369) |
| 09-VU-04147 (D22/2457) | 09-VU-01179 (D22/1532) | 09-VU-03366 (D22/2370) |
| 09-VU-04149 (D22/2458) | 09-VU-01180 (D22/2699) | 09-VU-03368 (D22/2372) |
| 09-VU-04245 (D22/3631) | 09-VU-01181 (D22/1714) | 09-VU-03369 (D22/2373) |
| 09-VU-00770 (D22/1594) | 09-VU-01182 (D22/2700) | 09-VU-03371 (D22/2375) |
| 09-VU-00771 (D22/0556) | 09-VU-01184 (D22/1533) | 09-VU-03375 (D22/2379) |
| 09-VU-00772 (D22/0555) | 09-VU-01188 (D22/2701) | 09-VU-03376 (D22/3143) |
| 09-VU-00773 (D22/0554) | 09-VU-01189 (D22/2702) | 09-VU-03377 (D22/2380) |
| 09-VU-01327 (D22/0645) | 09-VU-01190 (D22/2703) | 09-VU-03378 (D22/2381) |

[១៦៦] បណ្តឹងឧទ្ធរណ៍សង្ខេប ប្រឆាំងនឹងដីកាសម្រេចស្តីពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មកពីខេត្តកំពង់ស្ពឺ (D411), 19 September 2010, D411/4/1 ("Appeal PTC 139").
សាលដីកាលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតស្តីពីភាព... ទំព័រទី ៧៧ អាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

| | | |
|---|---|---|
| 09-VU-01331 (D22/1887) | 09-VU-01191 (D22/2704) | 09-VU-03379 (D22/2382) |
| 09-VU-01332 (D22/1886) | 09-VU-01192 (D22/1489) | 09-VU-03381 (D22/2384) |
| 09-VU-01335 (D22/0646) | 09-VU-01307 (D22/0663) | 09-VU-03383 (D22/2386) |
| 09-VU-01338 (D22/1596) | 09-VU-01310 (D22/0660) | 09-VU-03385 (D22/2388) |
| 09-VU-01340 (D22/1881) | 09-VU-01311 (D22/0630) | 09-VU-03386 (D22/2389) |
| 09-VU-01424 (D22/0708) | 09-VU-01312 (D22/0631) | 09-VU-03387 (D22/2390) |
| 09-VU-01425 (D22/0709) | 09-VU-01313 (D22/0632) | 09-VU-01322 (D22/0641) |
| 09-VU-01319 (D22/0638) | 09-VU-01314 (D22/0633) | 09-VU-01323 (D22/0642) |
| 09-VU-01320 (D22/0639) | 09-VU-01318 (D22/0637) | 09-VU-01326 (D22/1889) |
| 09-VU-01433 (D22/0659) | 09-VU-01459 (D22/2128) | 09-VU-02107 (D22/2202) |
| 09-VU-01434 (D22/0658) | 09-VU-01461 (D22/2129) | 09-VU-02108 (D22/3062) |
| 09-VU-01435 (D22/1847) | 09-VU-01462 (D22/2130) | 09-VU-02109 (D22/3063) |
| 09-VU-01436 (D22/1846) | 09-VU-01465 (D22/2714) | 09-VU-02110 (D22/3064) |
| 09-VU-01438 (D22/1844) | 09-VU-01467 (D22/2716) | 09-VU-02111 (D22/2203) |
| 09-VU-01440 (D22/1843) | 09-VU-01468 (D22/2717) | 09-VU-02112 (D22/3065) |
| 09-VU-01442 (D22/1842) | 09-VU- 01752 (D22/2165) | 09-VU-02132 (D22/3066) |
| 09-VU-01445 (D22/1831) | 09-VU-01753 (D22/2166) | 09-VU-02237 (D22/3118) |
| 09-VU-01447 (D22/1830) | 09-VU-01754 (D22/2167) | 09-VU-02502 (D22/2278) |
| 09-VU-01448 (D22/1829) | 09-VU-01757 (D22/2170) | 09-VU-03285 (D22/2294) |
| 09-VU-01449 (D22/1828) | 09-VU-01761 (D22/2762) | 09-VU-03286 (D22/2295) |
| 09-VU-01452 (D22/2121) | 09-VU-01762 (D22/2763) | 09-VU-03287 (D22/2296) |
| 09-VU-01453 (D22/2122) | 09-VU-01763 (D22/2764) | 09-VU-03289 (D22/2298) |
| 09-VU-01454 (D22/2123) | 09-VU-01767 (D22/2766) | 09-VU-03293 (D22/2302) |
| 09-VU-01455 (D22/2124) | 09-VU-01769 (D22/2768) | 09-VU-03294 (D22/2303) |
| 09-VU-01456 (D22/2125) | 09-VU-01772 (D22/2771) | 09-VU-03296 (D33/2305) |
| 09-VU-01457 (D22/2126) | 09-VU-02105 (D22/3061) | 08-VU-01554 (D22/384) |
| 08-VU-01869 (D22/0731) | 09-VU-00065 (D22/1669) | 08-VU-01559 (D22/1007) |
| 08-VU-01870 (D22/2650) | 09-VU-00066 (D22/1664) | 08-VU-01846 (D22/2649) |
| 08-VU-01895 (D22/0467) | 09-VU-00070 (D22/1538) | 08-VU-01855 (D22/0733) |
| 08-VU-01927 (D22/0767) | 09-VU-00071 (D22/0955) | 09-VU-00769 (D22/0557) |
| 08-VU-01929 (D22/0950) | 09-VU-00072 (D22/1610) | 09-VU-00546 (D22/1106) |
| 08-VU-01931 (D22/0951) | 09-VU-00076 (D22/1035) | 09-VU-00548 (D22/1237) |
| 08-VU-02150 (D22/1765) | 09-VU-00249 (D22/1462) | 09-VU-00717 (D22/0835) |
| 09-VU-02154 (D22/1782) | 09-VU-00250 (D22/1037) | 09-VU-00719 (D22/0834) |
| 08-VU-02190 (D22/1948) | 09-VU-00252 (D22/1461) | 09-VU-00720 (D22/0833) |
| 08-VU-02191 (D22/1211) | 09-VU-00253 (D22/1038) | 09-VU-00724 (D22/0829) |
| 08-VU-02201 (D22/1054) | 09-VU-00255 (D22/1460) | 09-VU-00742 (D22/1115) |
| 08-VU-02204 (D22/1153) | 09-VU-00256 (D22/1040) | 09-VU-00744 (D22/1075) |
| 08-VU-02209 (D22/1727) | 09-VU-00257 (D22/1041) | 09-VU-00768 (D22/1546) |
| 08-VU-02361 (D22/1138) | 09-VU-00258 (D22/1042) | 09-VU-00348 (D22/1822) |
| 08-VU-02363 (D22/0464) | 09-VU-00259 (D22/1043) | 09-VU-00545 (D22/1076) |
| 08-VU-02366 (D22/0492) | 09-VU-00260 (D22/1044) | 09-VU-00064 (D22/1668) |
| 08-VU-02367 (D22/1144) | | |
| **PTC 113** | | |
| 08-VU-01561 (D22/1064) | 09-VU-01308 (D22/0662) | 08-VU-01790 (D22/1143) |
| 09-VU-00069 (D22/2671) | 09-VU-01316 (D22/0635) | 08-VU-01556 (D22/1006) |
| 09-VU-00254 (D22/1039) | 09-VU-0174 (D22/2172) | 09-VU-00788 (D22/1584) |
| 09-VU-00547 (D22/1133) | 09-VU-01337 (D22/1883) | 09-VU-00789 (D22/1593) |
| 09-VU-00549 (D22/1223) | 08-VU-02203 (D22/0420) | 08-VU-02368 (D22/0470) |
| 09-VU-00721 (D22/0832) | 10-VU-00833 (D22/3851) | 09-VU-01521 (D22/0791) |
| 09-VU-00802 (D22/1448) | 09-VU-01432 (D22/0760) | 08-VU-02365 (D22/465) |
| 09-VU-00805 (D22/2085) | 09-VU-01333 (D22/1885) | 09-VU-00216 (D22/1262) |
| 09-VU-01185 (D22/2093) | 09-VU-01309 (D22/0661) | 09-VU-01451 (D22/2120) |



PRE-TRIAL CHAMBER · E.C.C.C · C.E.T.C · CHAMBRE PRÉLIMINAIRE

| | | |
|---|---|---|
| 09-VU-00758 (D22/1488) | | |
| **PTC 114** | | |
| 09-VU-04252 (D22/3638) | 09-VU-00620 (D22/901) | |
| **PTC 115** | | |
| 08-VU-0827 (D22/1027) | 09-VU-03795 (D22/3446) | 09-VU-03792 (D22/3443) |
| 09-VU-00626 (D22/1443) | 08-VU-02199 (D22/1131) | 09-VU-01428 (D22/1917) |
| 09-VU-04251 (D22/3637) | 08-VU-00830 (D22/993) | 09-VU-01429 (D22/1918) |
| 09-VU-03869 (D22/3520) | 08-VU-01829 (D22/393) | |
| **PTC 157** | | |
| 08-VU-02155 (D22/1799) | 09-VU-00347 (D22/1797) | 09-VU-00328 (D22/1814) |
| 09-VU-00322 (D22/1795) | | |

ឃ. ច្រានចោលជាឯកច្ឆន្ទ នូវបណ្តឹងឧទ្ធរណ៍នេះ ត្រង់ចំណុចដែលពាក់ព័ន្ធនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចមានក្នុងបញ្ជីខាងក្រោម ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ ត្រូវបានបដិសេធរួចមកហើយ។

| **Appeal against Impugned Order D411 (Kampong Speu Province)** | | |
|---|---|---|
| **PTC 76** | | |
| 08-VU-02051 (D22/0360) | | |

ភ្នំពេញ ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១១

**អង្គបុរេជំនុំជម្រះ**

**Katinka LAHUIS** **ន័យ ថុល** **Catherine MARCHI-UHEL** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

**ក្រឡាបញ្ជី**

សរ ច័ន្ទរ៉ាត Ekela JOSIFI

គង់ ភារភាត Anne-Marie BURNS

**មតិជំទាស់របស់ចៅក្រម** Catherine Marchi Uhel

# យោបល់ជំទាស់ដោយឡែក និងមួយផ្នែក

# របស់លោកស្រីចៅក្រម CATHERINE MARCHI-UHEL

## សេចក្តីផ្តើម

១. ខ្ញុំបានអានសេចក្តីសម្រេចរបស់ចៅក្រមភាគច្រើន ("ចៅក្រមភាគច្រើន") នៅក្នុងបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាន ("ដីកាដែលរងការជំទាស់នីមួយៗ" និង "ដីកាដែលរងការជំទាស់ទាំងអស់") ដែលបានចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ("សហចៅក្រមស៊ើបអង្កេត") ពាក់ព័ន្ធនឹងជនរងគ្រោះទាំងអស់នោះ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ របស់ពួកគាត់ត្រូវបានយល់ឃើញថា មិនអាចទទួលយកបាន និងជាអ្នកដែលបានធ្វើបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅអង្គបុរេជំនុំជម្រះ ("អ្នកដាក់ពាក្យសុំ") ឬ "ម្ចាស់បណ្តឹងឧទ្ធរណ៍")។

២. ខ្ញុំយល់ស្របតាមចៅក្រមភាគច្រើនដែលថា បណ្តឹងឧទ្ធរណ៍ទាំងអស់អាចទទួលយកបាន។ ដូចដែលបានលម្អិតខាងក្រោម ទោះបីជាខ្ញុំពិចារណាឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំផ្នែកអង្គហេតុ និងមានការភ័ន្តច្រឡំរួមទាំងផ្នែកអង្គហេតុ និងអង្គច្បាប់ក៏ដោយ ក៏ខ្ញុំយល់ឃើញថា ការពិនិត្យបណ្តឹងឧទ្ធរណ៍*ជាថ្មីម្តងទៀត* ដែលធ្វើឡើងដោយចៅក្រមភាគច្រើន មិនត្រូវបានធានានោះទេ។ ផ្អែកតាមខ្លឹមសារបណ្តឹងឧទ្ធរណ៍ទាំងអស់នេះបានលើកឡើងនូវបញ្ហាសំខាន់ពីរ ទាក់ទិនទៅនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

៣. ផ្អែកតាមខ្លឹមសារបណ្តឹងឧទ្ធរណ៍ទាំងអស់នេះបានលើក ឡើងនូវបញ្ហាសំខាន់ពីរ ទាក់ទិនទៅនឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី។ បញ្ហាទីមួយ គឺជាបញ្ហានៃការបកស្រាយវិធានផ្ទៃក្នុង ទាក់ទិននឹងការបង្ហាញចំណងទាក់ទងរវាងព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួលរង និងបទឧក្រិដ្ឋមួយយ៉ាងតិចបំផុតក្នុង ចំណោមបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ។ ពាក់ព័ន្ធនឹងបញ្ហានេះ តាមការយល់ឃើញរបស់ខ្ញុំ ចៅក្រមភាគច្រើនមិនបានពិចារណាឲ្យបានត្រឹមត្រូវអំពីទំនាក់ ទំនងរវាងវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសេចក្តីសម្រេចចុងក្រោយស្តីពីភាពអាចទទួលយកបាន

របស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ អនុលោមតាមវិធានផ្ទៃក្នុង[១] "ជនរងគ្រោះ" សំដៅទៅលើរូបវន្តបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ។ ជនរងគ្រោះណាក៏ដោយ ក៏អាចដាក់ពាក្យបណ្តឹងទៅសហព្រះរាជអាជ្ញាបានដែរ អនុលោមតាមវិធាន ៤៩(២) នៃវិធានផ្ទៃក្នុង។ "ដើមបណ្តឹងរដ្ឋប្បវេណី" សំដៅទៅលើជនរងគ្រោះ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ។ ខ្ញុំឯកភាពជាមួយសហចៅក្រមស៊ើបអង្កេត និងចៅក្រមភាគច្រើនដែលថា អ្នកដាក់ពាក្យសុំភាគច្រើនដែលពាក្យសុំរបស់ខ្លួនត្រូវបានប្រកាសមិនទទួលស្គាល់នៅក្នុងដីកានានា ដែលរងការជំទាស់បានបង្ហាញថា វាទំនងឱ្យជឿបានថា ពួកគាត់បានទទួលរងព្យសនកម្មដែលជាផលវិបាកផ្ទាល់នៃបទឧក្រិដ្ឋយ៉ាងតិចមួយ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។ អ្នកដាក់ពាក្យសុំទាំងអស់នេះអាចត្រូវបានចាត់ទុកថាជាជនរងគ្រោះ តាមអត្ថន័យនៃវិធានផ្ទៃក្នុង។ ទោះបីជាយ៉ាងណាក៏ដោយ មិនមែនគ្រប់អ្នកដាក់ពាក្យសុំទាំងអស់បានបំពេញលក្ខខណ្ឌកំណត់នានា ដើម្បីឱ្យមានការពិចារណាទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួននោះទេ។ ជាពិសេស ចំណុចនេះគឺដូច្នេះ នៅពេលណាដែលបទឧក្រិដ្ឋ (នានា) ដែលពួកគាត់បានអះអាងថាបានបង្កឱ្យមានព្យសនកម្មដល់ពួកគាត់រៀងៗខ្លួននោះ មិនមែនជាបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់ទេ ហើយខ្ញុំមិនអាចយល់ស្របជាមួយនឹងខ្លឹមសារនៃសេចក្តីសម្រេចរបស់ចៅក្រមភាគច្រើន ពាក់ព័ន្ធនឹងបញ្ហានេះបានទេ។ ខ្ញុំពិចារណាឃើញថា ម្ចាស់បណ្តឹងឧទ្ធរណ៍ភាគច្រើនបានលើកឡើងពីបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត ដើម្បីឈានទៅសម្រេចគោលនយោបាយមួយ ឬច្រើនក្នុងចំណោមគោលនយោបាយនានា ហើយបើយោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការប្រព្រឹត្តបទឧក្រិដ្ឋដើម្បីសម្រេចគោលនយោបាយទាំងអស់នេះបង្កើតបានជាផ្នែកមួយនៃគោលបំណងរួម ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថាពិតជាបានចូលរួមចំណែក។ ជាការពិត យោងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ គោលបំណងរួមរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ("CPK") គឺដើម្បីបង្កើតបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅក្នុងប្រទេសកម្ពុជា តាមរយៈគ្រប់មធ្យោបាយចាំបាច់តាម

---

[១] វិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៦) ដែលបានធ្វើវិសោធនកម្ម នៅថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០។





PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

"សន្ទុះមហាលោតផ្លោះ" និងដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវពីខាងក្រៅ[២]។ ដើម្បីធ្វើឱ្យសម្រេចផែនការរួមនេះ មេដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា *ក្នុងចំណោមទង្វើនានា* បានរៀបចំបង្កើត និងអនុវត្តគោលនយោបាយទាំងប្រាំ ដូចខាងក្រោម: (១) ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារ ទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយទៅកាន់ទីជនបទមួយផ្សេងទៀត (២) ការបង្កើត និងការដាក់ឱ្យដំណើរការសហករណ៍ និងការដ្ឋាន (៣) ការអប់រំ "សមាសភាពមិនល្អ" និងការកម្ទេច "ខ្មាំង" ដែលត្រូវបានរកឃើញទាំងនៅក្នុង និងនៅក្រៅបក្ស (៤) ការចេញវិធានការជាពិសេសចំពោះក្រុមមនុស្សជាក់លាក់នានា ដូចជាជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិកជន និងអតីតអ្នករដ្ឋការនានានៃរបបសាធារណៈរដ្ឋខ្មែរ (រួមទាំងមន្ត្រីរាជការ អតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគាត់) និង (៥) ការដាក់បទបញ្ជាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍[៣]។ បន្ថែមពីលើនេះ ក្នុងចំណោមព្រឹត្តិការណ៍ដែលត្រូវបានលើកឡើងថា បានកើតឡើងកាន់តែច្រើនទៅៗស្របជាមួយនឹងបដិវត្តន៍ គោលនយោបាយទាំងអស់នេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានពណ៌នាពីព្រឹត្តិការណ៍ទ្រង់ទ្រាយធំនៃការបោសសម្អាតផ្ទៃក្នុង[៤]។ ទោះបីជាយ៉ាងណាក៏ដោយ ជាសំខាន់ ជនជាប់ចោទមិនត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋនីមួយៗ ឬបទឧក្រិដ្ឋទាំងអស់ដែលត្រូវបានលើកឡើងថា បានប្រព្រឹត្តដោយខ្មែរក្រហមនៅក្នុងរបបបក្សកុម្មុយនីស្តកម្ពុជានោះទេ ទោះបីជាផ្នែកមួយនៃគោលនយោបាយដែលបានលើកឡើងខាងលើ និង/ឬ ប្រឆាំងនឹងសមាជិកក្រុមនានាដែលត្រូវបានកំណត់ក៏ដោយ។ ជាពិសេស សម្រាប់បទឧក្រិដ្ឋភាគច្រើនដែលជនជាប់ចោទត្រូវបានចោទប្រកាន់ វិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានកំហិតត្រឹមតែបទឧក្រិដ្ឋនានា ដែលត្រូវបានប្រព្រឹត្តនៅក្នុងដំណាក់កាលជាក់លាក់ចំនួនបី នៃការផ្លាស់ទីប្រជាជនដោយបង្ខំ និងនៅតាមការដ្ឋាន សហករណ៍ មន្ទីរសន្តិសុខ និងកន្លែងប្រហារជីវិតមួយចំនួនដែលត្រូវបាន

---

[២] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៦។

[៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៥៧។

[៤] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩២ និងបន្តបន្ទាប់។



E.C.C.C. • C.E.T.C.
PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

រៀបរាប់[៥]។ ខ្ញុំជឿថា ចៅក្រមភាគច្រើនបានដឹងពីវិសាលភាពនេះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ទោះបីជាយ៉ាងណាក៏ដោយ តាមការយល់ឃើញរបស់ខ្ញុំ ការបកស្រាយវិធាន ផ្ទៃក្នុងរបស់ចៅក្រមភាគច្រើន ពាក់ព័ន្ធទៅនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺផ្ទុយទៅនឹងស្មារតីផង និងអត្ថន័យនៃវិធានផ្ទៃក្នុង ដែលបានលើកឡើងផង និងមានន័យស្មើនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នកទាំងឡាយ ដែលមិនបានលើកឡើងថា ខ្លួនបានទទួលរងនូវព្យសនកម្មដោយសារបទឧក្រិដ្ឋយ៉ាងតិចមួយក្នុងចំណោមបទឧក្រិដ្ឋនានាដែលជនជាប់ចោទត្រូវបានចោទប្រកាន់ឡើយ។ ដោយសារតែខ្ញុំមានការយល់ឃើញខុសពីចៅក្រមភាគច្រើនលើចំណុចនេះ ខ្ញុំមិនឯកភាពទេថា ដីកាដែលរងការជំទាស់គួរតែត្រូវបានបដិសេធ ពាក់ព័ន្ធនឹងការទទួលយកអ្នកដាក់ពាក្យសុំមួយចំនួន។ ខ្ញុំបន្ថែមនៅខាងចុង មតិយោបល់នេះនូវឧបសម្ព័ន្ធមួយដែលផ្តល់នូវមូលហេតុជាក់លាក់នានាទាក់ទងនឹងអង្គហេតុផ្ទាល់ខ្លួនរបស់អ្នកដាក់ពាក្យសុំម្នាក់ៗដែលបានលើកឡើង។

៤. តាមការយល់ឃើញរបស់ខ្ញុំ ការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីដែលមិនបានលើកឡើងថាទទួលរងព្យសនកម្មដោយសារបទឧក្រិដ្ឋយ៉ាងតិចមួយក្នុងចំណោមបទឧក្រិដ្ឋ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២ មិនគ្រាន់តែជាការប្រឆាំងនឹងស្មារតី និងអត្ថន័យរបស់វិធានផ្ទៃក្នុងប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវហានិភ័យមួយចំនួនទៀតផងដែរ ដូចជា ១) ប៉ះពាល់ដល់តួនាទីរបស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចងក្រងជាក្រុម នៅក្នុងសវនាការ ដែលធម្មានុរូបភាពរបស់ពួកគាត់កើតចេញផ្ទាល់មកពីអង្គហេតុដែលថា ពួកគាត់ទទួលរងការឈឺចាប់ដោយសារបទឧក្រិដ្ឋយ៉ាងតិចមួយក្នុងចំណោមបទឧក្រិដ្ឋនានា ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ និងដែលការចូលរួមរបស់ពួកគាត់មានបំណងគាំទ្រការចោទប្រកាន់អំពីបទឧក្រិដ្ឋទាំងអស់នេះ និងស្នើសុំសំណងសមូហភាព និងសំណងផ្លូវចិត្តសម្រាប់ព្យសនកម្មដែលបង្កឡើងដោយសារបទឧក្រិដ្ឋទាំងនេះ ២) ពន្យារនីតិវិធីដោយសារតែសហមេធាវីនាំមុខនឹងត្រូវកំណត់ផលប្រយោជន៍របស់ក្រុម ដែលសមាជិកក្រុមនោះទាំងអស់គ្នាមិន

[៥] សម្រាប់ការជំទាស់ទៅនឹងវិធីសាស្ត្រនេះ សូមមើលខាងក្រោម ការពិភាក្សាតាមមូលដ្ឋានទី៨ ទាក់ទិនទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារហេតុផលសាសនា និងមូលដ្ឋានទី១០ និងទី១១ ពាក់ព័ន្ធនឹងអំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

00709923



បានលើកឡើងពីបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់នោះទេ ហើយស្ថានភាពនេះ បង្កើតនូវសក្តានុពលនៃការប្រឈមមុខគ្នាដែលមិនចាំបាច់របស់ភាគីនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ៣) ធ្វើឲ្យខកខានដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបំពេញលក្ខខណ្ឌកំណត់នៃភាពអាចទទួលយកបាន ហើយនឹងជួបប្រទះការប្រឈមមុខគ្នាដែលនឹងពន្យារពេលសវនាការ និង ៤) ធ្វើឲ្យខកខានផងដែរដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយកដោយការភ័ន្តច្រឡំផ្អែកតាមអង្គហេតុដែលថា បទឧក្រិដ្ឋដែលពួកគាត់ជាជនរងគ្រោះផ្ទាល់ នឹងមិនត្រូវបានពិភាក្សានៅពេលសវនាការនោះទេ និងមិននាំឲ្យមានការផ្តន្ទាទោសនោះដែរ។

៥. ខ្ញុំសូមអះអាងថា មានមធ្យោបាយផ្សេងទៀតនៅក្នុងវិធានផ្ទៃក្នុងដែលបញ្ជាក់ពីផលប្រយោជន៍របស់ជនរងគ្រោះដែលមិនបានបំពេញលក្ខខណ្ឌកំណត់ ដើម្បីទទួលយកធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ ជាបឋម សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា វាទំនងឲ្យជឿបានថា ពួកគាត់បានទទួលរងព្យសនកម្ម ដែលជាផលវិបាកផ្ទាល់កើតចេញពីបទឧក្រិដ្ឋយ៉ាងតិចមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ទីពីរ ពាក់ព័ន្ធនឹងអ្នកដាក់ពាក្យសុំទាំងឡាយ ដែលខ្ញុំយល់ឃើញថាមិនអាចទទួលយកធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីបាន ខ្ញុំបានប្រឹងប្រែងលើកឡើងនូវមតិយោបល់នេះនៅក្នុងឧបសម្ព័ន្ធ ដើម្បីបញ្ជាក់ពីបទឧក្រិដ្ឋនីមួយៗដែលបានលើកឡើងដោយអ្នកដាក់ ពាក្យសុំទាំងអស់នេះដែលត្រូវបានអះអាងនៅក្នុងបណ្តឹងឧទ្ធរណ៍។ នេះមិនគ្រាន់តែជាការយល់ឃើញ ដើម្បីផ្តល់មតិយោបល់ដែលមានហេតុផលប៉ុណ្ណោះទេ ថែមទាំងដើម្បីទទួលស្គាល់ការឈឺចាប់ដែលបានរាយការណ៍ដោយអ្នកដាក់ពាក្យសុំទាំងអស់នេះផងដែរ។ ជាចុងក្រោយ ខុសពីសំណាងនានា ដែលអាចត្រូវបានអង្គជំនុំជម្រះសាលាដំបូងផ្តល់ឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចងក្រងជាក្រុម នៅក្នុងសំណុំរឿង ០០២ នៅក្នុងករណីដែលសវនាការនាំមកនូវការផ្តន្ទាទោសលើជនជាប់ចោទម្នាក់ ឬច្រើននាក់ វិធានការដែលបានចែងដោយវិធាន ១២*ស្ទួន*(៣) នៃ វិធានផ្ទៃក្នុង មានបំណងលើកឡើងពីផលប្រយោជន៍ទូលំទូលាយជាងរបស់ “ជនរងគ្រោះ” និង មិនកំហិតត្រឹមតែចំពោះដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ជាការពិត វិធាននេះប្រគល់ឲ្យផ្នែកគាំពារជនរងគ្រោះបង្កើត និងអនុវត្តកម្មវិធីនិងវិធានការនានា ក្រៅពីកម្មវិធី និងវិធានការដែលមានលក្ខណៈគតិយុត្តិដែល



អង្គបុរេជំនុំជម្រះ
E.C.C.C • C.E.T.C
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

បង្ហាញពីផលប្រយោជន៍របស់ជនរងគ្រោះទូលំទូលាយជាង រួមទាំងករណីសមស្របនៅក្នុងកិច្ចសហការជាមួយអង្គភាពរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដែលនៅក្រៅ អ.វ.ត.ក។ នៅពេលអនុម័តវិសោធនកម្មលើកទីប្រាំនៃវិធានផ្ទៃក្នុង អង្គចៅក្រមបានពិនិត្យមើលឡើងវិញយ៉ាងយកចិត្តទុកដាក់លើការប្រើប្រាស់ពាក្យថា “ជនរងគ្រោះ” និង “ដើមបណ្តឹងរដ្ឋប្បវេណី” នៅក្នុងវិធាននីមួយៗ ហើយខ្ញុំច្បាស់លាស់ថា វិធានការនានាដែលបានលើកឡើងដែលមិនមែនជារបស់តុលាការអាចមានវិសាលភាព និងផលប្រយោជន៍ទូលំទូលាយជាងចំពោះជនរងគ្រោះ ស្របជាមួយនឹងនីតិវិធីតុលាការ រួមទាំងចំពោះអ្នកទាំងឡាយណាដែលមិនមានលក្ខណៈសម្បត្តិជាដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំជឿជាក់ថា ពាក់ព័ន្ធនឹងជនរងគ្រោះ ដែលមិនបានលើកឡើងថាបានរងព្យសនកម្មដែលជាផលវិបាកផ្ទាល់ ដែលកើតចេញមកពីបទឧក្រិដ្ឋយ៉ាងតិចមួយ ដែលជនជាប់ចោទត្រូវបានចោទប្រកាន់ មធ្យោបាយដែលបានផ្តល់ដោយវិធាន ១២ *ស្ទួន*(៣) នៃវិធានផ្ទៃក្នុង គឺជាមធ្យោបាយសមស្របសម្រាប់លើកឡើងពីការឈឺចាប់នានារបស់ជនរងគ្រោះប្រភេទនេះ។ តាមការយល់ឃើញរបស់ខ្ញុំ មធ្យោបាយដែលត្រូវបានជ្រើសរើសដោយចៅក្រមភាគច្រើនមិនមែនជាមធ្យោបាយសមស្របនោះទេ។

៦. បញ្ហាសំខាន់ទីពីរដែលបណ្តឹងឧទ្ធរណ៍ទាំងអស់នេះបានលើកឡើង សំដៅលើវិធីដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើឱ្យអង្គជំនុំជម្រះនេះជឿជាក់ថា ខ្លួនបានទទួលរងព្យសនកម្មផ្លូវចិត្តដែលកើតឡើងដោយសារបទឧក្រិដ្ឋ (នានា) ដែលបានលើកឡើង។ ពាក់ព័ន្ធនឹងបញ្ហានេះ ទោះបីជាខ្ញុំត្រូវតែទទួលស្គាល់ថា ខ្ញុំមិនបានយល់ពេញលេញទេ ថាតើចៅក្រមភាគច្រើនចង់មានន័យយ៉ាងដូចម្តេច តាមរយៈសញ្ញាណនៃការធ្វើឱ្យរងគ្រោះ ដែលចៅក្រមភាគច្រើនយកធ្វើជាសំអាង និងតើជាក់ស្តែងវាអនុវត្តចំពោះអ្នកដាក់ពាក្យសុំរៀងៗខ្លួនរបៀបណា ខ្ញុំពិតជាឯកភាពថា សហចៅក្រមស៊ើបអង្កេតមានភាពតឹងរ៉ឹងខ្លាំងពេកនៅក្នុងវិធីសាស្ត្ររបស់ខ្លួន។ ខ្ញុំសូមពន្យល់ដូចខាងក្រោម អំពីមូលហេតុដែលខ្ញុំពិចារណាឃើញថា អ្នកដាក់ពាក្យសុំច្រើនជាងអ្នក ដែលសហចៅក្រមស៊ើបអង្កេតសម្រេចទទួលយកត្រូវទទួលផលប្រយោជន៍ពីការសន្មតទុកជាមុននៃព្យសនកម្មផ្លូវចិត្តនៅចំពោះមុខ អ.វ.ត.ក។ លើសពីនេះទៀត ដូចចៅក្រមភាគច្រើនដែរ ខ្ញុំពិចារណាឃើញថា កាលៈទេសៈដែលមាននៅ អ.វ.ត.ក សម្រាប់សំណុំរឿង 00២ ទាមទារឱ្យអង្គបុរេជំនុំជម្រះទទួលយកការថ្លែង ឬចំណុចពិសេស

នានាដែលបានមកពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើររឿងបណ្តឹងឧទ្ធរណ៍ នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

## I. មូលដ្ឋានរួម និងកំណត់សម្គាល់បឋមដែលពាក់ទងនៅនឹងមូលដ្ឋាននោះ

៧. អង្គបុរេជំនុំជម្រះបានទទួលបណ្តឹងឧទ្ធរណ៍ចំនួន៩៤ ដែលបណ្តឹងឧទ្ធរណ៍ទាំងនោះ មានមូលដ្ឋានច្រើន និងផ្សេងៗពីគ្នា។ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ភាគច្រើន ដែលចោទប្រកាន់ពីការភ័ន្តច្រឡំផ្នែកអង្គហេតុ ការភ័ន្តច្រឡំផ្នែកអង្គច្បាប់ និងការភ័ន្តច្រឡំរួមគ្នានៃអង្គច្បាប់ និងអង្គហេតុ ត្រូវបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍ជាច្រើន ទោះបីជាការរៀបចំអាចខុសគ្នាពីបណ្តឹងឧទ្ធរណ៍មួយទៅបណ្តឹងឧទ្ធរណ៍មួយទៀតក៏ដោយ ("មូលដ្ឋានរួម")។ អ្នកដាក់ពាក្យសុំទាំងអស់ មិនបានលើកឡើងនូវមូលដ្ឋានទាំងអស់ដូចមានរៀបរាប់នៅក្នុងមតិយោបល់ជំទាស់នេះទេ។ ក៏ប៉ុន្តែ ដោយផ្អែកលើ (១) ផលប្រយោជន៍រួមរបស់អ្នកដាក់ពាក្យសុំជាច្រើន (២) ការពិតដែលថាប្រព័ន្ធនៃការទទួលយកអ្នកដាក់ពាក្យសុំ ដូចមានចែងក្នុងវិធាននៃផ្ទៃក្នុង ហើយត្រូវបានបកស្រាយបន្ថែមដោយសហចៅក្រមស៊ើបអង្កេត ត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះគ្រប់អ្នកដាក់ពាក្យសុំ និង (៣) ជាពិសេស ស្របតាមការអនុវត្តរបស់សហមេធាវី ដែលច្រើនតែនិយាយយោងទៅលើចំណុចរណីនៃបណ្តឹងឧទ្ធរណ៍មួយ ទៅក្នុងបណ្តឹងឧទ្ធរណ៍មួយទៀតនោះ ជាពិសេសបណ្តឹងឧទ្ធរណ៍របស់សហមេធាវី ខ្ញុំយល់ស្របតាមចៅក្រមភាគច្រើន ដែលថា វាជាការសមស្របក្នុងការចេញមតិយោបល់មួយ ពាក់ព័ន្ធនឹងមូលដ្ឋានរួមទាំងអស់នេះ និងក្នុងការចេញហេតុផលនានាបន្ថែមទៀតជាទម្រង់នៃឧបសម្ព័ន្ធ សម្រាប់ករណីជាក់លាក់របស់អ្នកដាក់ពាក្យសុំនីមួយៗ ដោយធានាថា ការពិចារណាលើអង្គហេតុ និងអង្គច្បាប់ នៃពាក្យសុំនីមួយៗ និង/ឬបណ្តឹងឧទ្ធរណ៍នីមួយៗ ត្រូវបានធ្វើឡើងសព្វគ្រប់ជ្រុងជ្រោយ។ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ដែលនឹងលើកយកមកធ្វើការពិភាក្សានៅក្នុងមតិយោបល់នេះ គឺជាមូលដ្ឋានដែលត្រូវបានលើកឡើងក្នុងបណ្តឹងឧទ្ធរណ៍លើសពីមួយ ដែលបានដាក់ដោយសហមេធាវី។ ក្នុងករណីដែលសហមេធាវី បានដាក់សារណាដែលមានលក្ខណៈខុសប្លែកបន្តិចបន្តួច ទាក់ទងទៅនឹងមូលដ្ឋានដូចគ្នានៃបណ្តឹងឧទ្ធរណ៍នោះ ខ្ញុំបានដាក់បញ្ចូលសារណាទាំងនោះ តាមភាពសមស្រប ទៅក្នុងផ្នែកពិភាក្សារបស់ខ្ញុំអំពីមូលដ្ឋាននីមួយៗ ព្រមទាំងសារណាដែលបាន



E.C.C.C * C.E.T.C.
CHAMBER CHAMBRE PRÉLIMINAIRE

00709926



ធ្វើឡើងទាក់ទិនទៅនឹងមូលដ្ឋាននោះ។ នៅពេលដែលអង្គបុរេជំនុំជម្រះគ្មានកាតព្វកិច្ចត្រូវតែពិចារណាទៅលើទឡ្ហីករណ៍ទាំងឡាយណា ដែលមិនមានអង្គសេចក្ដី ឬមិនត្រូវបានសហមេធាវីលើកឡើងដោយសមស្របទេនោះ ខ្ញុំមិនបានលើកទឡ្ហីករណ៍ទាំងនោះនៅក្នុងមតិយោបល់ជំទាស់នេះទេ។ ដើម្បីធានាអំពីសមភាពនៃការប្រព្រឹត្តចំពោះអ្នកដាក់ពាក្យសុំទាំងអស់ដែលបានប្ដឹងឧទ្ធរណ៍លើការសម្រេចបដិសេធពួកគាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី និងវិធីសាស្ត្រដែលមាននៅក្នុងការគ្រប់គ្រងប្រព័ន្ធ នៃភាពអាចទទួលយកបានសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំបានពិនិត្យមើលឡើងវិញរាល់ពាក្យសុំទាំងអស់របស់បុគ្គលម្នាក់ៗ ស្របជាមួយនឹងសេចក្ដីសន្និដ្ឋាននានារបស់ខ្ញុំអំពីមូលដ្ឋានរួម។ ចំណុចនេះមានន័យថា នៅក្នុងករណីខ្លះ ទោះបីជាសហមេធាវីមិនបានលើកឡើងពីការភ័ន្តច្រឡំជាក់លាក់ណាមួយក៏ដោយ ឬបញ្ជាក់ន័យផ្សេងពីនេះក៏ដោយ ខ្ញុំបានអនុវត្តសំអាងហេតុនានារបស់ខ្ញុំចំពោះអ្នកដាក់ពាក្យសុំម្នាក់ៗ និងបានទទួលស្គាល់អ្នកដាក់ពាក្យសុំមួយចំនួន ដោយផ្អែកលើមូលដ្ឋាននានាដែលមិនត្រូវបានលើកឡើងដោយសហមេធាវីរបស់ពួកគាត់។

៨. ខ្ញុំយល់ឃើញថា មានមូលដ្ឋានរួមនានាដែលត្រូវបានលើកឡើង នៅក្នុងបណ្ដឹងឧទ្ធរណ៍នានាច្រើន ជាងមូលដ្ឋានមួយចំនួនដែលត្រូវបានជ្រើសរើសដោយចៅក្រមភាគច្រើន។ ហេតុដូច្នេះខ្ញុំនឹងពិចារណាលើមូលដ្ឋានរួមនីមួយៗដែលខ្ញុំបានបង្ហាញជាបន្តបន្ទាប់ ជាជាងធ្វើតាមរចនាសម្ព័ន្ធដែលបានអនុម័តដោយចៅក្រមភាគច្រើន ដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នា ក្នុងការបង្ហាញហេតុផល និងការដោះស្រាយរបស់ខ្ញុំលើបណ្ដឹងឧទ្ធរណ៍ទាំងអស់នេះ។

៩. ខាងក្រោមនេះគឺជាការភ័ន្តច្រឡំផ្នែកអង្គច្បាប់ ដែលត្រូវបានសង្ខេបដូចតទៅនេះ សម្រាប់ផ្ដល់ភាពងាយស្រួលក្នុងការយោង។

(១) មូលដ្ឋានទី១៖ សហចៅក្រមស៊ើបអង្កេតមិនបានផ្ដល់សេចក្ដីសម្រេចដោយមានសំអាងហេតុ ជាពិសេសក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតចេញ "ដីកាសម្រេចបដិសេធជារួម" ហើយនិងការបំពានទៅលើវិធាន២៣(៣) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ដែលជាការបំពានទៅលើតម្រូវការឱ្យមានដំណើរការនីតិវិធីប្រកបដោយភាពយុត្តិធម៌។

(២) មូលដ្ឋានទី២៖ ការដាក់កំហិតដោយភ័ន្តច្រឡំទៅលើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

(៣) មូលដ្ឋានទី៣៖ ការអនុវត្តដោយភ័ន្តច្រឡំរបស់សហចៅក្រមស៊ើបអង្កេតចំពោះវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) និងជាពិសេសគឺការអនុវត្តនូវការបកស្រាយដោយខុសឆ្គងទៅលើវិធាន២៣(១)(ខ) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) វិធាន២១(១), ២១(១)(ក)(គ) និង២៣(២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤ និងលើកមុន) ដែលនាំឲ្យមានការបំពានលើភាពយុត្តិធម៌នៃដំណើរការនីតិវិធី។

(៤) មូលដ្ឋានទី៤៖ ការកំណត់ដោយភ័ន្តច្រឡំទៅលើ "វិសាលភាពនៃកិច្ចស៊ើបសួរ" ដោយសហចៅក្រមស៊ើបអង្កេត ព្រមទាំងការអនុវត្តនូវការកំណត់នេះទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេសគឺការដាក់កំហិតនូវវិសាលភាពនៃកិច្ចស៊ើបសួរ តែត្រឹមកថាខណ្ឌ ៣៧ ដល់៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម តែប៉ុណ្ណោះ។

(៥) មូលដ្ឋានទី៥៖ ការបង្កើតដោយភ័ន្តច្រឡំនូវពាក្យ "ព្យសនកម្ម" និង "ផលប៉ះពាល់ដោយផ្ទាល់" តាមវិធាន ២៣(២)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤ និងលើកមុន) ព្រមទាំងវិធាន ២៣ស្ទួន(១)(ខ) (វិសោធនកម្មលើកទី៥) ដែលនាំឲ្យមានការបដិសេធចំពោះជនរងគ្រោះដែលទទួលរងព្យសនកម្ម ដែលជាផលប៉ះពាល់ដោយផ្ទាល់ពីការបានឃើញ ឬបានដឹងពីបទឧក្រិដ្ឋ ដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ឬស្ថិតក្រោមវិសាលភាពនៃកិច្ចស៊ើបសួរ។

១០. ខ្ញុំបានធ្វើការពិចារណាអំពីការភ័ន្តច្រឡំដែលរងការចោទប្រកាន់ ដែលមានជាពិសេសសម្រាប់តែអ្នកដាក់ពាក្យសុំម្នាក់ៗនៅក្នុងឧបសម្ព័ន្ធដែលភ្ជាប់ទៅនឹងមតិយោបល់ជំទាស់នេះ ប៉ុន្តែសម្រាប់ការភ័ន្តច្រឡំលើអង្គហេតុ ដែលសហមេធាវីបានលើកឡើងច្រើនដង នឹងត្រូវយកមកពិភាក្សានៅទីនេះ។ ការភ័ន្តច្រឡំលើអង្គហេតុទាំងនោះ ត្រូវបានកត់ត្រានៅខាងក្រោម ដោយប្រើចំណងជើងដែលជាការពណ៌នាទូទៅ លើការភ័ន្តច្រឡំដែលសហមេធាវីបានផ្តល់មកឲ្យ។ សេចក្តីសន្និដ្ឋានរបស់ខ្ញុំអំពីអង្គហេតុដែលរងការចោទ ត្រូវអនុវត្តចំពោះបណ្តឹងឧទ្ធរណ៍ទាំងអស់ដែលមានអង្គហេតុទាំងនោះ ហើយដែលទាក់ទិនទៅនឹងការភ័ន្តច្រឡំដែលរងការចោទ ដោយមិនគិតត្រឹមតែអង្គហេតុដែលសហចៅក្រមស៊ើបអង្កេត បានសម្រេចថាបដិសេធទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែសំអាងហេតុផ្សេងនោះឡើយ។ ការមិនបានរៀបរាប់នូវរាល់ការភ័ន្តច្រឡំផ្នែកអង្គហេតុដែលស្ថិតនៅក្នុងមូលដ្ឋានទាំងអស់ ដែលរក្សា



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

00709928



ទុកដោយសហចៅក្រមស៊ើបអង្កេត នឹងមិនប៉ះពាល់ដល់ការពិចារណារបស់ខ្ញុំ ទៅលើអង្គហេតុ និងការភ័ន្តច្រឡំដែលរងការចោទ ឬក៏ការសម្រេចជាស្ថាពរ ដែលធ្វើឡើងសម្រាប់អ្នកដាក់ពាក្យសុំម្នាក់ៗ ទៅលើបញ្ហាដូចគ្នានោះឡើយ។

(៦) មូលដ្ឋានទី៦៖ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានដោយភ័ន្តច្រឡំទៅលើអង្គហេតុ ទើបបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានដែលថាមិនមានព័ត៌មានគ្រប់គ្រាន់ ដែលតាមពិតទៅគឺមានព័ត៌មានគ្រប់គ្រាន់នៅក្នុងពាក្យសុំសម្រាប់ឱ្យសហចៅក្រមធ្វើការពិនិត្យវិនិច្ឆ័យ អនុលោមតាមវិធាន២៣ស្ទួន(១) និង(៤) នៃវិធានផ្ទៃក្នុង។ បញ្ហាទាំងនោះគឺផ្តោតចំពោះអ្នកដាក់ពាក្យសុំដែលចោទប្រកាន់ថា គាត់ត្រូវបានគេជម្លៀសដោយបង្ខំពីទីក្រុង ទៅទីជនបទ ហើយសហចៅក្រមស៊ើបអង្កេតបានទទួលនូវអង្គហេតុទាក់ទិនទៅនឹងការជម្លៀសបែបនេះ ពេលដែលខ្លួនបានទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពីសហព្រះរាជអាជ្ញា។

(៧) មូលដ្ឋានទី៧៖ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានដោយភ័ន្តច្រឡំទៅលើអង្គហេតុ ទើបបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានដែលថាមិនមានព័ត៌មានគ្រប់គ្រាន់ ដែលតាមពិតទៅគឺមានព័ត៌មានគ្រប់គ្រាន់នៅក្នុងពាក្យសុំសម្រាប់ឱ្យសហចៅក្រមធ្វើការពិនិត្យវិនិច្ឆ័យ អនុលោមតាមវិធាន២៣ស្ទួន(១) និង(៤) នៃវិធានផ្ទៃក្នុង។ បញ្ហាទាំងនោះគឺផ្តោតចំពោះព័ត៌មានមិនគ្រប់គ្រាន់ស្តីអំពីការសម្លាប់នៅទីកន្លែងផ្សេងៗទៀត ក្រៅពីទីកន្លែងដែលបានកត់ត្រា។

(៨) មូលដ្ឋានទី៨៖ សហចៅក្រមស៊ើបអង្កេតបានសម្រេចដោយភ័ន្តច្រឡំ ថាអ្នកដាក់ពាក្យសុំមិនបានបង្ហាញពីទំនាក់ទំនងសំខាន់រវាងព្យសនកម្ម ជាមួយនឹងបទឧក្រិដ្ឋប្រឆាំងនឹងជនជាប់ចោទនោះទេ។ ការនេះសំដៅចំពោះឧក្រិដ្ឋកម្ម ធ្វើទុក្ខបុកម្នេញខាងផ្លូវសាសនា។

(៩) មូលដ្ឋានទី៩៖ សហចៅក្រមស៊ើបអង្កេតបានធ្វើការសន្និដ្ឋានដោយភ័ន្តច្រឡំទៅលើអង្គហេតុ ទើបបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានដែលថាមិនមានព័ត៌មានគ្រប់គ្រាន់ ដែលតាមពិតទៅគឺមានព័ត៌មានគ្រប់គ្រាន់នៅក្នុងពាក្យសុំសម្រាប់ឱ្យសហចៅក្រមធ្វើការពិនិត្យវិនិច្ឆ័យ អនុលោមតាមវិធាន២៣ស្ទួន(១)



អង្គជំនុំជម្រះសាលាដំបូង
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C * C.E.T.C

និង(៤) នៃវិធានផ្ទៃក្នុង។ បញ្ហាទាំងនោះ គឺផ្តោតចំពោះអ្នកដាក់ពាក្យសុំដែលចោទប្រកាន់ថាគាត់បានទទួលរងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងទៅនឹងការបោសសម្អាតមន្ត្រីសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ។ ម៉្យាងវិញទៀតគឺថា សហចៅក្រមស៊ើបអង្កេតបានសម្រេចដោយភ័ន្តច្រឡំ ថាអ្នកដាក់ពាក្យសុំមិនបានបង្ហាញពីទំនាក់ទំនងសំខាន់រវាងព្យសនកម្ម ជាមួយនឹងបទឧក្រិដ្ឋប្រឆាំងនឹងជនជាប់ចោទនោះទេ។ ការនេះសំដៅចំពោះឧក្រិដ្ឋកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងនឹងការបោសសម្អាតមន្ត្រីសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគេ។

១១. ស្ថិតនៅត្រង់ចំណុចប្រសព្វនេះ ខ្ញុំសូមធ្វើការសង្កត់ធ្ងន់ថា បើទោះបីជាសហចៅក្រមស៊ើបអង្កេតបានដឹងខ្លឹមសារនៃដីកាដំណោះស្រាយ[៦] ដែលនឹងត្រូវចេញផ្សាយ នៅពេលដែលពួកគាត់បានចេញដីកាដែលរងការជំទាស់នេះក៏ដោយ ការនេះមិនមែនជាករណីរបស់អ្នកប្តឹងឧទ្ធរណ៍នោះឡើយ។ ដោយសារតែផ្នែក "ការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម" នៅក្នុងដីកាបញ្ជូនរឿងទៅ ជំនុំជម្រះ គឺមានលក្ខណៈលម្អិតខ្លាំងជាងផ្នែក "ឧក្រិដ្ឋកម្ម" នៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ដូច្នេះហើយទើបដីកាបញ្ជូនរឿងទៅជំនុំជម្រះមានរាល់សមាសធាតុដែលគាំទ្រដល់ការទាមទាររបស់ដើមបណ្តឹងឧទ្ធរណ៍ ដែលប្រើដើម្បីបង្ហាញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ក្នុងការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំបានធ្វើការពិចារណាទៅលើអង្គសេចក្តីរបស់បណ្តឹងឧទ្ធរណ៍ ដែលធ្វើឡើងដោយអ្នកដាក់ពាក្យសុំនីមួយៗ ដោយពិនិត្យមើលទៅលើស្ថានភាពជាក់លាក់របស់អ្នកដាក់ពាក្យសុំមួយរូបៗ ដោយផ្អែកទៅលើបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ព្រមទាំងចំណុចនានានៅក្នុងផ្នែកការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលទាក់ទងទៅនឹងបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់។ នៅក្នុងដំណាក់កាលស៊ើបសួរតាមផ្លូវតុលាការ សហចៅក្រម

---

[៦] ដោយសារតែដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេតមានការចោទប្រកាន់ និងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានោះត្រូវបានវិនិច្ឆ័យដោយអង្គបុរេជំនុំជម្រះ រីឯជនជាប់ចោទត្រូវបានចោទប្រកាន់ នៅក្នុងផ្នែកនៅសល់នៃមតិយោបល់ជំទាស់នេះ និងឧបសម្ព័ន្ធរបស់វា ខ្ញុំនឹងប្រើពាក្យថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅពេលចង់សំដៅទៅលើដីកាដំណោះស្រាយ លើកលែងតែតម្រូវការផ្សេងពីនេះ។

ស៊ើបអង្កេតមានសិទ្ធិអំណាចបង្រួមបទល្មើសដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា។ ហេតុដូច្នេះអង្គហេតុមួយចំនួន ដែលទាក់ទងទៅនឹងការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមាននៅក្នុងផ្នែក "បទល្មើស" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អាចត្រូវបានដកចេញពីក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ដោយសារតែមានការបង្រួមពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មកដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទើបវាមានផលប៉ះពាល់ដល់ការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលកំពុងប្តឹងដូច្នេះ។

១២. បន្ថែមពីលើកំណត់សម្គាល់បឋម ទាក់ទិនទៅនឹងបទល្មើស និងការភ័ន្តច្រឡំនៃអង្គហេតុដែលបានរៀបរាប់ក្នុងកថាខណ្ឌកន្លងមកហើយនេះ ខ្ញុំសូមកត់សម្គាល់ថា ជាចាំបាច់ត្រូវចងចាំថាបទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលរងការជំទាស់អនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះធ្វើការពិចារណាមិនត្រឹមតែលើបញ្ហាថាតើសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តការភ័ន្តច្រឡំផ្នែកអង្គហេតុ ឬអង្គច្បាប់ប៉ុណ្ណោះទេ តែថែមទាំងលើបញ្ហាថាតើបានប្រព្រឹត្តការភ័ន្តច្រឡំទាំងផ្នែកអង្គហេតុ និងអង្គច្បាប់ឬអត់ ក្នុងការបកស្រាយក៏ដូចជាការអនុវត្តលក្ខខណ្ឌសម្រាប់ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី។ សហចៅក្រមស៊ើបអង្កេតត្រូវបានណែនាំដោយវិធាន ១២, ១២*ស្ទួន*, ២១, ២៣, ២៣*ស្ទួន*, ២៣*ស្ទួនពីរ*, ៤៩, ៥៣, ៥៥, ៥៦(២)(ក), ៦៦ និង ១០០ នៃវិធានផ្ទៃក្នុង អ.វ.ត.ក (វិសោធនកម្មលើកទី៥) សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[៧] ព្រមទាំងសេចក្តីសម្រេចរបស់តុលាការ ឬអង្គជំនុំជម្រះនានា ដែលអនុញ្ញាតឲ្យមានជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីចូលរួម ដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតអាចប្រើប្រាស់នូវការណែនាំដែលមានក្នុងវិធានផ្ទៃក្នុង ចំពោះស្ថានភាពនៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន។ ខ្ញុំទទួលស្គាល់ថា ការងារនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតទាមទារឲ្យមានការទទួលយកទាំងលទ្ធផល ឬបទដ្ឋាន ព្រមទាំងសំអាងហេតុ ឬហេតុផលនៃលទ្ធផល ឬបទដ្ឋានរបស់អង្គជំនុំជម្រះទាំងនោះ ដើម្បីធ្វើការសម្រេចលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នេះ។ ខ្ញុំក៏សូមធ្វើការកត់សម្គាល់បន្ថែមទៀតថា ដោយសារតែជនរងគ្រោះមួយចំនួនដែលស្នះ

---

[៧] ដីកាដែលរងការជំទាស់ ទំព័រ ២ និងកថាខណ្ឌ ១៣, ១៥ និង ១៦ យោងក្រមព្រហ្មទណ្ឌកម្ពុជា មាត្រា ១៣ និង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("CPC") មាត្រា ១៣, ១៣៨ ដល់ ១៤២។

ស្វែងរកការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី មានស្ថានភាពពិសេស ទើបសហចៅក្រមស៊ើបអង្កេត ចាំបាច់ត្រូវធ្វើការសម្រេចក្នុងករណីជាច្រើន ដោយមិនមានព័ត៌មានគ្រប់គ្រាន់។ ក្រោយពីបានពិនិត្យទៅលើបណ្ដឹងឧទ្ធរណ៍រួចមក ខ្ញុំបានកត់សម្គាល់ថា ខាងក្រោមនេះបានបង្ហាញនូវការភ័ន្តច្រឡំផ្នែកអង្គច្បាប់ និងការភ័ន្តច្រឡំផ្នែកអង្គហេតុដែលអាចមាន ដែលបានកំណត់ដោយសហមេធាវី ឬដោយអង្គបុរេជំនុំជម្រះខ្លួនឯង ហើយខ្ញុំបានបរិយាយដូចនេះ៖

(៩) មូលដ្ឋានទី១០៖ ការប្រើប្រាស់ និងការអនុវត្តដោយភ័ន្តច្រឡំ នូវការសន្មតពីព្យសនកម្មផ្លូវចិត្តចំពោះសមាជិកគ្រួសារផ្ទាល់ និងសាច់ញាតិ នៃជនរងគ្រោះផ្ទាល់។

(១០) មូលដ្ឋានទី១១៖ សហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តដោយភ័ន្តច្រឡំ ទាក់ទិនទៅនឹងការសន្មតពីព្យសនកម្មផ្លូវចិត្ត ដែលត្រូវប្រើប្រាស់ចំពោះសមាជិកផ្ទាល់ នៃក្រុមគ្រួសារជនរងគ្រោះដោយការរៀបការដោយបង្ខំ។

## II. ~~អង្គសេចក្ដី~~: ការភ័ន្តច្រឡំផ្នែកអង្គច្បាប់

### មូលដ្ឋានទី១៖ ការមិនបានផ្ដល់សេចក្ដីសម្រេចដោយមានសំអាងហេតុ នាំឱ្យមានភាពអយុត្តិធម៌នៃដំណើរការនីតិវិធី

១៣. សហមេធាវីបានចោទប្រកាន់ថា ការណ៍ដែលសហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាបដិសេធរួម" គឺជាការភ័ន្តច្រឡំផ្នែកអង្គច្បាប់ ហើយរំលោភទៅលើវិធាន ២៣(៣) និង(៤) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៣) ក៏ដូចជាការរំលោភទៅលើកាតព្វកិច្ច ក្នុងការដំណើរការនីតិវិធីប្រកបដោយភាពយុត្តិធម៌ ដោយរួមបញ្ចូលការផ្ដល់សេចក្ដីសម្រេចដោយមានសំអាងហេតុ។ មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះ ត្រូវបានគាំទ្រដោយទឡ្ហីករណ៍ដូចតទៅនេះ។ ទីមួយ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានរិះគន់ទៅលើផ្នែកមួយចំនួននៃដីកាដែលរងការជំទាស់ ដូចជាកថាខណ្ឌ២២ និង២៤ ដោយរួមបញ្ចូលទាំងជើងទំព័រ ព្រមទាំងឧបសម្ព័ន្ធ៣ ដែលជាឧបសម្ព័ន្ធមួយរៀបរាប់ពីមូលដ្ឋានជាក់លាក់នៃមូលដ្ឋាន ដែលប្រើប្រាស់សម្រាប់បដិសេធអ្នកដាក់ពាក្យសុំនីមួយៗ។ សហមេធាវីបានបញ្ជាក់ថា ម្ចាស់បណ្ដឹងឧទ្ធរណ៍តម្រូវឱ្យធ្វើការទាយស្មានថាតើសំអាងហេតុទូទៅណាមួយនៅក្នុងកថាខណ្ឌ៤ ដល់កថាខណ្ឌ១៨ នៃដីកាដែលរង





អង្គបុរេជំនុំជម្រះ * E.C.C.C * C.E.T.C * PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

00709932



ការជំទាស់ អាចឬត្រូវអនុវត្តចំពោះពួកគេ។ បន្ថែមពីលើនេះទៀត សហមេធាវីបានបញ្ជាក់ថា កថាខណ្ឌ១៥ ដល់១៨ នៃដីកាដែលរងការជំទាស់ មិនអាចចាត់ទុកថាជា "សំអាងហេតុ" សម្រាប់បដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានឡើយ ហើយពួកគេបានបន្ថែមបន្តទៀតថា ដីកាដែលរងការជំទាស់មិនមានឯកសារយោងជាក់លាក់ណាមួយ ទៅលើព័ត៌មានលម្អិត ដែលផ្តល់ដោយអ្នកដាក់ពាក្យសុំនីមួយៗ ដូចមានក្នុងទម្រង់ព័ត៌មានជនរងគ្រោះ ក៏ដូចជាឯកសារព័ត៌មានបន្ថែមរបស់ពួកគាត់នីមួយៗឡើយ។

១៤. ខ្ញុំយល់ស្របជាមួយសហមេធាវី និងចៅក្រមភាគច្រើនថា ដីកាបដិសេធលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែមានសំអាងហេតុ។ សហមេធាវីបានកត់សម្គាល់ដោយត្រឹមត្រូវថា លក្ខខណ្ឌនេះ ដែលមានចែងយ៉ាងច្បាស់នៅក្នុងវិធានផ្ទៃក្នុង វិសោធនកម្មលើកមុន បែរជាមិនបានចែងឱ្យច្បាស់លាស់នៅក្នុងវិសោធនកម្មលើក៥ នៃវិធានផ្ទៃក្នុងទៅវិញ។ ទោះបីជាវិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មច្រើនដងក៏ដោយ ក៏លក្ខខណ្ឌក្នុងការផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចនៅតែមាន ហើយតម្រូវឱ្យភ្ជាប់ជាមួយដីកា ឬសេចក្តីសម្រេច ដែលភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍។ លក្ខខណ្ឌនេះនៅតែមាន គឺមួយផ្នែកដើម្បីជួយសម្របសម្រួលដល់បណ្តឹងឧទ្ធរណ៍របស់អ្នកដាក់ពាក្យសុំដែលពាក្យសុំរបស់ខ្លួនត្រូវបានបដិសេធ។ អ្នកដាក់ពាក្យសុំទាំងនេះត្រូវបានទទួលការជូនដំណឹងដោយលម្អិតនូវសំអាងហេតុនៃការបដិសេធ ហើយអាចធ្វើការសម្រេចចិត្តថាតើត្រូវប្តឹងឧទ្ធរណ៍ ឬអត់ ហើយបើប្តឹង តើប្តឹងលើមូលដ្ឋានអ្វី។ លក្ខខណ្ឌមួយនេះក៏ជួយឱ្យផ្នែកដែលទទួលពាក្យបណ្តឹងឧទ្ធរណ៍ អាចធ្វើការពិនិត្យលើបណ្តឹងឧទ្ធរណ៍ប្រកបដោយប្រសិទ្ធភាពផងដែរ[៨]។

១៥. ខ្ញុំមិនយល់ស្របជាមួយសហមេធាវី និងចៅក្រមភាគច្រើនដែលថា ដីកាដែលរងការជំទាស់មិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការសម្រេចបដិសេធលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហចៅក្រមស៊ើបអង្កេតបានធ្វើការបញ្ជាក់ហេតុផល ទៅលើ

[៨] សូមមើលឧទាហរណ៍ ពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ និងបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹង "ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១០" ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ D353/2/3 កថាខណ្ឌ ២៣។

ផ្នែកទាំងមូលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្រោមចំណងជើងថា “II. សំអាងហេតុសម្រាប់សេចក្តីសម្រេច”។ ផ្នែកនេះត្រូវបានបែងចែកជាពីរផ្នែក។ ផ្នែកទីមួយមានចំណងជើងថា “ គោលការណ៍ណែនាំ” ដែលក្នុងផ្នែកនេះសហចៅក្រមស៊ើបអង្កេតបានពណ៌នាពីកម្រិតនៃភស្តុតាង ព្រមទាំងកម្រិតនៃភាពគ្រប់គ្រាន់សម្រាប់ព័ត៌មានដែលតម្រូវឱ្យមាន។ ក្រៅពីនេះសហចៅក្រមស៊ើបអង្កេតបានរៀបរាប់ពីវត្តមាននៃព្យសនកម្ម ជាពិសេសព្យសនកម្មផ្លូវចិត្ត ព្រមទាំងទំនាក់ទំនងដែលបានកំណត់រវាងព្យសនកម្មជាមួយបទល្មើស ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ។ ផ្នែកទីពីរដែលមានចំណងជើងថា “ការវាយតម្លៃជាបុគ្គលទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី” ដែលក្នុងផ្នែកនេះ សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់គោលការណ៍ណែនាំ ទៅក្នុងស្ថានភាពនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ។ នៅក្នុងដីកាដែលរងការជំទាស់ ផ្នែកនេះពិតជារៀបរាប់យ៉ាងពិតប្រាកដនូវសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេត។ ខ្ញុំសង្កេតឃើញថា ការដាក់បញ្ចូលនូវបទដ្ឋានគតិយុត្តិដែលត្រូវអនុវត្តចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទៅក្នុងផ្នែក “សំអាងហេតុសម្រាប់សេចក្តីសម្រេច” ដោយរួមបញ្ចូលទាំងការដាក់បទដ្ឋាននានាដែលទាក់ទិនទៅនឹងតែអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មួយចំនួនជាក់លាក់ប៉ុណ្ណោះនោះ មិនបានបន្ថយ ឬក៏លុបបំបាត់នូវការពិតដែលថា សហចៅក្រមស៊ើបអង្កេតពិតជាបានផ្តល់សំអាងហេតុ ក្នុងការបដិសេធអ្នកដាក់ពាក្យសុំនីមួយៗ នៅក្នុងដីកាដែលរងការជំទាស់នីមួយៗនោះឡើយ។

១៦. ខ្ញុំមិនមានការលំបាកក្នុងការស្វែងយល់ពីសំអាងហេតុ ក្នុងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ។ សហចៅក្រមស៊ើបអង្កេតមិនត្រូវធ្វើការយោងជាពិសេសណាមួយចំពោះព័ត៌មាននីមួយៗ នៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ ឬព័ត៌មានបន្ថែមរបស់អ្នកដាក់ពាក្យសុំនីមួយៗនោះឡើយ។ សំអាងហេតុដែលផ្តល់ឱ្យដោយសហចៅក្រមស៊ើបអង្កេតគឺគ្រប់គ្រាន់ ហើយអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំនីមួយៗ អាចដាក់បណ្តឹងឧទ្ធរណ៍ទាក់ទិនទៅនឹងការបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់។ ការយល់ឃើញរបស់ខ្ញុំដែលថា ដីកាដែលរងការជំទាស់មានសំអាងហេតុនោះ ពិតជាមិនពាក់ព័ន្ធដល់ការវិភាគលើបញ្ហាថាតើសំអាងហេតុទាំងនោះរបស់សហចៅក្រមស៊ើបអង្កេត ពិតជាត្រឹមត្រូវតាមអង្គ





PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ហេតុ ឬអង្គច្បាប់នោះទេ។

**មូលដ្ឋានទី២៖ ការដាក់កំហិតដោយភ័ន្តច្រឡំទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

១៧. សហមេធាវីបានលើកឡើងនូវទឡ្ហីករណ៍ជាច្រើន ក្នុងបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការប្រព្រឹត្តជាទូទៅចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក។ សហមេធាវីបានរៀបរាប់ចំណុចជាក់លាក់នានាស្តីពីការប្រព្រឹត្ត ក៏ដូចជាឋានៈទូទៅនៃដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគាត់ ដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតថាជាការភ័ន្តច្រឡំផ្នែកអង្គច្បាប់។ ខ្ញុំសូមកត់សម្គាល់ថា ខ្លួនមិនអាចធ្វើការពិចារណាទៅលើគ្រប់ទឡ្ហីករណ៍ទូទៅទាំងអស់ដែលសហមេធាវីបានលើកឡើងនោះឡើយ ព្រោះទឡ្ហីករណ៍ជាច្រើនត្រូវបានលើកឡើងដោយមិនច្បាស់លាស់ និងមិនសមស្រប។ អង្គបុរេជំនុំជម្រះគ្មានកាតព្វកិច្ចធ្វើការពិចារណាទៅលើទឡ្ហីករណ៍បែបនេះឡើយ ហេតុដូច្នេះហើយខ្ញុំនឹងធ្វើការសង្ខេប ព្រមទាំងវាយតម្លៃតែទឡ្ហីករណ៍ទាំងឡាយណាដែលខ្ញុំយល់ឃើញថាត្រូវពិចារណាតែប៉ុណ្ណោះ។ ទឡ្ហីករណ៍ទាំងនោះរួមមានការប្តឹងដែលលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ដូចតទៅ៖ (១) ម្ចាស់បណ្តឹងមិនត្រូវបានគេសម្ភាសន៍ឱ្យស្របតាមវិធាន៥៩ នៃវិធានផ្ទៃក្នុង (២) អង្គហេតុដែលម្ចាស់បណ្តឹងបានរាយការណ៍ ហើយដែលស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ មិនត្រូវបានជូនដំណឹងទៅសហព្រះរាជអាជ្ញាតាមវិធាន៥៥ នៃវិធានផ្ទៃក្នុង (៣) សិទ្ធិរបស់ម្ចាស់បណ្តឹងត្រូវបានបំពានដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ និងសម្ភារៈ ជាពិសេសគឺម្ចាស់បណ្តឹងត្រូវបានគេផ្តល់ឱ្យនូវមេធាវីតំណាង នៅខណៈពេលចុងក្រោយបំផុត ហើយពួកគាត់មិនត្រូវបានផ្តល់ឱ្យនូវពេលវេលាបន្ថែម ដើម្បីធ្វើការផ្តល់ព័ត៌មានបន្ថែមឡើយ និង (៤) ព័ត៌មានដែលពួកគាត់បានទទួលនៅដំណាក់កាលស៊ើបសួរតាមផ្លូវតុលាការមិនគ្រប់គ្រាន់ឡើយ។

១៨. ទាក់ទិននឹងបញ្ហាទីមួយដែលបានលើកឡើងជាទឡ្ហីករណ៍ទូទៅនោះ ខ្ញុំសូមកត់សម្គាល់ថានៅពេលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសហចៅក្រមស៊ើបអង្កេតធ្វើការសម្ភាសន៍តាមលក្ខណៈធម្មតា តាមប្រព័ន្ធច្បាប់ស៊ីវិល[៩] ប៉ុន្តែវិធាន ៥៩ ដែលបានដក

[៩] សូមមើល ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១៥០។

00709935



ស្រង់ភាគច្រើនចេញពីបរិបទ អ.វ.ត.ក ជាពិសេសនោះ គឺប្រជាជនភាគច្រើនលើសលប់ដែលអាចដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានអនុញ្ញាតឱ្យទទួលការសម្ភាសន៍ពីសហចៅក្រមស៊ើបអង្កេត ប៉ុន្តែនេះមិនមែនជាការតម្រូវជាចាំបាច់នោះឡើយ។ បន្ថែមពីលើនេះទៀត ដោយសារទំហំនៃអង្គហេតុដែលអាចស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ធ្វើឱ្យសហចៅក្រមស៊ើបអង្កេតមិនអាចធ្វើការស៊ើបសួរនូវរាល់អង្គហេតុទាំងអស់បាននោះឡើយ ហើយម្ចាស់បណ្ដឹងឧទ្ធរណ៍ហាក់ដូចជាបានទទួលស្គាល់នូវដែនកំណត់នេះ ដោយខ្លួនបានទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេត *មិនអាច*ធ្វើការស៊ើបសួរលើគ្រប់អង្គហេតុទាំងអស់ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក បានឡើយ។ ហេតុដូច្នេះ ខ្ញុំសូមច្រានចោលទឡ្ហីករណ៍ទាំងឡាយណាដែលថាសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំផ្នែកអង្គច្បាប់ ព្រោះមិនបានធ្វើកិច្ចសម្ភាសន៍លើគ្រប់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

១៩. បន្ទាប់ទៅទៀត ទាក់ទិននឹងបញ្ហាទីពីរដែលបានលើកឡើងជាទឡ្ហីករណ៍ទូទៅនោះ ខ្ញុំសូមរំឭកថា ដោយសារមូលហេតុនីតិវិធី ទើបសហព្រះរាជអាជ្ញា បានដាក់កំហិតវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ទៅលើតែអង្គហេតុមួយចំនួនដែលសហព្រះរាជអាជ្ញាបានដឹងនៅពេលនោះ។ ទាំងអស់នេះត្រូវបានធ្វើឡើងដោយការជ្រើសរើសអង្គហេតុណាខ្លះ ដែលត្រូវបញ្ជូនទៅឱ្យសហចៅក្រមស៊ើបអង្កេត ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនានា។ នៅក្នុងទឡ្ហីករណ៍ទូទៅដែលបានលើកឡើងទាក់ទិននឹងការណ៍ដែលសហចៅក្រមស៊ើបអង្កេតមិនបានបញ្ជូននូវអង្គហេតុ ដែលស្ថិតនៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ ទៅសហព្រះរាជអាជ្ញានោះ ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនបានបញ្ជាក់ឱ្យច្បាស់លាស់ ថាតើអង្គហេតុណាមួយដែលខ្លួនបានប្ដឹងថាបង្កឱ្យមានព្យសនកម្ម ហើយដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញថា ខុសពីអង្គហេតុដែលខ្លួនបានទទួល ហើយត្រូវជាអង្គហេតុថ្មី ដែលសហចៅក្រមស៊ើបអង្កេតត្រូវបញ្ជូនទៅឱ្យព្រះរាជអាជ្ញាឡើយ ដោយអនុលោមទៅតាមវិធាន៥៥(២)[១០]។ ការមិនបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើប

---

[១០] ខ្ញុំកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តនីតិវិធីដែលកំណត់ដោយវិធាន ៥៥(២) ពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃអង្គហេតុជាច្រើន រួមទាំងការជម្លៀសចេញពីខេត្តសៀមរាប កាលពីខែមេសា ឆ្នាំ ១៩៧៥៖ ការបញ្ជូនដីកាចុះថ្ងៃ ទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារ D77។

សួរបន្ថែមទៅលើអង្គហេតុដែលរងការប្ដឹងនោះ មិនមែនជាការលើកលែងឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍បានរួចផុតពីការបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងវិធាន២៣ស្ទួន(១)(ខ)នោះឡើយ មានន័យថាអ្នកដាក់ពាក្យសុំត្រូវតែបង្ហាញថាខ្លួនពិតជាបានទទួលរងព្យសនកម្មផ្លូវកាយ ផ្លូវចិត្ត ឬសម្ភារៈ ដែលជាផលវិបាកដោយផ្ទាល់នៃបទឧក្រិដ្ឋយ៉ាងតិចមួយ ក្នុងចំណោមបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់ប្រឆាំងជនត្រូវចោទ ដូចមានពន្យល់បន្ថែមខាងក្រោម។ ភាពមិនប្រាកដប្រជានៃទឡ្ហីករណ៍ដែលលើកឡើងដោយម្ចាស់បណ្ដឹងឧទ្ធរណ៍បង្ហាញថា ទឡ្ហីករណ៍នេះមិនត្រឹមត្រូវ ដូច្នេះវាមិនចាំបាច់ត្រូវធ្វើការពិចារណាបន្ថែមទៀតនោះទេ។ ជាចុងក្រោយ ខ្ញុំកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាបានទទួលរាល់ព័ត៌មានទាំងអស់ ដែលផ្ដល់ឱ្យដោយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយសហព្រះរាជអាជ្ញាអាចពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរផ្អែកលើមូលដ្ឋានទាំងនេះ ក្នុងករណីដែលចាំបាច់។

២០. ពាក់ព័ន្ធនឹងបញ្ហាទីបីដែលលើកឡើងជាទឡ្ហីករណ៍ទូទៅនោះ ដែលទាក់ទិននឹងជំនួយដែលត្រូវផ្ដល់ឱ្យម្ចាស់បណ្ដឹងឧទ្ធរណ៍ ដើម្បីគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងឧទ្ធរណ៍របស់ពួកគាត់ ខ្ញុំសូមកត់សម្គាល់ថា កាលបរិច្ឆេទកំណត់សម្រាប់ទទួលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រឹមថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០ ដែលត្រូវនឹងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីថ្ងៃបិទកិច្ចស៊ើបសួរ[១១]។ ទោះបីជាយ៉ាងណា សហចៅក្រមស៊ើបអង្កេតបានអនុញ្ញាតឱ្យអ្នកដាក់ពាក្យសុំដាក់ព័ត៌មានបន្ថែម ទាក់ទិនទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដំបូងរបស់ខ្លួន ដោយពិចារណាលើសេចក្ដីប្រកាសព័ត៌មានចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ស្ដីពីវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងសំណុំរឿង ០០២[១២]។ នៅពេលដែលសហចៅក្រមស៊ើប

[១១] សេចក្ដីប្រកាសព័ត៌មាន មានចំណងជើងថា "សេចក្ដីសន្និដ្ឋានស្ដីពីកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស" ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០។ អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៩ ឯកសារ D337។

[១២] សេចក្ដីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ដែលមានចំណងជើងថា "សេចក្ដីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតស្ដីពីការស៊ើបអង្កេតសំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី" ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នៅ http://www.eccc.gov.kh/english/cabinet/press/138/ECCC_Press_Release_5_Nov_2009_Eng.pdf ("សេចក្ដីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ស្ដីពីវិសាលភាពនៃកិច្ចស៊ើបសួរ")។ នៅក្នុងសេចក្ដីប្រកាសព័ត៌មានរបស់ ក.ស.ច.ស សហចៅក្រមស៊ើបអង្កេតបានលើក[illegible] វិសាលភាពនៃកិច្ច





PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C

អង្កេតបានកំណត់កាលបរិច្ឆេទដំបូង ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១០[13] ក្រោយមក សហចៅក្រមស៊ើបអង្កេតបានពន្យារដល់ថ្ងៃទី ៣០ ខែ មិថុនា[14]។ ខ្ញុំបានកត់សម្គាល់ថា មានអ្នកដាក់ពាក្យសុំជាច្រើនរូបបានដាក់ពាក្យផ្ទេរសិទ្ធិទៅឱ្យមេធាវីការពារ ដែលជាការផ្ទុះបញ្ចាំងពីការចាត់តាំងផ្តល់មេធាវី និងការផ្តល់នូវព័ត៌មានបន្ថែម គាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដំបូងរបស់ខ្លួន។ ខ្ញុំបានកត់សម្គាល់ជាពិសេសថា ក្នុងបណ្តឹងឧទ្ធរណ៍ដែលសហមេធាវីបានជំទាស់ជាមួយនឹងដំណើរការរបស់សហចៅក្រមស៊ើបអង្កេត សហមេធាវីមិនបានចោទប្រកាន់ជាពិសេសណាមួយ ដែលថាម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានដាក់លិខិតផ្ទេរសិទ្ធិទៅឱ្យមេធាវីតំណាង ឬក៏ការផ្តល់ព័ត៌មានបន្ថែម ព្រោះថាពួកគាត់មិនអាចធ្វើបាននោះទេ។ ស្របតាមស្ថានការណ៍នេះ ខ្ញុំបានរកឃើញថា សហចៅក្រមស៊ើបអង្កេតមិនបានប្រព្រឹត្តនូវការភ័ន្តច្រឡំផ្នែកអង្គច្បាប់ណាមួយឡើយ។ ខ្ញុំបានរកឃើញប្រហាក់ប្រហែលគ្នាថា មិនមានការបំពានទៅលើសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍តាមវិធាន២១(១) ដូចការចោទដាច់ដោយឡែករបស់សហមេធាវីមួយចំនួននោះទេ។

២១. បន្ថែមលើទឡ្ហីករណ៍ទូទៅដែលបានលើកឡើងទាក់ទិននឹងមធ្យោបាយ និងការប្រព្រឹត្តមកលើដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីកត់សម្គាល់ថា អ្នកដាក់ពាក្យសុំចំនួន ៧៩៩នាក់ មិនទទួលបានមេធាវីរបស់ខ្លួននោះទេ រហូតដល់ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១០[15]។ អ្នកដាក់ពាក្យសុំទាំងនេះ មិនមានលទ្ធភាពផ្តល់ព័ត៌មានបន្ថែមឱ្យបានមុនថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ

---

ស៊ើបសួរអាចត្រូវបានគេយល់ថាជាទីកន្លែងប្រព្រឹត្តបទល្មើសផ្សេងៗ និងអំពើទានាប្រឆាំងនឹងប្រជាជន។ សេចក្តីប្រកាសព័ត៌មានលើកឡើងថា “ប្រសិនបើជនរងគ្រោះចង់ក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ព្យសនកម្មដែលបានលើកឡើងរបស់គាត់ត្រូវតែជាព្យសនកម្មផ្ទាល់ខ្លួន និងមានចំណងទាក់ទងផ្ទាល់ទៅនឹងស្ថានភាពអង្គហេតុមួយ ឬច្រើនដែលបង្កើតបានជាមូលដ្ឋាននៃកិច្ចស៊ើបសួរដែលកំពុងធ្វើ”។

[13] សេចក្តីប្រកាសព័ត៌មានមានចំណងជើងថា “សហចៅក្រមស៊ើបអង្កេតបានកំណត់កាលបរិច្ឆេទផុតកំណត់សម្រាប់ការដាក់ព័ត៌មានបន្ថែមពីអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២” ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១០។

[14] អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០១០ ឯកសារ D337/6។

[15] ដីកាសម្រេចស្តីពីការរៀបចំតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុវត្តតាមវិធាន ២៣ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D337/10។

00709938



២០១០ នោះទេ។ សហមេធាវីសង្កត់ធ្ងន់ថា ដោយខកខានក្នុងការពិចារណាលើបញ្ហានេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឱ្យអ្នកប្ដឹងឧទ្ធរណ៍ទាំងនេះស្ថិតនៅក្នុងស្ថានភាពមួយ ដែលមិនមានសមភាពស្មើគ្នាជាមួយនឹងអ្នកដាក់ពាក្យសុំដទៃទៀត។ ខ្ញុំទទួលស្គាល់ថា ការផ្ដល់មេធាវីតំណាងយឺតយ៉ាវទៅឱ្យអ្នកដាក់ពាក្យសុំ អាចធ្វើឱ្យពួកគាត់ទាំងនោះមានភាពលំបាកក្នុងការគាំទ្រដល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួន។ បញ្ហានេះគឺជាការពិតជាពិសេស នៅពេលដែលសហចៅក្រមស៊ើបអង្កេតបដិសេធមិនផ្ដល់ពេលវេលាបន្ថែមដល់សហមេធាវី ដើម្បីស្វែងរក និងដាក់ព័ត៌មានបន្ថែមដើម្បីគាំទ្រពាក្យសុំនានា បន្ទាប់ពីការរៀបចំឱ្យមានមេធាវីតំណាង នៅក្នុងខែសីហា ឆ្នាំ២០១០ នោះ។ ខ្ញុំសង្កេតឃើញថា នៅក្នុងចំណោមសហមេធាវីទាំងអស់ដែលបានលើកទឡ្ហីករណ៍ទូទៅនេះនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួន មានតែសហមេធាវីមួយចំនួនតែប៉ុណ្ណោះ ដែលបានស្នើសុំដាក់ព័ត៌មានបន្ថែម ឬដាក់ព័ត៌មានបន្ថែមដោយគ្មានសំណើដាក់ជូនអង្គបុរេជំនុំជម្រះ ដូចដែលបានស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតនោះ។ សហមេធាវីក៏មិនបានដាក់សំណើសុំពេលវេលាបន្ថែម ដើម្បីដាក់ព័ត៌មានបន្ថែមនោះដែរ។ ដោយពិចារណាទៅលើទឡ្ហីករណ៍នេះ ដែលបានរៀបរាប់យ៉ាងក្បោះក្បាយដោយសហមេធាវីតំណាង ទាក់ទិនទៅនឹងផលវិបាកដែលបណ្ដាលមកពីការរៀបចំតំណាងមេធាវីយឺតយ៉ាវនោះ ខ្ញុំយល់ឃើញថា មិនមានការបង្ហាញណាមួយថា (១) សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំអង្គច្បាប់ ដោយសន្និដ្ឋានសម្រេចថា ពាក្យសុំណាមួយមិនអាចទទួលយកបាននោះទេ និង (២) ថាសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំអង្គច្បាប់ ដោយយល់ឃើញថាពាក្យសុំទាំងនោះមិនអាចទទួលយកបាននោះទេ។

២២. សហមេធាវីបានចោទប្រកាន់បន្ថែមទៀតថា ពួកគាត់មិនបានទទួលព័ត៌មានគ្រប់គ្រាន់ក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរឡើយ។ សហមេធាវីចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតបានរំលោភលើកាតព្វកិច្ចរបស់ខ្លួន ក្នុងការធានាឱ្យបាននូវយុត្តិធម៌ក្នុងដំណើរការនីតិវិធីចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី តាមរយៈការរៀបចំ និងការគ្រប់គ្រងលើបែបបទនៃការទទួលយកដើមបណ្ដឹងរដ្ឋប្បវេណី។ ជាការគាំទ្រដល់ការអះអាងមួយនេះ សហមេធាវីយោងទៅលើការផ្លាស់ប្ដូរឱសានវាទ និងការប្រកាសផ្សេងៗរបស់សហចៅក្រមស៊ើបអង្កេត ហើយសហមេធាវីកត់សម្គាល់ថា អស់រយៈពេលជាច្រើនឆ្នាំមកនេះ





E.C.C.C * C.E.T.C
PRE-TRIAL CHAMBER CHAMBRE

ក្រុមសង្គមស៊ីវិល (ដោយរួមទាំងក្រុមការងារអ្នកស្ម័គ្រចិត្តផងដែរ) បានធ្វើការជាមួយអ្នកដាក់ពាក្យសុំ ដើម្បីបំពេញពាក្យសុំទាំងឡាយ ដោយមិនមានការយល់ដឹងពេញលេញអំពីបែបបទនៃការទទួលយកចុងក្រោយនៃពាក្យសុំ និងដោយមិនបានដឹងពីវិសាលភាពនៃកិច្ចស៊ើបសួរដែលត្រូវបានលាតត្រដាងជាសាធារណៈ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ នោះទេ។ សហមេធាវីបានប្តឹងឧទ្ធរណ៍ចំពោះអ្វី ដែលពួកគាត់យល់ឃើញថាជាការសម្រេចដោយអយុត្តិធម៌ទៅលើបញ្ហានេះ ជាពិសេសការខ្វះខាតនៃភាពជាក់លាក់ និងភាពច្បាស់លាស់ ដែលខុសពីការរំពឹងទុករបស់ពួកគាត់ ដែលថាបញ្ហានេះនឹងត្រូវដោះស្រាយតាមលក្ខណៈច្បាស់លាស់ និងអាចស្មានទុកជាមុនបាន។ ទោះបីជាខ្ញុំមិនយល់ស្របទាំងស្រុង ទៅលើបែបបទនៃការទទួលយកដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតក៏ដោយ ក៏ខ្ញុំពិចារណាឃើញថាចៅក្រមភាគច្រើនមិនបានពិចារណាយ៉ាងត្រឹមត្រូវ ទៅលើទំនាក់ទំនងរវាងវិសាលភាពនៃកិច្ចស៊ើបអង្កេត និងការសម្រេចចុងក្រោយលើភាពអាចទទួលយកបាននៃដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ ដោយហេតុថា ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្តល់ឱ្យអ្នកដាក់ពាក្យសុំទាំងឡាយណាដែលអាចបង្ហាញពីទំនាក់ទំនងមូលហេតុសមស្របរវាងព្យសនកម្ម និងបទល្មើសដែលបានចោទប្រកាន់តែនៅក្នុងដំណាក់កាលមុនអង្គសេចក្តី និងនៅពេលណាដែលមានបណ្តឹងឧទ្ធរណ៍ ក្នុងករណីដែលមានជនជាប់ចោទណាមួយត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះ សហចៅក្រមស៊ើបអង្កេត មុនសម្រេចចេញដីកាដំណោះស្រាយ មិនអាចដឹងដោយប្រាកដច្បាស់នោះទេថា អ្នកដាក់ពាក្យសុំណាមួយនឹងត្រូវទទួលយក ហើយអ្នកដាក់ពាក្យសុំណាខ្លះនឹងមិនត្រូវទទួលយកនោះ។ ក្នុងន័យនេះ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីជួបប្រទះការលំបាកស្រដៀងគ្នា ទៅនឹងការលំបាកដែលសហចៅក្រមស៊ើបអង្កេតបានជួបប្រទះដែរ នោះគឺការដឹកនាំកិច្ចស៊ើបអង្កេតដោយអញ្ញាក្រឹតប្រាកដណាមួយ មានន័យថាគេមិនអាចដឹងបានជាមុននោះទេថាបទល្មើសណាខ្លះ ដែលនឹងត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងឱ្យទៅជំនុំជម្រះនោះ។ វិសាលភាពនៃបទល្មើសជាក់ស្តែងដែលអាចត្រូវចោទលើជនត្រូវចោទណាមួយនោះ នឹងវិវឌ្ឍ ដែលជាលទ្ធផលនាំឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ពាក្យសុំរបស់កូនក្តីខ្លួនបន្ថែមទៀត នៅពេលដែលក្របខ័ណ្ឌអង្គហេតុនោះមានការវិវឌ្ឍន៍ដូច្នេះ។ សហចៅក្រមស៊ើបអង្កេតយល់ពីការវិវឌ្ឍទៅមុខនៃក្របខ័ណ្ឌអង្គហេតុនេះ។ ប្រសិន

00709940



បើដើមបណ្តឹងរដ្ឋប្បវេណីសម្រេចដាក់ពាក្យសុំនៅដើមដំណាក់កាលស៊ើបសួរ ពួកគាត់ប្រហែលជាត្រូវដាក់ឯកសារសម្ភារៈបន្ថែម ដើម្បីគាំទ្រដល់ពាក្យសុំរបស់ពួកគាត់ដដែល។ ខ្ញុំបានកត់សម្គាល់ពីខាងលើរួចហើយថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានណែនាំដោយសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់ឯកសារសម្ភារៈបន្ថែមទាំងឡាយណា ភ្ជាប់ជាមួយនឹងបណ្តឹងឧទ្ធរណ៍របស់ខ្លួន ប្រសិនបើចាំបាច់។ ការងាររបស់មេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចមានការលំបាក ក៏ប៉ុន្តែ កិច្ចនីតិវិធីនេះមិនមានភាពអយុត្តិធម៌នោះទេ ដោយហេតុថា សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានឱកាសមួយចំនួនដើម្បីដាក់បង្ហាញភស្តុតាងល្អប្រសើរនានាតាមដែលអាចធ្វើទៅបាន ដើម្បីជាផលប្រយោជន៍ដល់កូនក្តីរបស់ខ្លួន នៅដំណាក់កាលផ្សេងៗទៀតនៃកិច្ចស៊ើបសួរ ដោយរួមទាំងនៅពេលដែលកិច្ចស៊ើបសួរជិតត្រូវបានបញ្ចប់ផងដែរ។ ហេតុនេះ ខ្ញុំយល់ឃើញថា ការតវ៉ារបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងមធ្យោបាយរបស់ខ្លួនក្នុងការទទួលបានព័ត៌មាន ពេលវេលាក្នុងការទទួលបាននូវព័ត៌មាន និងភាពអយុត្តិធម៌នៃកិច្ចនីតិវិធីដែលកើតចេញពីកត្តាទាំងពីរនេះ ត្រូវតែបដិសេធចោល។

២៣. ក្នុងករណីណាក៏ដោយ ដើម្បីភាពយុត្តិធម៌ដល់អ្នកដាក់ពាក្យសុំ និងដោយបានពិចារណាអំពីការលំបាកទាំងឡាយដែលមេធាវីមួយចំនួនបានជួបប្រទះ នៅក្នុងការជួយកូនក្តីរបស់ខ្លួន នៅក្នុងការដាក់ពាក្យសុំនានា អង្គបុរេជំនុំជម្រះបានទទួលស្គាល់ព័ត៌មានបន្ថែមដែលបានដាក់ដោយសុពលភាព ដោយអ្នកដាក់ពាក្យសុំជាឧបសម្ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍ ឬបានរួមបញ្ចូលនៅក្នុងបណ្តឹងឧទ្ធរណ៍។ នៅក្នុងករណីខ្លះ អង្គបុរេជំនុំជម្រះបានណែនាំឲ្យសហមេធាវីដាក់ជូនព័ត៌មានបន្ថែម ជាពិសេសនៅក្នុងករណីខ្វះការបង្ហាញភស្តុតាងអំពីអត្តសញ្ញាណ ឬឲ្យបំភ្លឺព័ត៌មានមួយចំនួនដែលមាននៅក្នុងពាក្យសុំ។

**មូលដ្ឋានទី៣៖ ការអនុវត្តដោយភ័ន្តច្រឡំទៅលើវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥**

២៤. សហមេធាវីបានចោទប្រកាន់សហចៅក្រមស៊ើបអង្កេតថា បានប្រើប្រាស់ដោយភ័ន្តច្រឡំនូវវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥ ក្នុងការសម្រេចលើការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួន



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារហេតុនេះហើយទើបសេចក្តីសម្រេចនេះមានផលប៉ះពាល់អវិជ្ជមានចំពោះអ្នកដាក់ពាក្យសុំ។ សហមេធាវីបានតវ៉ាថា វិសោធនកម្មលើកទី៥ មិនទាន់ចូលជាធរមាននៅឡើយទេ នៅពេលដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយថាវិធាន២៣(២) (វិសោធនកម្មលើកទី៤) ចែងលក្ខណៈវិនិច្ឆ័យដែលទូលំទូលាយជាងសម្រាប់ការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ សហមេធាវីស្នើថា ការអនុវត្តវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥ សម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាការរំលោភទៅលើតម្រូវការសម្រាប់ភាពយុត្តិធម៌នៃដំណើរការនីតិវិធី។ សហមេធាវីបានបន្ថែមទៀតថា វិធានផ្ទៃក្នុងដែលនៅជាធរមាន ពេលដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដាក់ គួរត្រូវបានប្រើប្រាស់សម្រាប់ធ្វើការសម្រេចលើឋានៈរបស់ដើមបណ្តឹងរដ្ឋប្បវេណី[១៦]។

២៥. បន្ថែមពីលើការកំណត់ជំហរថា "វិធាន" ដែលត្រូវអនុវត្តចាំបាច់ជា "វិធាន" ដែលនៅជាធរមាន ពេលដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះ សហមេធាវីបានពន្យល់ថា វិធាន២៣(២) (វិសោធនកម្មលើកទី៤) សិទ្ធិក្នុងការចូលរួមក្នុងបណ្តឹងរដ្ឋប្បវេណី គួរត្រូវបានប្រើប្រាស់ដោយជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការនៃ អ.វ.ត.ក ហើយដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលយកបាន ព្យសនកម្មត្រូវតែជា ក) ការខូចខាតខាងរូបរាងកាយ ផ្លូវចិត្ត ឬសម្ភារៈ និង ខ)ផលវិបាកដោយផ្ទាល់ពីបទល្មើសជាព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន[១៧]។ តាមការយល់ឃើញរបស់សហមេធាវី ការចូលជាធរមានរបស់វិធាន ២៣ស្ទួន(១)(ខ) នៃវិធានផ្ទៃក្នុងវិសោធនកម្មថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១០ បានរឹតបន្តឹងយ៉ាងច្បាស់ទៅលើការចូលរួមរបស់ជនរងគ្រោះ ជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះជនរងគ្រោះដែលទទួលរងព្យសនកម្មដែលជាផល

---

[១៦] សូមមើលឧទាហរណ៍ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចអំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងពីអ្នករស់នៅក្រៅព្រះរាជាណាចក្រកម្ពុជា (ឯកសារ D404) ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D404/1/3 (បណ្តឹងឧទ្ធរណ៍ អ.ប.ជ ៧៧) កថាខណ្ឌ ១២ ដល់ ១៤។ អំណះអំណាងស្រដៀងគ្នាក៏ត្រូវបានធ្វើ នៅក្នុងបណ្តឹងឧទ្ធរណ៍ដែលបានដាក់នៅក្នុងឯកសារ អ.ប.ជ ៧៣, ៨០, ៨១, ៨៦, ១០៨, ១១៨, ១៤១។

[១៧] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៤) ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ (សេចក្តីបញ្ជាក់បន្ថែម)

វិបាកផ្ទាល់នៃបទល្មើសយ៉ាងតិចមួយ ដែលនោះជាបទល្មើសត្រូវបានចោទប្រកាន់ប្រឆាំងជនត្រូវចោទ[១៨]។ សហចៅក្រមសន្និដ្ឋានថា ការអនុវត្តវិធានផ្ទៃក្នុងវិសោធនកម្មលើកទី៥ នឹងនាំឱ្យមានការរឹតបន្តឹងយ៉ាងខ្លាំងទៅលើសិទ្ធិរបស់ជនរងគ្រោះ។ ដូច្នេះហើយ មិនគួរដាក់ឱ្យអនុវត្តជាលក្ខណៈប្រតិសកម្ម ទៅលើពាក្យសុំទាំងឡាយណាដែលបានដាក់មុនថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១០ នោះឡើយ។ សហចៅក្រមជំទាស់ថា សុពលភាពនៃសេចក្តីសម្រេចមុនៗរបស់អង្គបុរេជំនុំជម្រះ ដែលអង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆន្ទថា វិធានផ្ទៃក្នុងទាំងពីរវិសោធនកម្មចែងថា "ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំត្រូវបង្ហាញថា ខ្លួនបានទទួលនូវព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់នៃបទល្មើសមួយឬច្រើន ក្នុងចំណោមបទល្មើសដែលបានចោទប្រកាន់ចំពោះជនត្រូវចោទ"[១៩]។ សហចៅក្រមបានជំទាស់ថា វិធាន២៣(២)(ខ) វិសោធនកម្មលើកទី៤ មិនបានរឹតបន្តឹងលើអត្ថន័យនៃពាក្យ "បទល្មើស" ថាសំដៅចំពោះតែបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទនោះទេ គឺមិនដូចក្នុងវិធានផ្ទៃក្នុង វិសោធនកម្មលើកទី៥ ដែលចែងបញ្ជាក់យ៉ាងច្បាស់លាស់នោះទេ។ ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ពួកគាត់ សហចៅក្រមបានផ្អែកទៅលើយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដោយលើកពីវិធាន៨៥ នៃវិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ ICC ដែលមិនមានចែងរឹតបន្តឹងការចូលរួមរបស់ជនរងគ្រោះ តែចំពោះជនរងគ្រោះណាដែលអាចបង្ហាញនូវទំនាក់ទំនងជាមួយបទល្មើសដែលត្រូវចោទនោះទេ[២០]។

២៦. ខ្ញុំបានពិចារណាទៅលើការចោទប្រកាន់ពីការភ័ន្តច្រឡំផ្នែកអង្គច្បាប់ ព្រមទាំងវិធានផ្ទៃក្នុងដែលបានលើកឡើងនេះ និងបានសន្និដ្ឋានថា នៅក្នុងការលើកឡើងរបស់ខ្លួន សហចៅក្រមមាន

---

[១៨] វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៥) ចុះថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១០ (សេចក្តីបញ្ជាក់បន្ថែម)។

[១៩] ម្ចាស់បណ្តឹងឧទ្ធរណ៍យោងលើសាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីការួមរបស់សហចៅក្រមស៊ើបអង្កេត ឯកសារ D250/3/3 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ និងដីកា D250/3/2 ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០ ស្តីពីការទទួល យកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១០ ឯកសារ D250/3/2/1/5 ("សាលដីកាស្តីពី ដីការួម") កថាខណ្ឌ ២៩។

[២០] វិធាន ៨៥ ចែងត្រង់ផ្នែកពាក់ព័ន្ធថា "ជនរងគ្រោះ សំដៅទៅលើរូបវន្តបុគ្គលដែលបានទទួលរងព្យសនកម្ម ដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ" វិធាននីតិវិធី និងភស្តុតាងរបស់តុលាការ ICC U.N. Doc. ICC-ASP/1/3 (ឆ្នាំ ២00២) ("វិធានតុលាការ ICC") វិធាន ៨៥។





PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ការយល់ខុសថា ការអនុវត្តវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មលើកទី៥ គឺជាការយល់ច្រឡំ និងមានបុរេវិនិច្ឆ័យចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទៀតផង។ វិធាន ២៣ និងវិធាន ២៣ *ស្ទួន* នៃវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មលើកទី ៤ និងលើកទី ៥ មានចែងអំពី លក្ខខណ្ឌចំនួនពីរ ស្តីពីភាពអាចទទួលយកបាន ដែលតាមការយល់ឃើញរបស់ខ្ញុំ គឺមានន័យដូចគ្នាទៅនឹងវិសោធនកម្មនៃវិធានផ្ទៃក្នុងទាំងពីរលើកនេះ។

២៧. លក្ខខណ្ឌទីមួយ គឺទាក់ទងទៅនឹងយុត្តាធិការ។ វិធាន ២៣(២) នៃវិសោធនកម្មលើកទី ៤ និង វិធាន ២៣(១) នៃវិសោធនកម្មលើកទី ៥ គឺសំដៅទៅលើលក្ខខណ្ឌស្តីពីយុត្តាធិការនេះ ដោយមានការបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមនៅក្នុងដំណើរការនីតិវិធី ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក តែប៉ុណ្ណោះ ដោយជួយគាំទ្រដល់ការចោទប្រកាន់។

២៨. លក្ខខណ្ឌទីពីរគឺថា ព្យសនកម្មដែលបានលើកឡើង ត្រូវតែជាផលវិបាកដោយផ្ទាល់ពីបទល្មើស ឬឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ។ ចំណែកឯវិធាន ២៣ *ស្ទួន*(១)(ខ) នៃវិសោធកម្មលើកទី ៥ មានភាពច្បាស់លាស់ជាងលក្ខខណ្ឌដែលមានចែងនៅក្នុងវិធាន ២៣(២)(ខ) នៃវិសោធនកម្មលើកទី ៤ ដែលចែងថា ព្យសនកម្មត្រូវតែជាផលវិបាកដោយផ្ទាល់ពី "បទល្មើស" គឺពិតជាសំដៅទៅលើបទល្មើសដែលបានចោទប្រកាន់នេះហើយ គ្មានអ្វីគួរឱ្យសង្ស័យនោះឡើយ។ លក្ខខណ្ឌទីពីរនេះ គឺឆ្លុះបញ្ចាំងពីលក្ខខណ្ឌសម្រាប់ភាពអាចទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយយោងទៅលើសញ្ញាណនៃច្បាប់ស៊ីវិលពីមុនៗមក ដែលផ្នែកខ្លះត្រូវបានអនុម័តយក និង អនុវត្តនៅ អ.វ.ត.ក។ ហេតុដូច្នេះ ការប្រៀបធៀបជាមួយវិធាន និងការអនុវត្តជាក់ស្តែងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) មិនមែនជាការសម្រេចចុងក្រោយនោះទេ។ តាមពិតទៅ នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា និងប្រព័ន្ធច្បាប់បារាំង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចចូលរួមនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌតាមមធ្យោបាយពីរ៖ គឺជនរងគ្រោះអាចផ្តួចផ្តើមបណ្តឹងអាជ្ញា ដោយការដាក់ពាក្យបណ្តឹងស្នើសុំឱ្យក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី ("plainte avec constitution de partie

civile")[២១] ឬចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌតាមរយៈការធ្វើអន្តរាគមន៍ពីសំណាក់ព្រះរាជអាជ្ញា[២២]។ នៅក្នុងករណីពីរ ចាំបាច់ត្រូវមានទំនាក់ទំនងរវាងព្យសនកម្ម ដែលបានលើកឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងពាក្យសុំរបស់ខ្លួន និងបទល្មើសដែលត្រូវបានយកមកចោទប្រកាន់ចំពោះជនជាប់ចោទនៅក្នុងសវនាការ។ ដូចដែលបានបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដែលរងការជំទាស់ ("ផ្ទុយពីក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នៅចំពោះមុខនីតិវិធី អ.វ.ត.ក ជនរងគ្រោះ ដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចធ្វើការស៊ើបអង្កេតបានទេ មានន័យថា ដោយការចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីនិងដោយការកំហិតត្រឹម*សកម្មភាពតាមផ្លូវអន្តរាគមន៍* នោះជនរងគ្រោះដែលដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គ្រាន់តែអាចចូលរួមនៅក្នុងដំណើរការនីតិវិធីដែលកំពុងតែបន្តតាមរយៈការដាក់ពាក្យសុំនេះតែប៉ុណ្ណោះ និងមិនអាចពង្រីកការស៊ើបអង្កេតឱ្យហួសពីបណ្ដឹងទៅលើអង្គហេតុ *(in rem seisin) ដែលសហព្រះរាជអាជ្ញាបានប្ដឹងមកសហចៅក្រមស៊ើបអង្កេតនោះបានទេ*")[២៣]។ អាចនិយាយម៉្យាងទៀតបានថា នៅ អ.វ.ត.ក សហព្រះរាជអាជ្ញាមានអំណាចកំណត់ព្រំដែនវិសាលភាពនៃដំណើរការនីតិវិធីព្រហ្មទណ្ឌសំខាន់ៗ ប្រឆាំងចំពោះជនជាប់ចោទ នៅក្នុងរឿងក្ដីនីមួយៗ ដោយការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនៅដំណាក់កាលស៊ើបសួរ និងការផ្ដន្ទាទោសនៅក្នុងកម្រិតព្រំដែននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងដំណាក់កាលជំនុំជម្រះ និងដំណាក់កាលបន្តបន្ទាប់ទៅទៀត។ ជាលទ្ធផល ដើម្បីឱ្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយអាចទទួលយកបាននោះ ពាក្យសុំត្រូវស្ថិតនៅក្នុងវិសាលភាពនៃបទល្មើសដែលសហព្រះរាជអាជ្ញាបានសម្រេចយកមកធ្វើការចោទប្រកាន់ និងដែលជាផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះ លក្ខខណ្ឌទីពីរនេះ គឺស្របគ្នាទៅនឹងគោលបំណងនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.

---

[២១] មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រា ១ មាត្រា ២ និងមាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ("ក្រមនីតិវិធីបារាំង")។

[២២] មាត្រា ១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រា ៨៧ នៃក្រមនីតិវិធីបារាំង។

[២៣] សូមមើលឧទាហរណ៍ ដីកាដែលរងការជំទាស់លេខ D417 កថាខណ្ឌ ១៦។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. E.T.C.

00709945



ត.ក នេះហើយ គឺការគាំទ្រដល់ការចោទប្រកាន់។ លើសពីនេះទៅទៀត ការពិតដែលថា សោហ៊ុយទូទាត់សំណងផ្លូវចិត្ត និងជាសមូហភាព ដែលអាចផ្តល់ជូនដល់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែជាបន្ទុករបស់ទណ្ឌិតនោះ គឺជាហេតុផលបន្ថែមមួយទៀតសម្រាប់ការផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកំហិតចំពោះតែជនរងគ្រោះទាំងឡាយដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធទៅនឹងបទល្មើសទាំងឡាយដែលត្រូវបានយកមកផ្តន្ទាទោសលើជនជាប់ចោទជាចុងក្រោយបំផុតតែប៉ុណ្ណោះ[២៤]។

២៩. លក្ខខណ្ឌទាំងពីរសម្រាប់ការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណីបាន គឺតម្រូវឱ្យមានទាំងពីរ។ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីប្តឹងពីព្យសនកម្មណាមួយ ថាជាផលវិបាកដោយផ្ទាល់ពីបទល្មើសដែលត្រូវបានចោទប្រកាន់ ប៉ុន្តែត្រូវបានពិចារណាថា អ.វ.ត.ក មិនមានយុត្តាធិការទៅលើបទល្មើសនោះទេ នោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះមិនអាចទទួលយកបានឡើយ លើកលែងតែអំពើដែលបណ្តាលឱ្យមានព្យសនកម្មនោះ បង្កបានទៅជាផ្នែកមួយនៃបទល្មើសផ្សេងទៀតដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ ដូចគ្នានេះដែរ ប្រសិនបើអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចោទថា ព្យសនកម្មគឺជាផលវិបាកដោយផ្ទាល់នៃបទល្មើសដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតមិនបានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ នោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចទទួលយកបានឡើយ។ ខ្ញុំយល់ឃើញថា មិនមានទឡ្ហីករណ៍ណាមួយក្នុងចំណោម

---

[២៤] សូមមើលវិធាន ២៣(១១) នៃវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មលើកទី ៤ និងវិធាន ២៣ *ក្វាទ្រូន* នៃវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មលើកទី ៥ និងវិធានផ្ទៃក្នុងដែលត្រូវបានធ្វើវិសោធនកម្មលើកទី ៦ ដែលបានចូលជាធរមាននៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១០។ វិធាន ២៣ *ក្វាទ្រូន(៣)* នៃវិធានផ្ទៃក្នុងដែលបានធ្វើវិសោធនកម្មលើកទី ៦ ចែងថា បន្ថែមទៅលើប្រព័ន្ធច្បាប់ទំនៀមទម្លាប់ ដែលអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យទណ្ឌិតជាអ្នកទទួលខុសត្រូវចំពោះតម្លៃនៃសំណង នោះអង្គជំនុំជម្រះសាលាដំបូងអាចបោះឆ្នោតដើម្បីទទួលស្គាល់ថា គម្រោងជាក់លាក់មួយផ្តល់អានុភាពសមស្របទៅលើសំណងដែលបានស្នើសុំដោយសហមេធាវីនាំមុខ និងអាចអនុវត្តបាន។ ដើម្បីអាចទទួលបានការទទួលស្គាល់បែបនេះពីសំណាក់អង្គជំនុំជម្រះសាលាដំបូង គម្រោងនេះត្រូវតែរៀបចំឡើង និងឬកំណត់ឡើងដោយមានការសហការជាមួយអង្គភាពគាំពារជនរងគ្រោះ និងត្រូវធានាឱ្យមានការផ្តល់មូលនិធិពីខាងក្រៅឱ្យបានគ្រប់គ្រាន់។





E.C.C.C * C.E.T.C. TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ទឡ្ហីករណ៍ទាំងអស់ ដែលសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះមានមូលហេតុសមហេតុសមផល ដើម្បីអាចងាកចេញពីសេចក្ដីសម្រេចមុនៗរបស់អង្គបុរេជំនុំជម្រះដែលសម្រេចថា ទាំងវិធាន២៣(២) នៃវិសោធនកម្មលើកទី ៤ និងទាំងវិធាន ២៣ *ស្ទួន*(១)(ខ) នៃវិសោធនកម្មលើកទី ៥ ចែងថា៖ "ដើម្បីឲ្យពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចទទួលយកបាន អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង្ហាញថា *នៅក្នុងចំណោមបញ្ហាជាច្រើនទៀត* ខ្លួនបានទទួលរងព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់ពីបទល្មើសមួយយ៉ាងតិច ក្នុងចំណោមបទល្មើសដែលត្រូវបានចោទប្រកាន់ចំពោះជនត្រូវចោទ"[២៥]។ សម្រាប់សំអាងហេតុដូចដែលបានលើកឡើងខាងលើ ខ្ញុំយល់ឃើញថា មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះគួរត្រូវបានច្រានចោល។

**មូលដ្ឋានទី ៤៖ ការដាក់កំហិតដោយភ័ន្តច្រឡំទៅលើ "វិសាលភាពនៃកិច្ចស៊ើបសួរ" និងការអនុវត្តនូវការដាក់កំហិតនេះចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី**

៣០. សហមេធាវីបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំផ្នែកអង្គហេតុដោយការបង្កើតនិយមន័យនៃពាក្យថា "វិសាលភាពនៃកិច្ចស៊ើបសួរ" និងអង្គច្បាប់ ដោយតម្រូវថាភាពអាចទទួលយកបានត្រូវតែមានទំនាក់ទំនងទៅនឹង "វិសាលភាពនៃកិច្ចស៊ើបសួរ"[២៦]។ ខ្ញុំ

---

[២៥] សាលដីកាលើដីកាសម្រេចរួម កថាខណ្ឌ ២៩។ សូមមើលផងដែរ សាលដីកាជាសម្ងាត់លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចមិនទទួលយកសំណើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី [ត្រូវបានកោសលុប] ចុះថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D364/1/3 ("អបជ ៥៣") ទស្សនៈរបស់ចៅក្រម ន៉ី ថុល ចៅក្រម Catherine MARCHI-UHEL និងចៅក្រម ហួត វុទ្ធី ("ទស្សនៈ") កថាខណ្ឌ ១ ដែលក្នុងនោះចៅក្រមទាំងបីរូប ដោយយោងលើសេចក្ដីសម្រេចលើដីកាសម្រេចរួម បានកត់សម្គាល់ឃើញថា អត្ថន័យពាក្យពេចន៍ដែលចោទជាបញ្ហាមិនមានលក្ខណៈច្បាស់លាស់ជាងអត្ថន័យពាក្យពេចន៍នៃវិធាន ២៣(២)(ខ) ដូចដែលពួកគាត់បានប្រកាន់យកនោះទេ នៅពេលដែលដើម បណ្ដឹងឧទ្ធរណ៍បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ខ្លួន។

[២៦] ជាឧទាហរណ៍ សូមមើល អបជ៧៧ សម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៥៣ ដល់ ៦៥។ នៅក្នុងចំណោមបញ្ហាជាច្រើនទៀត ការលើកឡើងប្រហាក់ប្រហែលគ្នានេះនៅក្នុងបណ្ដឹងឧទ្ធរណ៍ដែលបានប្ដឹងក្នុងករណី អបជ៧៣ អបជ៧៨ អបជ៨០ អបជ៨៥ អបជ១០៨ អបជ១១៦ អបជ១១៨ និង អបជ១៤១។

00709947



ពិចារណាឃើញថាសំអាងហេតុនេះត្រូវបានពិចារណាយ៉ាងត្រឹមត្រូវ ថាជាមូលហេតុនៃបណ្ដឹងឧទ្ធរណ៍ទាក់ទងនឹងការភ័ន្តច្រឡំផ្នែកអង្គច្បាប់ដែលបានលើកឡើង ដែលជាទំនាក់ទំនងរវាងបញ្ហាទាំងឡាយដែលបានស៊ើបអង្កេត និងបញ្ហាដែលត្រូវចោទប្រកាន់ ហើយការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីគឺជាបញ្ហាអង្គច្បាប់។ វាអាស្រ័យទៅលើការបង្កើតទម្រង់នៃទំនាក់ទំនងដែលថា ការពិចារណាធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះបានក្លាយជាបញ្ហាអង្គហេតុ។

៣១. សហមេធាវីបានយោងទៅលើការបញ្ជាក់របស់សហព្រះរាជអាជ្ញា ដែលបានធ្វើឡើងកាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ ដើម្បីជាការឆ្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត[២៧] ទាក់ទងទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរដែលបានស្នើសុំនេះ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")[២៨]។ សហមេធាវីបានលើកទឡ្ហីករណ៍ថា ការដាក់កំហិតរបស់សហចៅក្រមស៊ើបអង្កេត ទៅលើបញ្ហាទាំងអស់ដែលត្រូវស្ថិតនៅក្នុងវិសាលភាពនៃការស៊ើបអង្កេត តែត្រឹមផ្នែកខ្លះនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយការមិនដាក់បញ្ចូលសារណានីមួយៗទៅក្នុងចំណុចរួមទាំងមូលនោះ គឺផ្ទុយទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និងមិនមានមូលដ្ឋាននៅក្នុងវិធានផ្ទៃក្នុង

---

[២៧] ដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៨ ឯកសារ D98។

[២៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីបញ្ជាក់ពីវិសាលភាពនៃកិច្ចស៊ើបសួរដែលបានស្នើសុំនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ខ្លួន ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨ ឯកសារ D98/I ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា") កថាខណ្ឌ ២។ នៅក្នុងចម្លើយតបនេះ សហព្រះរាជអាជ្ញាបញ្ជាក់ថា កិច្ចស៊ើបសួរដែលបានស្នើឡើង គឺមិនកំហិតត្រឹមតែអង្គហេតុដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ និងកថាខណ្ឌ ៥ ដល់ ២០ នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះទេ ប៉ុន្តែ វាលាតសន្ធឹងទៅលើអង្គហេតុទាំងអស់ ដែលបានយោងនៅក្នុងដីកាសន្និដ្ឋានទាំងពីរនេះថែមទៀតផង ដោយហេតុថា អង្គហេតុទាំងនេះជួយដល់ការស៊ើបអង្កេត៖ (ក) ធាតុផ្សំផ្នែកយុត្តាធិការ ដែលចាំបាច់ដើម្បីកំណត់ថាតើស្ថានភាពនៃអង្គហេតុទាំងឡាយដែលបានបញ្ជាក់នៅក្នុង កថាខណ្ឌ ២៧ ដល់ ៧២ និងកថាខណ្ឌ ៥ ដល់ ២០ នៃដីកាសន្និដ្ឋានបញ្ជូនទាំងនេះ បង្កើតបានជាបទឧក្រិដ្ឋផ្សេងៗដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬអត់ ឬ (ខ) ទម្រង់នៃការទទួលខុសត្រូវរបស់ជនជាប់សង្ស័យទាំងឡាយ ដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ។

ឬនៅក្នុងច្បាប់កម្ពុជានោះឡើយ[២៩]។ សហមេធាវីបានជំទាស់ទៅនឹងនិយមន័យនៃពាក្យថា "វិសាលភាពនៃកិច្ចស៊ើបសួរ" ដែលសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ ថាជាការរឹតត្បិតហួសហេតុទៅលើទីតាំង និងអំពើទាំងឡាយ ដែលបានរៀបរាប់នៅក្រោមចំណងជើងថា "ឧក្រិដ្ឋកម្ម" ក្នុងកថាខណ្ឌ ៣៧ ដល់៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬទៅលើតែអង្គហេតុដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមណាមួយ។ សហមេធាវីបានសន្និដ្ឋានបន្ថែមទៀតថា ការបកស្រាយបែបនេះ គឺផ្ទុយទៅនឹងសេចក្តីសម្រេចពីពេលមុនរបស់អង្គបុរេជំនុំជម្រះ[៣០]។ សហមេធាវីបានជំទាស់ថា ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនត្រូវកំហិតចំពោះអ្នកដាក់ពាក្យសុំណាដែលអាចបង្ហាញនូវទំនាក់ទំនងរវាងព្យសនកម្មដែលខ្លួនបានទទួលរង និងបទល្មើសដែលមានរៀបរាប់នៅក្នុងកថាខណ្ឌដែលបានលើកពីខាងលើរួចមកហើយ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនានានោះឡើយ។ សហមេធាវីបានលើកឡើងថា ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ក៏គួរតែពង្រីកបន្ថែមដល់អ្នកដាក់ពាក្យសុំទាំងឡាយណាដែលអាចបង្ហាញនូវទំនាក់ទំនងរវាងព្យសនកម្ម ដែលខ្លួនបានទទួលជាមួយនឹងអង្គហេតុដែលមានចែងនៅក្នុងផ្នែកដទៃនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយរួមបញ្ចូលទាំងផ្នែកដែលមាន

---

[២៩] ពេលខ្លះ សហមេធាវីយោងទៅលើវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង និងមាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("CPC") ដែលចែងថា៖

"សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ។

ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេតត្រូវជូនព័ត៌មានដល់សហព្រះរាជអាជ្ញា។ កាលណាអង្គហេតុថ្មីនោះត្រូវបានបញ្ជូនទៅឱ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា។

ប៉ុន្តែ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេតស្រាប់ នោះមិនចាំបាច់តម្រូវឱ្យមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ"។

[៣០] សហមេធាវីយោងទៅ អបជ ៥៣ ជាពិសេសកថាខណ្ឌ ១៦ នៃមតិយោបល់របស់ចៅក្រម ប្រាក់ គីម សាន និងចៅក្រម Rowan DOWNING។





E.C.C.C • C.E.T.C • CHAMBER CHAMBRE PRÉLIMINAIRE

ចំណងជើងថា "ការចូលរួម និងការដឹងឮ"។ សហមេធាវីបានលើកឡើងថា ដោយសារតែមានការបកស្រាយដែលមានលក្ខណៈរឹតត្បិតហួសហេតុបែបនេះ ទៅលើការកំហិតនៃវិសាលភាពនៃកិច្ចស៊ើបសួរ ទើបសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការប្រកាសបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើន ដោយផ្អែកលើមូលដ្ឋានដែលថា "អ្នកដាក់ពាក្យសុំមិនអាចបង្ហាញនូវទំនាក់ទំនងរវាងព្យសនកម្មដែលខ្លួនបានទទួល ជាមួយនឹងផ្នែកដែលស្ថិតនៅក្រោម"វិសាលភាពនៃកិច្ចស៊ើបសួរ"។

៣២. មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ហាក់ដូចជារួមបញ្ចូលនូវទស្សនៈពីរដាច់ដោយឡែកពីគ្នា គឺវិសាលភាពនៃកិច្ចស៊ើបសួរ និងបទល្មើស ដែលត្រូវបានចោទប្រកាន់ចំពោះជនត្រូវចោទ ហើយក្រោយមក ត្រូវបានបញ្ជូនរឿងទៅជំនុំជម្រះ។ យោងតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ខ្ញុំយល់ស្របជាមួយសហមេធាវីថា វិសាលភាពនៃកិច្ចស៊ើបសួរ គឺត្រូវតែទូលំទូលាយជាងបទល្មើស ដោយសារវិសាលភាពនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ មិនត្រូវដាក់កំហិតត្រឹមតែលើអង្គហេតុ ដែលមានចែងជាក់លាក់ក្នុងផ្នែកដែលមានចំណងជើងថា "ឧក្រិដ្ឋកម្ម" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (កថាខណ្ឌ ៣៧ ដល់ ៧២) និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី១ (កថាខណ្ឌ៥ ដល់ ២០) នោះទេ[៣១] តែផ្ទុយទៅវិញ វា

---

[៣១] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងមន្ទីរសន្តិសុខភូមិភាគឧត្តរ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០០៨ ឯកសារ D83 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ")។ ខ្ញុំយល់ឃើញថា កថាខណ្ឌ ១២ ដល់ ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ នៅក្រោមផ្នែកដែលមានចំណងជើងថា "II. បរិបទនៃឧក្រិដ្ឋកម្ម" មានព័ត៌មានលើសពី "អង្គហេតុ" ដែលត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ ក្រោមផ្នែកថា "ឧក្រិដ្ឋកម្ម"។ ក្នុងកថាខណ្ឌទីមួយនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ស៊ើបសួរទៅលើឧក្រិដ្ឋកម្ម ដែលខ្លួនមានហេតុផលអាចឲ្យជឿបានថា ត្រូវបានប្រព្រឹត្តឡើង និងដែលត្រូវបានបញ្ជាក់អះអាងនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញាដែលថា កថាខណ្ឌ ១២ ដល់ ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ ក៏ត្រូវបានពិចារណាថា ជាស្ថានភាពអង្គហេតុដែលបង្កបានជាឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នេះដែរ។ អង្គបុរេជំនុំជម្រះមិនមានអំណាចកែប្រែវិសាលភាពនៃកិច្ចស៊ើបសួរដែលបានកំណត់ដោយសហព្រះរាជអាជ្ញានោះទេ។ អង្គជំនុំជម្រះនេះក៏មិនអាចកែប្រែបទល្មើសដែលបានយកធ្វើការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះដែរ ប្រសិនបើអង្គជំនុំជម្រះមិនយល់ស្រប

ត្រូវពង្រីកដើម្បីគ្របដណ្តប់អង្គហេតុទាំងអស់ ដែលមានយោងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាំងនេះ ដោយហេតុថា អង្គហេតុទាំងនេះជួយដល់ការស៊ើបសួរ៖ ក) ធាតុផ្សំផ្នែកយុត្តាធិការដែលចាំបាច់សម្រាប់ការបង្ហាញថាតើស្ថានភាពនៃអង្គហេតុ ដែលមានចែងក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ និងកថាខណ្ឌ ៥ ដល់ ២០ នាំឲ្យមានបទល្មើសដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែរឬអត់ ឬ ខ) ទម្រង់នៃការទទួលខុសត្រូវរបស់ជនសង្ស័យដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[៣២]។ ដោយសារតែចម្លើយតបរបស់សហព្រះរាជអាជ្ញាត្រូវបានចេញ មុនពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដទៃទៀត ទើបចម្លើយតបរបស់សហព្រះរាជអាជ្ញា ដាក់កំហិតសមហេតុផលទៅលើតែកថាខណ្ឌដែលពាក់ព័ន្ធនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គិតមកត្រឹមពេលដែលសហព្រះរាជអាជ្ញាបានចេញចម្លើយតបនេះ នៅពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៨ ដែលទាក់ទងទៅនឹងវិសាលភាពនៃកិច្ចស៊ើបសួរ។ មានភស្តុតាងដែលថា ការបញ្ជាក់ដែលមាននៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា អាចអនុវត្តបានចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដទៃទៀត[៣៣]។

---

ជាមួយនឹងសេចក្តីសម្រេចរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់បញ្ចូលកថាខណ្ឌ ១២ ដល់ ២០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីមួយ ទៅក្នុងការណែនាំទាំងឡាយដែលសហព្រះរាជអាជ្ញាបានចេញនៅក្នុងចម្លើយតបរបស់ខ្លួន។

[៣២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២។

[៣៣] សូមមើល ឧទាហរណ៍ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអំពើប្រល័យពូជសាសន៍លើជនជាតិចាម ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារ D196 (កថាខណ្ឌ ៣ ដល់ ២៣)។ សូមមើលផងដែរ ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ ឯកសារ D146/3 កថាខណ្ឌ ២។ ការអនុញ្ញាតបន្ថែមទៀត ដោយអនុលោមតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D146/4។ សេចក្តីថ្លែងការណ៍បន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងចម្លើយតបចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ឯកសារ D146/5 និង សេចក្តីបញ្ជាក់អំពីការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងមណ្ឌលសន្តិសុខ និងទីតាំងសម្លាប់មនុស្សចំនួនប្រាំ ដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូន

**០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៦, អបជ ១១២ អបជ ១១៣ អបជ ១១៤ អបជ ១១៥ អបជ ១៤២ អបជ ១៥៧ អបជ ១៦៤ អបជ ១៦៥ និង អបជ ១៧២)**

៣៣. នៅក្នុងបរិបទនៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលនៃការស៊ើបសួរតាមផ្លូវតុលាការ វិសាលភាពនៃកិច្ចស៊ើបសួរ គឺទាក់ទិនជាពិសេសក្នុងការសម្រេច ថាតើសហចៅក្រមស៊ើបអង្កេតអាចបើកកិច្ចស៊ើបសួរ ដោយការផ្ដួចផ្ដើមគំនិតដោយខ្លួនឯង ឬក៏នៅពេលបានទទួលសំណើសុំពីភាគីណាមួយ[៣៤]។ ក្នុងដំណាក់កាលនៃដំណើរការនីតិវិធីស៊ើបអង្កេត ដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរ ដែលខ្លួនយល់ថាចាំបាច់សម្រាប់ការស៊ើបសួរ ទោះបីជាកិច្ចស៊ើបសួរនោះហួសពីអង្គហេតុ ដែលចោទប្រកាន់ដោយសហព្រះរាជអាជ្ញា ដែលស្ថិតនៅក្នុងបទល្មើសដែលត្រូវរងការចោទប្រកាន់ក៏ដោយ ឱ្យតែវាស្ថិតនៅក្នុងវិសាលភាពទូលំទូលាយនៃកិច្ចស៊ើបសួរ ដែលកំណត់ដោយសហព្រះរាជអាជ្ញា[៣៥]។ ផ្ទុយទៅនឹងគម្លាតដ៏ទូលំទូលាយនៃបញ្ហាដែលស្ថិតក្នុងវិសាលភាពនៃកិច្ចស៊ើប

---

រឿងឱ្យស៊ើបសួរ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ (កថាខណ្ឌ ៣ ដល់ ១៣)។ ការដាក់បញ្ចូលបទល្មើសក្នុងបណ្ដាកថាខណ្ឌដូចបានរៀបរាប់ខាងលើ ដោយយកចេញពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ត្រូវតែវិភាគឱ្យស្របជាមួយនឹងបទល្មើសដែលបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[៣៤] សាលដីកាលើដីកាសម្រេចរួម កថាខណ្ឌ ១៧ កថាខណ្ឌ ៤៨ និងកថាខណ្ឌ ៥១។

[៣៥] វិធាន៥៥(១០) ផ្ដល់សិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី (និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី) ស្នើឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរ។ ក្នុងសាលដីកាលើដីការួម អង្គបុរេជំនុំជម្រះបានអះអាងថា ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនមានសិទ្ធិប្ដឹងស្នើសុំកិច្ចស៊ើបសួរសម្រាប់ "អង្គហេតុថ្មី" លុះត្រាតែអង្គហេតុនោះត្រូវបានដាក់បញ្ចូលទៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយសហព្រះរាជអាជ្ញា។ សាលដីកាលើដីការួម កថាខណ្ឌ៤៨ "អង្គហេតុថ្មី" គឺជាអង្គហេតុដែលស្ថិតនៅក្រៅអង្គហេតុសម្ភារៈ ដែលចោទប្រកាន់ដោយសហព្រះរាជអាជ្ញាក្នុងដីកាសន្និដ្ឋាននានាដែលមានស្រាប់ ដូច្នេះអង្គហេតុថ្មីនេះមិនមែនជាកម្មវត្ថុនៃកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតនោះឡើយ ក្នុងករណីដែលមិនមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាបញ្ជាក់បន្ថែមថា បញ្ហាដែលត្រូវធ្វើការស៊ើបអង្កេតក្នុងដំណាក់កាលស៊ើបអង្កេតតាមផ្លូវតុលាការ មិនកំហិតត្រឹមតែអង្គហេតុសម្ភារៈដែលស្ថិតនៅក្រោមបទល្មើសដែលត្រូវចោទប៉ុណ្ណោះទេ។ ប៉ុន្តែវាច្បាស់ថា អង្គហេតុទាំងនោះត្រូវតែស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរដូចដែលបានកំណត់ដោយសហព្រះរាជអាជ្ញាក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ហើយបានបញ្ជាក់លម្អិតនៅក្នុងចម្លើយតបរបស់សហព្រះរាជអាជ្ញា។ ដូចដែលអង្គបុរេជំនុំជម្រះបានបញ្ជាក់ពីមុនរួចមកហើយ អនុលោមតាមវិធាន ៥៥(១០) នៅក្នុងដំណាក់កាលស៊ើបសួរតាមផ្លូវតុលាការ ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យមានកិច្ចស៊ើបសួរទៅលើបញ្ហាទាំងអស់នោះ ដោយគោរពដល់ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។



**យោបល់ជំទាស់របស់លោកស្រីចៅក្រម CATHERINE MARCHI-UHEL**

00709952



សួរតាមផ្លូវតុលាការ ដែលអាចជាកម្មវត្ថុនៃសំណើសុំបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការ ការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើលទ្ធភាពរបស់អ្នកដាក់ពាក្យសុំដោយការបង្ហាញថា យ៉ាងហោចណាស់ព្យសនកម្មដែលខ្លួនបានទទួល គឺជាផលវិបាកដោយផ្ទាល់នៃបទល្មើសមួយក្នុងចំណោមបទល្មើស ដែលត្រូវបានចោទប្រកាន់[៣៦]។

៣៤. ខ្ញុំបានកត់សម្គាល់ឃើញថា មានភាពមិនច្បាស់លាស់នៅត្រង់ចំណុចនេះ នៅក្នុងដីកាដែលរងការជំទាស់ ដែលហាក់ដូចជាចាត់ទុកថា ទស្សនៈទាំងពីរនេះអាចផ្លាស់ប្តូរគ្នាបាន តែការពិតគឺមិនមែនដូច្នេះនោះទេ។ នៅពេលកំណត់អត្តសញ្ញាណនៃបទដ្ឋានដែលនៅជាធរមាន ដីកាដែលរងការជំទាស់បានបង្ហាញតម្រូវការនៃ "ទំនាក់ទំនងរវាងព្យសនកម្ម និងបទល្មើសដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ"[៣៧] ហើយម្យ៉ាងទៀត បានបង្ហាញនូវ "ព្យសនកម្មដែលបានលើកឡើង គឺជាលទ្ធផលនៃអង្គហេតុ ដែលត្រូវបានស៊ើបសួរតាមផ្លូវតុលាការរួចរាល់ហើយតែប៉ុណ្ណោះ"[៣៨]។ បន្ថែមលើនេះទៅទៀត សហចៅក្រមស៊ើបអង្កេតបានរកឃើញថា មិនមានទំនាក់ទំនងជាសំខាន់រវាងព្យសនកម្មដែលប្តឹងដោយសហាមេធាវី ជាមួយនឹងអង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ រហូតដល់កម្រិតមួយដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា អង្គហេតុដែលបានលើកឡើង គឺស្ថិតនៅដាច់ដោយឡែកពីអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានទទួល ហើយគ្មានឱកាសណាមួយដែលថា ខ្លួនអាចធ្វើការពិចារណាទៅលើលទ្ធភាពនៃទំនាក់ទំនងដោយផ្ទាល់ រវាងព្យសនកម្មដែលបានប្តឹង ជាមួយនឹងបទល្មើសដែលរងការចោទប្រកាន់ នៅក្នុងកិច្ចស៊ើបសួរនោះឡើយ[៣៩]។ ដូចបានបញ្ជាក់ខាងលើរួចមកហើយថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវតែបង្ហាញនូវទំនាក់ទំនងជាមួយនឹងបទល្មើសដែលរងការចោទប្រកាន់ មិនមែនចំពោះ៖ ១) វិសាលភាពទូលំទូលាយនៃ

---

[៣៦] វិធាន ២៣ *ស្ទួន*(ខ) នៃវិធានផ្ទៃក្នុង។ សូមមើលផងដែរ សាលដីកាលើដីកាសម្រេចរួម កថាខណ្ឌ ៥១។

[៣៧] ដីកាដែលរងការជំទាស់ កថាខណ្ឌ ៧ (ចំណងជើង (ក) (iii))។

[៣៨] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៨។

[៣៩] ដីកាដែលរងការជំទាស់ កថាខណ្ឌ ២៤។

00709953



កិច្ចស៊ើបសួរ ២) អង្គហេតុដែលត្រូវបានបើកការស៊ើបអង្កេតរួចហើយ ឬ ៣) អង្គហេតុដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរនោះទេ។

៣៥. ខ្ញុំបានពិចារណាទៅលើទឡ្ហីករណ៍ដែលលើកឡើងដោយសហមេធាវី ទាក់ទិននឹង អ.ប.ជ៥៣ និងទទួលស្គាល់ថា កថាខណ្ឌ ៤ នៃទស្សនៈដាច់ដោយឡែករបស់ចៅក្រម MARCHI-UHEL ចៅក្រម ន័យ ធុល និងចៅក្រម ហួត វុទ្ធី ("ទស្សនៈនៅក្នុង អ.ប.ជ៥៣") អាចបណ្តាលឲ្យសហមេធាវីជឿជាក់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្កើតនូវទំនាក់ទំនងរវាងព្យសនកម្មដែលបានលើកឡើង ជាមួយនឹងអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក្រោមផ្នែកដែលមានចំណងជើងថា "ការចូលរួម និងការដឹងឮ" នឹងត្រូវបានទទួលស្គាល់ ដោយមិនគិតថា អង្គហេតុទាំងនោះជាអង្គហេតុសម្ភារៈមែន ឬក៏មិនមែននោះឡើយ ហើយដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា ដែលស្ថិតនៅក្រោមបទល្មើសជាក់លាក់ណាមួយ ដែលត្រូវបានសហព្រះរាជអាជ្ញាសំណូមពរឲ្យធ្វើការចោទប្រកាន់ និងដោយសារតែដីកាដំណោះស្រាយត្រូវបានចេញរួចហើយ ហើយជនជាប់ចោទត្រូវបានបញ្ជូនខ្លួនទៅជំនុំជម្រះ។ ការបកស្រាយនេះមិនមានចេតនាដូច្នោះទេ។ ជាចៅក្រមម្នាក់ក្នុងចំណោមចៅក្រមដែលជាអ្នកបញ្ចេញទស្សនៈទៅលើ អ.ប.ជ៥៣ ខ្ញុំជឿជាក់ថា អង្គហេតុដែលស្ថិតក្នុងកថាខណ្ឌ៨(ឃ) និង (ង) នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏មាននៅក្នុងអង្គហេតុសម្ភារៈក្នុងផ្នែកស្តីពី "បទល្មើស" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរផងដែរ ជាពិសេសនៅក្នុងផ្នែក ដែលមានចំណងជើងថា "ការធ្វើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅដោយអមនុស្សធម៌ និងការឃុំខ្លួនដោយខុសច្បាប់" ឬក្នុងផ្នែក "ការសម្លាប់ ការធ្វើទារុណកម្ម និងការរំលោភបំពានលើផ្នែករាងកាយ និងផ្លូវចិត្ត"។ ទស្សនៈទៅលើ អ.ប.ជ៥៣ គឺបានសំអាងទាំងមិនច្បាស់លាស់ទៅលើការយល់ឃើញដោយខុសឆ្គងបែបនេះ។

៣៦. ដោយហេតុថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបានចេញរួចហើយ ទើបខ្ញុំមានឱកាសដើម្បីពិចារណានៅពេលនេះថា ឯកសារយោងទៅលើអង្គហេតុជាច្រើននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមិនត្រូវបានចាត់ទុកថាជា "បទល្មើស" ក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ នោះទេ ហើយបានលេចឡើងជាថ្មីម្តងទៀត ថាជាអង្គហេតុសម្ភារៈដែលស្ថិតនៅក្នុងបទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នេះមិនមែនជាករណីសម្រាប់

អង្គហេតុទាំងអស់ដែលអាចរកឃើញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមណាមួយ ឬក៏នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ[៤០]។ ជាឧទាហរណ៍ សហព្រះរាជអាជ្ញាមិនបានអះអាងចំពោះអង្គហេតុដែលអ្នកដាក់ពាក្យ

---

[៤០] ខ្ញុំបានកត់សម្គាល់ឃើញថា ម្ចាស់បណ្ដឹងឧទ្ធរណ៍បានវែកញែកយ៉ាងប្រុងប្រយ័ត្ន នូវសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះក្នុង អ.ប.ជ៥៣ ដែលការពិនិត្យទៅលើស្ថានភាពរបស់អ្នកដាក់ពាក្យសុំបែបនេះ អាចមានលក្ខណៈជាការផ្ដល់ព័ត៌មាននៅក្នុងការបង្ហាញនូវទំនាក់ទំនងរវាងការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី យោងតាមបទល្មើសដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាមួយព័ត៌មានដែលផ្ដល់ឲ្យដោយអ្នកដាក់ពាក្យសុំនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលដីកាសន្និដ្ឋានបែបនេះបានរៀបរាប់ពីវិសាលភាពនៃកិច្ចស៊ើបសួរ។ អ្នកដាក់ពាក្យសុំក្នុង អ.ប.ជ៥៣ បានប្ដឹងពីព្យសនកម្មដែលជាលទ្ធផលនៃការចាប់ខ្លួនគាត់នៅក្រសួងការបរទេស ("ក្រសួង")។ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ផ្នែកដែលមានចំណងជើងថា ការចូលរួម និងការដឹងឮ របស់ជនត្រូវចោទអៀង សារី (កថាខណ្ឌ ៨៧ ដល់៨៨) សហព្រះរាជអាជ្ញាបានបញ្ជាក់ថា អៀង សារី បានចូលរួម ធ្វើផែនការ ត្រួតពិនិត្យ និងសម្របសម្រួលដល់ការចាប់ខ្លួន និងការសម្លាប់បុគ្គលិកនៅក្នុងក្រសួង (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៨៨ (ឃ))។ បុគ្គលមួយចំនួនដែលត្រូវបានឃុំឃាំងខ្លួននៅក្រសួង ហើយក្រោយមកត្រូវបានគេឃុំឃាំង ធ្វើទារុណកម្ម និងទទួលរងនូវអំពើសាហាវព្រៃផ្សៃនានា នៅពេលដែលពួកគេត្រូវបានបញ្ជូនទៅកន្លែងអប់រំកែប្រែនានា ដូចជា មន្ទីរម១ របស់ក្រសួងនៅបឹងត្របែក និងច្រាំងចំរេះ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៨៨(ង))។ អ្នកដាក់ពាក្យសុំមិនត្រូវបានគេបញ្ជូនទៅបឹងត្របែក ឬច្រាំងចំរេះនោះទេ។ ចៅក្រមដែលបានបញ្ចេញទស្សនៈនៅក្នុង អ.ប.ជ៥៣ បានយល់ឃើញថា យោងតាមអង្គហេតុដែលមាននៅក្នុងញសុំរបស់ខ្លួន អ្នកដាក់ពាក្យសុំខកខានមិនបានបង្ហាញឲ្យឃើញថា ខ្លួនស្ថិតនៅក្រោមការចាប់ខ្លួននៅឯក្រសួងនោះឡើយ (ទស្សនៈយល់ឃើញ កថាខណ្ឌ ៤)។ ចៅក្រមដែលបានបញ្ចេញទស្សនៈនៅក្នុង អ.ប.ជ ៥៣ បានធ្វើការកត់សម្គាល់ទៅលើអង្គហេតុដែលថា សេរីភាពក្នុងការដើរហើររបស់គាត់ត្រូវបានហាមឃាត់យ៉ាងតឹងរ៉ឹង ប៉ុន្តែ បានពិចារណាថា គាត់មិនមែនជាកម្មវត្ថុនៃ "ការចាប់ខ្លួនដែលត្រឹមត្រូវនោះទេ" (ទស្សនៈនៅក្នុង អ.ប.ជ ៥៣ កថាខណ្ឌ ៤)។ ចៅក្រមបានកត់សម្គាល់ឃើញថា តាមបទពិសោធន៍របស់អ្នកដាក់ពាក្យសុំ ដូចជាការឃុំខ្លួន ការធ្វើទារុណកម្ម និងការប្រព្រឹត្តឃោរឃៅ ដែលគាត់បានទទួលរងក្នុងនាមជាបុគ្គលិកក្រសួង អាចភ្ជាប់នូវទំនាក់ទំនងជាមួយបទល្មើសដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ប្រសិនបើអ្នកដាក់ពាក្យសុំបានទទួលរងនូវបទពិសោធន៍បែបនេះក្នុងទីតាំងណាមួយដែលជាផ្នែកនៃបទល្មើស ដែលត្រូវធ្វើការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនានារបស់សហព្រះរាជអាជ្ញា។ ដោយសារតែសហព្រះរាជអាជ្ញាបានកំណត់យ៉ាងជាក់លាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថាបុគ្គលិករបស់ក្រសួងត្រូវទទួលរងនូវការប្រព្រឹត្តមិនសមរម្យនៅ "មន្ទីរឃុំឃាំងជាច្រើន" ដូចជា មន្ទីរម១ របស់ក្រសួងនៅច្រាំងចំរេះ និងបឹងត្របែក" តែមិនមែននៅក្នុងក្រសួងផ្ទាល់នោះទេ។ ហេតុដូច្នេះ ចៅក្រមដែលបានបញ្ចេញទស្សនៈ

សុំបានលើកឡើងនៅក្នុង អ.ប.ជ៥៣ នោះឡើយ (ការឃុំឃាំង និងការប្រព្រឹត្តមិនសមរម្យ ដែលធ្វើឡើងចំពោះបុគ្គលិកក្រសួងការបរទេស នៅក្នុងអគាររបស់ក្រសួងនេះ) ថាជាអង្គហេតុសម្ភារៈនៃបទល្មើស ដែលបានចោទប្រកាន់នៅក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម)។ ដោយសារតែសហចៅក្រមស៊ើបអង្កេតមិនអាចពង្រីកបទល្មើស ដែលកំណត់ដោយសហព្រះរាជអាជ្ញាដើម្បីបើកកិច្ចស៊ើបសួរ នោះអ្នកដាក់ពាក្យសុំក្នុង អ.ប.ជ ៥៣ មិនអាចទទួលបានជោគជ័យនៅក្នុងការដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនបានឡើយ។

**មូលដ្ឋានទី ៥៖ អនុលោមតាមវិធាន ២៣(២)(ក) នៃវិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៤ និងវិសោធនកម្មមុនៗ) និងវិធាន ២៣ *ស្ទួន*(១)(ខ) (វិសោធនកម្មលើកទី ៥) ការបង្កើតពាក្យ "ព្យសនកម្ម" និង "ផលវិបាកដោយផ្ទាល់" ទាំងមិនត្រឹមត្រូវ បានបណ្តាលឱ្យមានការបដិសេធជនរងគ្រោះដែលបានទទួលរងការឈឺចាប់ពីព្យសនកម្ម ដែលជាផលវិបាកដោយផ្ទាល់នៃការមើលឃើញ ឬ ការដឹងឮអំពីឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ឬដែលស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ។**

៣៧. សហមេធាវីបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងការសម្រេចបដិសេធពាក្យសុំរបស់ជនរងគ្រោះដែលអះអាងថា ខ្លួនបានទទួលរងព្យសនកម្មផ្លូវចិត្តដែលជាផលវិបាកដោយផ្ទាល់កើតចេញពីការបានឃើញការប្រព្រឹត្តឧក្រិដ្ឋកម្មមួយ។ អ្នកដាក់ពាក្យសុំបានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានសម្រេចមិនទទួលយកពាក្យសុំរបស់ពួកគាត់ ដោយសារតែសហចៅក្រមស៊ើបអង្កេតភ័ន្តច្រឡំ និងអនុវត្តមិនត្រឹមត្រូវនូវលក្ខខណ្ឌតម្រូវនៃ "ព្យសនកម្មដែលជាផលវិបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្ម"។ ដើមបណ្តឹងឧទ្ធរណ៍បានផ្អែកទៅលើយុត្តិសាស្ត្រដែលមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានសម្រេចថា "ការប៉ះទង្គិចផ្លូវចិត្តដែលជាលទ្ធផលនៃ'ការបានឃើញព្រឹត្តិការណ៍ដែលមានលក្ខណៈព្រៃផ្សៃហួសហេតុ និងគួរឱ្យរន្ធត់ "អាចបំពេញលក្ខខណ្ឌដើម្បីឱ្យបុគ្គលនោះទទួល

---

នៅក្នុង អ.ប.ជ៥៣ មិនអាចសន្និដ្ឋានថា ព្យសនកម្មដែលអ្នកដាក់ពាក្យសុំបានទទួល អាចភ្ជាប់ទំនាក់ទំនងជាមួយបទល្មើសដែលជនត្រូវចោទស្ថិតក្រោមកិច្ចស៊ើបសួរតាមផ្លូវតុលាការនោះទេ (ទស្សនៈនៅក្នុង អ.ប.ជ៥៣ កថាខណ្ឌ ៤ ដល់ ៥)។

00709956



បានឋានៈជាជនរងគ្រោះ"[៤១]។ កថាខណ្ឌ ១៤ នៃដីកាដែលរងការជំទាស់បង្ហាញពីស្ថានភាពរបស់អ្នកដាក់ពាក្យសុំដែលបានឃើញឧក្រិដ្ឋកម្ម ហើយការបង្ហាញនេះធ្វើទៅតាមការវែកញែករបស់សហចៅក្រមស៊ើបអង្កេត ដែលលើកឡើងពីការសន្មតទុកជាមុនថា មានព្យសនកម្មផ្លូវចិត្តចំពោះប្រភេទអ្នកដាក់ពាក្យសុំជាក់លាក់មួយចំនួន និងព្យសនកម្មទាក់ទងទៅនឹងបទឧក្រិដ្ឋជាក់លាក់មួយចំនួន។ ដោយយល់ឃើញថា មានការសន្មតទុកជាមុនថា មានព្យសនកម្មផ្លូវចិត្តចំពោះក្រុមគ្រួសារសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះផ្ទាល់ (ដែលមានដូចជា ឪពុកម្តាយ កូនៗ សហព័ទ្ធ និងបងប្អូនបង្កើតរបស់ជនរងគ្រោះ) ដីកាដែលរងការជំទាស់បានសន្និដ្ឋានដូចខាងក្រោម ចំពោះអ្នកដាក់ពាក្យសុំដែលបានឃើញឧក្រិដ្ឋកម្មនានា៖

> "ហេតុដូច្នេះ ព្យសនកម្មផ្លូវចិត្តដោយផ្ទាល់ ដែលបានលើកឡើងដោយអ្នកដាក់ពាក្យសុំដែលពាក់ព័ន្ធនឹងអំពើមនុស្សឃាត ឬការបាត់ខ្លួនសាច់ញាតិ គឺមានលក្ខណៈងាយស្រួលក្នុងការទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ជាងក្នុងករណីនៃការរៀបការដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា។ ការផ្តល់សំអាងហេតុដូចគ្នាត្រូវតែយកមកអនុវត្តផងដែរ ក្នុងករណីដែលអ្នកស្នើសុំ គឺជាសាក្សីធម្មតាចំពោះអង្គហេតុដែលស្ថិតនៅក្រោមការស៊ើបអង្កេត ដែលថា៖ ព្យសនកម្មផ្លូវចិត្តបង្កប់នូវកម្រិត និងលក្ខណៈដោយឡែក ផ្សេងពីការឈឺចាប់ផ្នែកអារម្មណ៍ដែលសាក្សីធម្មតាត្រូវបង្ហាញ ហើយពាក្យស្នើសុំរបស់ពួកគាត់ នឹងត្រូវបដិសេធចោល លើកលែងតែថា សាក្សីនោះបង្ហាញថា ខ្លួនបានឃើញអង្គហេតុនៃអំពើហិង្សាដែលគួរឲ្យរន្ធត់ ព្រៃផ្សៃហួសហេតុនោះ"[៤២]។

៣៨. ជាការកត់សម្គាល់បឋមមួយ ខ្ញុំសូមសង្កត់ធ្ងន់ថា ខ្ញុំបានពិចារណា*ជាផ្លូវការ* (ex officio) ចំពោះការអនុវត្តនូវការសន្មតទុកជាមុននានា ដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងសាល

---

[៤១] អ្នកដាក់ពាក្យសុំបានយោងទៅលើសាលដីកាដូចខាងក្រោម របស់តុលាការ ICC ស្តីពីស្ថានភាពនៅក្នុងប្រទេសអ៊ូហ្គង់ដា ក្នុងសំណុំរឿង រដ្ឋអាជ្ញា *តទល់នឹង* Joseph Kony និងអ្នកដទៃទៀត៖ សាលដីកាលើពាក្យសុំរបស់ជនរងគ្រោះដើម្បីចូលរួមក្នុងដំណើរកិច្ចនីតិវិធី ឯកសារលេខ A/0010/06, a/0064/06 ដល់ a/0070/06, a/0081/06 ដល់ a/0104/06 និង a/0111 ដល់ a/0127/06 ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ ICC-02/04-01-01/05-252 កថាខណ្ឌ ២៧ និងកថាខណ្ឌ ៣១ កថាខណ្ឌ ៣៦ និងកថាខណ្ឌ ៥០។

[៤២] ដីការងការជំទាស់ កថាខណ្ឌ ១៤(ឃ)។



ឧបនៃជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

ដីកានេះ (សូមមើលមូលដ្ឋានទី ១០ និងមូលដ្ឋានទី ១១)។ ខណៈដែលសហចៅក្រមស៊ើបអង្កេតមិនបានយោងទៅលើឯកសារច្បាប់ណាមួយ ដើម្បីគាំទ្រដល់ការរកឃើញរបស់ខ្លួនថា អ្នក ដែលបានឃើញព្រឹត្តិការណ៍ដែលមានលក្ខណៈព្រៃផ្សៃហួសហេតុ និងគួរឱ្យរន្ធត់ អាចបំពេញលក្ខខណ្ឌតម្រូវដើម្បីក្លាយជាដើមបណ្តឹងរដ្ឋប្បវេណី សហចៅក្រមស៊ើបអង្កេតបានប្រើពាក្យពេចន៍ដែលមាននៅក្នុងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍។ដោយមើលទៅលើបរិបទ នៃការសម្រេចដូចបានរៀបរាប់ពីខាងលើនេះ ខ្ញុំយល់ឃើញបានថា បុគ្គលបែបនេះត្រូវបានគេសន្មតទុកជាមុនថា បានទទួលរងព្យសនកម្មផ្លូវចិត្ត ដែលជាលទ្ធផលនៃការបានឃើញព្រឹត្តិការណ៍ទាំងនោះ។ ខ្ញុំយល់ស្របទៅនឹងការយល់ឃើញបែបនេះ។ ប៉ុន្តែ ខ្ញុំយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការសម្រេចថា ពាក្យសុំរបស់អ្នកដែលបានឃើញឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នឹងត្រូវបដិសេធចោលបាន វៀរលែងតែសាក្សីទាំងនោះបានឃើញព្រឹត្តិការណ៍ដែលមានលក្ខណៈព្រៃផ្សៃហួសហេតុ និងគួរឱ្យរន្ធត់តែប៉ុណ្ណោះ។ ខ្ញុំមិនយល់ឃើញថា សាក្សីទាំងឡាយដែលបានឃើញព្រឹត្តិការណ៍នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ដែលមិនមានលក្ខណៈព្រៃផ្សៃហួសហេតុ និងគួរឱ្យរន្ធត់ នឹងមិនអាចបំពេញលក្ខខណ្ឌដើម្បីបានក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។ តាមពិតទៅ ក្រុមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រភេទនេះគួរតែអាចជ្រើសរើសស្វែងរកភស្តុតាងដើម្បីបង្ហាញថា ពួកគាត់អាចទទួលរងព្យសនកម្មផ្លូវចិត្ត ដែលជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តមកលើជនរងគ្រោះ។ ខ្ញុំយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ នៅក្នុងការយល់ឃើញថា ពាក្យសុំរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីប្រភេទនេះ នឹងត្រូវបានបដិសេធចោល វៀរលែងតែពួកគាត់បានឃើញព្រឹត្តិការណ៍ដែលមានលក្ខណៈព្រៃផ្សៃហួសហេតុ និងគួរឱ្យរន្ធត់តែប៉ុណ្ណោះ។

៣៩. ក្នុងករណីដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្វែងរកការទទួលយកឱ្យធ្វើជាសាក្សីដែលបានឃើញព្រឹត្តិការណ៍ ដែលមិនត្រូវបានចាត់ទុកថា ជាព្រឹត្តិការណ៍មានលក្ខណៈព្រៃផ្សៃហួសហេតុ និងគួរឱ្យរន្ធត់នោះ ខ្ញុំយល់ឃើញថា អ្នកដាក់ពាក្យសុំត្រូវបង្ហាញភស្តុតាង ដើម្បីបញ្ជាក់ថា វាអាចឱ្យជឿជាក់បានថា ខ្លួនបានទទួលរងព្យសនកម្មផ្លូវចិត្ត ដែល



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE

ជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងមកលើជនរងគ្រោះផ្ទាល់។ ជាឧទាហរណ៍ នៅក្នុងបណ្ដឹងឧទ្ធរណ៍ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ជូនសេចក្ដីអះអាងរបស់អ្នកដាក់ពាក្យសុំដែលបានឃើញការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ អ្នកដាក់ពាក្យសុំអះអាងថា គាត់ភិតភ័យយ៉ាងខ្លាំងនៅពេលដែលបានឃើញឧក្រិដ្ឋកម្មទាំងនេះ ព្រោះគាត់ជឿជាក់ថា ប្រជាជនដែលត្រូវបានបំបែកនោះនឹងត្រូវគេយកទៅសម្លាប់ចោល។ ខ្ញុំមិនមានមូលហេតុអ្វីដែលត្រូវសង្ស័យទេថា ការអះអាងបែបនេះគឺជាការពិត ហើយខ្ញុំយល់ឃើញថា កាលៈទេសៈនាពេលនោះគឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីអាចឲ្យជឿបានថា អ្នកដាក់ពាក្យសុំអាចទទួលរងព្យសនកម្មផ្លូវចិត្ត ដែលជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តមកលើជនរងគ្រោះផ្ទាល់ពីការជម្លៀសចេញពីភ្នំពេញ។ ប៉ុន្តែ ខ្ញុំយល់ឃើញថា ខណៈដែលខ្ញុំបានទទួលយកការអះអាងដែលធ្វើឡើងដោយមេធាវីរបស់ដើមបណ្ដឹងឧទ្ធរណ៍ ដែលបានអះអាងថា បានទទួលការណែនាំដោយផ្ទាល់ពីកូនក្ដីរបស់ខ្លួន នោះខ្ញុំក៏មិនទទួលយកការស្មានរបស់មេធាវីទាំងនោះ ចំពោះការជឿជាក់របស់ពួកគាត់ ថាតើកូនក្ដីរបស់ពួកគាត់បានទទួលរងព្យសនកម្មផ្លូវចិត្តប៉ុនណានោះ។

៤០. សហមេធាវីក៏បានលើកឡើងផងដែរថា "តាមរយៈការពន្លាត" ការយល់ឃើញមុនៗទាក់ទៅនឹងការឈឺចាប់កើតមានចំពោះជនរងគ្រោះ ដែលបានឃើញព្រឹត្តិការណ៍ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ នោះបុគ្គលទាំងឡាយ រួមទាំងសមាជិកគ្រួសារសាច់ឆ្ងាយ និងអ្នកដែលរស់នៅក្រៅប្រទេស ដែលបានដឹងអំពីឧក្រិដ្ឋកម្ម ប្រព្រឹត្តឡើងមកលើប្រជាជននៅក្នុងប្រទេសកម្ពុជាក៏អាចត្រូវបានពិចារណាក្នុងក្របខ័ណ្ឌដូចគ្នាថា ពួកគាត់ត្រូវបានសន្មតទុកជាមុនថា បានទទួលរងព្យសនកម្មផ្លូវចិត្ត ដោយសារតែការដឹងឮនេះ។ ខ្ញុំសូមរំឭកថា តាមការយល់ឃើញរបស់ខ្ញុំ ទំនាក់ទំនងដែលត្រូវបង្ហាញឲ្យឃើញរវាងអ្នកដាក់ពាក្យសុំប្រភេទនេះ គឺជាទំនាក់ទំនងរវាងព្យសនកម្មដែលបានទទួលរង និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ ជាជាងទំនាក់ទំនងរវាងព្យសនកម្ម និងវិសាលភាពដ៏ទូលំទូលាយនៃព្រឹត្តិការណ៍ដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរទៅវិញ។ ស្ថានភាពដែលថា បុគ្គលម្នាក់បានឃើញឧក្រិដ្ឋកម្មណាមួយនោះ មិនប្រាកដថាមានលក្ខណៈដូចគ្នាទៅនឹងស្ថានភាពរបស់បុគ្គលដែលបានដឹងឮអំពីឧក្រិដ្ឋកម្ម តាមមធ្យោបាយផ្សេងទៀត ក្រៅពីការបានឃើញនូវការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះមក





PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

00709959



លើសាច់ញាតិរបស់ពួកគាត់នោះទេ។ ចំពោះមូលហេតុដូចបានបញ្ជាក់ខាងក្រោម (មូលដ្ឋានទី ១០ និងមូលដ្ឋានទី ១១) ខ្ញុំយល់ឃើញថា សមាជិកក្រុមគ្រួសារសាច់ញាតិឆ្ងាយរបស់ជនរងគ្រោះផ្ទាល់ ត្រូវបានសន្មតទុកជាមុនថាបានទទួលរងព្យសនកម្មផ្លូវចិត្ត ដោយសារតែឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងមកលើសាច់ញាតិរបស់ពួកគាត់។ ហេតុដូច្នេះ មិនចាំបាច់បង្ហាញដាច់ដោយឡែកពីគ្នានូវផលប៉ះពាល់ពីការដឹងឮរបស់អ្នកដាក់ពាក្យសុំដែលថា សមាជិកនៃក្រុមគ្រួសាររបស់ខ្លួនគឺជាជនរងគ្រោះផ្ទាល់នៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ចំពោះជនជាប់ចោទនោះឡើយ។

## III. អង្គសេចក្តី៖ ការភាន់ច្រឡំផ្នែកអង្គហេតុ

### មូលដ្ឋានទី៦៖ ព័ត៌មានមិនគ្រប់គ្រាន់ - ការជម្លៀសដោយបង្ខំ

៤១. អ្នកដាក់ពាក្យសុំជាច្រើននាក់ចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការសម្រេចថា ពួកគាត់ផ្តល់ឲ្យព័ត៌មានមិនគ្រប់គ្រាន់ ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ២៣ *ស្ទួន*(១) និងវិធាន ២៣ *ស្ទួន*(៤) នៃវិធានផ្ទៃក្នុង ដោយពួកគាត់បានពណ៌នាថា ខ្លួនត្រូវបានជម្លៀសពីទីក្រុងឲ្យទៅរស់នៅទីជនបទ។ ខ្ញុំបានពិនិត្យឡើងវិញទៅលើសារណា ពាក្យសុំ និងឯកសារភស្តុតាងបន្ថែម នៅពេលដែលអាចធ្វើទៅបាន ដើម្បីសម្រេចថាតើអ្នកដាក់ពាក្យសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីអាចឲ្យជឿជាក់ថា បានបំពេញលក្ខខណ្ឌនៃវិធានផ្ទៃក្នុងដែរឬអត់។ បើនិយាយឲ្យទូលំទូលាយទៅ ខ្ញុំបានសង្កេតឃើញថា អ្នកដាក់ពាក្យសុំដែលបានអះអាងថា បានជួបប្រទះនូវការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី ២ និងទី ៣ ដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងរវាងឧក្រិដ្ឋកម្មនានា ដូចបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៤២. ប៉ុន្តែ ខ្ញុំបានកត់សម្គាល់ឃើញថា អ្នកដាក់ពាក្យសុំជាច្រើននាក់មិនបានរៀបរាប់អំពីបទពិសោធន៍របស់ខ្លួនឲ្យបានលម្អិតនោះទេ គឺពួកគាត់គ្រាន់តែអះអាងយ៉ាងសាមញ្ញថា ពួកគាត់

00709960



ត្រូវបានជម្លៀសដោយបង្ខំនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ តែប៉ុណ្ណោះ[៤៣]។ ទឡ្ហីករណ៍របស់សហមេធាវីដែលធ្វើឡើងក្នុងនាមឱ្យអ្នកដាក់ពាក្យសុំទាំងនោះ ទោះជាវិជ្ជមាន ឬអវិជ្ជមានក្ដី មិនបានបង្ហាញជាក់លាក់ថាតើអ្នកដាក់ពាក្យសុំទាំងនោះ ត្រូវបានជម្លៀសដោយបង្ខំដូចបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះដែរឬអត់នោះទេ។ បញ្ហាគឺថាតើនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាមានបំណងកំហិតអង្គហេតុដែលត្រូវស៊ើបអង្កេត ពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំនៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ឱ្យមកត្រឹមតែការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ ឬម្យ៉ាងវិញទៀត បានពន្លាតដើម្បីគ្របដណ្ដប់ទៅលើបទចោទ ទាំងការជម្លៀសដោយបង្ខំពីទីក្រុងនានា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ ឬ ទីកន្លែងដទៃទៀតដែរឬយ៉ាងណានោះ ត្រូវបានបញ្ជាក់ដោយសហព្រះរាជអាជ្ញារួចហើយ[៤៤]។ ដើម្បីជាការឆ្លើយតបទៅនឹងសំណួរផ្ទាល់របស់សហចៅក្រមស៊ើបអង្កេត ដែលបានចោទសួរតាមរយៈដីកាបញ្ជូនរឿងទៅពិនិត្យស្ដីពីភាពមិនច្បាស់លាស់ ដែលអាចមាននៅក្នុងកថាខណ្ឌ ៣៧ ដល់ ៣៩ នៃដីកាបញ្ជូនរឿងឱ្យស៊ើបសួរ សហព្រះរាជអាជ្ញាបានបំភ្លឺដូចខាងក្រោម៖

> 'កថាខណ្ឌទី ៣៧ ដល់ ៣៩ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រួមបញ្ចូលនូវសំណើមួយដើម្បីបើកការស៊ើបសួរទៅលើការជម្លៀសមនុស្សដោយបង្ខំពីទីក្រុងភ្នំពេញ (ដូចបានលើកឡើងនៅក្នុងចំណងជើង ពីមុខកថាខណ្ឌទាំងនោះ)។ កថាខណ្ឌទី ៣៩ រៀបរាប់អំពីដើមកំណើតនៃគោលនយោបាយដែលនាំឱ្យមានការជម្លៀស ហើយបានធ្វើការកត់សម្គាល់

---

[៤៣] ខ្ញុំពិចារណាឃើញថា ការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី ២ និងទី ៣ មិនអាចអនុវត្តបានទេ ដោយហេតុថាព្រឹត្តិការណ៍នៃការជម្លៀសដោយបង្ខំទាំងនេះ កើតឡើងនៅក្រៅក្របខ័ណ្ឌពេលវេលា ដែលបានពណ៌នាដោយអ្នកដាក់ពាក្យសុំប្រភេទនេះ។

[៤៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១ កថាខណ្ឌ ៤។ សេចក្ដីបញ្ជាក់នេះត្រូវបានធ្វើឡើងដោយអនុលោមតាមដីកាបញ្ជូនរឿងទៅពិនិត្យ ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៨ ចេញដោយសហចៅក្រមស៊ើបអង្កេត ឯកសារលេខ D77 ("ដីកាបញ្ជូនរឿងទៅពិនិត្យ")។

**០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៦, អបជ ១១២ អបជ ១១៣ អបជ ១១៤ អបជ ១១៥ អបជ ១៤២ អបជ ១៥៧ អបជ ១៦៤ អបជ ១៦៥ និង អបជ ១៧២)**

យ៉ាងសាមញ្ញថា គោលនយោបាយនេះត្រូវបានអនុវត្តចំពោះទីក្រុងទាំងអស់នៅក្នុងប្រទេសកម្ពុជា មិនមែន*សម្រាប់តែ*ទីក្រុងភ្នំពេញប៉ុណ្ណោះទេ *(មានគូសបញ្ជាក់បន្ថែម)*"[៤៥] ។

៤៣. យោងតាមការបំភ្លឺខាងលើនេះ អង្គហេតុដែលសហចៅក្រមស៊ើបអង្កេតទទួលបាននោះមិនរួមបញ្ចូលនូវការជម្លៀសដោយបង្ខំនៅតាមបណ្តាទីក្រុងនានា ក្រៅពីទីក្រុងភ្នំពេញនៅក្នុងខែមេសា ឆ្នាំ១៩៧៥ នោះទេ។ ហេតុដូច្នេះ ខ្ញុំយល់ឃើញថា អ្នកដាក់ពាក្យសុំណាម្នាក់ដែលស្នើសុំឱ្យទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈបណ្តឹងឧទ្ធរណ៍របស់ខ្លួនពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនដោយបង្ខំចេញពីទីប្រជុំជននានាក្នុងឆ្នាំ ១៩៧៥ ក្រៅពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ និងក្រៅពីអង្គហេតុដូចមានបញ្ជាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលអង្គហេតុទាំងនោះបង្កើតជាផ្នែកមួយនៃការជម្លៀសប្រជាជននៅដំណាក់កាលទី ២ ឬទី ៣ នោះដោយផ្អែកលើមូលដ្ឋាននេះ អ្នកដាក់ពាក្យសុំទាំងនោះមិនអាចទទួលយកបានឡើយ។

## មូលដ្ឋានទី៧៖ ព័ត៌មានមិនគ្រប់គ្រាន់ - ការសម្លាប់នៅទីកន្លែងផ្សេងៗទៀតក្រៅពីទីកន្លែងដែលបានកត់ត្រា

៤៤. អ្នកដាក់ពាក្យសុំមួយចំនួនធ្វើការចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការសម្រេចថា ពួកគាត់មិនបានផ្តល់ឱ្យព័ត៌មានមិនគ្រប់គ្រាន់ ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ២៣ *ស្ទួន*(១) និងវិធាន ២៣ *ស្ទួន*(៤) នៃវិធានផ្ទៃក្នុងទេ ដោយពួកគាត់បានលើកឡើងអំពីឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតដែលមានលក្ខណៈដូចគ្នា បន្ថែមលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់រួចហើយ ប៉ុន្តែ ត្រូវបានប្រព្រឹត្តនៅតាមការដ្ឋាន សហករណ៍ មន្ទីរសន្តិសុខ ឬទីកន្លែងសម្លាប់មនុស្សផ្សេងទៀត បន្ថែមទៅលើទីកន្លែងដែលត្រូវបានកំណត់រួចហើយ នៅក្នុងឯកសារចោទប្រកាន់ ហើយដែលចុងក្រោយក្លាយជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[៤៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើកទី ១ កថាខណ្ឌ ៤។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

៤៥. ម្យ៉ាងវិញទៀត ក្នុងការពិនិត្យទៅលើទឡ្ហីករណ៍នេះ ខ្ញុំបានកត់សម្គាល់នូវភាពមិនស្របគ្នាមួយ រវាងសំណៅជាភាសាខ្មែរ និងភាសាបារាំង ក្នុងប្រយោគទីពីរនៃកថាខណ្ឌ ១៣៧៣ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសំអាងហេតុតាមផ្លូវច្បាប់ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការធ្វើមនុស្សឃាត ដែលត្រូវបានប្រព្រឹត្តនៅតាមកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខនានា ជាមួយនឹងសំណៅជាភាសាអង់គ្លេស។ ទោះបីជាសំណៅជាភាសាអង់គ្លេសបញ្ជាក់ថា មានធាតុផ្សំគ្រប់គ្រាន់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមរូបភាពជាការធ្វើមនុស្សឃាត ហើយថាអង្គហេតុទាំងនេះពាក់ព័ន្ធទៅនឹងអ្នកដែលត្រូវបានសម្លាប់នៅតាមកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខនានាដែលបានរៀបរាប់យ៉ាងណាក៏ដោយ ក៏សំណៅជាភាសាបារាំង និងភាសាខ្មែរនៃកថាខណ្ឌនេះប្រើឃ្លាមួយដែលលើកឡើងថា បញ្ជីរៀបរាប់ទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខនានាដែលចោទជាបញ្ហា គឺគ្មានដែនកំណត់ឡើយ[៤៦]។ ពុំមានភាពខុសគ្នាបែបនេះកើតមានឡើងរវាងសំណៅទាំងបីភាសានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទិនទៅនឹងអំពើមនុស្សឃាតនៅតាមការដ្ឋានធ្វើការ និងនៅតាមសហករណ៍នានា ព្រមទាំងក្នុងអំឡុងដំណាក់កាលទី ១ និងដំណាក់កាលទី ៣ នៃការផ្លាស់ទីលំនៅប្រជាជន និងទាក់ទងទៅនឹងការប្រព្រឹត្តមកលើពុទ្ធសាសនិក ជនជាតិវៀតណាម និងជនជាតិចាម ពីព្រោះដីកាបញ្ជូនរឿងទៅជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា មានតែការកាប់សម្លាប់ទាំងឡាយ ដែលបានកើតឡើងនៅតាមទីកន្លែងជាក់លាក់ ឬនៅក្នុងអំឡុងព្រឹត្តិការណ៍ ឬកាលៈទេសៈជាក់លាក់ដែលបានបញ្ជាក់ប៉ុណ្ណោះ ទើបត្រូវបានចោទប្រកាន់។

---

[៤៦] សំណៅជាភាសាបារាំងនៃប្រយោគទីពីរនៃកថាខណ្ឌ ១៣៧៣ ចែងថា "[c]es faits concernent les personnes tuées dans les sites d'exécution *tels que* […]" ស្រដៀងគ្នាទៅនឹងសំណៅជាភាសាខ្មែរដែលចែងថា "បន្ថែមដើមប្រយោគទីពីរជាភាសាខ្មែរ"។ ការប្រើពាក្យពេចន៍នេះនៅក្នុងសំណៅជាភាសាបារាំង និងភាសាខ្មែរ ស្នើឡើងថា ការសម្លាប់នៅតាមទីកន្លែងសម្លាប់មនុស្ស ដូចជា ទីកន្លែងមួយដែលត្រូវបានកំណត់ នឹងត្រូវបានចោទប្រកាន់ ពុំបានឆ្លុះបញ្ចាំងនៅក្នុងសំណៅជាភាសាអង់គ្លេសដែលបញ្ជាក់ថា "អង្គហេតុទាំងនេះពាក់ព័ន្ធជាចម្បងទៅនឹងជនដែលត្រូវបានសម្លាប់នៅតាមកន្លែង សម្លាប់មនុស្សទាំងឡាយដូចជា នៅស្រុក ១២ […]" នោះឡើយ។ ទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខនានា ដែលចោទជាបញ្ហានោះ គឺជាទីកន្លែងសម្លាប់មនុស្សនៅ ក្នុងស្រុក ១២ ស្ទឹងតូច ទួលពោធិ៍ជ្រៃ និងជើងឯក នៅតាមមន្ទីរ សន្តិសុខនានា ដែលរួមមានមន្ទីរសន្តិសុខកោះខ្យង គោកក្ដួច ក្រាំងតាចាន់ មន្ទីរសន្តិសុខភូមិភាគឧត្តរ ភ្នំក្រោល អូរកន្សែង ព្រៃដំរីស្រុត ស-២១ សង់ វត្តគិរីរម្យ វត្តធ្លក។

00709963



៤៦. ខ្ញុំយល់ឃើញថា ភាពមានន័យមិនច្បាស់លាស់ដែលបណ្តាលមកពីភាពខុសគ្នានៅក្នុងប្រយោគទីពីរនៃកថាខណ្ឌ ១៣៧៣ លែងមានទៀតហើយ នៅពេលអានកថាខណ្ឌនេះ ជាមួយនឹងកថាខណ្ឌ ១៧៨ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ នៅក្នុងកថាខណ្ឌនោះ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា មន្ទីរសន្តិសុខប្រហែល ២០០ កន្លែង និងកន្លែងសម្លាប់មនុស្សយ៉ាងច្រើនរាប់មិនអស់ ត្រូវបានបង្កើតឡើង និងមានទីតាំងនៅគ្រប់ភូមិភាគទូទាំងប្រទេសកម្ពុជា ដែលជាផ្នែកមួយនៃគោលនយោបាយទាំងប្រាំដែលត្រូវអនុវត្ត និងការពារបដិវត្តន៍សង្គមនិយម រួមទាំងការអប់រំលត់ដំ "*សមាសភាពមិនល្អ*" និងការសម្លាប់ "*ខ្មាំង*" ទាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្ស និងបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតបានទទួល*ប្តឹងអំពីមន្ទីរសន្តិសុខចំនួន ១១ កន្លែង* ដែលក្នុងនោះរួមមាន (មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខកោះខ្យង មន្ទីរសន្តិសុខគោកក្តួច មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខភូមិភាគឧត្តរ មន្ទីរសន្តិសុខព្រៃដំរីស្រុត មន្ទីរសន្តិសុខភ្នំក្រោល មន្ទីរសន្តិសុខសង់ មន្ទីរសន្តិសុខវត្តគិរីរម្យ មន្ទីរសន្តិសុខវត្តធ្លក) និង*កន្លែងសម្លាប់មនុស្សចំនួនបីទៀត* ក្រៅពីជើងឯកដែលជាប់ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខ ស-២១៖ (កន្លែងសម្លាប់មនុស្សក្នុងស្រុក ១២ កន្លែងសម្លាប់មនុស្សស្ទឹងតូច កន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ[៤៧]។ យោងទៅលើការប្រើប្រាស់ពាក្យពេចន៍ដ៏ច្បាស់លាស់នេះ ខ្ញុំពុំមានចម្ងល់អ្វីទេថា ការកាប់សម្លាប់ដែលជនជាប់ចោទរងការចោទប្រកាន់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមរូបភាពជាការធ្វើមនុស្សឃាត ដែលត្រូវបានប្រព្រឹត្តឡើងនៅតាមទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខនានា ត្រូវបានកំណត់ត្រឹមការសម្លាប់ទាំងឡាយដែលត្រូវបានប្រព្រឹត្តឡើងនៅតាមទីកន្លែងនានា ដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ ១៣៧៣ តែប៉ុណ្ណោះ។ ហេតុដូច្នេះ ខ្ញុំយល់ឃើញថា អ្នកដាក់ពាក្យសុំអាចទទួលបានជោគជ័យនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន តែក្នុងករណីដែលអ្នកដាក់ពាក្យសុំផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីអាចឱ្យជឿជាក់បានថា អំពើមនុស្សឃាត ដែលបានប្រព្រឹត្តនៅតាមទីកន្លែងជាក់លាក់ណាមួយ ឬក្នុងអំឡុងនៃព្រឹត្តិការណ៍ដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[៤៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៧៨។

## មូលដ្ឋានទី៨៖ ការខកខានក្នុងការបង្ហាញអំពីទំនាក់ទំនងចាំបាច់ - ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា

### (i) <u>ការធ្វើទុក្ខបុកម្នេញផ្អែកសាសនាលើពុទ្ធសាសនិក</u>

៤៧. សហមេធាវី បានប្ដឹងជំទាស់ទៅនឹងការបដិសេធមិនទទួលយកអ្នកដាក់ពាក្យសុំ ដែលបានទទួលរងព្យសនកម្មបណ្ដាលមកពីការធ្វើទុក្ខបុកម្នេញទៅលើសាសនា ហើយក៏ប្ដឹងជំទាស់ផងដែរទៅលើការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតដែលថា ព្យសនកម្មត្រូវកំហិតត្រឹមតែព្រះសង្ឃនិង សាច់ញាតិជិតស្និទ្ធរបស់ព្រះសង្ឃអង្គនោះតែប៉ុណ្ណោះ។ ខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលមានការរកឃើញអង្គហេតុនៃឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងការប្រព្រឹត្តមកលើពុទ្ធសាសនិកនោះ សហចៅក្រមស៊ើបអង្កេតរកឃើញថា "បក្សកុម្មុយនីស្តកម្ពុជាបានអនុម័តគោលនយោបាយ *ហាមឃាត់មិនឱ្យមានព្រះពុទ្ធសាសនា និងគោរពព្រះពុទ្ធសាសនា*" (គូសបញ្ជាក់បន្ថែម)[៤៨]។ បន្ថែមទៅលើការចោទប្រកាន់ (១) ការបំផ្លាញវត្តអារាម និងទីសក្ការៈជាច្រើន ឬការប្រែក្លាយកន្លែងទាំងនោះដើម្បីគោលបំណងផ្សេងៗ ដូចជាយកធ្វើជាមន្ទីរសន្តិសុខ កន្លែងចិញ្ចឹមជ្រូក រោងបាយ មន្ទីរពេទ្យ ឬឃ្លាំងផ្ទុកសម្ភារៈ (២) ការកម្ទេចរូបសំណាកព្រះពុទ្ធ (៣) ការហាមឃាត់មិនឱ្យអុជធូប (៤) ការញុះញង់ឱ្យស្អប់ព្រះសង្ឃ និងដូនជី និង (៥) ការផ្សព្វផ្សាយការឃោសនាពាក់ព័ន្ធនានា នៅក្នុងកថាខណ្ឌដដែលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតបានលើកឡើងយ៉ាងជាក់លាក់ ដោយផ្អែកលើសក្ខីកម្មរបស់សាក្សីថា៖

> នៅពេលដែលខ្មែរក្រហមកាន់កាប់ទីនេះភ្លាម គេហាមមិនឱ្យមានសាសនា។ គេមិនអនុញ្ញាតឱ្យធ្វើបុណ្យធ្វើទានទេ លោកត្រូវគេផ្សឹកអស់។ មេកង មេភូមិ មេឃុំ គេប្រកាសថាមិនឱ្យមានអបិយជំនឿទេ[៤៩] (គូសបញ្ជាក់បន្ថែម)។

៤៨. កថាខណ្ឌបន្ទាប់ចោទប្រកាន់ថា ព្រះសង្ឃ និងដូនជីស្ទើរតែទាំងអស់ត្រូវបានចាប់ផ្សឹក ហើយ

---

[៤៨] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧៤០។

[៤៩] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧៤០។

ពួកគាត់មួយចំនួនត្រូវបានគំរាមសម្លាប់ បើសិនជាពួកគាត់មិនធ្វើតាមទេ[៥០]។ ទីបញ្ចប់ ផ្នែកដដែលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះបានប្រកាន់ថា "ការលុបបំបាត់សាសនា" កើតមាននៅគ្រប់តំបន់ទូទាំងប្រទេសកម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ[៥១]។

៤៩. ផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះមានចែងពីការឃើញទៅលើអង្គច្បាប់ ដែលពាក់ព័ន្ធទៅនឹងការធ្វើទុក្ខបុកម្នេញមកលើពុទ្ធសាសនិក ដោយចោទប្រកាន់ថា៖

> ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា បានកើតឡើងនៅគ្រប់តំបន់ទាំងអស់នៅកម្ពុជា ដូចជា (...)។ ការគោរពព្រះពុទ្ធសាសនាត្រូវបានហាមឃាត់។ វត្តអារាម និងវិហារត្រូវបានកម្ទេចចោល ឬប្រើប្រាស់សម្រាប់អ្វីផ្សេង និងរូបសំណាកព្រះពុទ្ធក៏ត្រូវបានកម្ទេចផងដែរ។ ព្រះសង្ឃ និងដូនជីទាំងអស់ត្រូវបានចាប់ផ្សឹក ហើយមានព្រះសង្ឃខ្លះ ត្រូវបានគំរាមដល់អាយុជីវិត ឬត្រូវសម្លាប់ចោល បើសិនជាមិនព្រមតាមទេ (...)[៥២]។

៥០. យោងតាមអត្ថន័យទូលំទូលាយនៃបទចោទ ដូចជា ការហាមឃាត់មិនឱ្យមានព្រះពុទ្ធសាសនានៅគ្រប់ភូមិភាគទាំងអស់ក្នុងប្រទេសកម្ពុជា ដែលត្រូវបានចោទប្រកាន់ថា ជាអំពើឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនានោះ ខ្ញុំយល់ឃើញថា វាមិនចាំបាច់នោះទេថា អ្នកដាក់ពាក្យសុំត្រូវលើកឡើងថា ខ្លួនបានទទួលរងព្យសនកម្មដែលជាផលវិបាកនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើព្រះសង្ឃ ដូចដែលបានបន្តលើកឡើងដោយសហចៅក្រមស៊ើបអង្កេតនោះទេ ប៉ុន្តែ ការទទួលរងព្យសនកម្មពីការហាមមិនឱ្យមានព្រះពុទ្ធសាសនា ដូចដែលបានបកស្រាយខាងលើ គឺជាការគ្រប់គ្រាន់ដើម្បីទទួលយកអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីទៅហើយ។ បញ្ហាពាក់ព័ន្ធតែមួយគត់ទាក់ទងទៅនឹងអ្នកដាក់ពាក្យសុំទាំងឡាយដែលបានលើកឡើងថា ពួកគាត់គួរតែត្រូវបានទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី ដោយការសំអាងទៅលើការធ្វើទុក្ខបុកម្នេញផ្នែកសាសនាមកលើពុទ្ធសាសនិកនោះ គឺថាតើគួរឱ្យជឿជាក់បានថា ពួកគាត់បានទទួលរងព្យសនកម្មផ្លូវចិត្តដែលបានលើកឡើង ដែលជាផលវិបាកនៃ

---

[៥០] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧៤១។

[៥១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧៤៣។

[៥២] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤២១។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

ឧក្រិដ្ឋកម្មណាមួយ ក្នុងចំណោមឧក្រិដ្ឋកម្មដែលបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា មកលើពុទ្ធសាសនិក ដូចដែលបានចោទប្រកាន់ទៅលើជនជាប់ចោទដែរឬយ៉ាងណា រួមទាំងការហាមឃាត់មិនឱ្យគោរពព្រះពុទ្ធសាសនាផង។ តួនាទីនៃសាសនានៅក្នុងជីវិតរបស់អ្នកដែលប្រណិប័តន៍ គឺជាបញ្ហាបុគ្គលដែលមិនមានគុណតម្លៃដូចគ្នាពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតនោះទេ។ ហេតុដូច្នេះ គេអាចរំពឹងទុកបានថា បុគ្គលម្នាក់ៗនឹងមានប្រតិកម្មខុសៗគ្នាចំពោះការហាមឃាត់មិនឱ្យមានសាសនារបស់ខ្លួន។ ជាលទ្ធផលនៃការអនុវត្ត និងការឱ្យតម្លៃទៅលើសាសនាពីសំណាក់បុគ្គលទាំងឡាយមានភាពខុសៗគ្នា ជាពិសេសនៅពេលដែលត្រូវបានវាយតម្លៃដោយអ្នកដទៃនោះ ខ្ញុំនឹងពិចារណាទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍ ដោយផ្អែកទៅលើមូលដ្ឋាននេះ ដោយការពិចារណាថាតើមានព័ត៌មាននៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលមានមូលហេតុអាចឱ្យខ្ញុំជឿបានថា អ្នកដាក់ពាក្យសុំណាម្នាក់មិនមានភាពស្មោះត្រង់នៅក្នុងការអះអាង ទាក់ទងនឹងព្យសនកម្មដែលខ្លួនបានទទួលរងដែលជាលទ្ធផលនៃការហាមឃាត់មិនឱ្យមានព្រះពុទ្ធសាសនា ដូចដែលត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតដែរឬអត់នោះ។ ប្រសិនបើមិនមានមូលហេតុអ្វីឱ្យខ្ញុំជឿបានថា អ្នកដាក់ពាក្យនោះមិនមានភាពស្មោះត្រង់ដូចការអះអាងនោះទេ នោះខ្ញុំនឹងសន្និដ្ឋានបានថា អ្នកដាក់ពាក្យសុំនោះអាចជាជនរងគ្រោះផ្ទាល់នៃឧក្រិដ្ឋកម្មដោយការធ្វើទុក្ខបុកម្នេញ ដូចដែលបានចោទប្រកាន់ ព្រោះអាចឱ្យជឿបានថា អ្នកដាក់ពាក្យសុំនោះអាចទទួលរងព្យសនកម្មផ្លូវចិត្ត ដែលជាផលវិបាកផ្ទាល់នៃការហាមឃាត់មិនឱ្យមានព្រះពុទ្ធសាសនា។ ក្នុងករណីទាំងនេះ ខ្ញុំយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំនៅក្នុងការសម្រេចមិនទទួលយកយកពាក្យសុំទាំងនោះ។

(ii) <u>ការធ្វើទុក្ខបុកម្នេញផ្អែកសាសនាលើជនជាតិចាម</u>

៥១. ស្រដៀងគ្នានេះដែរ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលជាសមាជិកនៃសហគមន៍ជនជាតិចាមបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតខកខានដោយភ័ន្តច្រឡំពុំបានកំណត់អត្ថិភាពនៃចំណងទាក់ទងរវាងការទទួលរងព្យសនកម្មរបស់ពួកគេ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ព្រោះសហចៅក្រមស៊ើបអង្កេតបានកម្រិតដោយហួសហេតុពេកទៅលើមូលដ្ឋានភូមិសាស្ត្រ ចំពោះការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹង

រដ្ឋប្បវេណី ដែលចោទប្រកាន់អំពីការធ្វើទុក្ខបុកម្នេញទៅលើជនជាតិចាម។ ពួកគាត់លើកឡើងថា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពុំបានតម្រូវឱ្យមានការដាក់កំហិតបែបនេះឡើយ។ ខ្ញុំយល់ស្រប និងពិចារណាថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ក្នុងការសម្រេចបែបនេះ ដោយសំអាងលើហេតុផលដូចដែលបានបញ្ជាក់ខាងក្រោមនេះ។

៥២. សហចៅក្រមស៊ើបអង្កេត បានចង្អុលបង្ហាញក្នុងដីកាសម្រេច ស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនថា សហចៅក្រមស៊ើបអង្កេតបានពិចារណាថា ខ្លួនត្រូវបានអនុញ្ញាតឱ្យធ្វើការស៊ើបអង្កេត តែលើឧក្រិដ្ឋកម្មដែលទាក់ទងទៅនឹងប្រព្រឹត្តកម្ម ទៅលើជនជាតិចាមនៅភូមិភាគកណ្តាល និងបូព៌ាប៉ុណ្ណោះ(យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា)។ លើសពីនេះការស៊ើបអង្កេតនេះធ្វើឡើងតែចំពោះបរិបទនៃការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២) ដូចមានចែងក្នុងកថាខណ្ឌ ៤១ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងកថាខណ្ឌ ៣-២៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម (D196) ប៉ុណ្ណោះ[៥៣]។ ខ្ញុំយល់ឃើញថា ការកំណត់ទីតាំងភូមិសាស្ត្រនេះ គឺមានបង្ហាញយ៉ាងច្បាស់ពិតប្រាកដ នៅក្នុងផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាក់ទងនឹង "ការជម្លៀសដោយបង្ខំទៅភូមិភាគឧត្តរ និងពាយ័ព្យ - ដំណាក់កាលទី ២" ដែលនៅក្នុងកថាខណ្ឌ ៤១ ទាក់ទិននឹងការជម្លៀសជនជាតិចាម បានរៀបរាប់ថា៖

> "ក្នុងចំណោមមនុស្សដែលត្រូវបានឱ្យផ្លាស់ទីកន្លែង ដោយបង្ខំនោះ មានសមាជិកអប្បភាគជាតិពន្ធុ និងសាសនាអ៊ីស្លាមផង។ នៅឆ្នាំ ១៩៧៥ ប្រជាជនចាមនៅកម្ពុជាប្រជាធិបតេយ្យ ប្រមូលផ្តុំរស់នៅក្នុងខេត្តកំពង់ចាម កំពង់ឆ្នាំង និងពោធិ៍សាត់។ ចាប់ពីចុងឆ្នាំ ១៩៧៥ មក បក្សកុម្មុយនីស្តកម្ពុជា បានធ្វើការផ្លាស់ប្តូរទីកន្លែងដោយបង្ខំប្រជាជនចាមពីភូមិរបស់ពួកគេ ហើយបំបែកពួកគេដោយបង្ខំឱ្យទៅរស់នៅច្របូកច្របល់ក្នុងភូមិខ្មែរ។ ចាមរាប់សិបពាន់នាក់ ត្រូវបានផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ឱ្យទៅនៅភូមិភាគឧត្តរ និងពាយ័ព្យ ជាផ្នែកមួយនៃនយោបាយជាក់លាក់មួយ

---

[៥៣] សូមមើលជាឧទាហរណ៍ ដីកាសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមានអាសយដ្ឋាននៅខេត្តកំពត ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១០ D419 កថាខណ្ឌ ២៦ បានច្រានចោលពាក្យសុំទាំងនោះដោយផ្អែកលើមូលដ្ឋានថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់អ្នកដាក់ពាក្យសុំទាំងហុកសិបបួននាក់ គឺជាប់ពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មលើជនជាតិចាម នៅក្នុងខេត្តកំពត។

ដើម្បី "បំបែកពួកចាមចេញពីគ្នា"។ ការនេះបានកើតមាននៅក្នុងមូលដ្ឋានមួយចំនួន រួមមានឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម និងឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្ដាល។ ការធ្វើការផ្លាស់ប្ដូរទីកន្លែងដោយបង្ខំនេះ និងការរើសអើងជាខ្សែសង្វាក់ ដែលបានកើតមានឡើងនៅពេលក្រោយមក បណ្ដាលឲ្យចាមជាច្រើននាក់ស្លាប់ (ជើងទំព័រត្រូវបានដកចេញ)[៥៤]។

៥៣ ប៉ុន្តែការកំណត់ទីតាំងនេះ មិនត្រូវបានអនុវត្តចំពោះទម្រង់មួយចំនួន នៃការធ្វើទុក្ខបុកម្នេញក្រៅពីការជម្លៀសដោយបង្ខំ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើជនជាតិចាមនោះឡើយ[៥៥]។ ជាការពិត បើទោះបីជាមានចំណងជើងបែបនេះក៏ដោយ ក៏ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលបានលើកឡើងនេះ មិនបានដាក់កំហិតលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមថា នៅក្នុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ គោលនយោបាយត្រូវបានផ្លាស់ប្ដូរជាអំពើប្រល័យពូជសាសន៍ ដែលធ្វើឲ្យសហគមន៍ទាំងអស់របស់ជនជាតិចាម ត្រូវបានប្រមូលផ្ដុំ ហើយក្លាយជាជនរងគ្រោះនៃការកាប់សម្លាប់រង្គាល ដោយមានចេតនាបំផ្លាញទាំងស្រុង ឬដោយផ្នែក ចំពោះក្រុមជនជាតិ និងសាសនាអ៊ីស្លាមនោះទេ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ក៏បានពង្រីកកិច្ចស៊ើបអង្កេតទៅលើអំពើជាច្រើនទៀត ដែលត្រូវបានចោទប្រកាន់ថាជាប់ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ ទៅលើជនជាតិចាមដោយមូលហេតុជំនឿសាសនា និងជាតិពន្ធុ។ អំពើទាំងនេះត្រូវបានរៀបរាប់ក្នុងកថាខណ្ឌ ៤ ដល់ កថាខណ្ឌ ៦ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ក្នុងផ្នែកដែលមានចំណងជើង "ការធ្វើទុក្ខបុកម្នេញលើចាម"។ ដីកានេះបានលើកឡើងជាដំបូងទៅលើអំពើជម្លៀសប្រជាជនចាមដោយបង្ខំ ចេញពីតំបន់ដែលបានរៀបរាប់ពីខាងលើ[៥៦]។ បន្ទាប់មកដីកានេះបានបន្តលើកឡើងពីការហាមឃាត់ចំពោះសាសនា "ប្រតិកិរិយា" ដោយរួមបញ្ចូលសាសនាអ៊ីស្លាម ដោយរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជា

---

[៥៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ កថាខណ្ឌ ៤១។

[៥៥] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទិននឹងអំពើប្រល័យពូជសាសន៍លើចាម ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០០៩ ឯកសារ D196 ("ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើជនជាតិចាម")។

[៥៦] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើជនជាតិចាម កថាខណ្ឌ ៤ សំដៅជាពិសេសទៅលើការផ្លាស់ទីលំនៅប្រជាជនចាមដោយបង្ខំពីស្រុកកងមាស ក្រូច ឆ្មារ និងកោះសូទិន ខេត្តកំពង់ចាម។

00709969



ធិបតេយ្យ ព្រមទាំងការពិតដែលថា "ចាមត្រូវបានហាមឃាត់មិនឱ្យគោរពប្រតិបត្តិនូវភារកិច្ចតាមអ៊ីស្លាមសាសនាណាមួយឡើយ (វ៉ាជីប) ដូចជា ពិធីថ្វាយបង្គំ (សំប៉ះយ៉ាំង) ពិធីបួស ការបរិច្ចាគទាន ឬពិធីតាមបែបសាសនាអ៊ីស្លាមដទៃទៀត ឬពិធីបុណ្យសពជាដើម។ ពួកគេត្រូវបានហាមឃាត់មិនឱ្យរក្សាទុកអត្ថបទសៀវភៅសាសនាអ៊ីស្លាមទេ ដោយពួកកម្មាភិបាលខ្មែរក្រហម បានប្រមូលសៀវភៅទាំងនោះ ហើយដុតចោល។ វិហារអ៊ីស្លាមជាច្រើនត្រូវបានបំផ្លាញ ឬធ្វើឱ្យខូចខាត។ បក្សកុម្មុយនីស្តកម្ពុជា បានផ្តោតគោលដៅទៅលើមេដឹកនាំនយោបាយចាម និងមេដឹកនាំខាងសាសនាអ៊ីស្លាមរបស់ចាម រួមទាំងចាមទាំងឡាយណាដែលបដិសេធមិនព្រមបោះបង់ចោលនូវសាសនារបស់ខ្លួន ដើម្បីយកទៅសម្លាប់ចោល"[៩៧]។ "ភាសាចាមត្រូវបានហាមឃាត់ ដូចគ្នានឹងគ្រឿងប្រដាប់តែងកាយបែបសាសនាអ៊ីស្លាមដទៃទៀត (ដូចជាសារុង មួកកាតីបសម្រាប់ថ្វាយបង្គំ និងម៉ាក់ខ្នា ដែលជាខោអាវវែងសម្រាប់ស្ត្រីស្លៀកនៅពេលថ្វាយបង្គំ) និងការប្រើឈ្មោះចាម។ ចាមត្រូវបានបង្ខំឱ្យប្រព្រឹត្តអំពើផ្សេងៗដែលមានការហាមឃាត់យ៉ាងតឹងរ៉ឹងបំផុតតាមជំនឿ (ហារ៉ាំ) របស់ពួកគេ ដូចជាឱ្យបរិភោគសាច់ជ្រូកជាដើម ហើយស្ត្រីចាមត្រូវបានគេបង្ខំឱ្យកាត់សក់ខ្លី និងមិនអនុញ្ញាតឱ្យយកក្រណាត់រុំក្បាល តាមបែបប្រពៃណីរបស់ពួកគេទេ។ ការខកខានក្នុងការអនុវត្តតាមវិធានហាមឃាត់ទាំងនេះ ជាលទ្ធផលអាចត្រូវយកទៅសម្លាប់ចោល"[៩៨]។ ខ្ញុំកត់សម្គាល់ឃើញថាទម្រង់នៃការធ្វើទុក្ខបុកម្នេញទាំងអស់នេះ ក្រៅពីការជម្លៀសដោយបង្ខំទៅលើប្រជាជនចាមគឺមិនមានការដាក់កំហិតលើទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ។

៥៤ បន្ថែមពីលើនេះទៀត ខ្ញុំកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតខ្លួនឯងផ្ទាល់ បានធ្វើតាមវិធីដូចគ្នានេះ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទាក់ទិននឹងទម្រង់នៃការធ្វើទុក្ខបុកម្នេញទាំងអស់នេះ។ សហចៅក្រមស៊ើបអង្កេត មិនបានកំណត់ត្រឹមទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយនោះទេ គឺគ្របដណ្តប់ទៅលើផ្ទៃប្រទេសទាំងមូលតែម្តង។ តាមពិតទៅ នៅត្រង់កថាខណ្ឌ ៧៥៦ នៃការកត់សម្គាល់ឃើញអំពីអង្គហេតុនៃបទឧក្រិដ្ឋ ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ

[៩៧] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើជនជាតិចាម កថាខណ្ឌ ៥។

[៩៨] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមលើជនជាតិចាម កថាខណ្ឌ ៦។

បានថែងអំពីការប្រព្រឹត្តទៅលើជនជាតិចាម ក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៧ ថា "សាក្សីជាច្រើន (ជាជនជាតិចាម និងក្រៅពីជនជាតិចាម) ដែលរស់នៅទូទាំងប្រទេសកម្ពុជា បានបញ្ជាក់ដូចៗគ្នាថា ប.ក.ក មិនអនុញ្ញាតឱ្យមានការគោរពប្រតិបត្តិសាសនាអ៊ីស្លាម និងហាមឃាត់មិនឱ្យថ្វាយបង្គំព្រះ បានរឹបអូសយក និងដុតចោលនូវគម្ពីរកូរ៉ាន់ (កូរ៉អាន/Coran) វិហារចាមត្រូវបានបិទទ្វារ និងបំផ្លាញ ឬត្រូវបានគេប្រើប្រាស់ ក្នុងគោលបំណងផ្សេងៗទៀត ដូចជា៖ រោងបាយរបស់សហករណ៍ ឃ្លាំងដាក់សម្ភារៈ ឬជាទីកន្លែងសម្រាប់ចិញ្ចឹមជ្រូក។ សាក្សីជាច្រើន(លើកលែងបីនាក់ក្នុងចំណោមពួកគេ) បានលើកឡើងថា ជនជាតិចាម ត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក។ អ្នកដឹកនាំសាសនា និងអ្នករៀនចេះដឹងសាសនាអ៊ីស្លាមជ្រៅជ្រះត្រូវបានចាប់ខ្លួន និងសម្លាប់។ ស្ត្រីជនជាតិចាមត្រូវបានគេបង្ខំឱ្យកាត់សក់ និងហាមឃាត់មិនឱ្យយកក្រណាត់រុំក្បាល។ ភាសាចាមត្រូវបានគេហាមឃាត់។ ចំពោះសម្លៀកបំពាក់ប្រពៃណីចាម ក៏ត្រូវបានហាមឃាត់ដែរ"។ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រង់ផ្នែកដែលរៀបរាប់ពីការកត់សម្គាល់ឃើញពីអង្គច្បាប់ ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញខាងផ្លូវសាសនា បានថែងបន្ថែមទៀតថា៖

"១៤១៩. ទាក់ទងទៅនឹងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា ពុទ្ធសាសនិក និងជនជាតិចាម គឺជាជនរងគ្រោះជាប្រព័ន្ធនៃអំពើធ្វើទុក្ខបុកម្នេញនេះ ក្នុងកម្រិតធំធេង។ ពុទ្ធសាសនិក និងជនជាតិចាមត្រូវបានកំណត់មុខសញ្ញា ដោយសារមូលហេតុរើសអើង ដែលពួកគេមានសមាជិកភាពទៅនឹងក្រុមទាំងនោះ។ អំពើដែលរៀបរាប់ខាងក្រោមបង្កើតបានជាការរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានរបស់ក្រុមទាំងនោះ។

១៤២០. ធាតុផ្សំនៃឧក្រិដ្ឋកម្មការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាទៅលើពួកចាម ត្រូវបានបំពេញ (សូមពិនិត្យមើល "ការប្រព្រឹត្តមកលើពួកចាម" "ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ (ពីភូមិភាគកណ្តាល/ឧត្តរចាស់ ភូមិភាគនិរតី ភូមិភាគបូព៌ា និង ភូមិភាគបស្ចិម)" និង "ការដ្ឋានទំនប់១មករា") បានកើតមានឡើងយ៉ាងហោចណាស់នៅទីតាំងពីរដែលស្ថិតនៅក្រោមការស៊ើបសួរ គឺមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា។ ការលុបបំបាត់ចោលវប្បធម៌ ប្រពៃណី និងភាសា របស់ជនជាតិចាម កើតមានឡើងនៅថ្នាក់ជាតិ។ ប.ក.ក បានហាមឃាត់ជនជាតិចាមប្រតិបត្តិសាសនាអ៊ីស្លាម រឹបអូសយក និងដុតចោលគម្ពីរកូរ៉អាន បិទទ្វារនិងបំផ្លាញវិហារ ហើយជនជាតិចាមត្រូវបានគេបង្ខំឱ្យហូបសាច់ជ្រូក។ មេសាសនា និងនិស្សិត

00709971



សាសនា ត្រូវបានចាប់ខ្លួន និងសម្លាប់។ ស្ត្រីជនជាតិចាម ត្រូវបានបង្ខំឱ្យកាត់សក់ និង ហាមមិនឱ្យរុំក្បាល។ សហគមន៍ជនជាតិចាម ត្រូវបានបំបែក ផ្លាស់ទីលំនៅដោយបង្ខំនៅទូទាំងប្រទេស និងត្រូវបានបំបែក ឱ្យទៅរស់នៅក្នុងសហគមន៍នានា"។

៥៥ អនុលោមទៅតាមបទប្បញ្ញត្តិទាំងនេះ ខ្ញុំយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការច្រានចោលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានចោទប្រកាន់ទៅលើទម្រង់នានានៃការធ្វើទុក្ខបុកម្នេញ ទាក់ទងនឹងប្រព្រឹត្តកម្មទៅលើជនជាតិចាម ក្រៅពីការជម្លៀសដោយបង្ខំ ដោយការបដិសេធនេះផ្អែកលើមូលដ្ឋាននៃការកំណត់ទីតាំងភូមិសាស្ត្រ ដែលត្រូវបានកំណត់ឡើងដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលការកំណត់នេះទាក់ទងតែទៅនឹងការជម្លៀសដោយបង្ខំប៉ុណ្ណោះ។

**មូលដ្ឋានទី៩៖ ការមិនបានបង្កើតនូវទំនាក់ទំនងរវាងហេតុ និងផល៖ ការបោសសម្អាត/ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ**

៥៦ សហមេធាវី [តំណាងដើមបណ្ដឹងរដ្ឋប្បវេណី] បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការបដិសេធអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយបានលើកទឡ្ហីករណ៍ថាសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ក្នុងការប្រកាសបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់អ្នកដាក់ពាក្យសុំមួយចំនួនព្រោះថា ព្យសនកម្មដែលពួកគាត់បានចោទប្រកាន់គឺបណ្ដាលមកពីការបោសសម្អាត។ សហមេធាវីបានកត់សម្គាល់ថា នៅក្នុងសេចក្ដីថ្លែងការណ៍ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩ របស់សហចៅក្រមស៊ើបអង្កេត[៥៩] បានរួមបញ្ចូលការបោសសម្អាតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួរ ហើយបានកំណត់និយមន័យ "ការបោសសម្អាត" ថាជាអំពើមួយប្រឆាំងនឹងក្រុម "ធ្វើឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ និងជាពិសេសនៅភូមិភាគឧត្តរ (ចាស់ និង/ឬថ្មី) នាឆ្នាំ ១៩៧៦ ហើយនិងនៅភូមិភាគឧត្តរ (ថ្មី) នាចុងឆ្នាំ ១៩៧៦ និងដើមឆ្នាំ ១៩៧៧ និងនៅក្នុងភូមិភាគបូព៌ា ក្នុងឆ្នាំ ១៩៧៨"[៦០]។

[៥៩] សេចក្ដីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ស្ដីពីវិសាលភាពនៃកិច្ចស៊ើបសួរ។
[៦០] សេចក្ដីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ស្ដីពីវិសាលភាពនៃកិច្ចស៊ើបសួរ។



អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

៩៧ សហព្រះរាជអាជ្ញាបានបញ្ជាក់ថាវិសាលភាពនៃកិច្ចស៊ើបសួរ តាមផ្លូវតុលាការមិនដាក់កំហិតត្រឹមតែអង្គហេតុដែលមានរៀបរាប់ជាក់លាក់នៅក្នុងផ្នែក "ឧក្រិដ្ឋកម្ម" ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (កថាខណ្ឌ ៣៧ ដល់ ៧២) និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី១ (កថាខណ្ឌ ៥ ដល់ ២០)[៦១] "ក៏ប៉ុន្តែវាគ្របដណ្តប់គ្រប់អង្គហេតុទាំងអស់ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាំងពីរនេះទៀតផង ឲ្យតែអង្គហេតុទាំងអស់នេះជួយដល់កិច្ចស៊ើបសួរ ក) ធាតុផ្សំយុត្តាធិការនានា ដែលចាំបាច់ដើម្បីកំណត់ថាតើ ស្ថានភាពនៃអង្គហេតុនានាដូចមានចែងជាក់លាក់ នៅក្នុងកថាខណ្ឌ ៣៧ ដល់ ៧២ និងកថាខណ្ឌទី៥ ដល់២០ រួមបង្កើតបានទៅជាបទឧក្រិដ្ឋផ្សេងៗ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ? ឬ ខ) ទម្រង់នៃការទទួលខុសត្រូវ របស់ជនសង្ស័យទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ"[៦២]។ ជាពិសេសក្នុងករណីដែលនិយាយពីការបោសសម្អាត ពិតណាស់ថាវិសាលភាពនៃកិច្ចស៊ើបសួរ រួមបញ្ចូលការបង្កើតជាផ្នែកនៃផែនការរួម ដែលផ្តោតគោលដៅលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ (ទាំងមន្ត្រីរាជការស៊ីវិល អតីតបុគ្គលិកយោធា និងក្រុមគ្រួសាររបស់ពួកគេ)[៦៣] ហើយការបោសសម្អាតរួមបញ្ចូលទាំងការស្រាវជ្រាវរក ព្រមទាំងការសម្លាប់នៅក្រោយពេលស្រាវជ្រាវរកឃើញ។ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅដើមឆ្នាំ១៩៧៦ ការស្រាវជ្រាវ និងការសម្លាប់ទាំងនេះ ត្រូវបានពង្រីកដោយបញ្ចូលទាំងទាហានធម្មតា និងអ្នករដ្ឋការតូចតាច[៦៤]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រួមមានព័ត៌មានដូចខាងក្រោម ដែលទាក់ទងនឹងប្រព្រឹត្តកម្មលើអតីតមន្ត្រីរាជការនៃរបបសាធារណរដ្ឋខ្មែរ៖ ទាក់ទងនឹងឧក្រិដ្ឋកម្មនៃ (១) ការជម្លៀសប្រជាជនដោយបង្ខំ (ដំណាក់កាលទី១) កថាខណ្ឌ ៣៨ បានពិភាក្សាថាការស្វែងរក និងសម្លាប់អតីតមន្ត្រី និងនាយទាហានសាធារណរដ្ឋខ្មែរ ត្រូវបានធ្វើឡើងដោយទាហានបក្សកុម្មុយនីស្តកម្ពុជា (២) ការធ្វើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅអមនុស្សធម៌ និងការឃុំឃាំងខ្លួនដោយខុស

---

[៦១] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទី១។

[៦២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទំព័រ ១២។

[៦៣] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ១២។

[៦៤] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ១២(ក)។

ច្បាប់ ដូចជានៅភូមិភាគនិរតី ដូចបានរៀបរាប់ក្នុងកថាខណ្ឌ ៤៣ អំពីអំពើដែលបានធ្វើឡើងនៅក្នុងសហករណ៍នានាក្នុងស្រុកត្រាំកក់ ដែលអតីតមន្ត្រី និងនាយទាហានរបបសាធារណរដ្ឋខ្មែរ ត្រូវទទួលរងការរើសអើង តាមដាន ចាប់ខ្លួន និងប្រហារជីវិត ហើយ (៣) សម្លាប់ ធ្វើទារុណកម្ម និងការធ្វើបាបផ្នែករាងកាយ និងផ្លូវចិត្ត ជាឧទាហរណ៍ដូចជា នៅក្នុងតំបន់ក្រចេះ, មន្ទីរសន្តិសុខ គោកក្ដួច ដែលបានរៀបរាប់ក្នុងកថាខណ្ឌ ៦៣ ដែលនិយាយថា មានអ្នកទោសជាច្រើន រួមបញ្ចូលទាំងអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ។

៥៨ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានចែងថា ធាតុផ្សំផ្លូវច្បាប់នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ បានកើតឡើងនៅក្នុងករណីជាច្រើនដូចតទៅនេះ ហើយអង្គហេតុកើតមានស្ទើរតែនៅគ្រប់ទីកន្លែងទាំងអស់ដែលស្ថិតក្រោមការស៊ើបសួរ ដូចជា៖ នៅដំណាក់កាលទី១ ទី២ និងទី៣ នៃការផ្លាស់ទីលំនៅប្រជាជន, នៅការដ្ឋាន ឬជំរំធ្វើការដោយបង្ខំ ដូចជា ទំនប់១មករា ព្រលានយន្តហោះកំពង់ឆ្នាំង ព្រៃស ស្រែអំបិល សហករណ៍ត្រាំកក់ និងទំនប់ត្រពាំងថ្ម នៅតាមមន្ទីរសន្តិសុខ ដូចជា កោះខ្យង គោកក្ដួច ក្រាំងតាចាន់ ភូមិភាគឧត្តរ ភ្នំក្រោល អូរកន្សែង ព្រៃដំរីស្រុត មន្ទីរ ស-២១ សង់ វត្តគិរីរម្យ និងវត្តធ្លក និងនៅកន្លែងសម្លាប់មនុស្ស ដូចជា ជើងឯក និងក្នុងស្រុក១២ ស្ទឹងតូច និងទួលពោធិ៍ជ្រៃ[៦៥]។ ចំពោះក្រុមដែលជាគោលដៅនៃឧក្រិដ្ឋកម្ម ដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានចែងលម្អិតបន្ថែមទៀតថា៖

> "អាជ្ញាធរនៃបក្សកុម្មុយនីស្តកម្ពុជាបានកំណត់អត្តសញ្ញាណ "ខ្មាំង" ជាច្រើនក្រុម ដោយសារមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬសន្មតរបស់ក្រុមមនុស្សទាំងនោះ ឬដោយសារមូលហេតុនៃការប្រឆាំងរបស់ពួកគេទៅនឹងអ្នកកាន់អំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ មនុស្សប្រភេទខ្លះនៃក្រុមមនុស្សទាំងនេះ ដូចជាអតីតថ្នាក់ដឹកនាំស៊ីវិល និងយោធានៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានរាប់បញ្ចូលក្នុងផែនការរួមនៃការកសាងលទ្ធិសង្គមនិយម។ ចំណែកឯភ្នាក់ងារតូចតាចនៃរបបចាស់ អ្នកខ្លះត្រូវបានចាប់ខ្លួនភ្លាមៗ បន្ទាប់ពីបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាច ដោយសារការគាំទ្ររបស់ខ្លួនដល់រដ្ឋាភិបាលចាស់ ហើយជាញឹកញាប់ ពួកគេត្រូវបានសម្លាប់នៅតាមមន្ទីរសន្តិសុខ ដូចជាមន្ទីរ ស-២១ ឬទួលពោធិ៍ជ្រៃ។

---

[៦៥] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤១៥ ដល់ ១៤១៦។

ប្រជាជនទាំងអស់ដែលស្ថិតនៅតាមទីប្រជុំជន នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាឡើងកាន់អំណាច ត្រូវបានចាត់ទុកជា "ប្រជាជនថ្មី" ឬ "ប្រជាជន១៧មេសា" និងបានស្ថិតនៅក្រោមការប្រព្រឹត្តតឹងរ៉ឹងជាងប្រជាជនចាស់ ក្នុងគោលបំណងលត់ដំ ឬកំណត់អត្តសញ្ញាណ "ខ្មាំង" នៅក្នុងចំណោមពួកគេ។ បញ្ញវន្ត និស្សិត និងអ្នកការទូតដែលរស់នៅបរទេស ត្រូវបានហៅឱ្យត្រឡប់ចូលស្រុកវិញ ហើយនៅពេលមកដល់ ពួកគាត់ត្រូវបានបញ្ជូនទៅជំរំលត់ដំ ឬទៅមន្ទីរ ស-២១។ "ខ្មាំង" ប្រភេទនេះ កាន់តែមានច្រើនទៅៗ ទៅតាមពេលវេលា។ ម្យ៉ាងទៀត ការកំណត់មនុស្សដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញ ដោយឈរលើមូលដ្ឋាននៃការបំបាត់រាល់បុគ្គលទាំងឡាយណា ដែលមិនយល់ស្របនឹងមនោគមវិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជា ជាក់ស្តែង គឺជាទម្រង់មួយនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ[៦៦]។

នៅតាម**សហករណ៍ និងការដ្ឋាន**ធ្វើការដោយបង្ខំ ក៏ដូចជានៅពេលផ្លាស់ទីលំនៅប្រជាជនដែរ ខ្មាំងពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេធ្វើបាប និងដាក់ឱ្យរស់នៅក្នុងលក្ខខណ្ឌពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត។ មនុស្សទាំងនោះក៏ត្រូវបានគេចាប់ជាក្រុមៗផងដែរ ដើម្បីយកទៅអប់រំឡើងវិញ ឬទៅកម្ទេចចោលនៅតាមមន្ទីរសន្តិសុខនិងកន្លែងសម្លាប់មនុស្ស"[៦៧]។

៥៩ ខ្ញុំសូមសង្កត់ធ្ងន់ថា សហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិ ដើម្បីសម្រេចថាមិនចោទប្រកាន់លើគ្រប់ព្រឹត្តិការណ៍នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដែលអាចកើតឡើងក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីបានពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើងវិញរួចមក ខ្ញុំពិចារណាឃើញថា ព្រឹត្តិការណ៍ដែលមាននៅក្នុងបទចោទលើការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ដូចត្រូវបានរៀបរាប់នោះ គឺជាព្រឹត្តិការណ៍ដែលគ្របដណ្តប់លើអង្គហេតុសំខាន់ៗ ដូចបានកំណត់ដៅនៅក្នុងផ្នែកដែលមានចំណងជើងថា ការកត់សម្គាល់អំពីអង្គហេតុនៃឧក្រិដ្ឋកម្ម។ ហេតុដូច្នេះ អ្នកដាក់ពាក្យសុំទាំងឡាយណា ដែលបានអះអាងថា មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ប៉ុន្តែអំពើនេះមិនត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ (ជាពិសេសដូចករណី

---

[៦៦] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤១៧។

[៦៧] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤១៨។



E.C.C.C • C.E.T.C • PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

បោសសម្អាតលើមន្ត្រីសាធារណរដ្ឋខ្មែរ និងក្រុមគ្រួសាររបស់ពួកគាត់) ហើយស្វះស្វែងរកការទទួលយកជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការប្តឹងឧទ្ធរណ៍របស់ពួកគាត់ ដោយផ្អែកលើមូលដ្ឋានដែលថាសហចៅក្រមស៊ើបអង្កេត មានការភ័ន្តច្រឡំក្នុងការបដិសេធពាក្យសុំរបស់ពួកគាត់ ដោយសារការខកខានមិនបាន (១) បង្ហាញពីទំនាក់ទំនងរវាងហេតុនិងផលចាំបាច់រវាងព្យសនកម្ម និងបទឧក្រិដ្ឋដែលបានចោទប្រកាន់ (២) ផ្តល់ឲ្យនូវព័ត៌មានគ្រប់គ្រាន់ដើម្បីឲ្យសហចៅក្រមស៊ើបអង្កេតអាចពិនិត្យស្របតាមវិធាន ២៣ *ស្ទួន* (១) និង (៤) នៃវិធានផ្ទៃក្នុង ឬ (៣) ផ្តល់មូលដ្ឋានអ្វីផ្សេងទៀតនោះ បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋាននេះឡើយ។

៦០ យុត្តិកម្មដូចគ្នានេះក៏អនុវត្តចំពោះការបោសសម្អាតនៅភូមិភាគឧត្តរចាស់ និងថ្មី[៦៨] ក៏ដូចជាភូមិភាគបូព៌ាផងដែរ[៦៩]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ពណ៌នាការបោសសម្អាតនៅតាមភូមិ

---

[៦៨] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (កថាខណ្ឌ ១៩៣-១៩៨) បញ្ជាក់ថា ការបោសសម្អាតបានចាប់ផ្តើមឡើង បន្ទាប់ពីមានសេចក្តីសម្រេចនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ដើម្បីដឹកនាំ "ការកម្ទេច" នៅក្នុងជួរបដិវត្តន៍ ហើយការបោសសម្អាតនេះត្រូវបានអនុវត្ត *ក្នុងចំណោមមធ្យោបាយដទៃទៀត* ដោយការសម្លាប់រង្គាលលើសមាជិកបក្សនៅក្នុងភូមិភាគឧត្តរ និងនៅក្នុងតំបន់១០៦ ចាប់តាំងពីចុងឆ្នាំ១៩៧៦។ ការបោសសម្អាតនេះកើនឡើងយ៉ាងខ្លាំងនៅដើមឆ្នាំ១៩៧៧ ហើយបន្តកើនឡើងរហូតដល់ចុងឆ្នាំនោះ។ នៅក្នុងភូមិភាគឧត្តរ ការអនុវត្តនៃសេចក្តីសម្រេចនាថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ នេះបាននាំឲ្យមានការចាប់ខ្លួនកម្មាភិបាលជាន់ខ្ពស់នានា នៅក្នុងចុងឆ្នាំ១៩៧៦ ដែលអ្នកទាំងនោះត្រូវបានបញ្ជូនទៅស-២១ ហើយក្រោមការធ្វើទារុណកម្ម ត្រូវបង្ខំឲ្យសារភាពដោយចោទដាក់កម្មាភិបាលផ្សេងៗទៀត។ កត្តានេះបាននាំឲ្យមានការកើនឡើងដ៏ខ្លាំងមួយនៅក្នុងវិសាលភាពនៃការបោសសម្អាតអ្នកដែលត្រូវបានចោទថាជាជនក្បត់នៅតំបន់១០៦ ដែលអ្នកទាំងនោះបានមកដល់ស-២១ នៅដើមឆ្នាំ១៩៧៧។ ជនរងគ្រោះនៃការបោសសម្អាតដែលជាកម្មាភិបាលថ្នាក់ទាបត្រូវបានសម្លាប់នៅតាមតំបន់ ហើយត្រូវបានជំនួសដោយកម្មាភិបាលភូមិភាគនិរតី ដែលត្រូវបានបញ្ជូនឲ្យជួយដល់ការបោសសម្អាត ដោយសាច់ញាតិរបស់ តា ពក។ ការបោសសម្អាតនៅភូមិភាគឧត្តរ បន្តរហូតដល់ឆ្នាំ១៩៧៨។

[៦៩] ដីកាដំណោះស្រាយ (កថាខណ្ឌ ១៩៩-២០៣) បញ្ជាក់ថា ការបោសសម្អាតនៅភូមិភាគបូព៌ា បានចាប់ផ្តើមឡើងពីពាក់កណ្តាលឆ្នាំ១៩៧៦ ដោយមានការចាប់ខ្លួន សួរចម្លើយ និងធ្វើទារុណកម្មលើអតីតកម្មាភិបាលតំបន់២៤ និងអតីតកម្មាភិបាលកងពលធំភូមិភាគបូព៌ាលេខ១៧០។ បន្ទាប់មកមានការចាប់ខ្លួនជាស៊េរី លើកម្មាភិបាលភូមិភាគបូព៌ា ដែលអ្នកទាំងនោះភាគច្រើនត្រូវបានបញ្ជូនទៅ ស-២១ ពេញឆ្នាំ១៩៧៧។ នៅក្នុងខែមីនា ឆ្នាំ១៩៧៨ ការកើនឡើងដ៏សម្បើមនៃការបោសសម្អាតកម្មាភិបាល និងយុទ្ធជនភូមិភាគបូព៌ា បានកើតឡើងនៅក្នុងខេត្តស្វាយរៀង នៅតំបន់២៣។ បន្ទាប់មកមានការចាប់ខ្លួន និងសម្លាប់កាន់តែច្រើនឡើង ក្នុងចន្លោះពីខែឧសភា ដល់ខែមិថុនា ឆ្នាំ១៩៧៨ នៅក្នុងតំបន់ផ្សេងៗទៀតនៃភូមិ

ភាគទាំងនេះនៅក្នុងផ្នែកដែលមានចំណងជើងថា ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃសហកម្មឧក្រិដ្ឋកម្មរួម[៧០]។ ផ្នែកនោះបានលើកឡើងថា ពាក្យ "បោសសម្អាត" មានន័យថាធ្វើឱ្យបរិសុទ្ធផ្នែកគោលនយោបាយ តាមរយៈការដាក់ទណ្ឌកម្ម ដែលមានចាប់ពីការបញ្ចុះឋានន្តរសក្តិបុគ្គលណាម្នាក់ ឬការលត់ដំ រហូតដល់ការកម្ទេចចោល។ ដីកាដំណោះស្រាយក៏រៀបរាប់បន្ថែមផងដែរថា គោលនយោបាយនេះបានអនុវត្តចំពោះសមាជិកបក្សផង និងបុគ្គលដែលមិនមែនជាសមាជិកបក្សផងដែរ។ ស្ថានភាពមួយចំនួនដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ អាចត្រូវបានកំណត់ថាជាអង្គហេតុនៃការបោសសម្អាត[៧១]។ ខ្ញុំកត់សម្គាល់ឃើញថា រាល់អង្គហេតុទាំងអស់ដែលជាផ្នែកនៃបាតុភូតនៃការបោសសម្អាតនាសម័យនោះ មិនប្រាកដជាបង្កើតឱ្យទៅជាបទឧក្រិដ្ឋនោះទេ ហើយក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតអះអាងថា អង្គហេតុទាំងនោះបង្កើតឱ្យទៅជាបទឧក្រិដ្ឋ ដែលមានដូចជាការឃុំខ្លួនខុសច្បាប់ ការធ្វើទារុណកម្ម ការបង្ខំឱ្យធ្វើការ និងការសម្លាប់មនុស្ស ការរកឃើញនៃអង្គហេតុនានាគាំទ្របទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទាំងនេះ មានចែងនៅក្នុងផ្នែក ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃបទឧក្រិដ្ឋ ដែលក្នុងផ្នែកនេះមានការយោងទៅលើការរកឃើញអង្គច្បាប់ពាក់ព័ន្ធនានាផងដែរ[៧២]។ ទំនាក់ទំនងដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញនោះ គឺជាទំនាក់ទំនងរវាងព្យសនកម្មដែល

---

ភាគបូព៌ា។ ការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ាដែលនៅសេសសល់ និងកម្មាភិបាល ដែលមានប្រភពមកពីភូមិភាគបូព៌ា (បើទោះជាការបោសសម្អាតនេះបានធ្វើឡើងនៅក្រៅភូមិភាគបូព៌ាក៏ដោយ) ដោយរួមទាំង ក្រសួងផ្សេងៗមួយចំនួនដូចជា ក្រសួងសង្គមកិច្ចនោះ បានបន្តរហូតដល់របបបក្សកុម្មុយនីសកម្ពុជាដួលរលំ។ កម្មាភិ-បាលមួយចំនួនក្នុងចំណោមអ្នកទាំងនេះ ត្រូវបានបញ្ជូនពីភូមិភាគបូព៌ា ទៅកាន់ស-២១ ខណៈពេលដែលអ្នកដទៃទៀតត្រូវបានសម្លាប់នៅហ្នឹងកន្លែង ឬជម្លៀសទៅតំបន់ផ្សេងៗទៀតនៅទូទាំងប្រទេស។ កម្មាភិបាល និងយុទ្ធជនភូមិភាគបូព៌ា ឬអតីតកម្មាភិបាល និងយុទ្ធជនភូមិភាគបូព៌ាជាច្រើននាក់ទៀត ត្រូវបានបញ្ជូនឱ្យទៅ "លត់ដំ" នៅការដ្ឋាន ដូចជា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ អង្គហេតុបន្ថែមទៀតទាក់ទងនឹងការបោសសម្អាតនៅភូមិភាគបូព៌ា ត្រូវបានបញ្ជាក់នៅក្នុងផ្នែកមួយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលទាក់ទិនទៅនឹងស-២១ ព្រលានយន្តហោះកំពង់ឆ្នាំង កន្លែងសម្លាប់មនុស្សស្ទឹងតូច និងការជម្លៀសប្រជាជនមកពីភូមិភាគបូព៌ា (ដំណាក់កាលទី៣)។

[៧០] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩៣ ដល់ ២០៤។

[៧១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៩២។

[៧២] ជាឧទាហរណ៍ទាក់ទងនឹងការសម្លាប់ សូមមើល កថាខណ្ឌ ១៣៧៣ និង ១៣៨១ ពាក់ព័ន្ធនឹងបទឧក្រិដ្ឋនៃការធ្វើមនុស្សឃាត និងការកម្ទេច ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស។

ត្រូវបានចោទប្រកាន់ថាមាន និងអំពើឧក្រិដ្ឋ ដែលត្រូវបានចោទប្រកាន់ថាកើតឡើងនៅតាមការដ្ឋាន សហករណ៍ មន្ទីរឃុំឃាំង និងទីកន្លែងសម្លាប់មនុស្ស ដែលកើតឡើងនៅក្នុងដំណាក់កាលពាក់ព័ន្ធនានានៃការជម្លៀសប្រជាជន ដូចមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ តាមយោបល់ខ្ញុំ អ្នកដាក់ពាក្យសុំណាមួយដែលបានអះអាងថាខ្លួនទទួលរងនូវព្យសនកម្មនៃការបោសសម្អាតនៅតាមភូមិភាគឧត្តរចាស់/ថ្មី ឬភូមិភាគបូព៌ា ប៉ុន្តែការបោសសម្អាតនេះមិនត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយអ្នកដាក់ពាក្យសុំនោះប្តឹងឧទ្ធរណ៍ដើម្បីឱ្យខ្លួនត្រូវបានទទួលយក ដោយផ្អែកលើមូលដ្ឋានដែលថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំក្នុងការសម្រេចបដិសេធពាក្យសុំរបស់គាត់ ដែលខកខានមិនបាន (១) បង្ហាញពីទំនាក់ទំនងមូលហេតុចាំបាច់រវាងព្យសនកម្ម និងបទឧក្រិដ្ឋដែលត្រូវចោទ (២) ផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យស្របតាមវិធាន ២៣*ស្ទួន* (១) និង (៤) នៃវិធានផ្ទៃក្នុង ឬ (៣) តាមមូលដ្ឋានផ្សេងទៀតនោះ មិនអាចទទួលយកបានតាមរយៈបណ្តឹងឧទ្ធរណ៍ ដែលធ្វើឡើងតាមមូលដ្ឋានបែបនេះឡើយ។

## VI. *អង្គសេចក្តី៖ ការភ័ន្តច្រឡំអង្គច្បាប់ និងអង្គហេតុរួមគ្នា*

**មូលដ្ឋានទី១០ និងទី១១៖ ការប្រើប្រាស់ និងការអនុវត្តមិនត្រឹមត្រូវនៃគោលការណ៍សន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្តរបស់សមាជិកគ្រួសារសាច់ញាតិជិតស្និទ្ធ និងគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះផ្ទាល់ និងចំណាត់ការមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេត ចំពោះការសន្មតទុកជាមុនថា មានព្យសនកម្មផ្លូវចិត្ត ដែលអាចអនុវត្តបានចំពោះសមាជិកជាក់លាក់មួយចំនួននៃគ្រួសារសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះផ្ទាល់នៃការរៀបការដោយបង្ខំ**

**i) វិសាលភាពទូទៅនៃគោលការណ៍សន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត**

៦១ សហមេធាវីតំណាង បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលរងការជំទាស់ ដោយផ្អែកលើមូលដ្ឋានថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ ដោយមិនបញ្ចូលបងប្អូនបង្កើតរបស់ជនរងគ្រោះផ្ទាល់ទៅក្នុងក្រុមអ្នកទទួលផលប្រយោជន៍ពីគោលការណ៍នៃការសន្មតទុកជាមុន ថាមានព្យសនកម្មផ្លូវចិត្ត ក្នុងករណីរៀបការដោយបង្ខំ។ មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍មួយនេះគឺ

មានទំនាក់ទំនងទៅវិញទៅមកជាមួយនឹងការពិចារណារបស់*ខ្ញុំដោយខ្លួនឯង* ពាក់ព័ន្ធនឹងការប្រើប្រាស់ពាក្យពេចន៍ និងខ្លឹមសារនៃគោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត ដែលអនុវត្តដោយសហចៅក្រមស៊ើបអង្កេត។ ខ្ញុំនឹងត្រូវពិចារណាទៅលើគោលការណ៍នៃការសន្មតទុកជាមុន ព្រមទាំងពាក្យពេចន៍នេះ ហើយបន្ទាប់មកនឹងពិនិត្យមើលថាតើវាជាការភ័ន្តច្រឡំដែរឬទេ ប្រសិនបើសមាជិកគ្រួសារសាច់ឆ្ងាយ មិនត្រូវបានបញ្ចូលទៅក្នុងគោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្ម ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលបានប្រព្រឹត្តចំពោះជនរងគ្រោះដោយផ្ទាល់ ហើយជាពិសេសជាងនេះទៀត បងប្អូនបង្កើតពីការសន្មតទុកជាមុនថាមានព្យសនកម្ម ក្នុងករណីការរៀបការដោយបង្ខំ។

៦២ ដោយផ្អែកលើយុត្តិសាស្ត្រដែលមាននៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") និងគណៈកម្មការអន្តរអាមេរិកាំងដើម្បីសិទ្ធិមនុស្ស ("IACHR") ដីកាដែលរងការជំទាស់អះអាងថាមានគោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត ចំពោះសមាជិកគ្រួសារសាច់ញាតិជិតស្និទ្ធរបស់ជនរងគ្រោះផ្ទាល់ ហើយដោយអនុវត្តនូវលក្ខខណ្ឌវិនិច្ឆ័យនៅក្នុងដីកាដែលរងការជំទាស់នោះ ពាក្យថា "សាច់ញាតិជិតសិទ្ធ" រាប់បញ្ចូលឪពុកម្តាយ កូន ប្តី/ប្រពន្ធរបស់ជនរងគ្រោះផ្ទាល់[៧៣]។ ពួកគេបន្ថែមទៀតថា "ការសន្មតទុកជាមុន នឹងត្រូវចាត់ទុកថា*មិនអាចជំទាស់បាននោះទេ* នៅពេលជនរងគ្រោះផ្ទាល់បានស្លាប់ ឬបាត់ខ្លួន ឬត្រូវបានជម្លៀសដោយបង្ខំ ហើយត្រូវបំបែកចេញពីសាច់ញាតិជិតស្និទ្ធ ដែលបណ្តាលមកពីអង្គហេតុណាមួយដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ" (គូសបញ្ជាក់បន្ថែម)[៧៤]។ ក៏ប៉ុន្តែក្នុងករណីនៃការរៀបការ

[៧៣] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៤ (ក) ដោយផ្អែកទៅលើសេចក្តីប្រកាសស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម និងការរំលោភបំពាននៃអំណាច (សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ៤០/៤៣ អនុម័តនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥)។ គោលការណ៍ជាមូលដ្ឋាន និងសេចក្តីណែនាំស្តីពីសិទ្ធិទទួលបានសំណងចំពោះជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ។ ដីកាសម្រេចនេះក៏យោងទៅលើសំណុំរឿងមួយចំនួននៅតុលាការអន្តរជាតិ ICC និង IACHR (សូមមើលលេខយោងជើងទំព័រ ១២ នៃដីកាដែលរងការជំទាស់)។

[៧៤] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៥(ក)(i) និង (ii)។ ដូចបានបញ្ជាក់ពីខាងលើរួចហើយ ព្យសនកម្មត្រូវតែជាផលវិបាកផ្ទាល់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ ជាជាងផលវិបាកនៃអង្គហេតុនៅក្រោមកិច្ចស៊ើបសួរ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C.

ដោយបង្ខំ មានតែឪពុកម្តាយ ប្តី/ប្រពន្ធ និងកូន របស់ជនរងគ្រោះផ្ទាល់តែប៉ុណ្ណោះ ដែលបានទទួលផលប្រយោជន៍ពីគោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត។ បងប្អូនបង្កើតមិនត្រូវបានរាប់បញ្ចូលទៅក្នុងក្រុមអ្នកទទួលបានប្រយោជន៍ ពីការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្តនោះទេ។ ក្រៅពីនេះមិនមានការលើកឡើងទាក់ទិនដល់បទល្មើសដទៃទៀតដែលត្រូវបានចោទប្រកាន់រួមមានការឃុំឃាំង ការធ្វើទារុណកម្ម ការដាក់ឱ្យទៅជាទាសករ អំពើអមនុស្សធម៌នានាក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស ព្រមទាំងការធ្វើទុក្ខបុកម្នេញ។ ចំពោះសមាជិក "គ្រួសារសាច់ឆ្ងាយ" (មានដូចជា ជីដូនជីតា ពូមីង ក្មួយប្រុសក្មួយស្រី បងប្អូនជីដូនមួយ សាច់ញាតិថ្លៃ និងសាច់ញាតិឆ្ងាយដទៃទៀត) សហចៅក្រមស៊ើបអង្កេត យល់ស្របជាមួយនឹងការយល់ឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ព្យសនកម្មដោយផ្ទាល់មានការពិបាកក្នុងការបង្ហាញភស្តុតាង ទាក់ទិនដល់ទំនាក់ទំនងគ្រួសារសាច់ឆ្ងាយ" ហើយបានពិចារណាថា "ការសន្មតទុកជាមុន មានលក្ខណៈជាធម្មតាតែប៉ុណ្ណោះ" សម្រាប់សមាជិកគ្រួសារសាច់ឆ្ងាយ។ ករណីទាំងអស់នេះ គួរត្រូវយកមកដោះស្រាយតាមករណីជាក់ស្តែង ដោយធ្វើការសម្រេច "ថាតើមានធាតុផ្សំគ្រប់គ្រាន់ដែរឬទេ សម្រាប់ការសន្មតទុកជាមុន នូវចំណងនៃសេចក្តីស្រឡាញ់ ឬការនៅក្នុងបន្ទុក រវាងអ្នកដាក់ពាក្យសុំ និងជនរងគ្រោះផ្ទាល់"។ សហចៅក្រមស៊ើបអង្កេតបានបន្ថែមទៀតថា "ការសន្មតទុកជាមុន នឹងត្រូវចាត់ទុកថា *មិនអាចជំទាស់បាននោះទេ* នៅពេលជនរងគ្រោះផ្ទាល់បានស្លាប់ ឬបាត់ខ្លួន ឬត្រូវបានជម្លៀសដោយបង្ខំ ហើយត្រូវបំបែកចេញពីសាច់ញាតិជិតស្និទ្ធដែលបណ្តាលមកពីអង្គហេតុណាមួយដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរ"

៦៣ នៅពេលដំបូង ខ្ញុំសង្កេតឃើញថា វាហាក់ដូចជាមិនច្បាស់ទាល់តែសោះ ថាតើម្ចាស់បណ្តឹងឧទ្ធរណ៍ និងអង្គបុរេជំនុំជម្រះចង់មានន័យដូចម្តេចនៅពេលដែលបកស្រាយឃ្លារបស់សហចៅក្រមស៊ើបអង្កេតដែលថា ការសន្មតទុកជាមុនខ្លះ "មិនអាចជំទាស់បាន" ហើយការសន្មតទុកជាមុនខ្លះទៀត "មានលក្ខណៈជាធម្មតា"។ ការសន្មតទុកជាមុន គឺជាមធ្យោបាយមួយក្នុងការបង្ហាញនូវភស្តុតាងចំពោះអង្គហេតុ ដោយមិនចាំបាច់ត្រូវបង្ហាញភស្តុតាងអំពីអត្ថិភាពនោះឡើយ។ ប្រសិនបើសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត អំពីលក្ខណៈមិនអាចជំទាស់បាន របស់ការសន្មតទុកជាមុន ក្នុងករណីភាគច្រើន គឺចង់មានន័យថា ក្នុងករណីទាំង

អស់នោះ អ្នកដាក់ពាក្យសុំមិនចាំបាច់ត្រូវបង្ហាញភស្តុតាង ចំពោះអង្គហេតុដែលត្រូវបានគេពិចារណាថា បានបង្កើតឡើងរួចហើយនោះ ខ្ញុំយល់ស្របថាវាដូច្នេះមែន ប៉ុន្តែតែក្នុងករណីដែលមិនមានភស្តុតាងផ្ទុយពីនេះតែប៉ុណ្ណោះ។

៦៤ ខ្ញុំកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ "មានតែការសន្មតទុកជាមុនមានលក្ខណៈធម្មតាប៉ុណ្ណោះ ដែលមានអត្ថិភាពសម្រាប់សមាជិកគ្រួសារសាច់ឆ្ងាយ"[៧៥]។ ប្រសិនបើឃ្លានេះចង់មានន័យថា គោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត អាចបដិសេធបានសម្រាប់សមាជិកគ្រួសារសាច់ឆ្ងាយ របស់ជនរងគ្រោះផ្ទាល់ ប៉ុន្តែវាមិនអាចបដិសេធបានសម្រាប់សមាជិកគ្រួសារផ្ទាល់ទេនោះ ខ្ញុំសូមជំទាស់ទៅលើពីរចំណុច។ ចំណុចទីមួយគឺថា ការសន្មតទុកជាមុនដែលផ្តល់ប្រយោជន៍ដល់សមាជិកគ្រួសារជិតស្និទ្ធរបស់ជនរងគ្រោះផ្ទាល់ គឺអាចបង្ហាញថាមិនពិត។ ជាគោលការណ៍ មេធាវីការពារក្តី ឬសហព្រះរាជអាជ្ញា អាចបង្ហាញភស្តុតាងដើម្បីគាំទ្រថាគ្មានអត្ថិភាពនៃព្យសនកម្មផ្លូវចិត្ត ដូចដែលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានចោទប្រកាន់នោះឡើយ។ ចំណុចទីពីរ ការនិយាយយោងទៅលើស្ថានភាពរបស់សមាជិកគ្រួសារសាច់ឆ្ងាយ ដោយប្រើប្រធានបទ "ការសន្មតទុកជាមុនមានលក្ខណៈជាធម្មតា" គឺមានលក្ខណៈបំភាន្ត។ ប្រសិនបើសមាជិកគ្រួសារសាច់ឆ្ងាយជាតំណាងឱ្យអ្នកដាក់ពាក្យសុំមួយក្រុម ដែលតាមការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត គឺមិនអាចសន្មតទុកជាមុនថាបានទទួលនូវព្យសនកម្មផ្លូវចិត្ត ដែលជាលទ្ធផលនៃអំពើឧក្រិដ្ឋ ធ្វើឡើងប្រឆាំងនឹងជនរងគ្រោះដោយផ្ទាល់ទេនោះ ហើយពួកគាត់ត្រូវតែបង្ហាញថាពួកគាត់បានទទួលរងព្យសនកម្មផ្លូវចិត្ត ដោយការផ្តល់ជាភស្តុតាងពីចំណងនៃសេចក្តីស្រឡាញ់ ឬការនៅក្នុងបន្ទុកជាមួយជនរងគ្រោះផ្ទាល់ បើមិនដូច្នេះទេពួកគាត់នឹងមិនបានទទួលផលប្រយោជន៍អ្វីទាំងអស់ពីការសន្មតទុកជាមុន បើទោះបីជាគេហៅវាថាជាការសន្មតទុកជាមុន "មិនអាចជំទាស់បាន" ឬ "មានលក្ខណៈជាធម្មតា" ក៏ដោយ។ ខ្ញុំយល់ឃើញថា សហចៅក្រមស៊ើបអង្កេតនឹងច្រានចោលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលជាសមាជិកគ្រួសារសាច់ឆ្ងាយ លុះត្រាណាតែពួកគាត់បានបង្ហាញនូវភស្តុតាងដែលអាចជឿជាក់បានថា អ្នកដាក់ពាក្យសុំទាំងនោះបានទទួលរងព្យសនកម្មផ្លូវចិត្តដោយផ្ទាល់ ជាលទ្ធផលនៃ

---

[៧៥] ដីកាដែលរងការជំទាស់ កថាខណ្ឌ ១៤(គ)។

បទឧក្រិដ្ឋដែលបានធ្វើឡើងប្រឆាំងនឹងជនរងគ្រោះផ្ទាល់។ ខ្ញុំក៏សូមកត់សម្គាល់បន្ថែមថា មិនមានភាពច្បាស់លាស់ទាល់តែសោះអំពីវិធីសាស្ត្រ ដែលសហចៅក្រមស៊ើបអង្កេតប្រើប្រាស់ដើម្បីអនុវត្តចំពោះស្ថានការណ៍បែបនេះ គឺក្នុងករណីដែលសមាជិកគ្រួសារផ្ទាល់បានចោទប្រកាន់ថាឧក្រិដ្ឋកម្មទាំងនោះមិនជាប់ពាក់ព័ន្ធ ជនរងគ្រោះផ្ទាល់ដែលបានស្លាប់ ឬបាត់ខ្លួន ឬត្រូវបានជម្លៀសដោយបង្ខំ ឬត្រូវបំបែកចេញពីសាច់ញាតិ ព្រោះក្នុងករណីនេះ ការសន្មតទុកជាមុនហាក់ដូចជាមិនអាចចាត់ទុកថា "មិនអាចជំទាស់បាន" នោះទេ។

៦៥ ដោយគិតដល់ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលឧក្រិដ្ឋកម្មទាំងអស់នេះបានប៉ះពាល់ដល់សេរីភាព ការរស់នៅសុចរិតភាពផ្លូវកាយ និងផ្លូវចិត្ត ក៏ដូចជាសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះផ្ទាល់ ទើបខ្ញុំយល់ឃើញថា វាគួរឱ្យជឿទុកចិត្តបានថា អ្នកដាក់ពាក្យសុំដែលមានចំណងនៃសេចក្តីស្រឡាញ់ជាមួយជនរងគ្រោះផ្ទាល់ អាចទទួលរងនូវព្យសនកម្មផ្លូវចិត្ត ដែលជាលទ្ធផលដោយផ្ទាល់នៃការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងអស់នោះ។ ខ្ញុំយល់ឃើញថា គ្មានហេតុផលណាមួយក្នុងការបង្ហាញនូវភាពខុសគ្នានៃបណ្តាឧក្រិដ្ឋកម្មនានាដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ គ្រាន់តែដើម្បីនិយាយពីការសន្មតទុកជាមុននោះឡើយ។

៦៦ លើសពីនេះទៅទៀត ខ្ញុំបានពិចារណាថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ ដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គឺមិនគ្រាន់តែជាឧក្រិដ្ឋកម្មដែលមានភាពសាហាវយង់ឃ្នងបំផុតសម្រាប់មនុស្សជាតិនោះទេ ប៉ុន្តែវាថែមទាំងបានកើតឡើងក្នុងបរិបទដ៏ពិសេសមួយដែលប្រជាជនសឹងតែទាំងអស់ត្រូវទទួលរង "ការវាយប្រហារជាទ្រង់ទ្រាយធំ ឬជាប្រព័ន្ធ" ហើយក្រុមមនុស្សមួយចំនួនបានក្លាយជាគោលដៅសម្រាប់គោលបំណងបំផ្លាញចោលទាំងស្រុង។ បទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ក្នុងរបបខ្មែរក្រហមនោះ បានប៉ះពាល់យ៉ាងខ្លាំងទៅលើសង្គម ដោយសារតែការហាមឃាត់ការប្រតិបត្តិសាសនា, ការធ្វើឱ្យក្រុមគ្រួសារមិនទុកចិត្តគ្នា ដែលជាចេតនាបន្ទាបបន្ថោកទំនាក់ទំនងក្នុងគ្រួសារ, ការបង្ខំប្រជាជនឱ្យរៀបការ, ការដកហូតទ្រព្យសម្បត្តិបុគ្គល, ការបង្ខំឱ្យប្រជាជនចាកចេញពីផ្ទះសម្បែង ហើយទៅរស់នៅក្នុងស្ថានភាពអមនុស្សធម៌ ព្រមទាំងការបង្ខំឱ្យធ្វើការ និងការ





PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00709982



បំផ្លិចបំផ្លាញគ្រឹះស្ថានសាធារណៈ ដោយរួមបញ្ចូលទាំងប្រព័ន្ធយុត្តិធម៌ផងដែរ។ ជាលទ្ធផលបុគ្គលម្នាក់ៗបានបាត់បង់នូវអត្តសញ្ញាណ និងប្រវត្តិគ្រួសារ ហើយត្រូវរស់នៅក្នុងភាពភ័យខ្លាចជារៀងរហូត ដោយមិនអាចព្យាបាលការឈឺចាប់របស់ពួកគាត់បានឡើយ។ យើងគួរតែធ្វើការពិចារណាអំពីអង្គហេតុ ដែលប្រជាជនត្រូវបានគេទុកចោលឱ្យរស់នៅក្នុងស្ថានភាពដែលងាយរងគ្រោះបំផុត ប្រសិនបើយើងចង់ធ្វើការវាយតម្លៃថាតើវាគួរឱ្យជឿទុកចិត្តបានឬទេថា អ្នកដាក់ពាក្យសុំម្នាក់ៗបានទទួលរងនូវព្យសនកម្មដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មធ្វើឡើងប្រឆាំងនឹងជនរងគ្រោះផ្ទាល់នោះ។ លើសពីនេះទៅទៀត ដោយសារតែអ្នកដាក់ពាក្យសុំភាគច្រើនបានចោទប្រកាន់ថា បានទទួលរងព្យសនកម្មផ្លូវចិត្តដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មជាច្រើន ដែលឧក្រិដ្ឋកម្មមួយចំនួនត្រូវបានធ្វើឡើងប្រឆាំងខ្លួនគាត់ ឬសមាជិកគ្រួសារផ្ទាល់របស់គាត់ ហើយឧក្រិដ្ឋកម្មខ្លះទៀតត្រូវបានធ្វើឡើងប្រឆាំងសមាជិកគ្រួសារសាច់ឆ្ងាយ ឬក៏ចំពោះសហគមន៍របស់គាត់នោះ ទោះជាក្នុងស្ថានភាពណាក៏ដោយ វាពិតជាពិបាកក្នុងការសម្រេចឱ្យបានជាក់ច្បាស់ ថាតើឧក្រិដ្ឋកម្មនីមួយៗនោះបានជះឥទ្ធិពលបែបណាចំពោះអ្នកដាក់ពាក្យសុំ។ ខ្លួនខ្ញុំក៏យល់ពីការលំបាកក្នុងការស្វែងរកភស្តុតាងដូចជារបាយការណ៍វេជ្ជសាស្ត្រ និងរបាយ-ការណ៍វិភាគផ្លូវចិត្ត ដើម្បីគាំទ្រដល់បណ្តឹងពីព្យសនកម្មដោយផ្ទាល់ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្ម។ បើទោះបីជាភស្តុតាងប្រភេទនេះជាប្រភេទភស្តុតាងបទដ្ឋាន នៅក្នុងយុត្តាធិការដទៃក៏ដោយ ប៉ុន្តែអ្នកដាក់ពាក្យសុំទាំងអស់ មិនប្រាកដថាអាចស្វែងរកបានទាំងអស់នោះឡើយ។

៦៧ ដោយផ្អែកទៅលើសារណារបស់សហមេធាវី ក៏ដូចជាការឆ្លុះបញ្ចាំងយ៉ាងស៊ីជម្រៅរបស់ចៅក្រមជាតិស្តីអំពីសង្គមកម្ពុជា ខ្ញុំសូមទទួលស្គាល់ពីចំណងនៃសេចក្តីស្រឡាញ់ជាពិសេសរវាងសមាជិកគ្រួសារសាច់ឆ្ងាយ ក្នុងបរិបទនៃវប្បធម៌កម្ពុជា ដែលសមាជិកគ្រួសារសាច់ឆ្ងាយ អាចរស់នៅជាមួយគ្នា ឬក៏មានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នា ហើយជាញឹកញាប់តែងតែផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក។ សមាជិកគ្រួសារសាច់ឆ្ងាយដែលមានវ័យចំណាស់ត្រូវបានគេគោរពយ៉ាងខ្លាំង ហើយពេលខ្លះពួកគាត់ធ្វើជាគំរូសម្រាប់ក្មេងៗទៀតផង។ លក្ខណៈបែបនេះក៏មាននៅក្នុងសហគមន៍មួយចំនួនផងដែរ ដែលក្នុងសហគមន៍នោះ ប្រជាជនរស់នៅជាមួយគ្នាជាក្រុម ហើយមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ហើយពេលខ្លះពួកគាត់អាច

ចែករំលែកនូវធនធានដល់គ្នាទៀតផង។ បើទោះបីជាខ្ញុំមិនគាំទ្រលើទស្សនៈបែបទូលាយ ស្តីពី "សហគមន៍" ដែលមតិភាគច្រើនគាំទ្រក៏ដោយ ក៏ខ្ញុំសូមទទួលយកនូវអ្នកដាក់ពាក្យសុំមួយចំនួនតូច ជាឧទាហរណ៍ អ្នកដាក់ពាក្យសុំដែលបានពណ៌នាថាពួកគាត់គឺជាផ្នែកនៃសហគមន៍តូចមួយដែលប្រជាជនក្នុងសហគមន៍នេះ មានជំនឿដូចគ្នាទៅលើរុក្ខទេវតា ហើយបានកប់សាកសពនៅកន្លែងបញ្ចុះសាកសពក្នុងព្រៃ ព្រមទាំងប្រារព្ធពិធីបុណ្យរួមគ្នាផ្សេងៗ ហើយពួកគាត់បានចោទប្រកាន់ថា បានទទួលរងព្យសនកម្មពីឧក្រិដ្ឋកម្មដែលបានធ្វើឡើងប្រឆាំងនឹងសមាជិកនៅក្នុងសហគមន៍របស់ពួកគាត់[៧៦]។ ជាសង្ខេប ខ្ញុំពិចារណាថា ទស្សនៈបែបចង្អៀតអំពីគ្រួសារ ដូចដែលបានអនុម័តរួចមកហើយដោយយុត្តិសាស្ត្ររបស់តុលាការ ICC និងតុលាការ IACHR មិនបានឆ្លើយតបទៅនឹងការពិតជាក់ស្តែងនៅកម្ពុជា និងចំពោះបរិបទជាពិសេសនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ដោយសារតែទំនាក់ទំនងគ្រួសារយ៉ាងជិតស្និទ្ធ ព្រមទាំងក្នុងបរិបទដែលឧក្រិដ្ឋកម្មត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងពេញផ្ទៃប្រទេសកម្ពុជា ដែលធ្វើឱ្យប្រជាជនស្ថិតក្នុងស្ថានភាពមួយដែលងាយរងគ្រោះថ្នាក់បំផុតនោះ ខ្ញុំយល់ឃើញថា វាគួរឱ្យជឿជាក់បានថា សមាជិកគ្រួសារសាច់ឆ្ងាយរបស់ជនរងគ្រោះផ្ទាល់ដោយឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ប្រឆាំងជនជាប់ចោទ ឬក៏ជាសមាជិករបស់សហគមន៍ដែលទទួលរងគ្រោះ នៅក្នុងប្រទេសកម្ពុជា អាចទទួលរងនូវព្យសនកម្មផ្លូវចិត្តដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មទាំងនោះ។ ការដែលអ្នកដាក់ពាក្យសុំបានចំណាយពេលវេលា ហើយបានព្យាយាមក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយមានចេតនាទទួលយកតែ "សំណងផ្លូវចិត្ត" ដោយពួកគាត់ដឹងច្បាស់ថា នឹងមិនអាចទទួលបានសំណងហិរញ្ញវត្ថុនោះ គឺមានន័យថាទោះបីជាបទឧក្រិដ្ឋបានកើតឡើងជាង៣០ឆ្នាំហើយក៏ដោយ ក៏អ្នកដាក់ពាក្យសុំនៅតែទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីឧក្រិដ្ឋកម្មនេះ។

៦៨ ក្នុងស្ថានភាពបែបនេះ ខ្ញុំគិតថាវាជាការសមស្របក្នុងការអនុម័តយកវិធីសាស្ត្របែបទូលាយជាជាងយកវិធីសាស្ត្រដែលសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង បានអនុម័តក្នុងសំណុំរឿង ០០១ ហើយទទួលស្គាល់ថាមានគោលការណ៍ការសន្មតទុកជាមុន ក្នុងករណីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានប្រព្រឹត្ត

[៧៦] សូមមើលផងដែរ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី D22/0154 និង D22/0932 នៅក្នុងឧបសម្ព័ន្ធ ក។



E.C.C.C. · C.E.T.C. · CHAMBRE PRELIMINAIRE

00709984



ឡើងប្រឆាំងសមាជិកគ្រួសារ ជាសមាជិកផ្ទាល់ ឬសមាជិកគ្រួសារសាច់ឆ្ងាយ ដោយសមាជិកទាំងនោះរួមមានឪពុកម្តាយ, កូន, បងប្អូនបង្កើត, ជីដូនជីតា, គ្រួសារសាច់ថ្លៃ, ពូមីងអ៊ំ និងបងប្អូនជីដូនមួយ ថាឧក្រិដ្ឋកម្មបែបនេះនឹងបង្កឲ្យមានព្យសនកម្មផ្លូវចិត្តចំពោះអ្នកដាក់ពាក្យសុំ។ ខ្ញុំក៏នឹងអនុវត្តគោលការណ៍នៃការសន្មតទុកជាមុនថា មានព្យសនកម្មផ្លូវចិត្តក្នុងករណីទាំងឡាយណាដែលអ្នកដាក់ពាក្យសុំថា ខ្លួនគឺជាផ្នែកមួយនៃសហគមន៍ដែលខ្លួនមានចំណងទាក់ទងយ៉ាងជិតស្និទ្ធ ហើយប្តឹងថា បានទទួលរងនូវព្យសនកម្មដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងសមាជិកណាម្នាក់ នៅក្នុងសហគមន៍នោះ។

៦៩ ខ្ញុំកត់សម្គាល់ឃើញថា អ្នកដាក់ពាក្យសុំភាគច្រើនមិនបានផ្តល់ព័ត៌មានពីចំណងនៃសេចក្តីស្រឡាញ់ដែលខ្លួនមានចំពោះសមាជិកគ្រួសារសាច់ឆ្ងាយ ឬសាច់ញាតិដទៃ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួនឡើយ ប្រហែលជាដោយសារតែទម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទាមទារជាពិសេសចំពោះចំណុចនេះ។ អង្គបុរេជំនុំជម្រះនៅពេលពិចារណាលើបណ្តឹងឧទ្ធរណ៍ដំបូង បានស្នើជាដំបូងឲ្យអ្នកដាក់ពាក្យសុំមួយចំនួនដែលមិនបានបង្ហាញពីអត្ថិភាពនៃចំណងនៃសេចក្តីស្រឡាញ់ ចំពោះសមាជិកគ្រួសារសាច់ឆ្ងាយរបស់ខ្លួន នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឲ្យដាក់បន្ថែមនូវព័ត៌មានជាក់លាក់លើចំណុចនេះ។ បន្ទាប់មកអ្នកដាក់ពាក្យសុំមួយចំនួនបានផ្តល់នូវព័ត៌មានមកដោយផ្ទាល់ ឬតាមរយៈមេធាវីតំណាងរបស់ពួកគាត់ ដើម្បីបញ្ជាក់ពីអត្ថិភាពនៃចំណងនៃសេចក្តីស្រឡាញ់ ឬភាពនៅក្នុងបន្ទុក។ តាមរយៈចម្លើយដែលបានទទួល គឺវាជួយដល់ការបញ្ជាក់ពីអត្ថិភាពនៃចំណងនៃសេចក្តីស្រឡាញ់ រវាងសមាជិកគ្រួសារសាច់ឆ្ងាយ នៅក្នុងសង្គមកម្ពុជា។ បន្ទាប់ពីមានការពិភាក្សាសម្រេចបន្ថែម អង្គបុរេជំនុំជម្រះបានពិចារណាថា ចំណងនៃសេចក្តីស្រឡាញ់អាចសន្មតទុកជាមុនបាន ដូច្នេះហើយវាមិនចាំបាច់ក្នុងការស្វែងរកបន្ថែម ពីអ្នកដាក់ពាក្យសុំម្នាក់ៗនូវព័ត៌មានបែបនេះទៀតទេ។

៧០ ដោយសារការពង្រីកនូវវិសាលភាពនៃការសន្មតទុកជាមុន ដែលអ្នកដាក់ពាក្យសុំអាចទទួលបានប្រយោជន៍ពីការសន្មតនេះ ខ្ញុំនឹងពិចារណាទៅលើអ្នកដាក់ពាក្យសុំនីមួយៗ ជាលក្ខណៈបុគ្គល ថាតើសហមេធាវីបានចោទប្រកាន់ត្រឹមត្រូវដែរឬទេ ដែលថាអ្នកដាក់ពាក្យសុំមួយចំនួនគួរត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណី ដោយផ្អែកលើមូលដ្ឋានដែលពួកគាត់

បានទទួលរងនូវព្យសនកម្ម ក្នុងនាមជាជនរងគ្រោះផ្ទាល់ ជាសមាជិកនៃគ្រួសារផ្ទាល់ ឬគ្រួសារសាច់ឆ្ងាយ ឬជាសមាជិកនៃសហគមន៍របស់គាត់។ ក្រៅពីព្រំដែនកំណត់នៃការសន្មតទុកជាមុន ដូចបានរៀបរាប់ខាងលើ ខ្ញុំនឹងធ្វើការវាយតម្លៃទៅលើករណីនីមួយៗ ដោយផ្អែកលើមូលដ្ឋាននៃព័ត៌មាន ដែលអ្នកដាក់ពាក្យសុំបានផ្តល់ឱ្យអំពីអត្ថិភាពនៃចំណងនៃសេចក្តីស្រឡាញ់ ឬភាពនៅក្នុងបន្ទុកជាមួយជនរងគ្រោះផ្ទាល់ ដោយវាយតម្លៃលើព័ត៌មានដែលអ្នកដាក់ពាក្យសុំបានពណ៌នាពីចំណងនៃសេចក្តីស្រឡាញ់ ឬភស្តុតាងនានាដែលបានបង្ហាញទាក់ទងនឹងចំណុចនេះ។ ដោយសារតែទំនាក់ទំនងរវាងបុគ្គលម្នាក់ៗ មានលក្ខណៈអត្តនោម័តិ ខ្ញុំយល់ឃើញថា វាជាការសមស្របដែលខ្ញុំត្រូវពឹងផ្អែកទៅលើព័ត៌មានរបស់អ្នកដាក់ពាក្យសុំទាក់ទិននឹងបញ្ហានេះ ហើយខ្ញុំពិចារណាថា ការណ៍នេះគឺគ្រប់គ្រាន់សម្រាប់ការបង្កើតជាដំបូងនូវចំណងនៃសេចក្តីស្រឡាញ់។

**ii. គោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត ក្នុងករណីនៃការរៀបការដោយបង្ខំ**

៧១ ដោយសារតែការរៀបការដោយបង្ខំ គឺជាចំណុចដែលគួរយកចិត្តទុកដាក់ជាងគេ ខ្ញុំសូមកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតបានកំណត់គោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត តែត្រឹមឪពុក/ម្តាយ ប្តី/ប្រពន្ធ និងកូនរបស់ជនរងគ្រោះដោយផ្ទាល់តែប៉ុណ្ណោះ ដោយមិនបានយោងទៅលើលិខិតុបករណ៍ច្បាប់ណាមួយសម្រាប់ការយល់ឃើញរបស់ខ្លួន ដែលបានដកចេញនូវបងប្អូនបង្កើតរបស់ជនរងគ្រោះផ្ទាល់ មិនឱ្យបានទទួលផលប្រយោជន៍ពីគោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត ដែលជាផលវិបាកដោយផ្ទាល់នៃការរៀបការដោយបង្ខំរបស់ជនរងគ្រោះផ្ទាល់។ ខ្ញុំដូចជាមិនឃើញមានហេតុផលសមស្របណាមួយ សម្រាប់ការពិចារណាដែលថា បងប្អូនបង្កើតរបស់ជនរងគ្រោះផ្ទាល់ ដែលជាសមាជិកនៃក្រុមគ្រួសារផ្ទាល់របស់ជនរងគ្រោះ បែរជាត្រូវដកចេញមិនឱ្យទទួលផលប្រយោជន៍ពីការសន្មតទុកជាមុន ចំពោះបទល្មើសនៃអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការរៀបការដោយបង្ខំ។ លើសពីនេះទៅទៀត បន្ទាប់ពីបានពិនិត្យទៅលើសារណារបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ខ្ញុំបានកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេតពិតជាបានទទួលស្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដោយផ្អែកលើមូលដ្ឋាននៃព្យសនកម្មដែលពួកគេបានទទួលក្នុងនាមជាបងប្អូនបង្កើតរបស់ជន

រងគ្រោះដោយផ្ទាល់នៃការរៀបការដោយបង្ខំ។ ទាំងនេះគឺជាករណីរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលមាននៅក្នុងដីកាដែលរងការជំទាស់៖ D396,[៧៧] D397,[៧៨] D401,[៧៩] D406,[៨០] D408,[៨១] D409,[៨២] D411,[៨៣] D414,[៨៤] D415,[៨៥] D416,[៨៦] D417,[៨៧] D418,[៨៨] D423,[៨៩] D426[៩០], ដែលអ្នកដាក់ពាក្យសុំទាំងនេះហាក់ដូចជាបានទទួលប្រយោជន៍ពីការសន្មតទុកជាមុន ដែលមិនអាចជំទាស់បាន។ ដូច្នេះខ្ញុំយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំផ្នែកអង្គច្បាប់ ពេលសន្និដ្ឋានថា បងប្អូនបង្កើតគួរត្រូវដកចេញមិនឱ្យទទួលផលប្រយោជន៍ពីគោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត ក្នុងករណីនៃការរៀបការដោយបង្ខំ ចំពោះជនរងគ្រោះផ្ទាល់។ ខ្ញុំយល់ឃើញបន្ថែមទៀតថា គោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត គួរត្រូវអនុវត្តដូចគ្នាចំពោះសមាជិកនៃគ្រួសារសាច់ឆ្ងាយ និងចំពោះសមាជិកនៃសហគមន៍របស់ជនរងគ្រោះផ្ទាល់ ដោយសារតែតាមគំនិតរបស់ខ្ញុំ គឺគ្មានភាពខុសគ្នារវាងឧក្រិដ្ឋកម្មនានាដែលមានចែងក្នុងដីកាបញ្ជូន

---

[៧៧] D22/1674 (ការរៀបការដោយបង្ខំ ចំពោះបងស្រី របស់អ្នកដាក់ពាក្យសុំ) និង D396.1។

[៧៨] D22/1069 (ការរៀបការដោយបង្ខំ ចំពោះបងប្អូនប្រុស និង បងប្អូនស្រី របស់អ្នកដាក់ពាក្យសុំ) និង D397.1 ។

[៧៩] D22/1165 (ការរៀបការដោយបង្ខំ ចំពោះបងប្អូនប្រុសទាំងពីរនាក់ របស់អ្នកដាក់ពាក្យសុំ) និង D401.1 ។

[៨០] D22/2531 (ការរៀបការដោយបង្ខំ ចំពោះបងស្រី របស់អ្នកដាក់ពាក្យសុំ) និង D406.1។

[៨១] D22/2892 (ការរៀបការដោយបង្ខំ ចំពោះបងស្រីរបស់អ្នកដាក់ពាក្យសុំ) និង D408.1។

[៨២] D22/2218 (ការរៀបការដោយបង្ខំ ចំពោះប្អូនស្រីរបស់អ្នកដាក់ពាក្យសុំ) និង D409.1។

[៨៣] D22/0701 (ការរៀបការដោយបង្ខំ ចំពោះប្អូនស្រីរបស់អ្នកដាក់ពាក្យសុំ) និង D411.1។

[៨៤] D22/1510 (ការរៀបការដោយបង្ខំ ចំពោះបងប្អូនស្រីរបស់អ្នកដាក់ពាក្យសុំ) និង D414.1។

[៨៥] D22/2141 (ការរៀបការដោយបង្ខំ ចំពោះប្អូនស្រីរបស់អ្នកដាក់ពាក្យសុំ) និង D415.1។

[៨៦] D22/2596 (ការរៀបការដោយបង្ខំ ចំពោះប្អូនប្រុសពីរនាក់របស់អ្នកដាក់ពាក្យសុំ) និង D416.1។

[៨៧] D22/3678 (ការរៀបការដោយបង្ខំ ចំពោះប្អូនស្រីរបស់អ្នកដាក់ពាក្យសុំ) និង D417.1។

[៨៨] D22/0593 (ការរៀបការដោយបង្ខំ ចំពោះបងស្រីរបស់អ្នកដាក់ពាក្យសុំ) D22/0974 (ការរៀបការដោយបង្ខំ ចំពោះបងប្រុសរបស់អ្នកដាក់ពាក្យសុំ) និង D418.1។

[៨៩] D22/1581 (ការរៀបការដោយបង្ខំ ចំពោះបងប្រុសរបស់អ្នកដាក់ពាក្យសុំ) និង D423.1។

[៩០] D22/3101 (ការរៀបការដោយបង្ខំ ចំពោះបងស្រី និងបងប្រុសរបស់អ្នកដាក់ពាក្យសុំ), D22/1471 (ការរៀបការដោយបង្ខំ ចំពោះបងស្រីរបស់អ្នកដាក់ពាក្យសុំ) និង D426.1។



E.C.C.C. * C.E.T.C. * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE

រឿងទៅជំនុំជម្រះ និងឧក្រិដ្ឋកម្មការរៀបការដោយបង្ខំនោះឡើយ។ ក្នុងបរិបទដែលលេចធ្លោជាងគេនៅក្នុងប្រទេសកម្ពុជាក្នុងពេលនេះ ហើយដោយផ្អែកទៅតាមទំនាក់ទំនងសង្គមនៅក្នុងសង្គមកម្ពុជានោះ ខ្ញុំយល់ឃើញថាវាអាចជឿទុកចិត្តបានថា បុគ្គលទាំងឡាយណាដែលហាក់ដូចជាមានចំណងនៃសេចក្តីស្រឡាញ់ជាមួយជនរងគ្រោះដោយផ្ទាល់នៃការរៀបការដោយបង្ខំ អាចទទួលរងនូវព្យសនកម្មផ្លូវចិត្តជាបុគ្គលដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មការរៀបការដោយបង្ខំមួយនេះ។

៧២ ដោយសារតែឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ដទៃទៀត តាមរយៈការរៀបការដោយបង្ខំ គឺជាប្រធានបទនៃមូលដ្ឋានជាក់លាក់មួយនៃបណ្តឹងឧទ្ធរណ៍ ហើយដោយសារតែការភ័ន្តច្រឡំផ្នែកអង្គច្បាប់ត្រូវបានកំណត់រួចរាល់ហើយ ដោយសារតែសហចៅក្រមស៊ើបអង្កេតបានដកជាពិសេសនូវបងប្អូនបង្កើតរបស់ជនរងគ្រោះផ្ទាល់ ចេញពីគោលការណ៍នៃការសន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត ហើយសហចៅក្រមស៊ើបអង្កេតបានបដិសេធជារួមចំពោះអ្នកដាក់ពាក្យសុំទាំងឡាយណា ដែលខ្ញុំគិតថាមានចំណងនៃសេចក្តីស្រឡាញ់ជាមួយជនរងគ្រោះផ្ទាល់គ្រប់គ្រាន់សម្រាប់ការសន្មតទុកជាមុនថា បានទទួលរងព្យសនកម្មដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មការរៀបការដោយបង្ខំ ដែលប្រព្រឹត្តចំពោះជនរងគ្រោះដោយផ្ទាល់។ ខ្ញុំពិចារណាថា ជាការសមស្របក្នុងការពិនិត្យមើលថាតើការភ័ន្តច្រឡំផ្នែកអង្គច្បាប់នេះ ពិតជាធ្វើឱ្យសហចៅក្រមស៊ើបអង្កេតមានការភ័ន្តច្រឡំ នៅពេលពិចារណាពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែរឬអត់។

៧៣ ដីកាដំណោះស្រាយអះអាងថា នៅក្នុងផ្នែកដែលរៀបរាប់ពីការកំណត់ប្រភេទបទល្មើសពាក់ព័ន្ធនឹង “បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ អំពើអមនុស្សធម៌ដទៃទៀតតាមរយៈការរៀបការដោយបង្ខំ” ដែលសម្រាប់ “អង្គហេតុនីមួយៗ ដែលមានរៀបរាប់នៅក្នុងផ្នែកស្តីអំពី “ការរៀបអាពាហ៍ពិពាហ៍” និង “ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃបទឧក្រិដ្ឋ”” សហចៅក្រមស៊ើបអង្កេតយល់ឃើញថា មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅគ្រប់ទីកន្លែងនៅប្រទេសកម្ពុជា ដូចជានៅ ទំនប់១មករា សហករណ៍ត្រាំកក់ ទំនប់ត្រពាំងថ្ម

00709988



មន្ទីរសន្តិសុខគោកក្ដួច និងនៅក្នុងបរិបទនៃការប្រព្រឹត្តចំពោះពុទ្ធសាសនិក"[៩១]។ ខ្ញុំកត់សម្គាល់ថា ត្រង់ផ្នែកនេះក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាភាសាអង់គ្លេស ហាក់ដូចជាបញ្ជាក់ថា ជនជាប់ចោទត្រូវបានចោទប្រកាន់តែចំពោះករណីជាក់លាក់នានានៃការរៀបការដោយបង្ខំ ដែលបានរៀបរាប់យ៉ាងជាក់លាក់ដោយសហចៅក្រមស៊ើបអង្កេត ក្នុងផ្នែកស្ដីអំពី 'ការរៀបអាពាហ៍ពិពាហ៍" និង 'ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃបទឧក្រិដ្ឋ" និង/ឬ ដែលបានរៀបរាប់ក្នុងភស្តុតាងដែលបានយោងនៅក្នុងជើងទំព័រពី ៣៥៤៥ ដល់ ៣៦៥១ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៩២]។ និយាយម្យ៉ាងទៀត ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាអង់គ្លេសហាក់ដូចជាចង់បង្ហាញថា ជនជាប់ចោទត្រូវបានចោទប្រកាន់ តែចំពោះករណីជាក់លាក់នានានៃការរៀបការដោយបង្ខំ គឺមិនមែនចោទប្រកាន់ជាទូទៅចំពោះគ្រប់អង្គហេតុទាំងអស់នៃការរៀបការដោយបង្ខំ ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលអំពើនេះជាផ្នែកមួយនៃគោលនយោបាយរបស់ខ្មែរក្រហម។ ការណ៍នេះបានរារាំងមិនឱ្យខ្ញុំ ប្រកាសទទួលស្គាល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយណាដែលចោទប្រកាន់ទៅលើករណីនៃការរៀបការដោយបង្ខំ ដែលបានពណ៌នាយ៉ាងជាក់លាក់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬចំពោះករណីណាដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនបាននិយាយយោងជាពិសេសនោះឡើយ។

៧៤ តាំងពីដំបូង ខ្ញុំកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាបារាំងគ្មានភាពស្រពិចស្រពិលបែបនេះទេ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាបារាំងបានបញ្ជាក់យ៉ាងច្បាស់ថា ជនជាប់ចោទត្រូវបានចោទប្រកាន់ចំពោះគ្រប់អង្គហេតុទាំងអស់ដែលមានចែងក្នុងផ្នែកស្ដីអំពី

---

[៩១] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤៤២ (ការសង្កត់ធ្ងន់របស់យើង)។ ខ្ញុំកត់សម្គាល់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាបារាំង ត្រង់កថាខណ្ឌ ១៤៤២ មិនបានយោងទៅលើផ្នែកទាំងពីរនៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ប៉ុន្តែវាយោងទៅលើអនុផ្នែក "[បទបញ្ញា] ការរៀបអាពាហ៍ពិពាហ៍" នៅក្នុងផ្នែក "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃបទឧក្រិដ្ឋ" ជាឧទាហរណ៍ "'Le mariage' (dans la partie 'Caractérisation factuelle des crimes')" ដែលស្របទៅនឹងវិធីសាស្ត្រដែលសហចៅក្រមស៊ើបអង្កេតបានអនុម័តយក នៅក្នុងផ្នែកនៅសល់នៃសេចក្ដីសន្និដ្ឋានអង្គច្បាប់។

[៩២] កថាខណ្ឌ ៨៤២ ដល់ ៨៦១ នៃ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងផ្នែក "ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃបទឧក្រិដ្ឋ"។

"ការរៀបអាពាហ៍ពិពាហ៍"[៩៣]។ ទាំងដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាបារាំង និងភាសាអង់គ្លេស បានចែងថា "មានធាតុផ្សំគ្រប់គ្រាន់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅគ្រប់ទីកន្លែងនៅប្រទេសកម្ពុជា" ដែលចំណុចនេះបញ្ជាក់ច្បាស់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនបានកំណត់ក្នុងវិសាលភាពទីតាំងភូមិសាស្ត្ររបស់ខ្លួន ដូចឧក្រិដ្ឋកម្មដទៃទៀតនោះឡើយ[៩៤]។ ខ្ញុំក៏បានកត់សម្គាល់បន្ថែមទៀតថា អង្គហេតុដែលបានលើកឡើងដើម្បីគាំទ្រទៅលើបទចោទ ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងៗទៀត នៅក្នុងក្របខ័ណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានរៀបរាប់ក្នុងលក្ខណៈទូទៅ មិនមែនរៀបរាប់ដោយយោងទៅលើករណីជាក់លាក់ណាមួយឡើយ។ ការរៀបរាប់នេះបានបង្កប់នូវគោលគំនិតគាំទ្រដល់ការកត់សម្គាល់ឃើញថា គោលនយោបាយរបស់ខ្មែរក្រហម ទាក់ទងដល់បទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានអនុវត្តជាប្រព័ន្ធនៅទូទាំងប្រទេសកម្ពុជា។

៧៥ វិធីសាស្ត្រនេះគឺស្របជាមួយនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលបានស្នើឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតលើករណីនៃការរៀបការដោយបង្ខំ នៅក្នុងប្រទេសកម្ពុជា ដោយសំណើនេះមិនមានចែងពីការកំណត់ទីតាំងភូមិសាស្ត្រ ឬការកំណត់ណាមួយផ្សេងទៀតឡើយ។ ជាការពិតនៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ [សហព្រះរាជអាជ្ញា] បានអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការស៊ើបអង្កេតទៅលើបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ទាក់ទងទៅនឹងការចោទប្រកាន់ពីការរៀបការដោយបង្ខំ និងសម្ព័ន្ធភាពផ្លូវភេទដោយបង្ខំ នៅខេត្តកំពត

---

[៩៣] ដីកាបញ្ជូនរឿងទៅជំនុំជម្រះជាភាសាបារាំង កថាខណ្ឌ ១៤៤២ បានចែងដូចតទៅ « Pour chacun des faits décrits dans la section « *Le mariage* » (dans la partie « *Caractérisation factuelle des Crimes* »), les éléments constitutifs du crime contre l'humanité constitué d'autres actes inhumains sous forme de mariages forcés ont été établis dans l'ensemble du Cambodge et, en particulier, dans les sites suivantes : **Barrage du premier janvier**, **Barrage de Trapeang Thma, Cooperatives de Tram Kok**, le centre de sécurité de **Kok Duoch,** ainsi que dans le contexte du **traitement des bouddhistes**. »

[៩៤] ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ១៤៤២។

និងខេត្តតាកែវ ("ចម្លើយតបចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩")[៥៥]។ នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអនុញ្ញាតសហចៅក្រមស៊ើបអង្កេតដើម្បី "ពិចារណា និងធ្វើការស៊ើបសួរបន្ថែមទៀត ទៅលើឧប្បត្តិហេតុនានា ដូចបានចោទប្រកាន់អំពីអាពាហ៍ពិពាហ៍ និងសម្ព័ន្ធភាពផ្លូវភេទដោយបង្ខំ ក្រៅអំពីឧប្បត្តិហេតុនានាដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ នៃចម្លើយតប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩"[៥៦]។

៧៦ ខ្ញុំសូមកត់សម្គាល់បន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតមិនបានដាក់កំហិតខ្លួនឯងឲ្យទទួលយកតែអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណា ដែលបានប្តឹងចោទថាបានទទួលរងនូវព្យសនកម្មដែលជាលទ្ធផលនៃករណីមួយ ក្នុងចំណោមករណីជាក់លាក់នានានៃការរៀបការដោយបង្ខំ ដូចមានយោងនៅក្នុងជើងទំព័រ ដែលគាំទ្រដល់ការសន្និដ្ឋានលើអង្គហេតុ ទាក់ទងនឹងការរៀបការដោយបង្ខំ។ ជាការពិត នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលនូវអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗមួយចំនួន ដែលខ្លួនបានទទួលស្គាល់ថាជាជនរងគ្រោះនៃការរៀបការដោយបង្ខំ

[៥៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ឯកសារ D146/3 ("ចម្លើយតប ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩") កថាខណ្ឌ ២។

[៥៦] សេចក្តីអនុញ្ញាតបន្ថែម ដោយអនុលោមតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ តបទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យ របស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D146/4 ("សេចក្តីអនុញ្ញាតបន្ថែមចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៩") កថាខណ្ឌ ៣។ នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញា បានដាក់សេចក្តីអនុញ្ញាតទាក់ទិនដល់ការអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការស៊ើបសួរលើឧប្បត្តិហេតុដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងសម្ព័ន្ធភាពផ្លូវភេទដោយបង្ខំ ដែលបានចែងថាឧប្បត្តិហេតុនោះ "អាចកំណត់ប្រភេទថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការរំលោភលើផ្លូវភេទ ឬអំពើអមនុស្សធម៌ផ្សេងៗទៀត) ដែលអាចដាក់ទណ្ឌកម្មបានតាមមាត្រា៥, មាត្រា២៩(ថ្មី) និងមាត្រា៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលអំពើបែបដូច្នោះត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃការវាយប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ សំដៅប្រឆាំងទៅលើប្រជាជនស៊ីវិល ដោយមូលហេតុ ជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ" សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងចម្លើយតបចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៩ ទៅនឹងដីកាបញ្ជូនរឿងទៅពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D146/5 កថាខណ្ឌ ៣។





PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C * C.E.T.C

00709991

**០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៧៦, អបជ ១១២ អបជ ១១៣ អបជ ១១៤ អបជ ១១៥ អបជ ១៤២ អបជ ១៥៧ អបជ ១៦៤ អបជ ១៦៥ និង អបជ ១៧២)**

ហើយពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ទាំងនោះ មិនចាំបាច់ត្រូវយោងទៅរកជើងទំព័រដូចបានរៀបរាប់ខាងលើនោះឡើយ។ វិធីសាស្រ្តដែលសហចៅក្រមស៊ើបអង្កេតបានធ្វើគឺបានបញ្ជាក់ច្បាស់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនមែនចោទប្រកាន់ត្រឹមតែករណីជាក់លាក់ ដែលបានរៀបរាប់ជាការគាំទ្រដល់ការពណ៌នាពីអង្គហេតុនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំង និងជនជាប់ចោទប៉ុណ្ណោះទេ ប៉ុន្តែជនជាប់ចោទត្រូវបានចោទប្រកាន់យ៉ាងទូលំទូលាយ ចំពោះគ្រប់អង្គហេតុទាំងអស់ដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រង់ផ្នែក “ការរៀបអាពាហ៍ពិពាហ៍” ដែលមាននៅក្នុងផ្នែក “ការកត់សម្គាល់ឃើញអំពីអង្គហេតុនៃបទឧក្រិដ្ឋ” ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

៧៧ សម្រាប់គ្រប់សំអាងហេតុទាំងអស់នេះ ខ្ញុំយល់ឃើញថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះអនុញ្ញាត ឲ្យខ្ញុំទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណាដែលបានទទួលផលប្រយោជន៍ពីគោលការណ៍សន្មតទុកជាមុនថាមានព្យសនកម្មផ្លូវចិត្ត ដែលជាលទ្ធផលនៃការរៀបការដោយបង្ខំ ហើយដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគាត់ បើតាមការយល់ឃើញរបស់ខ្ញុំ ត្រូវសហចៅក្រមស៊ើបអង្កេតបដិសេធដោយភ័ន្តច្រឡំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១១

Catherine MARCHI-UHEL
ចៅក្រមអង្គបុរេជំនុំជម្រះ



**យោបល់ជំទាស់របស់លោកស្រីចៅក្រម CATHERINE MARCHI-UHEL**